PHNOM PENH
SPECIAL ECONOMIC ZONE

COMMITTED TO THE FUTURE

# របាយការណ៍ប្រចាំឆ្នាំ២០១៦

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦)

## របស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

---


+855 (0)23 729 798
+855 (0)23 729 799
sales@ppsez.com

www.ppsez.com

# ទស្សនវិស័យ

ទស្សនៈវិស័យរបស់យើង គឺធ្វើជាអ្នកអភិវឌ្ឍ និងប្រតិបត្តិករតំបន់សេដ្ឋកិច្ចពិសេសដែលឈានមុខគេនៅ ព្រះរាជាណាចក្រកម្ពុជា និងបង្កើតគុណតម្លៃសម្រាប់ភាគហ៊ុនិករបស់យើង បុគ្គលពាក់ព័ន្ធ និងសហគមន៍របស់យើង។

# បេសកកម្ម

បេសកកម្មរបស់យើង គឺក្លាយជាតំបន់សេដ្ឋកិច្ចពិសេសឈានមុខគេនៅ ព្រះរាជាណាចក្រកម្ពុជា។ យើងមានបំណងផ្តល់ឲ្យក្រុមហ៊ុនផលិតកម្ម នូវអត្ថប្រយោជន៍ ផ្នែកហិរញ្ញវត្ថុ ដើម្បីធានាដល់ការវិនិយោគរយៈពេលវែង ស្របពេលដែលយើងមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក ដោយសារយើងមានហេដ្ឋារចនាសម្ព័ន្ធ ដែលទទួលស្គាល់ដោយបទដ្ឋានអន្តរជាតិ ISO សេវាកម្មរដ្ឋបាលក្នុងតំបន់ និងទីតាំងល្អសម្រាប់ទូរគមនាគមន៍ក្នុងតំបន់។

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | សម្ព័ន្ធក្រុមហ៊ុន | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | | ២០១៦ | ២០១៥ | ២០១៤ | ២០១៦ | ២០១៥ | ២០១៤ |
| **ស្ថានភាពហិរញ្ញវត្ថុ ( ពាន់រៀល )** | | | | | | | |
| ទ្រព្យសកម្មសរុប | | ២២៦,៧០៩,៨៥០ | ១៩៦,២៩៥,៤៥៩ | ១៩៩,៤៨៥,៨៩៧ | ២២៦,៧៥៨,៤៨៥ | ១៩៧,១១៥,៤៤០ | ១៩៩,៥០១,៩៣១ |
| បំណុលសរុប | | ៨០,៣៩៩,៩៨៣ | ៨៥,៧៨៩,១៤០ | ១០៥,០៨៧,៩១៩ | ៧៩,១៩៨,២៩៩ | ៨៥,៧៥៨,៣៩៣ | ១០៥,០៧៤,៥៩៦ |
| មូលធនសរុប | | ១៤៦,៣០៩,៨៦៧ | ១១០,៥០៦,៣១៩ | ៩៤,៣៩៧,៩៧៨ | ១៤៧,៥៦០,១៨៦ | ១១១,៣៥៧,០៤៧ | ៩៤,៤២៦,៩៣៥ |
| លទ្ធផលហិរញ្ញវត្ថុ ( ពាន់រៀល ) | | | | | | | |
| ចំណូលសរុប | | ៣៨,១៩០,៤៥២ | ៦៦,៣៣០,៣៩៤ | ៩៥,១៥៩,០៦២ | ៣៧,១៤៣,៣៨៧ | ៦៥,៤១៨,១៧៣ | ៩៤,៥១៩,៥៧២ |
| ចំណេញមុនបង់ពន្ធ | | ៦,៦៩៦,៦៩៣ | ២០,៦៤៩,៤១៣ | ៣០,០៩០,៧៥៨ | ៧,០៨៥,២៥៨ | ២១,៤៤៥,៧០០ | ៣០,១១៣,៥០០ |
| ចំណេញសុទ្ធក្រោយបង់ពន្ធ | | ៥,៨៣៦,១៧៨ | ១៦,៦៨៧,៤៦៨ | ២៣,៩៤៩,៨៨០ | ៦,២៣៨,៥០១ | ១៧,៥០៩,៤១៦ | ២៣,៩៧៨,៨៣៦ |
| **អនុបាតហិរញ្ញវត្ថុ** | | | | | | | |
| អនុបាតសាធនភាព | | | | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ៥,១០ | ២,៩៤ | ២,១៨ | ៤,៤៩ | ២,៣៣ | ២,១៨ |
| | អនុបាតចរន្តលឿន | ២,១១ | ១,២៥ | ១,១៤ | ៣,០៩ | ១,៣២ | ១,១៥ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ២,៥៧% | ៨,៥០% | ១២,០១% | ២,៧៥% | ៨,៨៨% | ១២,០២% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ៣,៩៩% | ១៥,១០% | ២៥,៣៧% | ៤,២៣% | ១៥,៧២% | ២៥,៣៩% |
| | គម្លាតចំណេញដុល | ៦៩,៥៧% | ៦២,៨៥% | ៥៣,៥៧% | ៧១,១៣% | ៦៣,៩០% | ៥៣,៨៤% |
| | គម្លាតចំណេញភាព | ១៥,២៨% | ២៥,១៦% | ២៥,១៧% | ១៦,៨០% | ២៦,៧៧% | ២៥,៣៧% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ១០១ | ៣៦០ | ៥១៧ | ១០១ | ៣៧៨ | ៥១៨ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ( ប្រសិនបើមាន ) | | - | - | - | - | - | - |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប (Charts)



## រចនាសម្ព័ន្ធដើមទុន (ត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៦)




## រចនាសម្ព័ន្ធដើមទុន (ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦)




<u>សម្គាល់៖</u> ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន គឺសំដៅទៅដល់អ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី១%ឡើងទៅនៅក្នុងក្រុមហ៊ុន

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

# សមាសភាពក្រុមប្រឹក្សាភិបាល

លោកជំទាវឧកញ៉ា លីម ឈីវហួរ
ប្រធានក្រុមប្រឹក្សាភិបាល



លោក Hiroshi Uematsu
អភិបាលប្រតិបត្តិ



លោក តាន់ កាក់យុន
អភិបាលមិនប្រតិបត្តិ



លោកស្រី តាន់ សឺយមួយ
អភិបាលមិនប្រតិបត្តិ



លោក Hiroshi Otsubo
អភិបាលមិនប្រតិបត្តិ



លោក Kenji Toyota
អភិបាលមិនប្រតិបត្តិ





លោក ហែម សុវត្ថិ
អភិបាលឯករាជ្យ



លោក Kang Wei Geih
អភិបាលឯករាជ្យ



លោក Tanate Piriyothinkul
អភិបាលមិនប្រតិបត្តិ

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលបោះផ្សាយ

សមាជិកភាគហ៊ុនិកជាទីគោរព!

ឆ្នាំ ២០១៦ គឺជាការចាប់ផ្តើមនៃការខិតខំប្រឹងប្រែងយ៉ាងសំខាន់មួយសម្រាប់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ដោយការក្លាយខ្លួនទៅជាក្រុមហ៊ុនចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា កាលពីថ្ងៃទី ៣០ ខែឧសភាឆ្នាំ ២០១៦កន្លងទៅ ដែលនេះបានកើតឡើង ១០ ឆ្នាំបន្ទាប់ពីក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការនៅក្នុងឆ្នាំ ២០០៧។ យើងគឺជាអ្នកត្រួសត្រាយតំបន់សេដ្ឋកិច្ចពិសេសដែលអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀតមិនធ្លាប់ធ្វើពីមុនមក ដែលនេះជាការជាប់ពាក់ព័ន្ធដ៏សំខាន់ក្នុងប្រតិបត្តិការអាជីវកម្ម និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលមានគោលបំណងជាគោលគឺការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ / ជួល។ លើសពីនេះទៅទៀត ក្នុងតួនាទីជាប្រតិបត្តិករ ក្រុមហ៊ុនយើងត្រូវបានចូលរួមក្នុងការផ្តល់សេវាកម្មពាក់ព័ន្ធផ្សេងៗទៀត និងសម្ភារៈបរិក្ខារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញផងដែរ ដូចជាការផ្គត់ផ្គង់និងចែកចាយទឹកស្អាត សេវាជួល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ សេវាផ្តល់ប្រឹក្សា និងជំនួយរដ្ឋបាល ប្រព្រឹត្តិកម្មទឹកសំអុយ និងសេវាកម្មផ្សេងៗទៀត។ បច្ចុប្បន្នយើងកំពុងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ យើងត្រូវបានគេចាត់ទុកជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានជោគជ័យបំផុតនៅកម្ពុជា ដោយផ្អែកទៅលើចំនួនវិនិយោគិនក្នុងតំបន់។ ក្រៅពីនេះយើងមានគោលដៅដ៏មោះមុតបំផុតគឺចង់ក្លាយទៅជាផ្នែកដ៏សំខាន់មួយនៃឧស្សាហនីយកម្មរបស់ប្រទេសកម្ពុជា។

ប្រតិបត្តិការអាជីវកម្មសម្រាប់ឆ្នាំ២០១៦ បានធ្លាក់ចុះពីឆ្នាំមុន។ លំហូរនៃការវិនិយោគបានធ្លាក់ចុះស្របពេលដែលទស្សនវិស័យសេដ្ឋកិច្ចនាពេលអនាគតមានភាពមិនប្រាកដប្រជា។ លើសពីនេះទៅទៀត សេដ្ឋកិច្ចក្នុងតំបន់នៅតែមានកត្តាគាំទ្រមិនគ្រប់គ្រាន់ក្នុងការជំរុញសក្តានុពលសេដ្ឋកិច្ចដើម្បីឈានទៅដល់ចំណុចកំពូល។ ដោយសារលក្ខខណ្ឌអវិជ្ជមានដែលបានលើកឡើងទាំងអស់នេះ ទើបធ្វើឱ្យអាជីវកម្មអចលនឧស្សាហកម្មមានការធ្លាក់ចុះ។

ប្រាក់ចំណូលសរុបសម្រាប់ឆ្នាំ ២០១៦ ដែលគិតត្រឹមថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០១៦ គឺ ៣៨.១៩០.៤៥២ ពាន់រៀល ដែលមានការថយចុះ ៤២,៤២% ពីចំនួនទឹកប្រាក់ ៦៦.៣៣០.៣៩៤ ពាន់រៀល នៅឆ្នាំ ២០១៥។ កត្តាចម្បងគឺដោយសារតែការថយចុះនៃប្រាក់ចំណូលពីការលក់ដីនិង ជួល។ ជាលទ្ធផល បរិមាណនៃប្រាក់ចំណេញសុទ្ធគឺ ៥.៨៣៦.១៧៨ ពាន់រៀល ដែលជាការថយចុះ ៦៥,០៣% ពីចំនួនទឹកប្រាក់ ១៦.៦៨៧.៤៦៨ ពាន់រៀល នៅឆ្នាំ ២០១៥។

ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននៅតែបន្តអភិវឌ្ឍស្ថានភាពហិរញ្ញវត្ថុ នៅឆ្នាំ២០១៦ នេះ។ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅតែរឹងមាំ នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយមានទ្រព្យសកម្មសរុបចំនួន ២២៦.៧០៩.៨៥០ ពាន់រៀល ដែលរួមមានទ្រព្យសកម្មរយៈពេលវែងចំនួន ១០៨.៧៥៤.៥៩២ ពាន់រៀល និងទ្រព្យសកម្មរយៈពេលខ្លីចំនួន ១១៧.៩៥៥.២៥៨ ពាន់រៀល។ មូលធនសរុបមានចំនួន ១៤៦.៣០៩.៨៦៧ ពាន់រៀល មានការកើនឡើង ២,១% បើធៀបទៅនឹងចុងឆ្នាំ២០១៥ ដែលមានចំនួន ១៤៣.២៥៣.៥៧០ពាន់រៀល។ ជាលទ្ធផល អនុបាតបំណុលធៀបនឹងមូលធន មានភាពកាន់តែប្រសើរដោយកាត់បន្ថយពី ០,៧៨x នៅចុងឆមាសទី១ នៃឆ្នាំ២០១៦ ទៅ ០,៥៥x នៅចុងឆ្នាំ ២០១៦នេះ។

ឆ្នាំ ២០១៧ នឹងក្លាយជាឆ្នាំដែលមានការប្រកួតប្រជែងមួយផ្សេងទៀតសម្រាប់ក្រុមហ៊ុន។ យើងកំពុងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសថ្មី ៦៦ ហិកតា នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យនៃប្រទេសកម្ពុជា ដែលនឹងត្រូវបានដំណើរការដោយក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងគឺ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ប៉ោយប៉ែត។ ក្រុងប៉ោយប៉ែតមានទីតាំងស្ថិតនៅជិតច្រកពាណិជ្ជកម្ម Laem Chabang ដែលជាច្រកពាណិជ្ជកម្មដ៏ធំសម្បូរបែប និងជាកំពង់ផែអន្តរជាតិរបស់

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ប្រទេសថៃផងដែរ។ ដោយប្រើប្រាស់តម្លៃពលកម្មជាអត្ថប្រយោជន៍ប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគិន តំបន់សេដ្ឋកិច្ចពិសេសថ្មីខាងមុខនេះ មានគោលបំណងទាក់ទាញឧស្សាហកម្មរថយន្ត និងគ្រឿងអេឡិចត្រូនិចក្នុងការផ្លាស់ប្តូរ ឬបើកខ្សែរចង្វាក់ផលិតកម្មថ្មីដើម្បីគាំទ្រដល់ការបើករោងចក្រតម្លើងរថយន្តនៅប្រទេសថៃ។

រាល់ការខិតខំប្រឹងប្រែង និងបញ្ហាជួបប្រទះក្នុងពេលកន្លងមក គឺពិតជាមិនអាចបំភ្លេចបានសម្រាប់យើងខ្ញុំ។ វានឹងមិនអាចធ្វើទៅបាន ប្រសិនបើគ្មានការគាំទ្រ និងកិច្ចសហប្រតិបត្តិការរបស់អ្នកទាំងអស់គ្នា។ ដោយមិនគិតពីឧបសគ្គ និងបញ្ហាប្រឈមនាពេលអនាគត ក្រុមហ៊ុននឹងនៅតែបន្តការប្តេជ្ញាចិត្ត ក្នុងការធ្វើអាជីវកម្មប្រកបដោយភាពទទួលខុសត្រូវ និងដោយស្មើភាពក្នុងគម្រោងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ក្នុងនាមជាក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់ ខ្ញុំសូមបង្ហាញពីការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ភាគហ៊ុនិក អតិថិជនដ៏មានតម្លៃរបស់យើង និងដៃគូអាជីវកម្មផ្សេងទៀតដែលនៅតែបន្តការគាំទ្រដល់ក្រុមហ៊ុន។ យើងទាំងអស់គ្នា នៅតែរក្សានិងពង្រឹងជំហរក្រុមហ៊ុនឲ្យឈានមុខគេនៅក្នុងអាជីវកម្មអភិវឌ្ឍឧស្សាហកម្មអចលនទ្រព្យនេះ អោយមានស្ថិរភាព និងនិរន្តរភាពដើម្បីជាប្រយោជន៍ និងការពេញចិត្តបំផុតសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរអ្នកទាំងអស់គ្នាជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

........ភ្នំពេញ....កាលបរិច្ឆេទ..២៨.../.មីនា/..២០១៧

ហត្ថលេខា ត្រា និងឈ្មោះប្រធានក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភ្នំពេញ សេអ៊ីហ្សិត ភីអិលស៊ី
PHNOM PENH SEZ PLC.
KINGDOM OF CAMBODIA

លោកជំទាវឧកញ៉ា លឹម ឈីវហូរ

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

សមាជិកភាគហ៊ុនិកជាទីគោរព!

ឆ្នាំ២០១៦ គឺជាឆ្នាំដែលក្រុមហ៊ុនបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនយើង គឺជាក្រុមហ៊ុនឯកជនកាប់កាប់ដោយកម្ពុជាដែលសម្រេចបាននូវជោគជ័យមួយនេះដំបូងគេ។ ក្រៅពីមូលធនពង្រីកអាជីវកម្មនាពេលអនាគត ការបោះផ្សាយជាសាធារណៈលើកដំបូង ("IPO") របស់យើង បានជួយត្រួសត្រាយឱកាសអាជីវកម្មថ្មីជាមួយដៃគូពាណិជ្ជកម្មអន្តរជាតិដែលទទួលបានជោគជ័យជាច្រើន។

តាមរយៈចក្ខុវិស័យរយៈពេលវែងក្នុងការសម្រេចបានជាអ្នកអភិវឌ្ឍនិងប្រតិបត្តិករតំបន់សេដ្ឋកិច្ចពិសេសដែលឈានមុខគេនៅព្រះរាជាណាចក្រកម្ពុជា និងបង្កើតគុណតម្លៃរយៈពេលវែងសម្រាប់ភាគហ៊ុនិក បុគ្គលពាក់ព័ន្ធ និងសហគមន៍ទាំងមូល យើងនៅតែបន្តអនុវត្តយុទ្ធសាស្ត្ររបស់យើង ហើយយើងចង់សម្រេចបានជោគជ័យក្នុងការប្រកួតប្រជែងដើម្បីក្លាយជាក្រុមហ៊ុនដែលមានការវិវត្តន៍យ៉ាងឆាប់រហ័ស ជាមួយនឹងការផ្តល់សេវាកម្មពេញលេញដើម្បីធានានូវអត្ថប្រយោជន៍ នៃការប្រកួតប្រជែងរបស់ក្រុមហ៊ុនផលិតកម្ម ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក។

នៅក្នុងកំឡុងពេលនៃប្រតិបត្តិការអាជីវកម្ម ឆ្នាំ ២០១៦ ជាឆ្នាំដែលមានការប្រកួតប្រជែងមួយផ្សេងទៀតសម្រាប់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ។ ខណៈពេលដែលយើងបានព្យាយាមជំរុញផ្តួចផ្តើមជាយុទ្ធសាស្ត្រគន្លឹះក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់យើង និងបង្កើតតម្លៃសម្រាប់ភាគហ៊ុនិក អាជីវកម្មលក់ដីបានបន្តប្រឈមមុខនឹងបញ្ហាលើការធ្លាក់ចុះតម្រូវការ។

នៅក្នុងឆ្នាំ២០១៦ ប្រាក់ចំណូលរបស់ក្រុមហ៊ុនមានការថយចុះចំនួន ៣៨.១៩០.៤៥២ ពាន់រៀល ជាការធ្លាក់ចុះ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ ដែលមានចំនួន ៦៦.៣៣០.៣៩៤ ពាន់រៀល។ ការថយចុះគួរអោយកត់សម្គាល់នេះបណ្តាលមកពីកត្តាជាចម្បងគឺ ប្រាក់ចំណូលពីការលក់ដី (២៦.២៦១.៨០៣ពាន់រៀល ទល់នឹង ៥៥.២៤៥.៤៩៩ពាន់រៀល នៅឆ្នាំ ២០១៥)។ ទោះបីជាមានបញ្ហាប្រឈមក៏ដោយ ក្រុមហ៊ុនសម្រេចបានប្រាក់ចំណេញសុទ្ធជាវិជ្ជមាននៅក្នុងឆ្នាំ ២០១៦ នេះផងដែរ ជាមួយនឹងប្រាក់ចំណេញសុទ្ធចំនួន ៥.៨៣៦.១៧៨ ពាន់រៀល បើប្រៀបធៀបទៅនឹងប្រាក់ចំណេញចំនួន ១៦.៦៨៧.៤៦៨ ពាន់រៀលនៅក្នុងឆ្នាំ២០១៥។

ពួកយើងនៅតែពង្រឹងរចនាសម្ព័ន្ធមូលធនរួមឲ្យមានភាពរឹងមាំ ជាមួយនឹងអនុបាតបំណុលធៀបនឹងមូលធនមានចំនួន ០,៧៨X ទល់ នឹង០,៥៥X នៅក្នុងឆ្នាំ២០១៦នេះ ដោយសារការបោះផ្សាយជាសាធារណៈលើកដំបូង ការកើនឡើងនៃប្រាក់ចំណេញរក្សាទុក និងភាពប្រសើរឡើងនៃការគ្រប់គ្រងមូលធនជាបន្តបន្ទាប់។ ក្រុមហ៊ុនមានទំហំដីដែលអាចលក់បានមានកំរិតខ្ពស់នៅចុងឆ្នាំ២០១៦នេះ ដែលបង្ហាញពីបំណិនក្នុងការបង្កើតប្រាក់ចំណូលនៅក្នុងពេលអនាគត។

ដើម្បីអោយកាន់តែមាននិរន្តរភាព យើងខិតខំផ្តល់នូវភាពជោគជ័យជាបន្ត ដោយផ្អែកលើយុទ្ធសាស្ត្រស្នូលដូចខាងក្រោម (១). ការទិញដីយកមកពង្រីកបន្ថែម (២). ស្វែងរកប្រភេទអ្នកវិនិយោគិនតំបន់មានលក្ខណៈចម្រុះ (៣). ពង្រីកការផ្តល់សេវាដែលពាក់ព័ន្ធផ្សេងទៀត និងប្រភពចំណូលថ្មីពីចំណូលដែលទទួលជាប្រចាំ។ យើងនឹងព្យាយាមដើម្បីសម្រេចបាននូវគោលដៅនៃប្រាក់ចំណូល៥០% ពីប្រភពចំណូលដែលអាចទទួលបានជាប្រចាំត្រឹមឆ្នាំ២០២០។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់បុគ្គលិកទាំងអស់សម្រាប់ការខិតខំប្រឹងប្រែង និងការចូលរួមចំណែកធ្វើអោយដំណើរការអាជីវកម្មរបស់យើងមានភាពល្អប្រសើរឡើង។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់បុគ្គលិកជាន់ខ្ពស់សម្រាប់ការផ្តល់ដំបូន្មានដ៏មានតម្លៃរបស់ពួកគេ។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ភាគហ៊ុនិកសម្រាប់ការបន្ត

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ការជឿទុកចិត្ត និងគាំទ្ររបស់លោកអ្នក។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជនទាំងអស់ សម្រាប់ការជឿជាក់របស់ពួកគាត់មកលើក្រុមហ៊ុន ក៏ដូចជាធនធានមនុស្ស បរិក្ខារ និង សេវាកម្មនានារបស់យើង។

យើងទាំងអស់គ្នានៅក្នុង ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺបានតាំងចិត្តយ៉ាងមុតមាំទៅនឹងយុទ្ធសាស្ត្រ និងគោលដៅរបស់យើង ហើយយើងនឹងនូវបន្តអនុវត្តយុទ្ធសាស្ត្ររបស់យើងដើម្បីផ្តល់នូវលទ្ធផលប្រតិបត្តិការដ៏ល្អឥតខ្ចោះ។

......ភ្នំពេញ.....កាលបរិច្ឆេទ ២៩ / មីនា / ២០១៧

ហត្ថលេខា ត្រា និងឈ្មោះនាយកប្រតិបត្តិ

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
PHNOM PENH SEZ PLC.
KINGDOM OF CAMBODIA

Mr. Hiroshi Uematsu



PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

# មាតិកា


**ទស្សនវិស័យ**........................................ i

**បេសកកម្ម**........................................ ii

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប**........................................ iii

**សមាសភាពក្រុមប្រឹក្សាភិបាល**........................................ iv

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........................................ v

**សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ**........................................ vi

**ផ្នែកទី ១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ**

១. ព័ត៌មានទូទៅអំពីបុគ្គលបោះផ្សាយ

២. ដំណើរការធុរកិច្ចសង្ខេប

៣. ស្ថានភាពទីផ្សារ

៤. ស្ថានភាពប្រកួតប្រជែង

៥. ផែនការអនាគត

**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

១. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

២. ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៣. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣ : អភិបាលកិច្ចសាជីវកម្ម**

១. ភាគហ៊ុនិក

២. អង្គការលេខ

៣. ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

៤. បុគ្គលិកជាន់ខ្ពស់

៥. ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

៦. លាភការ ឬប្រាក់បំណាច់ចំពោះអភិបាល និងបុគ្គលិកជាន់ខ្ពស់

៧. ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

៨. សិទ្ធិភាគីពាក់ព័ន្ធ

**ផ្នែកទី ៤ : បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន**

១. ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់

២. ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន

**ផ្នែកទី ៥ : ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ**

១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

២. ថ្លៃ និងបរិមាណជួញដូរ

**ផ្នែកទី ៦ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង**

**ផ្នែកទី ៧ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ**

**ផ្នែកទី ៨ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ**

១. ប្រតិបត្តិការជាមួយភាគហ៊ុនិក

២. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

៣. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

៤. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលបោះផ្សាយក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយបុគ្គលបោះផ្សាយ

៥. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ

៦. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈសម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយ ដល់បុគ្គលបោះផ្សាយប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត

**ផ្នែកទី ៩ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

១. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

២. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

៣. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

៤. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity)

៥. ផលប៉ះពាល់នៃអតិផរណា

៦. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល

**ផ្នែកទី ១០ : ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលរបស់បុគ្គលបោះផ្សាយ**

**ផ្នែកទី ១១ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការវិនិយោគ (ប្រសិនបើមាន)**

ហត្ថលេខារបស់អភិបាលរបស់បុគ្គលបោះផ្សាយ

# ផ្នែកទី ១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ

## ១.១. ព័ត៌មានទូទៅអំពីបុគ្គលបោះផ្សាយ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ: ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
ជាអក្សរឡាតាំង: PHNOM PENH SEZ PLC.
អក្សរកូដ: KH1000050000
អាសយដ្ឋាន: តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវជាតិលេខ ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
លេខទូរស័ព្ទ: (+៨៥៥) ២៣ ៧២៩ ៧៩៨ លេខទូរសារ: (+៨៥៥) ២៣ ៧២៩ ៧៩៩
គេហទំព័រ: www.ppsez.com អ៊ីម៉ែល: info@ppsez.com
លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Inv. ១០៧៦ KH/២០០៦ កាលបរិច្ឆេទ: ១០ ឧសភា ២០០៦
លេខអាជ្ញាបណ្ណអាជីវកម្ម: ៣៣ អនក្រ.បក (អនុក្រឹត្យ)
ចេញដោយ: រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទ: ១៩ មេសា ២០០៦
សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ: ០២៦/១៦ គ.ម.ក./ស.ស.រ
កាលបរិច្ឆេទ: ២៣ មីនា ២០១៦
បុគ្គលតំណាងបុគ្គលបោះផ្សាយ: លោកជំទាវឧកញ៉ា លឹម ឈីវហូរ

## ១.២. ដំណើរការធុរកិច្ចសង្ខេប

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (”PPSEZ”) និង ប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត (“Poipet PPSEZ”) ដែលជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេសឈានមុខគេមួយ នៅព្រះរាជាណាចក្រកម្ពុជា បើគិតលើចំនួននៃវិនិយោគិនតំបន់ដែលមាននៅក្នុងតំបន់។ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ ហើយបច្ចុប្បន្ននេះយើងខ្ញុំជា តំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ងារជាតំបន់សេដ្ឋកិច្ចពិសេស បានផ្តល់នូវការលើកទឹកចិត្ត និងអត្ថប្រយោជន៍ជាច្រើន ពីសំណាក់រាជរដ្ឋាភិបាលដល់អ្នកអភិវឌ្ឍប្រតិបត្តិករ និងវិនិយោគិនតំបន់ដែលរួមមានការលើកលែងពន្ធគយ ពន្ធលើប្រាក់ចំណូល និងពន្ធដទៃទៀតដែលជាលទ្ធផលធ្វើឲ្យមានការកាត់បន្ថយលើការចំណាយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈប្រើប្រាស់វត្ថុធាតុដើម និងធនធានដទៃទៀត ដែលធ្វើឲ្យមានការបង្កើនការប្រកួតប្រជែងសម្រាប់ការនាំចេញ និងអត្ថប្រយោជន៍ជំនួញអន្តរជាតិ។

ក្រុមហ៊ុនយើងខ្ញុំ មានធុរកិច្ចចម្បងលើការធ្វើប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលមានកម្មវត្ថុអាជីវកម្ម ចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ បន្ថែមពីលើនេះ ក្នុងនាមជាប្រតិបត្តិករ ក្រុមហ៊ុនយើង បានចូលរួមផ្គត់ផ្គង់សេវាកម្មចាំបាច់ពាក់ព័ន្ធនិងបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមានការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកសំអុយ និងសេវាកម្មដទៃទៀត។ បច្ចុប្បន្ន យើងកំពុងធ្វើប្រតិបត្តិការ PPSEZ ដែលមានទីតាំងស្ថិតនៅលើផ្លូវជាតិលេខ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

បច្ចុប្បន្ន PPSEZ កំពុងប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ។ គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ ថ្ងៃទី៣១ ខែធ្នូ PPSEZ ជាតំបន់សេដ្ឋកិច្ចពិសេសមួយ ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសដប់បី (១៣) ដែលកំពុងមានប្រតិបត្តិការ (ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំងសាមសិបបួន(៣៤)ដែលទទួលបានការអនុញ្ញាត)នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ បើគិតតាមវិនិយោគិនតំបន់ PPSEZ មានវិនិយោគិនតំបន់ច្រើនជាងគេនៅកម្ពុជា។ លើសពីនេះទៀត PPSEZ ជាតំបន់សេដ្ឋកិច្ចពិសេសធំមួយក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសដែលមានផ្ទៃដីធំជាងគេនៅ កម្ពុជា បើគិតតាមទំហំនៃផ្ទៃដីរបស់ PPSEZ ប្រមាណ ៣៥៧.៣២ ហិកតា។

គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនរបស់យើងមានបុគ្គលិកចំនួនមួយរយ (១០០) នាក់។ សម្ព័ន្ធក្រុមហ៊ុន យើង ក៏មានផ្តល់នូវសេវាសន្តិសុខ ផលិត និង ចែកចាយថាមពលអគ្គិសនី និងសេវាផែស្ងួតតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុន ជាសម្ព័ន្ធភាពរបស់យើងជូនវិនិយោគិនតំបន់ និងអ្នកជួលដទៃទៀតក្នុង PPSEZ។

គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រចនាសម្ព័ន្ធសាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុនរបស់យើងមានដូចខាង ក្រោម៖




| ឈ្មោះ | ទំនាក់ទំនង | ផ្នែកអាជីវកម្ម | កាលបរិច្ឆេទចុះបញ្ជី | ទីកន្លែងអាជីវកម្ម |
|---|---|---|---|---|
| សហ័ស ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | សេវាសន្តិសុខឯកជន | ០៦ វិច្ឆិកា ២០១៣ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ពាណិជ្ជកម្មនិងជំនួញ | ៣១ ធ្នូ ២០១៤ | ខេត្តបន្ទាយមានជ័យ |
| ខូលបេន ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនជាសម្ព័ន្ធភាព | រោងចក្រផលិតថាមពល អគ្គិសនី | ១៦ មិថុនា ២០០៩ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |
| ឬក សេង ភីភីអេសអ៊ីហ្សិត | ក្រុមហ៊ុនជាសម្ព័ន្ធភាព | ផែស្ងួត | ២២ មករា ២០០៨ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រាជធានីភ្នំពេញ |

យើងចាប់ផ្ដើមប្រតិបត្តិការរបស់យើងក្នុង PPSEZ ក្នុងឆ្នាំ២០០៧ ជាមួយនឹងការសាងសង់ដំណាក់កាល១ នៃ PPSEZ ហើយមកដល់ខែសីហា ឆ្នាំ២០០៨ យើងទទួលបានវិនិយោគិនតំបន់ដំបូងគេបង្អស់ ដែលចាប់ផ្ដើមធ្វើប្រតិបត្តិការក្នុង PPSEZ ច្រើនឆ្នាំកន្លងមកនេះ ការកើនឡើងនៃការចាប់អារម្មណ៍ពីសំណាក់វិនិយោគិនជាតិ និងអន្តរជាតិ ក្នុងការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្នុង PPSEZ បានធ្វើឲ្យ PPSEZ មានការរីកចម្រើនយ៉ាងឆាប់រហ័ស។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ PPSEZ មានវិនិយោគិនចម្រុះជាតិសាសន៍ចំនួនប៉ែតសិបមួយ (៨១) ដែលវិនិយោគិនភាគច្រើនមកពីប្រទេសជប៉ុន ម៉ាឡេស៊ី តៃវ៉ាន់ ចិន សហរដ្ឋអាមេរិក និងកូរ៉េដែលវិនិយោគលើឧស្សាហកម្មផ្សេងៗគ្នា ដូចជា គ្រឿងបន្លាស់យានយន្ត កាត់ដេរ អាហារនិងភេសជ្ជៈ ផលិតផល ប្លាស្ទិច ផលិតផលអេឡិចត្រូនិច និងគ្រឿងអលង្ការ។ បច្ចុប្បន្ន យើងកំពុងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ទីតាំងរបស់ PPSEZ មានបង្ហាញដូចខាងក្រោម៖




(ប្រភព៖ PPSP)

PPSEZ មានទីតាំងយុទ្ធសាស្ត្រ ដែលតភ្ជាប់ទៅនឹងបណ្ដាញផ្លូវដែក និងបណ្ដាញផ្លូវថ្នល់។ PPSEZ មានទីតាំងស្ថិតនៅចម្ងាយប្រមាណជាដប់ប្រាំបី (១៨) គីឡូម៉ែត្រ ពីចំណុចកណ្ដាលនៃរាជធានីភ្នំពេញ ដែលងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តភ្នំពេញ (កំពង់ផែទន្លេអន្តជាតិនៅរាជធានីភ្នំពេញ) និងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (អាកាសយានដ្ឋានអន្តរជាតិធំជាងគេនៅកម្ពុជា)។ ជាងនេះទៅទៀត PPSEZ ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៤ ដែលជាផ្លូវគមនាគមន៍ចម្បង និងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែអន្តរជាតិ និងពាណិជ្ជកម្មសមុទ្រទឹកជ្រៅតែមួយគត់របស់កម្ពុជា។

បន្ថែមលើទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន PPSEZ ជួយសម្រួល និងទាក់ទាញវិនិយោគិនរបស់ខ្លួន តាមរយៈ លក្ខណៈពិសេស ដូចខាងក្រោម៖

រោងចក្រផលិតថាមពលអគ្គិសនីឯកជន ធ្វើការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅពេលដែលមានកង្វះខាតថាមពលអគ្គិសនីពីរោងចក្រផ្គត់ផ្គង់អគ្គិសនីជាតិ ដែលដំណើរការដោយក្រុមហ៊ុន ខូលបេន ភីភីអេសអ៊ីហ្សេត ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនជាសម្ព័ន្ធភាពទាំងអស់របស់ក្រុមហ៊ុនយើង។

I. ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជន ដែលមានស្ថានីយ៍បន្សុទ្ធទឹក និងប្រព្រឹត្តិកម្មទឹកសំអុយ។

II. ផែស្ងួតក្នុង PPSEZ ផ្តល់សេវាលើកដាក់ និងសេវាផ្ទុកទំនិញដែលអាចទុកចិត្តបាន និងឆាប់រហ័ស ដើម្បីសម្រួល ដល់ការនាំចេញនាំចូល និងដល់តម្រូវការដឹកជញ្ជូននានា ដែលដំណើរការដោយក្រុមហ៊ុន បុកសេង ភីភីអេស អ៊ីហ្សេត ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនជាសម្ព័ន្ធភាពទាំងអស់របស់ក្រុមហ៊ុនយើង។

III. បណ្តាញទូរគមនាគមន៍ខ្វាត់ខ្វែង និងធំទូលាយ ដែលអាចតភ្ជាប់ជាមួយអ្នកផ្តល់សេវាកម្មអ៊ីនធឺណេតចំនួនដប់ពីរ (១២) ផ្សេងគ្នា និងអ្នកផ្តល់សេវាកម្មទូរស័ព្ទខុសគ្នាចំនួនបួន(៤)។

IV. ប្រព័ន្ធទប់ស្កាត់ទឹកជំនន់បំពាក់ដោយប្រព័ន្ធបង្ហូរទឹកទំនើប ដែលធានាដល់ប្រតិបត្តិការរបស់វិនិយោគិនតំបន់ឲ្យ មានភាពរលូន និងមានសុវត្ថិភាពខ្ពស់។

V. សេវាសន្តិសុខផ្តល់ដោយក្រុមហ៊ុន សហ័ស ភីភីអេសអ៊ីហ្សិត ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ទាំងស្រុងដោយ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) ដើម្បីត្រួតពិនិត្យ និងរក្សាសុវត្ថិភាពក្នុងតំបន់។ និង

VI. "សេវាច្រកចេញចូលតែមួយ" ដែលមាននៅក្នុងតំបន់ស្រាប់ ដែលសហការជាមួយភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនានា ដូចជាភ្នាក់ងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា នាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសម្រួលដល់ការបង់ពន្ធគយ ការចុះបញ្ជីពាណិជ្ជកម្ម និងការគោរព តាមច្បាប់ដល់វិនិយោគិនតំបន់របស់ខ្លួន។

ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដ៏ទំនើប PPSEZ បានទាក់ទាញវិនិយោគិនជាច្រើនឲ្យមកបង្កើតប្រតិបត្តិការរបស់ពួកគេក្នុងតំបន់។ ក្រុមហ៊ុនរបស់ពួកយើងមានសេវាកម្ម ដូចខាងក្រោមនេះ៖

## ១.២.១. ការលក់ដី

សម្រាប់រយៈពេលប្រាំ (០៥) ឆ្នាំសារពើពន្ធចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ រហូតដល់ឆ្នាំ២០១៦ មុនកាលបរិច្ឆេទ អនុវត្តន៍ចុងក្រោយ ចំណូលបានពីការលក់ដីក្នុង PPSEZ គឺជាផ្នែកសំខាន់នៃ ប្រាក់ចំណូលដុលរបស់សម្ព័ន្ធក្រុមហ៊ុនយើង។ ប្រាក់ចំណូលដុលដែលបានពីការលក់ដីអាស្រ័យ ទៅលើចំនួនឡូតិ៍ និងទំហំនៃឡូតិ៍នីមួយៗដែលត្រូវបានលក់។

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ មានទីតាំងប្រហែលជាដប់ប្រាំបី (១៨) គីឡូម៉ែត្រពីចំណុចកណ្តាលនៃ រាជធានីភ្នំពេញ ហើយស្ថិតនៅជាប់ជាមួយផ្លូវជាតិលេខ៤។ ក្នុងនាមជាវិនិយោគិនតំបន់សេដ្ឋកិច្ចពិសេសវិនិយោគិនតំបន់អាចស្នើសុំ និងទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល និងទទួលបាននូវអត្ថប្រយោជន៍ ដែលបានមកពីការកាត់បន្ថយចំណាយ លើហេដ្ឋារចនាសម្ព័ន្ធនៅពេលវិនិយោគិនតំបន់បង្កើតរោងចក្ររបស់ខ្លួនក្នុង PPSEZ ។

យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ដែលមាន សិទ្ធិកម្មសិទ្ធិលើដីក្នុងព្រះរាជាណាចក្រកម្ពុជា ដូចនេះ ការលក់ដីដែលធ្វើឡើងក្នុង PPSEZ គឺតាមការលក់ផ្តាច់ ឬការជួលរយៈពេលវែង។ ប្រតិបត្តិការលក់ដីធ្វើឡើងសម្រាប់រូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ តាមរយៈកិច្ចព្រមព្រៀងទិញលក់ ដែលក្នុងនោះប័ណ្ណកម្មសិទ្ធិ ដីនៃដីឡូតិ៍ដែលត្រូវលក់នោះ នឹងត្រូវផ្ទេរទៅឲ្យអ្នកទិញនៅពេលអ្នកទិញបានទូទាត់ថ្លៃទិញលក់ដល់ដំណាក់កាលចុងក្រោយ។ ម្យ៉ាងវិញទៀត ការជួលរយៈពេលវែងដែលអាចជួលឲ្យអ្នកជួលក្នុងស្រុក ឬបរទេស ត្រូវបាន អនុវត្តតាមរយៈកិច្ចព្រមព្រៀងជួលរយៈពេលហាសិប (៥០)ឆ្នាំ ដែលមិនអាចប្តូរជា ប្រាក់វិញបាន ដោយភ្ជាប់មកជាមួយនឹងជម្រើសក្នុងការបន្តបានរយៈពេលហាសិប (៥០) ឆ្នាំទៀត តាមខសន្យា និងលក្ខខណ្ឌដែលដែលអាចបន្តជាថ្មីដោយអ្នកជួល។

សម្រាប់រយៈពេលប្រាំ (០៥) ឆ្នាំសារពើពន្ធបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ សម្រាប់ឆ្នាំ២០១២ រហូតដល់ឆ្នាំ២០១៦ ចំនួនប្រតិបត្តិការលក់ដីរបស់ក្រុមហ៊ុនក្នុង PPSEZ ដែលត្រូវបានធ្វើឡើងតាមរយៈការទិញ និងការជួលរយៈពេលវែង មានដូចខាងក្រោម៖

| ពិពណ៌នា | ២០១៦ | ២០១៥ | ២០១៤ | ២០១៣ | ២០១២ |
|---|---|---|---|---|---|
| ការលក់ផ្តាច់ | ០ | ០ | ១ | ១ | ៣ |
| ការជួលរយៈពេលវែង | ៨ | ៨ | ៦ | ១៤ | ១១ |
| ប្រតិបត្តិការលក់ដីសរុប | ៨ | ៨ | ៧ | ១៥ | ១៤ |

PHONM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ដោយគិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ PPSEZ មានដីសរុបទំហំប្រមាណ ៣៥៧.៣២ ហិកតា ដែលនឹងត្រូវអភិវឌ្ឍ ជាបី (០៣) ដំណាក់កាលដូចខាងក្រោម៖

I. ដំណាក់កាល១ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗ បានបញ្ចប់ ក្នុងឆ្នាំ២០០៩។ វាមានទំហំ សរុបប្រមាណ ១៣៧.៩៤ ហិកតា ដែលក្នុងនោះផ្ទៃដីប្រមាណ ៨៦.៧១ ហិកតា ត្រូវបានអភិវឌ្ឍជាទីតាំងដីឡូត៍សម្រាប់រោងចក្រចំនួនហុកសិបមួយ (៦១) ដែលឡូត៍នីមួយៗមានទំហំចាប់ពី ០.១៩ ហិកតា ដល់ ១០.៥៧ ហិកតា។ ដំណាក់កាល១ក៏រួមបញ្ចូលនូវដីប្រមាណ ២៤.៤៦ ហិកតា ដែលត្រូវបានរៀបចំសម្រាប់ការអភិវឌ្ឍពាណិជ្ជកម្មដែលអាចបង្កើតជាទីតាំងផ្សេងៗដូចជា ហាង ភោជនីយដ្ឋាន ធនាគារ។ បន្ថែមពីនេះ ផ្ទៃដីប្រហែល ១.៥៣ ហិកតា ត្រូវបានរៀបចំធ្វើជាកន្លែងស្នាក់នៅឲ្យកម្មករ តំបន់នៅសល់ត្រូវបានរៀបចំសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ដែលរួមមានទីស្នាក់ការកណ្តាលរបស់យើង។

II. ដំណាក់កាល២ មានទំហំប្រមាណ ១៦១.៥៩ ហិកតា ដែលត្រូវបានបែងចែកជាពីរ (០២) ផ្នែកផ្សេងទៀត គឺដំណាក់កាល២-១ និង ដំណាក់កាល២-២។ ចំពោះដំណាក់កាល២-១ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារបានបញ្ចប់ក្នុងឆ្នាំ២០១៤។ ដំណាក់កាល២-១ គ្របដណ្តប់លើតំបន់ដែលមានទំហំប្រមាណ ៨៧.៨៥ ហិកតា ដែលក្នុងនោះ ៥៩.៨៥ ហិកតា ត្រូវបានអភិវឌ្ឍដើម្បីបង្កើតជាទីតាំងឡូត៍រោងចក្រចំនួនម្ភៃប្រាំបី (២៨) ដែលឡូត៍នីមួយៗមានទំហំចាប់ពី ០.៥០ ហិកតា ដល់ ១០ ហិកតា ហើយផ្ទៃដីប្រហែល ២.៨២ ហិកតា ត្រូវបានធ្វើជាកន្លែងស្នាក់នៅឲ្យកម្មករ និងដីនៅសល់ត្រូវបានប្រើសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ។ មកដល់បច្ចុប្បន្ន ដំណាក់កាល២-២ កំពុងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗ ដែលរំពឹងថានឹងបញ្ចប់នៅដើមឆ្នាំ២០១៦។ ដំណាក់កាល២-២ គ្រប់ដណ្តប់លើដីដែលមានទំហំប្រមាណ ៧៣.៧៤ ហិកតា ដែលក្នុងនោះ ៥៧.៨២ ហិកតា ត្រូវបានអភិវឌ្ឍដើម្បីបង្កើតជាទីតាំងឡូត៍រោងចក្រចំនួនសាមសិបមួយ (៣១) ដែលដីឡូត៍នីមួយៗមានទំហំចាប់ពី ០.៦៤ ហិកតា ដល់ ៩.២៨ ហិកតា តំបន់នៅសល់ត្រូវបានប្រើសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម។ និង

III. ដំណាក់កាល៣ ដែលមានដីទំហំប្រមាណ ៥៧.៧៩ ហិកតា កំពុងស្ថិតក្នុងដំណាក់កាលរៀបចំគម្រោង និងមិនទាន់ត្រូវបានអភិវឌ្ឍនៅឡើយទេ។ គម្រោងបឋមរបស់ដំណាក់កាល៣ សម្រាប់ឡូត៍រោងចក្រ ត្រូវបានរំពឹងថានឹងចាប់ផ្តើមដំណើរការហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗ នៅក្នុងឆ្នាំ២០១៧។

ចាប់ពីឆ្នាំ២០១០ ក្រុមហ៊ុនយើងបានទទួលវិញ្ញាបនបត្របញ្ជាក់បទដ្ឋានអន្តរជាតិ ISO 9001 សម្រាប់ ការប្តេជ្ញាក្នុងការគ្រប់គ្រងយ៉ាងមានគុណភាព និង ISO 14001 សម្រាប់ការប្តេជ្ញាក្នុងការត្រួតពិនិត្យ បរិស្ថានរបស់ខ្លួន។

## ១.២.២. សេវាកម្មដែលផ្តល់ជូន

ស្របជាមួយនឹងការអភិវឌ្ឍនៃការលក់ដីក្នុង PPSEZ ក្រុមហ៊ុនយើងផ្តល់ឲ្យអ្នកជួលក្នុង PPSEZ នូវសេវាកម្ម និងហេដ្ឋារចនា សម្ព័ន្ធ ក្នុងការសម្រួលដល់ប្រតិបត្តិការរបស់ពួកគេដែលរួមមាន៖

### បរិក្ខារ

ក្រុមហ៊ុនរបស់យើង ផ្តល់ឲ្យអ្នកជួលនៅក្នុង PPSEZ នូវការផ្គត់ផ្គង់ទឹកដែលមានស្ថេរភាព និងឯករាជ្យ។ យើងផ្គត់ផ្គង់ទឹកតាមរយៈការដំឡើងស្ថានីយ៍ចម្រោះទឹក ដែលមានសមត្ថភាពផលិតទឹកស្អាតចំនួន ១០.៦០០ ម៣ ក្នុងមួយថ្ងៃ។ រោងចក្រចម្រោះទឹកមានទីតាំងស្ថិតនៅក្នុង PPSEZ ដោយវាប្រមូលទឹកពីស្ទឹងព្រែកត្នោតដែលមានទីតាំងជាប់នឹង PPSEZ។ លើសពីនេះ ទឹកមួយចំនួនទៀតក៏មានប្រភពពីទឹកភ្លៀង ដែលយើងប្រមូលដោយប្រើប្រាស់នូវត្រពាំង ស្តុកទឹកភ្លៀង ដែលមានសមត្ថភាពស្តុកចំនួន ២៥.០០០ ម៣ ។ ត្រពាំងស្តុកទឹកភ្លៀងត្រូវបានប្រើជាប្រព័ន្ធបម្រុងសម្រាប់ផ្គត់ផ្គង់ទឹកបណ្តោះអាសន្ន ក្នុងករណីដែលការផ្គត់ផ្គង់ទឹក ពីទឹកស្ទឹងមានភាពរអាក់រអួល។ មុនពេលផ្គត់ផ្គង់ទឹកទៅអ្នកជួលក្នុង PPSEZ វិស្វករដែលមានបទពិសោធន៍ក្នុងការចម្រោះទឹក បានធ្វើតេស្តគុណភាពរបស់ទឹកដោយប្រើឧបករណ៍ទំនើប និងមានប្រសិទ្ធភាព នៅក្នុងមន្ទីរពិសោធន៍របស់ស្ថានីយ៍ ដើម្បីធានាគុណភាពទឹកស្របតាមស្តង់ដារឧស្សាហកម្ម។ ក្រុមហ៊ុនរបស់យើងបានដំឡើងអាងស្តុកទឹកកំពស់ខ្ពស់ និងអាងទឹកសរុបចំនួនប្រាំ (០៥) សម្រាប់ស្តុកទឹក និងបង្កើនសម្ពាធទឹកសម្រាប់ការប្រើប្រាស់របស់អ្នកជួល។

យើងបានចូលរួមក្នុងប្រតិបត្តិការរោងចក្រផលិតអគ្គិសនីក្នុង PPSEZ តាមរយៈក្រុមហ៊ុនជាសម្ព័ន្ធរបស់យើងគឺក្រុមហ៊ុន ខូលបេន ភីភីអេសអ៊ីហ្សេត ដែលផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកជួល និងរាល់អគារនៅក្នុង PPSEZ សម្រាប់ប្រើប្រាស់ក្នុងករណីដែលមានការខ្វះខាតថាមពលដែលផ្គត់ផ្គង់ដោយអគ្គីសនីជាតិ។ រោងចក្រផលិតអគ្គិសនីនេះ ត្រូវបានសង់នៅលើផ្ទៃដីដែលមានទំហំប្រមាណ ៥.០៤ ហិកតា និងមានសមត្ថភាពផលិតអគ្គិសនីសរុបដប់បី (១៣) មេហ្គាវ៉ាត តាមរយៈម៉ាស៊ីនភ្លើងធុនធំប្រើប្រេងឥន្ធនៈចំនួនបី (០៣)។

រូបភាពខាងក្រោមបង្ហាញពីរោងចក្រអគ្គិសនីឯកជនដែលស្ថិតនៅក្នុង PPSEZ៖





(ប្រភព៖ PPSP)

### ការថែទាំហេដ្ឋារចនាសម្ព័ន្ធ

ដើម្បីផ្គត់ផ្គង់ចំណាយក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងប្រតិបត្តិការទូទៅរបស់ PPSEZ ក្នុងទីធ្លាសាធារណៈដូចជាផ្លូវថ្នល់ អគ្គិសនីសម្រាប់អំពូលតាមផ្លូវ និងចំណាយថែទាំបរិក្ខារហេដ្ឋារចនាសម្ព័ន្ធក្នុង PPSEZ ក្រុមហ៊ុនរបស់យើងប្រមូលថ្លៃថែទាំហេដ្ឋារចនាសម្ព័ន្ធពីអ្នកកាន់កាប់ក្នុង PPSEZ។ ថ្លៃថែទាំហេដ្ឋារចនាសម្ព័ន្ធនេះ ត្រូវបានប្រមូលផ្អែកលើទំហំដីរបស់អ្នកកាន់កាប់ ដែលត្រូវគុណដោយអត្រាកំណត់ទុកមុននៃថ្លៃថែទាំ។

### សេវាផ្ដល់ប្រឹក្សា និងជំនួយរដ្ឋបាល

ដើម្បីជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយ សម្រាប់វិនិយោគិនតំបន់របស់យើង ក្រុមហ៊ុន របស់យើងផ្ដល់ប្រឹក្សា និងសេវាកម្មជំនួយរដ្ឋបាល។ ការផ្ដល់ឲ្យនូវការប្រឹក្សា និងជំនួយខាងរដ្ឋបាលនេះមានគោលបំណងក្នុងការសម្រួល សកម្មភាពចុះបញ្ជីរបស់វិនិយោគិនតំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា។ សេវាកម្មជំនួយរដ្ឋបាលទាំងនេះរួមមានការចុះបញ្ជីប្រតិបត្តិការអាជីវកម្មរបស់វិយោគិនតំបន់ ជាមួយនឹងអជ្ញាធរផ្សេងៗទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានដូចខាងក្រោម៖

- ការចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- ការដាក់ពាក្យសុំការលើកទឹកចិត្តផ្នែកពន្ធដារ
- ការរៀបចំបញ្ជីគោលសម្រាប់ការផលិត
- វិញ្ញាបនបត្រ និងការប្រកាសបើករោងចក្រ
- ការចុះបញ្ជីនៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- វិញ្ញាបនបត្រប្រព័ន្ធអនុគ្រោះទូទៅ (សម្រាប់វិនិយោគិនតំបន់ដែលត្រូវនាំទំនិញចេញ) សម្រាប់ការបង់ពន្ធអាករ។

### ប្រព្រឹត្តិកម្មទឹកសំអុយ

យើងមានផ្ដល់សេវាប្រព្រឹត្តិកម្មទឹកសម្រាប់ទឹកសំណល់ ដែលត្រូវបានបញ្ចេញចោលដោយអ្នកកាន់កាប់តំបន់ ដោយប្រើប្រាស់ប្រព័ន្ធបង្ហូរទឹកការពារច្រេះ ដែលត្រូវបានដំឡើងនៅក្នុង PPSEZ។ ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកសំអុយ ប្រើប្រាស់ប្រព័ន្ធ Aerated Lagoon ដែលប្រើប្រាស់ Aeration Ponds ដែលមាន Aerators Settling Ponds និង Polishing Pond ដើម្បីច្រោះសារធាតុពុលក្នុងទឹកសំណល់មុនពេលបញ្ចេញចោលទៅក្រៅតំបន់ ឬប្រើប្រាស់ឡើងវិញក្នុងគោលបំណងស្រោចស្រព ក្នុងបរិវេណតំបន់។

រូបភាពខាងក្រោមបង្ហាញពីការច្រោះទឹក និងបរិក្ខារប្រព្រឹត្តិកម្មទឹកសំអុយ នៅក្នុង PPSEZ៖





(ប្រភព៖ PPSP)

## ១.២.៣. ប្រាក់ចំណូលបានពីការជួល

យើងផ្ដល់សេវាកម្មជួលអគាររួមមាន រោងចក្រ និវេសនដ្ឋាន ឃ្លាំង និងហាងក្នុង PPSEZ។ សេវាកម្មជួលទាំងនេះ ភាគច្រើនគឺជាការជួលរយៈពេលខ្លី។ ជាទូទៅរយៈពេលជួលមានចាប់ពីបី (០៣)ដល់ប្រាំ (០៥) ឆ្នាំ ជាមួយនឹងជម្រើសក្នុងការបន្តបី (០៣) ដល់ប្រាំ (០៥) ឆ្នាំទៀត។

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ១.៣. ស្ថានភាពទីផ្សារ

គិតមកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនរបស់យើងធានាបានវិនិយោគិនតំបន់/អ្នកជួលសរុបចំនួន ប៉ែតសិបបី (៨៣) ក្នុង PPSEZ ដែលមានប្រភពពី ប្រទេសជប៉ុន សឹង្ហបុរី ម៉ាឡេស៊ី តៃវ៉ាន់ កូរ៉េ ហ្វីលីពីន ចិន វៀតណាម ទួគី សហរដ្ឋអាមេរិក កម្ពុជា និងថៃ។

គោលដៅអតិថិជនរបស់យើង គឺវិនិយោគិនតំបន់ដែលចូលរួមក្នុងឧស្សាហកម្មចាប់ពីធុនស្រាលទៅមធ្យម និងឧស្សាកម្មប្រើប្រាស់ពលកម្មច្រើន ហើយកន្លងមក យើងបានទាក់ទាញវិនិយោគិនពីឧស្សាហកម្មដូចខាងក្រោម៖

- ផលិតផលមេកានិក និងអគ្គិសនីទុកសម្រាប់ការនាំចេញ និងទីផ្សារក្នុងស្រុក
- ឧស្សាហកម្មវាយនភណ្ឌ ស្បែកជើង និងសំលៀកបំពាក់
- ឧស្សាហកម្មចំណីអាហារ និងកសិកម្មសម្រាប់ទីផ្សារក្នុងតំបន់ និងក្នុងស្រុក
- ផលិតផលប្រើប្រាស់ (ឱសថ ទំនិញខ្ចប់ ។ល។)
- គ្រឿងបន្លាស់យានយន្ត
- ការដំឡើងផ្នែកផលិតផលមិនទាន់សម្រេចទៅជាផលិតផលសម្រេចសម្រាប់ទីផ្សារក្នុងស្រុក និងក្នុងតំបន់ និងក្រុមហ៊ុនដឹកជញ្ជូន។

ផ្អែកតាមការធ្វើបច្ចុប្បន្នភាពថ្មីៗនេះពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត បានទទួលគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធំៗជាងគេបំផុត ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ដែល មានគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំនួន ៨៣ គម្រោង។

| ឈ្មោះតំបន់សេដ្ឋកិច្ចពិសេស | ទីតាំង | ឆ្នាំបង្កើត | ផ្ទៃដី (ហិកតា) | គ.ល.គ |
|---|---|---|---|---|
| តំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ | ភ្នំពេញ | ២០០៦ | ៣៦០ | ៨៣ |
| តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ២ | ព្រះសីហនុ | ២០០៨ | ១.១១៣ | ៧៤ |
| តំបន់សេដ្ឋកិច្ចពិសេស ម៉ាន់ហាធែន | ស្វាយរៀង | ២០០៦ | ១៥៧ | ៣២ |
| តំបន់សេដ្ឋកិច្ចពិសេស តាយ សេង បាវិត | បាវិត | ២០០៧ | ៩៩ | ២៦ |
| តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត អូរនាង | ប៉ោយប៉ែត | ២០០៦ | ៤៦៧ | ៥ |
| តំបន់សេដ្ឋកិច្ចពិសេស នាង កុក កោះកុង | កោះកុង | ២០០៧ | ៣៣៥ | ៥ |
| តំបន់សេដ្ឋកិច្ចពិសេស ដ្រេហ្គន ឃីង បាវិត | ស្វាយរៀង | ២០១២ | ១០៦.៥ | ៤ |
| តំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វយ័តក្រុងព្រះសីហនុ | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២០០៩ | ៧០ | ៣ |
| តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ១ | ព្រះសីហនុ | ២០០៦ | ១៧៨ | ២ |
| តំបន់សេដ្ឋកិច្ចពិសេស សានកូ ប៉ោយប៉ែត | សានកូ ខេមបូ | ២០១៣ | ៦៦.៥ | ២ |
| តំបន់សេដ្ឋកិច្ចពិសេស សានដុង សាន់សែល | ស្វាយរៀង | ២០១៣ | ៩៦ | ២ |
| តំបន់សេដ្ឋកិច្ចពិសេស H. K. T | ព្រះសីហនុ | ២០១២ | ៣៤៥ | ១ |
| តំបន់សេដ្ឋកិច្ចពិសេស កំពត់ | កំពត | ២០០៧ | ១៤៥ | ១ |

(សំគាល់៖ "គ.ល.គ" គម្រោងវិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ទោះបីជាមានកំណើនយឺតនៅក្នុងឆ្នាំនេះក៏ដោយ ទស្សនវិស័យទៅថ្ងៃអនាគតសម្រាប់តំបន់សេដ្ឋកិច្ច ពិសេសនៅក្នុងប្រទេសកម្ពុជា ត្រូវបានព្យាករណ៍ថានឹងនៅមានភាពវិជ្ជមាន ស្របជាមួយនឹងការប្រមើលឃើញនូវកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការវិនិយោគ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ជាការពិត គម្រោងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានណែនាំដោយរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញការវិនិយោគ ដោយមានគោលបំណងបង្កើតនីតិវិធីរដ្ឋបាលឲ្យកាន់តែមានប្រសិទ្ធិភាព និងលើកទឹកចិត្តឲ្យវិស័យឯកជន ចូលរួមនៅគ្រប់ទិដ្ឋភាព ទាំងអស់ក្នុងការអភិវឌ្ឍន៍ និងប្រតិបត្តិការក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះទៀត ច្បាប់ និងគោលនយោបាយត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីលើកទឹកចិត្តនិងការពារដល់ការវិនិយោគបរទេស ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុករបស់ប្រទេសកម្ពុជា ជាពិសេសច្បាប់ស្តីពីការវិនិយោគត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៣។ ដោយសារ ប្រទេសកម្ពុជានៅតែបន្តខំយ៉ាងខ្លាំង សម្រាប់ឧស្សាហូបនីយកម្ម កំណើនរឹងមាំត្រូវបានរំពឹងថា នឹងបានមកពីឧស្សាហកម្មសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ជាពិសេសពីវិស័យកសិកម្ម រោងចក្រ កាត់ដេរសំណង់ និងទេសចរណ៍។ ការគាំទ្រយ៉ាងសកម្មពីរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ ប្រទេសជាតិបានជះឥទ្ធិពលទៅដល់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសទាំងមូល។

ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា គឺនៅតែស្ថិតក្នុងដំណាក់កាលដំបូងរបស់ខ្លួននៅឡើយ។ សព្វថ្ងៃនេះ អ្នកផ្តល់ការវិនិយោគផ្ទាល់ពីបរទេសធំៗ មួយចំនួនមកប្រទេសកម្ពុជារួមមាន ប្រទេសចិន កូរ៉េ ម៉ាឡេស៊ី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ ក្នុងចំណោម ៣៤ តំបន់សេដ្ឋកិច្ចពិសេស ដែលបានអនុម័ត មានតែ ១៣តំបន់សេដ្ឋកិច្ចពិសេសតែប៉ុណ្ណោះដែលបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ការអភិវឌ្ឍន៍ដ៏រឹងមាំនិងការរីកចម្រើនផ្នែកឧស្សាហកម្ម ត្រូវបានរំពឹងថានឹងធានាបាននូវកំណើនយ៉ាងខ្លាំង សម្រាប់អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស នៅសល់នៅក្នុងប៉ុន្មានឆ្នាំខាងមុខ។ ប្រទេសកម្ពុជាមានបរិយាកាសវិនិយោគគួរឱ្យទាក់ទាញមួយ តាមរយៈបរិយាកាសស្ថិរភាពនយោបាយ គុណប្រយោជន៍ភូមិសាស្ត្រប្រព័ន្ធសេដ្ឋកិច្ចបើកចំហ និងថ្លៃកម្លាំងពលកម្មទាប។ លើសពីនេះ រដ្ឋាភិបាលកម្ពុជាបានផ្តល់នូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ពន្ធនាំចូល និងការលើកទឹកចិត្តជាច្រើនដូចជាសេវាកម្មច្រកចេញចូលតែមួយ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសចូលទៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះ។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង កន្លែងផ្តល់ភាពងាយស្រួលមួយចំនួនក្នុងតំបន់សេដ្ឋកិច្ចពិសេសជាការទាក់ទាញបន្ថែម វិនិយោគិនតំបន់ដើម្បីធ្វើការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ហេតុដូចនេះវាជួយបង្កើនល្បឿននៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ច ពិសេសផងដែរ។

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ១.៤. ស្ថានភាពប្រកួតប្រជែង

ចំណុចសំខាន់ផ្សេងៗដំបូងសម្រាប់គុណសម្បត្តិ នៃការប្រកួតប្រជែងរបស់យើងមានដូចខាងក្រោម៖

### ១.៤.១. ទីតាំងយុទ្ធសាស្ត្ររបស់ PPSEZ

PPSEZ មានទីតាំងស្ថិតនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា និងមានចម្ងាយប្រមាណដប់ប្រាំបី (១៨) គីឡូម៉ែត្រពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ ដែលងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ កំពង់ផែស្វយ័តភ្នំពេញ (កំពង់ផែទន្លេអន្តជាតិនៅរាជធានីភ្នំពេញ) និងមានចម្ងាយប្រាំបី (០៨) គីឡូម៉ែត្រ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ជាងនេះទៅទៀត PPSEZ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ដែលជាផ្លូវគមនាគមន៍ចម្បង និងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។ PPSEZ ក៏អាចធ្វើដំណើរទៅដល់ដោយមធ្យោបាយគមនាគមន៍ ផ្សេងទៀត។ បន្ថែមពីនេះ PPSEZ មានទីតាំងស្ថិតនៅជិតផ្លូវដែកសំខាន់របស់កម្ពុជា។ ទីតាំងយុទ្ធសាស្ត្ររបស់ PPSEZ បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅដល់ និងជួយសម្រួលក្នុងការចែកចាយទំនិញផលិតបានទៅកាន់ តំបន់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២. ការបង្កើតទំនាក់ទំនងល្អជាមួយនឹងអតិថិជន

បច្ចុប្បន្ន ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) បានចូលរួមក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសអស់រយៈពេលលើសពីដប់ (១០)ឆ្នាំ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ PPSEZ មានវិនិយោគិនតំបន់ចំនួនប៉ែតសិបមួយ (៨១) (អតិថិជនត្រូវបានស្គាល់ថាជាវិនិយោគិនតំបន់ផងដែរ នៅពេលពួកគេបានបង្កើតប្រតិបត្តិការក្នុង PPSEZ) ដែល បានបង្កើតរោងចក្ររួចរាល់ ឬកំពុងបង្កើតរោងចក្រផលិតកម្ម/ដំឡើងម៉ាស៊ីនក្នុង PPSEZ។ បន្ថែមពីនេះ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ PPSEZ មានវិនិយោគិនច្រើនជាងគេក្នុងចំណោម តំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតចំនួនសាមសិបបួន (៣៤) ក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត តាមរយៈភាគហ៊ុនិកជនជាតិជប៉ុនរបស់យើង និងបណ្តាញធុរកិច្ចទូលំទូលាយរបស់គណៈគ្រប់គ្រងរបស់ PPSP ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនរបស់យើងបានទាក់ទាញបានយ៉ាងជោគជ័យនូវក្រុមហ៊ុនជប៉ុនចំនួនសែសិបប្រាំ (៤៥) ដែលបានមកវិនិយោគក្នុង PPSEZ ដែលបានធ្វើឲ្យ PPSEZ មានវិនិយោគិនជនជាតិជប៉ុនធំជាងគេក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.៤.៣. បុគ្គលិកជាន់ខ្ពស់ដែលមានបទពិសោធន៍ខ្ពស់

ក្រុមហ៊ុនរបស់យើង ដឹកនាំដោយបុគ្គលិកជាន់ខ្ពស់ដែលមានបទពិសោធន៍ខ្ពស់។ ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិរបស់យើង លោកជំទាវឧកញ៉ា លឹម ឈីវហូរ បានដឹកនាំក្រុមហ៊ុនតាំងពីការបង្កើតក្រុមហ៊ុនដំបូងក្នុងឆ្នាំ ២០០៦។ លោកជំទាវឧកញ៉ា លឹម ឈីវហួរ បានចូលរួមក្នុងការគ្រប់គ្រង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍអចលនទ្រព្យ និងការវិនិយោគ ការជួញដូរទំនិញប្រើប្រាស់ ការលំហែ និងបដិសណ្ឋារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា អស់រយៈពេលជាងសាមសិប (៣០) ឆ្នាំ។ មួយវិញទៀតនាយក ប្រតិបត្តិរបស់យើង លោក Hiroshi Uematsu បានចូលរួមក្នុងរដ្ឋបាលធុរកិច្ច និង វិស័យដែលទាក់ទងនឹងវិស្វកម្ម អស់រយៈពេលជាងម្ភៃ (២០) ឆ្នាំ។

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ បានដឹកនាំបុគ្គលិកជាន់ខ្ពស់ចំនួន ប្រាំបួន (០៩) រូប ដែលមានជំនាញផ្សេងៗគ្នាក្នុងការសាងសង់ ការគ្រប់គ្រងគម្រោង វិស្វកម្ម សេវាអតិថិជន ទីផ្សារ គណនេយ្យ ហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងទំនាក់ទំនងវិនិយោគិន គឺជាចំណែកយ៉ាងធំក្នុងភាពជោគជ័យរបស់សម្ព័ន្ធក្រុមហ៊ុនយើង។

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

### ១.៤.៤ .សេវាកម្មចាំបាច់បន្ថែម

បន្ថែមទៅលើការអភិវឌ្ឍ និងការគ្រប់គ្រង PPSEZ សម្ព័ន្ធក្រុមហ៊ុនរបស់យើងមានសមត្ថភាពក្នុងការផ្តល់សេវាកម្មចាំបាច់បន្ថែមក្នុង PPSEZ ដែលរួមមាន៖

- សេវាសន្តិសុខដែលផ្តល់ដោយក្រុមហ៊ុន សហ័ស ភីភីអេសអ៊ីហ្សិត ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ កាន់កាប់ទាំងស្រុងដោយ PPSP។
- ការផ្គត់ផ្គង់ថាមពលអគ្គិសនីបម្រុងដែលមានស្ថេរភាព ពីស្ថានីយ៍ថាមពលអគ្គិសនីឯកជនដែលមានទីតាំងស្ថិតនៅក្នុង PPSEZ ដែលដំណើរការដោយក្រុមហ៊ុន ខូលបេន ភីភីអេសអ៊ីហ្សេត ជាក្រុមហ៊ុនជាសម្ព័ន្ធភាពរបស់។
- បរិក្ខារផែស្ងួតក្នុង PPSEZ ដែលប្រតិបត្តិការដោយក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត ដែលជាក្រុមហ៊ុនជាសម្ព័ន្ធភាពរបស់ PPSP។ និង
- ហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ដូចជាស្ថានីយ៍ចម្រោះទឹកស្អាត និងស្ថានីយ៍ប្រព្រឹត្តិកម្មទឹកសំអុយឯកជន បណ្តាញ ទូរគមនាគមន៍ ទីធ្លាឃ្លាំងជួលគ្រប់គ្រាន់ សេវាកម្មជួលនិវេសនដ្ឋាន និង សេវាកម្មដទៃទៀតដែលបំពេញតម្រូវការរបស់អ្នកជួលក្នុង PPSEZ។

## ១.៥. ផែនការអនាគត

តទៅមុខទៀត បេសកកម្មរបស់ក្រុមហ៊ុនរបស់យើងគឺ រក្សាតំណែងជាតំបន់សេដ្ឋកិច្ចពិសេសឈានមុខគេក្នុងព្រះរាជាណាចក្រកម្ពុជា។ ផែនការអនាគតរបស់ក្រុមហ៊ុនយើងមានដូចខាងក្រោម៖

### ១.៥.១. ការចាប់ផ្តើមនូវការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារចម្បងក្នុងដំណាក់កាល៣

ការបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារចម្បងក្នុងដំណាក់កាល២ គឺជាការចាប់ផ្តើមនៃការអភិវឌ្ឍដំណាក់ កាល៣ ដែលដំណាក់កាលនេះគ្រោងថានឹងត្រូវចាប់ផ្តើមក្នុងឆ្នាំ២០១៧។ ដំណាក់កាល៣ មានផ្ទៃដីសរុបប្រមាណ ៥៧.៧៩ ហិកតា។ ព័ត៌មានលម្អិតនៃគម្រោងអភិវឌ្ឍន៍នៃដំណាក់កាល៣ កំពុងត្រូវបានរៀបចំ។ ទោះជា យ៉ាងនេះក្តី យើងបានប៉ាន់ប្រមាណថានឹងវិនិយោគប្រមាណជា ៨.៥៤ លានដុល្លារអាមេរិក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍក្នុងដំណាក់កាល៣ ដែលរួមមានដូចជាការអភិវឌ្ឍដី និងទីតាំង ផ្លូវថ្នល់ប្រព័ន្ធផ្គត់ផ្គង់ទឹក និងថាមពល អគ្គិសនី បំពង់បង្ហូរទឹក លូ និងរបង។

ក្រុមហ៊ុនពុំទាន់បានចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងណាមួយ ឬធ្វើការអញ្ជើញមកដេញថ្លៃឬការដាក់តម្លៃដល់ភាគីណាមួយ សម្រាប់ការសាងសង់ដំណាក់កាល៣ រួមទាំងការងារហេដ្ឋារចនាសម្ព័ន្ធដែលគ្រោងនឹងសាងសង់ក្នុងដំណាក់កាលនេះឡើយ។ ការរៀបចំចំណាយសម្រាប់គម្រោងនេះគឺអាស្រ័យតាមបទពិសោធន៍ក្នុងការអភិវឌ្ឍដំណាក់កាល១ និង២របស់ PPSEZ នៃគណៈគ្រប់គ្រងរបស់យើង និងការប៉ាន់ស្មាននៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនយើង។

ផ្ទុយទៅវិញ ក្រុមហ៊ុនបានកំពុងត្រិះរិះពិចារណាយ៉ាងច្បាស់លាស់នូវជម្រើសនៃការអភិវឌ្ឍនូវផ្នែកមួយនៃដំណាក់កាល៣ ទៅជាតំបន់ឧស្សាហកម្ម និងអគាររោងចក្រ នៅពេលដែលដីទាំងនោះបានលក់ទៅឲ្យវិនិយោគិន។ ការធ្វើបែបនេះ អនុញ្ញាត ឲ្យក្រុមហ៊ុនរបស់យើងគ្រប់គ្រងការផ្គត់ផ្គង់ក៏ដូចជាត្រួតពិនិត្យលំហូរសាច់ប្រាក់នៅពេលជាមួយគ្នាផងដែរ។

## ១.៥.២. ការចាប់ផ្តើមនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសម្រាប់គម្រោងប៉ោយប៉ែត

ក្នុងឆ្នាំ២០១៤ យើងបានទិញដីទំនេរក្នុងខេត្តបន្ទាយមានជ័យប្រមាណ ៥២.៩៥ ហិកតា ហើយបច្ចុប្បន្នយើងកំពុងសិក្សាលើគម្រោងអភិវឌ្ឍ ដែលអាចធ្វើទៅបានលើដីខាងលើ ដើម្បីប្រែក្លាយវាជាតំបន់សេដ្ឋកិច្ចពិសេស (គម្រោងប៉ោយប៉ែត)។ គម្រោងប៉ោយប៉ែតនេះ នឹងត្រូវប្រតិបត្តិការដោយក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុនយើង គឺក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត។

គម្រោងប៉ោយប៉ែត មានទីតាំងស្ថិតនៅប៉ែកខាងកើត និងមានចម្ងាយប្រមាណជា ៥.៦០គីឡូម៉ែត្រ ពីទីប្រជុំជនក្រុងប៉ោយប៉ែត ដែលតភ្ជាប់ទៅច្រកទ្វារព្រំប្រទល់ស្ថិតនៅទិសខាងជើងឈៀងខាងលិច (ទិសពាយព្យ) នៃព្រះរាជាណាចក្រកម្ពុជា ជាប់នឹងទល់ដែននៃប្រទេសថៃ។ ទីក្រុងប៉ោយប៉ែត ស្ថិតនៅប្រមាណជា ៣០៦ គីឡូម៉ែត្រ ពីទីក្រុងបាងកក និងប្រមាណ ៤១០ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ។ គិតត្រឹមកាលបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ នៅក្រុងប៉ោយប៉ែត មានតំបន់សេដ្ឋកិច្ចពិសេសពីរ (០២) ដែលទទួលបានការអនុញ្ញាត មានតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត អូរនាង និង តំបន់សេដ្ឋកិច្ចពិសេស សានកូ ខេមបូ ។

គម្រោងប៉ោយប៉ែត ស្ថិតនៅតំបន់យុទ្ធសាស្ត្រដែលភ្ជាប់ទៅផ្លូវជាតិលេខ៥ ដែលនឹងក្លាយទៅជាផ្នែកមួយនៃផ្លូវហាយវេអាស៊ាន ១ ដែលផ្តល់ភាពងាយស្រួលដល់ការចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្នែកខាងក្នុងនៃប្រទេសថៃ និងប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន។ គម្រោងនេះ ក៏ស្ថិតនៅប្រមាណជា ២៥0 គីឡូម៉ែត្រ ពីកំពង់ផែ Laem Chabang ដែលជាកំពង់ផែសមុទ្រជ្រៅដ៏សំខាន់មួយស្ថិតនៅផ្នែកខាងកើតនៃប្រទេសថៃ។

ទស្សនៈបឋមសម្រាប់គម្រោងប៉ោយប៉ែត គឺដើម្បីអភិវឌ្ឍគម្រោងនេះឲ្យទៅជា តំបន់សេដ្ឋកិច្ចពិសេសមួយ ដែលអាចទាក់ទាញយកវិនិយោគិនឧស្សាហកម្មធុនស្រាលដែលមានសក្តានុពលដែលមានបំណងចង់យកព្រះរាជាណាចក្រកម្ពុជាជាទីតាំងផលិតកម្មជំនួសប្រទេសថៃ។ បច្ចុប្បន្ននេះ យើងកំពុងស្ថិតក្នុងដំណាក់កាលរៀបចំឯកសារចាំបាច់នានា ដើម្បីដាក់ស្នើសុំការអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធ ដើម្បីឲ្យគម្រោងប៉ោយប៉ែតនេះក្លាយជាតំបន់សេដ្ឋកិច្ចពិសេស។

ក្នុងកាលៈទេសៈនេះ យើងគ្រោងអភិវឌ្ឍគម្រោងប៉ោយប៉ែតជាពីរ (០២) ដំណាក់កាល៖ ដំណាក់កាល១ និងដំណាក់កាល២។

ផែនទីនៃគម្រោងអភិវឌ្ឍន៍សម្រាប់គម្រោងប៉ោយប៉ែតបានដាក់ បង្ហាញដូចខាងក្រោម៖

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE




ប្រភព៖ PPSP

ដំណាក់កាល១ នៃគម្រោងប៉ោយប៉ែត បានចាប់ផ្តើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារចម្បងនៅដំណាច់ឆ្នាំ២០១៦ ដែលការសាងសង់នេះនឹងត្រូវគ្របដណ្តប់លើផ្ទៃដីប្រមាណជា ៣៤.៨៣ ហិកតា ដែលផ្ទៃដីប្រមាណ ២១.៤០ ហិកតា ត្រូវបែងចែកសម្រាប់ទីតាំងរោងចក្រចំនួនសែសិបមួយ (៤០) ដែលទីតាំងសម្រាប់រោងចក្រនីមួយៗមានទំហំចាប់ពី ០.៤០ ហិកតា ដល់ ០.៩០ ហិកតា។ គម្រោងនេះក៏រួមមានផងដែរនូវតំបន់ពាណិជ្ជកម្ម ផែស្ងួត កន្លែងស្នាក់នៅសម្រាប់កម្មករ អគារការិយាល័យរដ្ឋបាល និងសំណង់បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត។ គម្រោងនេះត្រូវការចំនួនទឹកប្រាក់ប្រមាណ ៨.២៣ លានដុល្លារអាមេរិកទៅលើហេដ្ឋារចនាសម្ព័ន្ធនិងការអភិវឌ្ឍដូចជាការអភិវឌ្ឍដីបណ្តាញផ្លូវថ្នល់ ទឹក និងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីលូ ប្រព័ន្ធបង្ហូរទឹក របងហ៊ុមព័ទ្ធ និងបរិក្ខាផ្សេងៗទៀត។

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

នៅពេលខាងមុខ ដំណាក់កាល២ នៃគម្រោងប៉ោយប៉ែត នឹងចាប់ផ្ដើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារចម្បង។ ការសាងសង់នេះនឹងត្រូវគ្របដណ្ដប់លើផ្ទៃដីប្រមាណជា ២០.៦៧ ហិកតា ដែលផ្ទៃដីប្រមាណជា ១៥.៨៩ ហិកតា នឹងត្រូវបែងចែកសម្រាប់ទីតាំងរោងចក្រសរុបចំនួនម្ភៃប្រាំបី (២៨) ដែលទីតាំងរោងចក្រនីមួយៗមានទំហំចាប់ពី ០.៣៨ ហិកតា ដល់ ០.៨០ ហិកតា ហើយផ្ទៃដីដែលនៅសល់គឺត្រូវបានរៀបចំធ្វើជាតំបន់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម។

ក្នុងឆ្នាំនេះ យើងបញ្ចប់ការទិញដីបន្ថែមទៀតចំនួន ១៣ ហិកតា សម្រាប់ឱកាសធុរកិច្ចនៅពេលអនាគត។

## ១.៥.៣. ការពង្រីកសេវាកម្មពាក់ព័ន្ធផ្សេងៗ

ទោះបីជាលំហូរនៃប្រាក់ចំណូលរបស់យើងបច្ចុប្បន្នភាគច្រើនទទួលបាន ពីការលក់ដី និងការជួល តែយើងព្យាយាមបង្កើតគំរូអាជីវកម្ម ប្រកបដោយនិរន្តរភាពសម្រាប់ការអភិវឌ្ឍតំបន់ឧស្សាហកម្ម។ យើងបានខិតខំប្រឹងប្រែងធ្វើការណែនាំ និងបង្កើនប្រាក់ចំណូលពីប្រភពដែលប្រកបដោយនិរន្តរភាពអោយបានកាន់តែច្រើន។

បច្ចុប្បន្ននេះ ក្នុងបរិវេណ PPSEZ យើងបានដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជនមួយ ដែលរួមមានអាងស្តុកទឹក និងប្រព័ន្ធប្រព្រឹត្តិកម្មទឹក ដែលមានសមត្ថភាពផ្គត់ផ្គង់ទឹកប្រមាណជា ១.៩០០ម$^{៣}$ ក្នុងមួយថ្ងៃ ដែលបង្កើននូវការផ្គត់ផ្គង់តាមតម្រូវការនៃកំណើនវិនិយោគិនមកពីគ្រប់ទិសទីដូចដែលបានរំពឹងទុក។ ប្រព័ន្ធនេះ នឹងកាត់បន្ថយនូវការកាត់ផ្ដាច់ការផ្គត់ផ្គង់ទឹក ដែលអាចកើតមាននៅក្នុង PPSEZ និងធានាជូនវិនិយោគិនក្នុង PPSEZ ជាពិសេសអ្នកដែលប្រតិបត្តិការពាក់ព័ន្ធ នឹងឧស្សាហកម្មអាហារ និងភេសជ្ជៈ ដែលត្រូវការការផ្គត់ផ្គង់ទឹកឲ្យបានឋិតថេរសម្រាប់ប្រតិបត្តិការរបស់ខ្លួន មិនឲ្យប្រឈមនឹងការកាត់ផ្ដាច់ទឹកឡើយ។ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ការប្រើប្រាស់ទឹកពីប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជនរបស់យើងមានប្រមាណជា ៣.៧០០ម$^{៣}$ ក្នុងមួយថ្ងៃ ដែលស្មើនឹងការប្រើប្រាស់២៥% ។ ទោះជាយ៉ាងណា យើងរំពឹងថាការប្រើប្រាស់ទឹកនឹងកើនឡើងចំនួន ៥.០០០ម$^{៣}$ ក្នុងមួយថ្ងៃដោយផ្អែកទៅលើប្រតិបត្តិការថ្មីពីក្រុមហ៊ុនភេសជ្ជៈក្នុងតំបន់នោះ។

លើសពីនេះទៀត យើងកំពុងស្ថិតនៅក្នុងដំណើរការនៃការបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធថ្មីដែលផ្តល់ជូននូវសេវាពាណិជ្ជកម្មសំណង់នៅក្នុងគោលបំណង ទាក់ទាញនូវកំណើនតម្រូវការពីអតិថិជនរបស់យើង។ ក្រុមជំនាញរបស់យើង ទទួលខុសត្រូវសម្រាប់ការផ្តល់នូវសេវាដ៏ល្អ និងការងារផ្នែកសំណង់ទាំងនេះដល់អតិថិជនរបស់យើង។

# ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ២.១. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

នៅក្នុងឆ្នាំ២០១៦ ប្រតិបត្តិការអាជីវកម្មរបស់យើង មានការថយចុះ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ខណៈពេលដែលប្រាក់ចំណូលពីការផ្តល់សេវា និងចំណូលពីការជួល គឺស្ថិតតាមផែនការណ៍ដែលបានគ្រោងទុក (កើនឡើង ១០.១២% និង១.៧៦% រៀងៗគ្នា)។ ក្រុមហ៊ុនមានភាពលំបាកទៅនឹងការធ្លាក់ចុះនៃប្រាក់ចំណូល ពីការលក់ដី ឬជួលអចិន្ត្រៃយ៍នៅក្នុងឆ្នាំនេះ មានចំនួន ២៦.២៦១.៨០៣ពាន់រៀល បើប្រៀបធៀបទៅ៥៥.២៤៥.៤៩៩ពាន់រៀលនៅឆ្នាំមុន។

នៅក្នុងឆ្នាំ២០១៦ យើងបានឈានដល់ការចុះកិច្ចព្រមព្រៀង ដោយជោគជ័យជាមួយបណ្តាក្រុមហ៊ុន ដូចខាងក្រោមនេះ៖

| ល.រ | ភាគីកិច្ចព្រមព្រៀង | ប្រភេទ | វេបសាយ | ប្រទេស | វិស័យឧស្សាហកម្ម | ទំហំដី(ម៉ែត្រការ) |
|---|---|---|---|---|---|---|
| ១ | Sankei Engineering | ជួល | http://eng.sankei-engineering.com/ | ជប៉ុន | ផលិតគ្រឿងបង្គុំអគ្គិសនី | ៩.០០០ |
| ២ | Midori Technopark | ជួល | http://www.midori-anzen.co.jp/english/ | ជប៉ុន | ផលិតសម្ភារៈផ្នែកខាងក្នុងរថយន្ត | ១២.៦៦៩ |
| ៣ | Winsun Cambodia | ជួល | http://taisun.trustpass.alibaba.com/ | តៃវ៉ាន់ | ផលិត ខោទឹកនោមសម្រាប់ទារក និងមនុស្សចាស់ សំឡីអនាម័យស្ត្រី និង កន្សែងសើម | ១៧.២៨៧ |
| ៤ | Shinohara | ជួល | http://www.shinohara-web.co.jp/ | ជប៉ុន | ឧបករណ៍កែសម្ផស្ស | ១៣.៨៨៥ |
| ៥ | Tanaka Foresight | ជួល | http://www.tanaka-pd.co.jp/english/ | ជប៉ុន | ឧបករណ៍កែសម្ផស្ស | ១៣.៨៨៥ |
| ៦ | Kingtel (EMAXX) | ជួល | http://www.kingtel.com.kh/ | ចិន | ឃ្លាំងសម្រាប់អ៊ិនធឺណែត | ១.៥០០ |
| ៧ | Herba Ingredients | ជួល | http://www.herbaingredients.com/ | ហូឡង់ | លក់ដុំស្រូវអង្ករ គ្រាប់ធញ្ញជាតិ ម្សៅមី និង ស្ករ | ២០.៣៦៨ |
| ៨ | IKEE Paving Systems | ជួល | http://www.ikee.jp/ | ជប៉ុន | សម្ភារៈសំណង់ | ៨.៣១០ |

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ២.២. ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

ដូចបានរៀបរាប់ខាងលើ ការផ្លាស់ប្តូរយ៉ាងសំខាន់នៃការធ្វើប្រតិបត្តិការអាជីវកម្ម គឺមានការធ្លាក់ចុះនៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៦ បើប្រៀបធៀបទៅនឹង ឆ្នាំ២០១៥។

## ២.៣. វិចនាសម្ព័ន្ធចំណូល

យើងខ្ញុំ គណនាចំណូលដោយគិតតាមតម្លៃសមស្របតាមការព្រមព្រៀងទិញលក់ សេវាដែលបានទទួល ឬនឹងត្រូវទទួល ឬតម្លៃបន្ទាប់ពីការបញ្ចុះថ្លៃ និងការបង្វិលសងវិញ។ យើងខ្ញុំក៏កត់ត្រាចំណូលស្របទៅតាមផលចំណេញពីសេដ្ឋកិច្ច ដែលអាចនឹងទទួលបានពីប្រតិបត្តិការណាមួយដែលក្រុមហ៊ុននឹងទទួលបាន ព្រមទាំងចំណូល និងការចំណាយនានាដែលកើតមានឡើង ឬនឹងអាចកើតមានឡើង ពាក់ព័ន្ធនឹងប្រតិបត្តិការទាំងនោះ ហើយដែលចំណូល ឬចំណាយទាំងនោះអាចកំណត់ជាក់លាក់បាន និងលក្ខខណ្ឌវិនិច្ឆ័យជាក់លាក់ច្បាស់លាស់នៃការទទួលស្គាល់ត្រូវបានបំពេញសម្រាប់សកម្មភាពនីមួយៗរបស់យើងខ្ញុំ ដូចខាងក្រោម៖

### ក. ចំណូលពីការលក់ដី

ចំណូលដែលបានពីការលក់ដីត្រូវបានទទួលស្គាល់នៅពេលដែលហានិភ័យ និងកម្មសិទ្ធិលើដីត្រូវបានផ្ទេរទៅឲ្យអ្នកទិញ ហើយចំនួននៃចំណូលអាចកំណត់បានច្បាស់លាស់។

### ខ. ចំណូលពីសេវាកម្ម

ចំណូលដែលបានមកពីការផ្តល់សេវាកម្ម គឺមួយផ្នែកធំបានមកពីការផ្តល់សេវាថែទាំ ឧបករណ៍បរិក្ខារ ការប្រើប្រាស់បណ្តាញខ្សែបញ្ជូនអគ្គិសនី និងសេវាសន្តិសុខ ដែលត្រូវបានទទួលស្គាល់នៅពេលសេវាកម្មទាំងនោះត្រូវបានផ្តល់ឲ្យ។

### គ. ចំណូលពីការជួល

ចំណូលដែលបានមកពីការជួល ត្រូវបានកំណត់ក្នុងមូលដ្ឋានតម្លៃថេរ ក្នុងរយៈពេលជួលនៃកិច្ចសន្យាជួលណាមួយដែលមិនទាន់ផុតអាណត្តិ។ ការចំណាយសរុបនៃការលើកទឹកចិត្ត ដែលបានផ្តល់ជូនអ្នកជួលត្រូវបានទទួលស្គាល់ថា ជាចំណូលពីការជួលបន្ទាប់ពីបានដកចំណាយរួច ក្នុងរយៈពេលជួលដោយគិតលើមូលដ្ឋាននៃចំនួនថេរមួយ។

ប្រាក់ចំណូលរបស់យើងដោយផ្អែកសម្រាប់រយៈពេលបី(៣)ឆ្នាំចុងក្រោយនេះ ត្រូវបានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភពចំណូល | ឆ្នាំ២០១៦ | | ឆ្នាំ២០១៥ | | ឆ្នាំ២០១៤ | |
|---|---|---|---|---|---|---|---|
| | | បរិមាណ | ភាគរយ | បរិមាណ | ភាគរយ | បរិមាណ | ភាគរយ |
| ១ | ចំណូលពីការលក់ដី | ២៦.២៦១.៨០៣ | ៦៨.៧៧% | ៥៥.២៤៥.៤៩៩ | ៨៣.២៩% | ៨៥.៦៩៦.៩០៤ | ៩០.០៦% |
| ២ | ចំណូលពីសេវាកម្ម | ៨.៥៤៩.៥២៦ | ២២.៣៩% | ៧.៧៦៤.១៧៤ | ១១.៧១% | ៦.៧៨៤.១៣៣ | ៧.១៣% |
| ៣ | ចំណូលពីការជួល | ៣.៣៧៩.១២៣ | ៨.៨៥% | ៣.៣២០.៧២១ | ៥.០១% | ២.៦៧៨.០២៥ | ២.៨១% |
| ចំណូលសរុប | | ៣៨.១៩០.៤៥២ | ១០០.០% | ៦៦.៣៣០.៣៩៤ | ១០០.០% | ៩៥.១៥៩.០៦២ | ១០០.០% |

ឯកតា៖ ពាន់រៀល

# ផ្នែកទី ៣ : អភិបាលកិច្ចសាជីវកម្ម

## ៣.១. ភាគហ៊ុនិក

### ក-ការការពារសិទ្ធិភាគហ៊ុនិក

ភាគហ៊ុនិកនីមួយៗ គឺត្រូវបានការពារដោយក្រុមប្រឹក្សាភិបាលចំពោះសិទ្ធិដែលមានភ្ជាប់ទៅលើភាគហ៊ុនដែលផ្តល់ដោយ PPSP ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដូចខាងក្រោម៖

- **សិទ្ធិទទួលបានភាគលាភ៖** អ្នកកាន់កាប់ភាគហ៊ុននីមួយៗ មានសិទ្ធិទទួលបានភាគលាភដែលត្រូវបានប្រកាសដោយ PPSP លុះត្រាតែមានចែងផ្សេងពីនេះក្នុងលក្ខន្តិកៈរបស់ PPSP ឬសេចក្តីសម្រេចពិសេសរបស់ភាគហ៊ុនិក ។ ភាគលាភដែលឃើញថា ត្រឹមត្រូវ និងត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាល នឹងត្រូវបែងចែកទៅឲ្យភាគហ៊ុនិកទាំងស្រុង ឬដោយផ្នែក ក្រោមទម្រង់ជាសាច់ប្រាក់ ឬមិនមែនជាសាច់ប្រាក់ (ប្រការ៤៩ នៃលក្ខន្តិកៈរបស់ PPSP)។

- **សិទ្ធិទិញមុនគេ៖** ភាគហ៊ុនិករបស់ PPSP មានសិទ្ធិទិញមុនគេនូវមូលបត្រកម្មសិទ្ធិសាធារណៈបន្ថែមទៀតដែលត្រូវបានបោះផ្សាយដោយ PPSP តាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់ទៅតាមចំណាត់ថ្នាក់នៃភាគហ៊ុននោះ ក្នុងតម្លៃ និងលក្ខខណ្ឌដែលមូលបត្រកម្មសិទ្ធិសាធារណៈទាំងនោះ ត្រូវបានស្នើលក់ទៅឲ្យតតិយជន (ប្រការ១០ នៃលក្ខន្តិកៈរបស់ PPSP)។

- **មហាសន្និបាតនៃភាគហ៊ុនិក៖** ភាគហ៊ុនិកដែលមានឈ្មោះនៅកាលបរិច្ឆេទកំណត់ត្រាដែលកំណត់ដោយក្រុមប្រឹក្សាភិបាល នឹងត្រូវមានសិទ្ធិចូលរួមមហាសន្និបាតនៃភាគហ៊ុនិក និងទទួលបានការជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិក យ៉ាងហោចណាស់ម្ភៃ (២០) ថ្ងៃមុន និងយ៉ាងច្រើនហាសិប (៥០) ថ្ងៃមុនកាលបរិច្ឆេទនៃកិច្ចប្រជុំ (ប្រការ ៣៧ នៃលក្ខន្តិកៈរបស់ PPSP)។ ការជូនដំណឹងអំពីកិច្ចប្រជុំនឹងបញ្ជាក់អំពីកាលបរិច្ឆេទ ម៉ោង ទីតាំង និងរបៀបវារៈនៃកិច្ចប្រជុំនោះ។

- **សិទ្ធិបោះឆ្នោត៖** លើកលែងតែមានការចែងផ្សេងក្នុងលក្ខន្តិកៈ អ្នកកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ត្រូវមានសិទ្ធិបោះឆ្នោតដែលភាគហ៊ុននីមួយៗមានសិទ្ធិទទួលបានមួយ (០១) សម្លេង (ប្រការ៧ នៃលក្ខន្តិកៈរបស់ PPSP) និងមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក របស់ក្រុមហ៊ុនយើង (ប្រការ១៨.១ នៃលក្ខន្តិកៈរបស់ PPSP)។

- **សិទ្ធិទាមទារឲ្យមានការវាយតម្លៃ៖** អ្នកកាន់កាប់ភាគហ៊ុន ដែលមានសិទ្ធិបោះឆ្នោតក្នុង PPSP មានសិទ្ធិស្នើសុំឲ្យមានការវាយតម្លៃភាគហ៊ុនរបស់ខ្លួនក្នុងក្រុមហ៊ុន ក្នុងករណីមានការបញ្ចូលគ្នា នូវក្រុមហ៊ុនយើងជាមួយក្រុមហ៊ុនផ្សេង (ដូចមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម)។

- **បញ្ជីភាគហ៊ុនិក និងកាលបរិច្ឆេទកំណត់ត្រា៖** PPSP នឹងរក្សាបញ្ជិកាជាលាយលក្ខណ៍អក្សរពី ភាគហ៊ុនិកជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។ ភ្នាក់ងារបញ្ជិកាមូលបត្រ នឹងកត់ត្រាភាពជាក់លាក់របស់ភាគហ៊ុនិក និងការផ្ទេរ បន្ទុក និងការកែប្រែភាគហ៊ុននីមួយៗ។ មានតែបុគ្គល ឬអង្គភាព ដែលត្រូវបានចុះបញ្ជីជាភាគហ៊ុនិកក្នុងបញ្ជីរបស់ភ្នាក់ងារបញ្ជិកាមូលបត្រតែប៉ុណ្ណោះ នឹងត្រូវចាត់ទុកជាភាគហ៊ុនិក របស់ក្រុមហ៊ុនយើង (ប្រការ ១៣ នៃលក្ខន្តិកៈរបស់ PPSP)។

- **សិទ្ធិទទួលបានព័ត៌មាន៖** អ្នកកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតរបស់ PPSP មានសិទ្ធិទទួលបានព័ត៌មានគ្រប់ប្រភេទដែលរួមមាន ព័ត៌មានទាក់ទងនឹងធុរកិច្ចរបស់ក្រុមហ៊ុនយើង និងអាចចូលមើលនូវសៀវភៅ និងកំណត់ត្រារបស់ក្រុមហ៊ុនយើងបាន (ប្រការ១៨.១ នៃលក្ខន្តិកៈរបស់ PPSP)។

- **ការផ្ទេរភាគហ៊ុន៖** រាល់ភាគហ៊ុនរបស់ PPSP ដែលត្រូវបានចុះបញ្ជីលក់ អាចត្រូវបានជួញដូរដោយសេរីនៅលើ ផ.ម.ក. ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិនៅគ្រប់ពេលក្នុងចំណោមភាគហ៊ុនិក ឬតតិយជន។ ដោយឡែកការផ្ទេរភាគហ៊ុនដែលមិនត្រូវបានចុះបញ្ជីលក់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយអ្នកផ្ទេរ និងអ្នកទទួល ហើយត្រូវចុះបញ្ជីជាមួយនឹង ក.ព.ណ និង គ.ម.ក. (ប្រការ១៤ នៃលក្ខន្តិកៈរបស់ PPSP)។
- **ការទិញយកភាគហ៊ុនរបស់ខ្លួនដោយក្រុមហ៊ុនបោះផ្សាយ៖** ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម របស់ព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឲ្យក្រុមហ៊ុនទិញ ឬលោះមកវិញនូវភាគហ៊ុនរបស់ខ្លួន ប្រសិនជាត្រូវបានអនុញ្ញាតដោយលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ។
- **សិទ្ធិជម្រះបញ្ជី៖** លុះត្រាតែមានការចែងផ្សេងពីនេះក្នុងសេចក្តីសម្រេចរបស់ភាគហ៊ុនិក ករណីដែលមានការរំលាយ PPSP អ្នកកាន់កាប់ភាគហ៊ុននីមួយៗនឹងមានសិទ្ធិទទួលបានទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុន បន្ទាប់ពីមានការរំលាយក្រុមហ៊ុន ទៅតាមចំណែកភាគហ៊ុនរបស់ពួកគេ (ប្រការ៧ នៃលក្ខន្តិកៈរបស់ PPSP)។

## ខ-ការបែងចែកប្រភេទភាគហ៊ុនិក

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦)

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ០៥ % | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ២១១ | ៥.៥២៩.៦៩៣ | ៩.៥៥% |
| | | នីតិបុគ្គល | - | - | - |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៦៥ | ១.៦១២.៨៥១ | ២.៧៩% |
| | | នីតិបុគ្គល | ២ | ១.៤៩៨.១៩៧ | ២.៥៩% |
| ចាប់ពី ០៥%ដល់ តិចជាង ៣០ % | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | ២ | ១៦.៨២៤.២៥៩ | ២៩.០៧% |
| ចាប់ពី ៣០ % ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១ | ៣២.៤១០.០០០ | ៥៦.០០% |
| | | នីតិបុគ្គល | - | - | - |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |

ភាគហ៊ុនចំនួន ៩៣៩.៦៩៣ ភាគហ៊ុន ឬ ៦៥.៥៥% នៃចំនួនភាគហ៊ុនទាំងអស់ បានកាន់កាប់ដោយសញ្ជាតិខ្មែរ បើគិតត្រឹមថ្ងៃទី ៣១ ខែធ្នូនេះ។

## គ-អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៥ | ៣២.៨៣១.៧០៦ | ៥៦.៧៣% |
| បុគ្គលិកជាន់ខ្ពស់ | ១ | ៤៣.០០០ | ០.០៧% |
| និយោជិត | - | - | - |
| សរុប | ៦ | ៣២.៨៧៤.៧០៦ | ៥៦.៨០% |

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

**ឃ-** ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ដោយបញ្ជាក់អំពីអត្តសញ្ញាណ។

នៅក្នុងឆ្នាំ២០១៦ ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួន ច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ទេ។

**ង-** អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន និងអត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាពចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព។

នៅក្នុង ឆ្នាំ២០១៦ ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅស្ថិតក្នុងស្ថានភាពអសាធនភាពនោះទេ ។ បន្ទាប់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ ជាសាធារណៈលើកដំបូង Finansia Syrus Securities Public Company Limited បានកាន់កាប់ភាគហ៊ុនចំនួន ៦.៦៣៨.៧៥៩ ភាគហ៊ុន (១១.៤៧% នៃភាគហ៊ុនសរុប)។

**ច-** កិច្ចប្រជុំមហាសន្និបាតវិសាមញ្ញត្រូវបានរៀបចំឡើងនៅថ្ងៃទី ៦ ខែកញ្ញាឆ្នាំ ២០១៦ ដោយមានរបៀបវារៈដូចដែលមានចែងដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| ១ | ០៦/កញ្ញា/២០១៦ | កិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ | ដើម្បីអនុម័តអភិបាលមិនប្រតិបត្តិថ្មី | លោក Tanate Piriyothinkul ត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិថ្មី |
| ២ | ០៦/កញ្ញា/២០១៦ | កិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ | ដើម្បីទទួលនិងអនុម័តរបាយការណ៍ហិរញ្ញវត្ថុ ដំណាច់ឆ្នាំនៅថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០១៥ | កិច្ចប្រជុំនៃការព្រមព្រៀងគ្នាក្នុងការអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅទី ៣១ ខែធ្នូឆ្នាំ ២០១៥ |

## ឆ-គោលនយោបាយភាគលាភ

### ឆ-១-គោលនយោបាយភាគលាភរបស់បុគ្គលបោះផ្សាយ

ដោយអនុលោមតាម សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលរបស់យើងចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥ សម្រាប់ឆ្នាំសារពើពន្ធ ២០១៥ និងបន្តបន្ទាប់ វាជាគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល របស់យើង ក្នុងការប្រកាសភាគលាភ ដើម្បីអនុញ្ញាតឲ្យភាគហ៊ុនិកទទួលបានប្រាក់ចំណេញរបស់ក្រុមហ៊ុនយើង ក៏ដូចជាបម្រុងទុកឲ្យបានគ្រប់គ្រាន់សម្រាប់ការលូតលាស់នាពេលអនាគតរបស់ក្រុមហ៊ុនយើង។

ក្រុមប្រឹក្សាភិបាលរបស់យើងបានអនុម័តគោលនយោបាយបម្រុងទុកប្រាក់ចំណេញ (plough back policy) ដើម្បីធានាអំពីការរីកចម្រើនរបស់ក្រុមហ៊ុនយើង ដូច្នេះសមត្ថភាពរបស់យើងក្នុងការបង់ភាគលាភ ឬធ្វើការចែកចាយក្រោមទម្រង់ផ្សេងទៀតដល់ភាគហ៊ុនិករបស់យើងអាស្រ័យលើកត្តាមួយចំនួន ដែលរួមមានជាអាទិ៍ដូចជា៖

i. ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុនយើង ដែលរួមមានលំហូរសាច់ប្រាក់ និងស្ថានភាពសន្ទនីយភាព អត្រានៃភាពខុសគ្នារវាងដើមទុន និងឥណទាន (gearing) និងអតិរេក (surplus) របស់សម្ព័ន្ធ ក្រុមហ៊ុនយើង

ii. ប្រតិបត្តិការហិរញ្ញវត្ថុដែលសម្ព័ន្ធក្រុមហ៊ុនយើងរំពឹងទុក រួមមានលទ្ធភាពចំណេញ

iii. ទុនបង្វិលដែលយើងមាន រួមមានមូលធនបែងចែកសម្រាប់ចំណាយមូលធន និងគម្រោងវិនិយោគពេលអនាគត និង

iv. កាតព្វកិច្ចបំណុលដែលមានស្រាប់ និងពេលអនាគតរបស់សម្ព័ន្ធក្រុមហ៊ុនយើង។

ក្រុមប្រឹក្សាភិបាលរបស់យើង បានស្នើបង់ភាគលាភ ដែលបានមកពីសាច់ប្រាក់ទទួលបានពីប្រតិបត្តិការសម្ព័ន្ធក្រុមហ៊ុនរបស់យើង បន្ទាប់ពីការផាត់ទាត់ចំណាយមូលធនដែលចាំបាច់ ទុនបង្វិលចាំបាច់ និងចំណុចផ្សេងទៀតដូចមានកំណត់ក្នុងចំណុច (i) ដល់ (iv) ខាងលើ។ ផ្អែកលើគោលនយោបាយភាគលាភនេះ ក្រុមហ៊ុនរបស់យើងបានកំណត់គោលដៅនៃអនុបាតនៃការបង់ភាគលាភមិនឲ្យតិចជាងម្ភៃភាគរយ (២០%) នៃប្រាក់ចំណេញរបស់ក្រុមហ៊ុន ដល់អ្នកកាន់កាប់ មូលបត្ររបស់ក្រុមហ៊ុនយើង អនុលោមតាម CIFRS។

វិនិយោគិនគួរកត់សម្គាល់ថា គោលនយោបាយបែងចែកភាគលាភគ្រាន់តែបង្ហាញអំពីគោលបំណងបច្ចុប្បន្នរបស់ក្រុមហ៊ុនយើងប៉ុណ្ណោះ ហើយវាមិនត្រូវបានចាត់ទុកថាជាសេចក្ដីថ្លែងចងកាតព្វកិច្ចតាមផ្លូវច្បាប់ណាមួយឡើយពាក់ព័ន្ធនឹងការបែងចែកភាគលាភ របស់ក្រុមហ៊ុនយើងនាពេលអនាគតឡើយ។ គោលនយោបាយនេះអាចត្រូវបានកែប្រែ (ដែលរួមមានការមិនប្រកាសផ្សេងទៀតដែលពាក់ព័ន្ធ) ដោយឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាភិបាល។ វិនិយោគិន មិនត្រូវចាត់ទុកសេចក្ដីថ្លែងណាមួយខាងលើថាជាលទ្ធភាពចំណេញនាពេលអនាគត ឬសមត្ថភាពរបស់យើងក្នុងការបែងចែកភាគលាភនាពេលអនាគតឡើយ។

### ឆ-២- ព័ត៌មានប្រវត្តិសាស្រ្តអំពីការបែងចែកភាគលាភក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ (ប្រសិនមាន)

ក្រុមហ៊ុន មិនមានការទូទាត់ភាគលាភ ក្នុងកំឡុងពេលបីឆ្នាំចុងក្រោយនេះទេ។

| ពិពណ៌នាលម្អិតអំពីការបែងចែងភាគលាភ | ឆ្នាំ២០១៦ | | ឆ្នាំ២០១៥ | | ឆ្នាំ២០១៤ | |
|---|---|---|---|---|---|---|
| | សម្ព័ន្ធក្រុមហ៊ុន | ក្រុមហ៊ុន | សម្ព័ន្ធក្រុមហ៊ុន | ក្រុមហ៊ុន | សម្ព័ន្ធក្រុមហ៊ុន | ក្រុមហ៊ុន |
| ចំណេញសុទ្ធ (ពាន់រៀល) | ៥.៨៣៦.១៧៨ | ៦.២៣៨.៥០១ | ១៦.៦៨៧.៤៦៨ | ១៧.៥០៩.៤១៦ | ២៣.៩៤៩.៨៨០ | ២៣.៩៧៨.៨៣៦ |
| ភាគលាភជាសាច់ប្រាក់សរុប | - | - | - | - | - | - |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | - | - | - | - | - | - |
| ភាគលាភផ្សេងទៀត | - | - | - | - | - | - |
| អនុបាតចំណាយភាគលាភ (%) | - | - | - | - | - | - |
| ទិន្នផលភាគលាភ (%) | - | - | - | - | - | - |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | - | - | - | - | - | - |

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ៣.២. អង្គការលេខ

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦) អង្គការលេខរបស់ក្រុមហ៊ុន អាចត្រូវបានបង្ហាញដូចដែលបានកំណត់ខាងក្រោម៖



## ៣.៣. ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

### ក. សមាសភាពក្រុមប្រឹក្សាភិបាល

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ អភិបាលរបស់យើងមានសមាសភាពដូចខាងក្រោម៖

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | លោកជំទាវឧកញ៉ា លឹម ឈីវហូរ | ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ២ | លោក HIROSHI UEMATSU | អភិបាលប្រតិបត្តិ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៣ | លោក តាន់ កាក់យុន | អភិបាលមិនប្រតិបត្តិ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៤ | លោកស្រី តាន់ សឹយមួយ | អភិបាលមិនប្រតិបត្តិ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៥ | លោក HIROSHI OTSUBO | អភិបាលមិនប្រតិបត្តិ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៦ | លោក KENJI TOYOTA | អភិបាលមិនប្រតិបត្តិ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៧ | លោក ហែម សុវត្ថិ | អភិបាល ឯករាជ្យ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៨ | លោក KANG WEI GEIH | អភិបាល ឯករាជ្យ | ២៩ ឧសភា ២០១៥ | ២៨ ឧសភា ២០១៧ |
| ៩ | លោក TANATE PIRIYOTHINKUL | អភិបាលមិនប្រតិបត្តិ | ០៦ កញ្ញា ២០១៦ | ០៥ កញ្ញា ២០១៨ |

**សម្គាល់ ៖**

*អភិបាលម្នាក់ៗ នឹងត្រូវបានជ្រើសតាំងសម្រាប់អាណត្តិពីរ(២)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទក្លាយជាអភិបាល ឬកាលបរិច្ឆេទបន្តអាណត្តិ ហើយនឹងអាចជ្រើសតាំងសារជាថ្មីដោយភាគហ៊ុនិក។ ចំពោះអភិបាលរៀបរាប់ខាងលើដែលផុតអាណត្តិនៅអាណត្តិចុងក្រោយរបស់គាត់ត្រូវបានជ្រើសតាំងឡើងវិញដោយភាគហ៊ុនិក។

ប្រវត្តិរូបនៃអភិបាលនីមួយៗមានរៀបរាប់ដូចខាងក្រោមនេះ៖

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## លោកជំទាវឧកញ៉ា លីម ឈីវហួរ - ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ

លោកជំទាវឧកញ៉ា លីម ឈីវហួរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៦១ នៅប្រទេសកម្ពុជា គឺជាប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុនយើង។ លោកជំទាវឧកញ៉ា លីម ឈីវហួរ ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦។ នាពេលបច្ចុប្បន្ននេះ លោកជំទាវឧកញ៉ា លីម ឈីវហួរ ក៏ជាអភិបាលនៅក្នុង ក្រុមហ៊ុនសហ័ស ភីភីអេសអ៊ីហ្សិត និងជាអភិបាលម្នាក់ក្នុងក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ដែលក្រុមហ៊ុនទាំងពីរនេះ គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមានសិទ្ធិកាន់កាប់ ទាំងស្រុងរបស់ក្រុមហ៊ុន PPSP។

លោកជំទាវឧកញ៉ា លីម ឈីវហួរ មានបទពិសោធន៍ច្រើនជាងសាមសិប (៣០) ឆ្នាំក្នុងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ វិនិយោគលើការអភិវឌ្ឍអចលនទ្រព្យ ជួញដូរលើទំនិញឧបភោគលំហែកំសាន្ត និងបដិសណ្ឋារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លោកជំទាវឧកញ៉ា លីម ឈីវហួរ បានចាប់ផ្តើមវិជ្ជាជីវៈតាមរយៈការធ្វើការជួញដូរទំនិញឧបភោគ និង ភេសជ្ជៈ នៅក្នុងទីផ្សារព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម។ បន្ទាប់ពីនោះមកក្នុងទសវត្សន៍ឆ្នាំ១៩៨០ លោកជំទាវឧកញ៉ា លីម ឈីវហួរ និងស្វាមីបានចាប់ផ្តើមប្រកបអាជីវកម្មជួញដូរ និងដឹកជញ្ជូន ដែលក្នុងនោះរួមមាន ការជួញដូរលើឧបករណ៍អេឡិចត្រូនិច និងភេសជ្ជៈនៅក្នុងទីផ្សារក្នុងស្រុក។ ក្រោយមកលោកជំទាវឧកញ៉ា លីម ឈីវហួរ បានបង្កើតក្រុមហ៊ុន Attwood Import Export Co.. Ltd. ក្នុងឆ្នាំ១៩៩៤ ដែលបានទទួលនូវសិទ្ធិផ្តាច់មុខ ក្នុងការនាំចូលភេសជ្ជៈដែលមានម៉ាកល្បីៗមួយចំនួន ដែលក្នុងនោះរួមមានស្រា Hennessy និង Johnnie Walker។

ក្នុងឆ្នាំ២០០៨ លោកជំទាវឧកញ៉ា លីម ឈីវហួរ បានបង្កើតក្រុមហ៊ុន L C H Investment Group Co.. Ltd. ដែលមានធុរកិច្ចទាក់ទងនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍអចលនទ្រព្យ ការជួញដូរលើទំនិញឧបភោគ ការលំហែកំសាន្ត និងបដិសណ្ឋារកិច្ច។

បទពិសោធន៍ដ៏ទូលំទូលាយរបស់លោកជំទាវឧកញ៉ា លីម ឈីវហួរ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍអចលនទ្រព្យ និងការគ្រប់គ្រងឧស្សាហកម្ម គឺជាការរួមចំណែកក្នុងភាពជោគជ័យរបស់ក្រុមហ៊ុន PPSP និងការរីកចម្រើននៃវិស័យឧស្សាហកម្មអចលនទ្រព្យ។

សព្វថ្ងៃនេះ លោកជំទាវឧកញ៉ា លីម ឈីវហួរ បានកំពុងបម្រើការក្នុងមុខងារផ្សេងៗក្នុងគ្រឹះស្ថានសេវាសាធារណៈ ដែលក្នុងនោះរួមមាន ជាប្រធាននៃសមាគមតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា អនុប្រធាននៃសភាពាណិជ្ជកម្មភ្នំពេញ អនុប្រធាននៃសភាពាណិជ្ជកម្មកម្ពុជា និងជាសមាជិកដែលមានឥទ្ធិពលនៃគណៈកម្មាធិការកណ្តាល ដែលជាសមាជិកនៃគាកបាទក្រហមកម្ពុជា ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកជំទាវឧកញ៉ា លីម ឈីវហួរ កាន់កាប់ភាគហ៊ុនភាគច្រើន និងកាន់កាប់ តំណែងជាភាគហ៊ុនិក និងអភិបាលក្នុងក្រុមហ៊ុន ដទៃទៀត ដែលក្នុងនោះរួមមានក្រុមហ៊ុន Attwood Investment Group Co.. Ltd. ក្រុមហ៊ុន Attwood Import Export Co.. Ltd. និងក្រុមហ៊ុន L C H Investment Group Co.. Ltd.។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកជំទាវឧកញ៉ា លីម ឈីវហួរ គឺជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគច្រើនរបស់ក្រុមហ៊ុន។ លោកជំទាវឧកញ៉ា លីម ឈីវហួរ គឺជាមាតារបស់លោក តាន់ កាក់ឃុន និងលោកស្រី តាន់ សឺយមួយ ដែលពួកគាត់ក៏ជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនផងដែរ។

## លោក Hiroshi Uematsu - អភិបាលប្រតិបត្តិ និងនាយកប្រតិបត្តិ

លោក Hiroshi Uematsu ជនជាតិជប៉ុន កើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៧ នៅប្រទេសជប៉ុន គឺជាអភិបាលប្រតិបត្តិ និងនាយកប្រតិបត្តិរបស់ក្រុមហ៊ុនយើង។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងជានាយកប្រតិបត្តិនាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។ លោក ក៏មានមុខតំណែងជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនយើងផងដែរ។ សព្វថ្ងៃនេះ លោកក៏ជាអភិបាលមួយរូបនៃក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមានសិទ្ធិកាន់កាប់ទាំងស្រុងរបស់ក្រុមហ៊ុន PPSP។ នាពេលបច្ចុប្បន្ននេះ លោកទទួលបន្ទុកមើលការខុសត្រូវលើសកម្មភាពអភិវឌ្ឍន៍ធុរកិច្ចរបស់ក្រុមហ៊ុនយើង។

លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រក្នុងជំនាញទំនាក់ទំនងសង្គមពី Rikkyo University ប្រទេសជប៉ុន ក្នុងឆ្នាំ១៩៩១។ លោកមានបទពិសោធន៍ជាងម្ភៃ (២០)ឆ្នាំ ក្នុងការគ្រប់គ្រងអាជីវកម្ម និងវិស័យពាក់ព័ន្ធនឹងឧស្សាហកម្មវិស្វកម្ម។ លោកចាប់ផ្តើមវិជ្ជាជីវៈរបស់លោក ជាអ្នកគ្រប់គ្រងរដ្ឋបាលជាន់ខ្ពស់ ឲ្យក្រុមហ៊ុន Shimizu Philippine Contractors Inc. ក្នុងឆ្នាំ១៩៩៤។ ក្រោយមកទៀត លោកធ្វើជាអ្នកគ្រប់គ្រងរបស់ការិយាល័យភូមិភាគកណ្តាល រៀបចំគម្រោង និងទីផ្សារនៃក្រុមហ៊ុន Oak Village Co.. Ltd. ក្នុងឆ្នាំ២០០០។

បន្ទាប់មក លោកបានមកធ្វើការជាមួយក្រុមហ៊ុន Zephyr ក្នុងឆ្នាំ២០០៧ ក្នុងនាមជាអ្នកតំណាងឲ្យក្រុមហ៊ុន Zephyr ក្នុងក្រុមហ៊ុនរបស់យើង ហើយដែលពេលនោះដែរ លោកត្រូវបានតែងតាំងជាប្រធានផ្នែករដ្ឋបាល និងគណនេយ្យឲ្យក្រុមហ៊ុនយើង។ លោកត្រូវបានដំឡើងតំណែងទៅជានាយកគ្រប់គ្រងរបស់ក្រុមហ៊ុនយើងក្នុងឆ្នាំ២០០៨។ នៅខែមិថុនា ឆ្នាំ២០១៣ លោកបានលាឈប់ពីមុខតំណែងរបស់លោកនៅក្នុងក្រុមហ៊ុន Zephyr ហើយបានមកកាន់តំណែងបច្ចុប្បន្នរបស់លោកនៅក្នុងក្រុមហ៊ុនរបស់យើង។ ក្នុងឆ្នាំ២០១៤ លោកត្រូវបានតែងតាំងជាអភិបាលមួយរូបក្នុងក្រុមហ៊ុន Zephyr (Cambodia) Co.. Ltd. ដែលលោកនៅបន្តកាន់តំណែងនេះរហូតដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។

## លោក តាន់ កាក់ឃុន - អភិបាលមិនប្រតិបត្តិ

លោក តាន់ កាក់ឃុន សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៨២ នៅប្រទេសកម្ពុជា គឺជាអភិបាល មិនប្រតិបត្តិរបស់ក្រុមហ៊ុនយើង។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។ លោកក៏កាន់មុខតំណែងជាសមាជិក នៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យរបស់ ក្រុមហ៊ុនផងដែរ។ នាពេលបច្ចុប្បន្ននេះ លោកជាអភិបាលនៅក្នុងក្រុមហ៊ុនប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមានសិទ្ធិកាន់កាប់ទាំងស្រុងរបស់ក្រុមហ៊ុន PPSP។ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រក្នុងជំនាញការគ្រប់គ្រងអាជីវកម្មពី California State University of Fullerton សហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៨។

លោកមានបទពិសោធន៍ច្រើនជាងបួន (០៤) ឆ្នាំ ក្នុងការគ្រប់គ្រង និងមានបទពិសោធន៍អាជីវកម្មក្នុងវិស័យអភិវឌ្ឍន៍អចលនទ្រព្យ ការតុបតែងខាងក្នុង និងទំនាក់ទំនងជំនួញផ្តាច់មុខនៃទូរស័ព្ទចល័ត។ ក្រោយពេល បញ្ចប់ការសិក្សាថ្នាក់អាជីវកម្ម លោកបានចូលធ្វើការក្នុងក្រុមហ៊ុន LCH Investment Group Co.. Ltd. ក្នុងឆ្នាំ២០១០ ជានាយកប្រតិបត្តិ ដែលលោកនៅបន្តកាន់តំណែងនេះរហូតមកដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។

គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ លោកមានកាន់តំណែងជាអភិបាលក្នុងក្រុមហ៊ុនឯកជនមួយចំនួនដែលក្នុងនោះរួមមាន ក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត ក្រុមហ៊ុន L C H Investment Group Co.. Ltd. ក្រុមហ៊ុន Phnom Penh Precast Co.. Ltd. និងក្រុមហ៊ុន L C H Mobile Co.. Ltd.។ លោកក៏ជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុន L C H Investment Group Co.. Ltd. ក្រុមហ៊ុន L C H Mobile Co.. Ltd. ក្រុមហ៊ុន Phnom Penh Precast Co.. Ltd. និងក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត។

លោកគឺជាកូនប្រុសរបស់ លោកជំទាវឧកញ៉ា លីម ឈីវហួរ ដែលជាប្រធានក្រុមប្រឹក្សាភិបាល និងជាបងប្រុសរបស់លោកស្រី តាន់ សឺយមួយ ដែលជាអភិបាលមិនប្រតិបត្តិមួយរូបរបស់ក្រុមហ៊ុនយើង។

## លោកស្រី តាន់ សីយមួយ - អភិបាលមិនប្រតិបត្តិ

លោកស្រី តាន់ សីយមួយ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨៣ នៅប្រទេសកម្ពុជា គឺជាអភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុនយើង។ លោកស្រីត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ លោកស្រី ក៏មានកាន់មុខតំណែងជា សមាជិកនៃគណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនផងដែរ។ សព្វថ្ងៃនេះ លោកស្រីក៏ជាអភិបាលមួយរូបនៃក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមានសិទ្ធិកាន់កាប់ទាំងស្រុងរបស់ក្រុមហ៊ុន PPSP។ លោកស្រី បានទទួលសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងអាជីវកម្មក្នុងជំនាញគ្រប់គ្រងពី Paris School of Business ប្រទេសបារាំង ក្នុងឆ្នាំ២០០៨។

លោកស្រីមានបទពិសោធន៍ច្រើនជាងដប់ពីរ (១២) ឆ្នាំក្នុងការគ្រប់គ្រង និងបទពិសោធន៍អាជីវកម្មក្នុងវិស័យម្ហូបអាហារ និងភេសជ្ជៈ និងអចលនទ្រព្យ។ លោកស្រី ចាប់ផ្តើមវិជ្ជាជីវៈរបស់លោកស្រីក្នុងឆ្នាំ២០០២ ពេលដែលលោកស្រីចូលកាន់មុខងារជាសមាជិកគ្រប់គ្រងជាន់ខ្ពស់នៅរោងផលិតកម្មអាហារ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ បន្ទាប់ពីនោះមក លោកស្រីបានចូលកាន់តំណែងក្នុងក្រុមហ៊ុនយើងក្នុងឆ្នាំ២០១៣។

គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ លោកស្រីកាន់តំណែង ជាអភិបាលក្នុងក្រុមហ៊ុនឯកជនមួយចំនួន ដែលក្នុងនោះរួមមានក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេតក្រុមហ៊ុនខូលបេន ភីភីអេសអ៊ីហ្សេត ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិតនិងក្រុមហ៊ុន L.C.H Development Co.. Ltd.។ លោកស្រីក៏ជាភាគហ៊ុនិក តែមួយគត់ក្នុងក្រុមហ៊ុន L.C.H Development Co.. Ltd.។ លោកស្រី គឺជាកូនស្រីរបស់លោកជំទាវឧកញ៉ាលីម ឈីវហូរ ដែលជាប្រធានក្រុមប្រឹក្សាភិបាល និងជាប្អូនស្រីរបស់លោក តាន់ កាក់ឃុន ដែលជាអភិបាលមិនប្រតិបត្តិមួយរូបរបស់ក្រុមហ៊ុនយើង។

## លោក Hiroshi Otsubo - អភិបាលមិនប្រតិបត្តិ

លោក Hiroshi Otsubo ជនជាតិជប៉ុន កើតនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៨៤ នៅប្រទេសជប៉ុន គឺជាអភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុនយើង។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤។ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រសេដ្ឋកិច្ចពី Nagasaki University ប្រទេសជប៉ុន ក្នុងឆ្នាំ២០០៨។

លោកមានបទពិសោធន៍ជាងប្រាំមួយ (០៦) ឆ្នាំក្នុងជំនាញការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម។ លោកចាប់ផ្តើមវិជ្ជាជីវៈរបស់លោកក្នុងឆ្នាំ២០០៨ ក្នុងមុខតំណែងជាលេខាធិការរបស់ថ្នាក់គ្រប់គ្រង របស់ក្រុមហ៊ុន TK Clean Environment Co.. Ltd.។ បន្ទាប់មក លោកបានកាន់តំណែងជាអ្នកគ្រប់គ្រងប្រតិបត្តិការរបស់ទីស្នាក់ការកណ្តាលនៃក្រុមហ៊ុន Clarus Environment Co.. Ltd. ក្នុងឆ្នាំ២០១០។ ក្រោយពីនោះមក លោកបានចូលកាន់តំណែងជាប្រធានការិយាល័យឲ្យក្រុមហ៊ុន Zephyr ក្នុងឆ្នាំ២០១១ ហើយត្រូវបានដំឡើងតំណែងជាអគ្គនាយកនៃក្រុមហ៊ុន Zephyr ក្នុងឆ្នាំ២០១៤ ដែល លោកនៅបន្តកាន់តំណែងនេះរហូតមកដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។ គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ លោកក៏កាន់តំណែងជាអភិបាលនៃក្រុមហ៊ុន Tomonius Co.. Ltd. ក្នុងប្រទេសជប៉ុនចាប់តាំងពីឆ្នាំ២០១៤ ហើយលោកក៏ជាភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននៅក្រុមហ៊ុន OHO Management Co.. Ltd. ក្នុងប្រទេសជប៉ុន ដែលជាក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុន Zephyr។

លោក មិនមានកាន់តំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយផ្សេងពីក្រុមហ៊ុន PPSP ឬកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុនណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## លោក Kenji Toyota - អភិបាលមិនប្រតិបត្តិ

លោក Kenji Toyota ជនជាតិជប៉ុន កើតនៅថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧១ នៅប្រទេសជប៉ុន គឺជាអភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុនយើង។ លោកត្រូវបានតែងតាំងជា សមាជិកក្រុមប្រឹក្សាភិបាលនាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤។ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រពី Tokyo University ប្រទេសជប៉ុន ក្នុងឆ្នាំ១៩៩៦។ បន្ទាប់មកក្នុងឆ្នាំ២០០១ លោកបានចុះបញ្ជីជាមេធាវីជាមួយគណៈមេធាវីជប៉ុន។

លោកមានបទពិសោធន៍ជាងដប់បី(១៣) ឆ្នាំ ក្នុងជំនាញទំនាក់ទំនងផ្នែកច្បាប់។ លោកចាប់ផ្តើមវិជ្ជាជីវៈរបស់លោកក្នុងមុខតំណែងជាសហការីឲ្យការិយាល័យមេធាវី Mitsui. Yasuda. Wani & Maeda ក្នុងឆ្នាំ២០០១។ បន្ទាប់មក លោកបានចូលកាន់តំណែងជាសហការីដដែលឲ្យការិយាល័យមេធាវី Orrick. Herrington & Sutcliffe LLP – Orrick Tokyo ក្នុងឆ្នាំ២០០៤។ ក្នុងឆ្នាំ២០០៦ លោកបានក្លាយជាស្ថាបនិក និងតំណាងអ្នកចូលហ៊ុនរបស់ការិយាល័យមេធាវី Tokyo Sakurabashi ដែលលោកនៅតែកាន់តំណែងតរហូតមកដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។ សព្វថ្ងៃនេះ លោកក៏ជាសវនករសាជីវកម្មនៃក្រុមហ៊ុន Yamada Corporation និងជាទីប្រឹក្សាច្បាប់នៃ ក្រុមហ៊ុន Zephyr តាំងពីឆ្នាំ២០១២មកម្ល៉េះ។ លើសពីនេះ លោកក៏ត្រូវបានតែងតាំងជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន TSK Company នៅប្រទេសជប៉ុនតាំងពីឆ្នាំ២០១១ និងជាអ្នកតំណាងអភិបាលរបស់ក្រុមហ៊ុន OHO Management Co.. Ltd. តាំងពីឆ្នាំ២០១៣។

គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ លោកគឺជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Zephyr (Cambodia) Co.. Ltd. នៅព្រះរាជាណាចក្រកម្ពុជា ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុន Zephyr។ លោកមិនមានកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## លោក ហែម សុវត្ថិ - អភិបាលឯករាជ្យ

លោក ហែម សុវត្ថិ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៨២ នៅប្រទេសកម្ពុជា គឺជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុនយើង។ លោកត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សានាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤។ លោកក៏មានកាន់មុខតំណែងជាប្រធាននៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនយើងផងដែរ។

លោកបានទទួលសញ្ញាបត្រ បរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្មក្នុងជំនាញពាណិជ្ជកម្មពី University of Delhi ប្រទេសឥណ្ឌា ក្នុងឆ្នាំ២០០១ និងសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងអាជីវកម្មក្នុងជំនាញគ្រប់គ្រង ពី University of Utara Malaysia ប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០០៣។

លោកមានបទពិសោធន៍ជាងដប់មួយ(១១) ឆ្នាំ ក្នុងជំនាញគណនេយ្យ និងហិរញ្ញវត្ថុ។ លោកចាប់ផ្តើមវិជ្ជាជីវៈរបស់លោក ជាអ្នកផ្តល់យោបល់ផ្នែកពន្ធដារឲ្យក្រុមហ៊ុន Pricewaterhouse Coopers (Cambodia) Co.. Ltd. ក្នុងឆ្នាំ២០០៣។ ក្រោយមក លោកបានចូលកាន់តំណែងជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន CamGSM Company Limited ក្នុងឆ្នាំ២០០៤។ បន្ទាប់មកទៀតលោកបានចូលកាន់តំណែងជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុនៃក្រុមហ៊ុន G4S Security Services (Cambodia) Ltd. ក្នុងឆ្នាំ២០០៨ មុនពេលលោកចូលទៅកាន់តំណែងជានាយកផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន EZECOM Ltd. ក្នុងឆ្នាំ២០១០ ដែលលោកនៅបន្តកាន់តំណែងរហូតមកដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។

លោកមិនមានកាន់តំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយផ្សេងពីក្រុមហ៊ុន PPSP ឬកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុនណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## លោក Kang Wei Geih - អភិបាលឯករាជ្យ

លោក Kang Wei Geih ជនជាតិម៉ាឡេស៊ី កើតនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នៅប្រទេសម៉ាឡេស៊ី គឺជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុនយើង។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល នាថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥។ លោកក៏បានកាន់មុខតំណែងជា ប្រធាននៃគណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនយើងផងដែរ។

លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពី Asian Institute of Management ក្នុងឆ្នាំ១៩៨៥។ លោកគឺជាសមាជិកនៃ Association of Chartered Accountants ចាប់តាំងពីឆ្នាំ១៩៨២ និងជាសមាជិកនៃ Malaysian Institute of Accountants («MIA») តាំងពីឆ្នាំ១៩៨៣ និងជាប្រធាននៃគណៈកម្មាធិការសវនកម្មរបស់ MIA តាំងពីឆ្នាំ២០០១ ហើយលោកក៏ជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា តាំងពីឆ្នាំ២០១០។

លោកមានបទពិសោធន៍ជាងសាមសិបប្រាំ(៣៥) ឆ្នាំក្នុងជំនាញគណនេយ្យ សវនកម្ម និងពន្ធដារ។ លោកបានចាប់ផ្តើមវិជ្ជាជីវៈរបស់លោក ក្នុងមុខតំណែងជាសហការីសវនកម្មនៅក្នុង ការិយាល័យសវនកម្ម Hanafiah Raslan & Mohamad ក្នុងឆ្នាំ១៩៧៩។ បន្ទាប់មកលោកបានចូលកាន់តំណែងជា សវនករផ្ទៃក្នុងរបស់ធនាគារ Southern Bank Berhad ក្នុងឆ្នាំ១៩៨៣។ ក្រោយមកលោកបានចូលទៅកាន់តំណែងជា អ្នកគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងក្រុមហ៊ុន Tamm Holdings (M) Sdn Bhd ក្នុងឆ្នាំ១៩៨៤។ ក្រោយមកទៀត លោកបានបង្កើត និងកាន់តំណែងជានាយករបស់ការិយាល័យ Billy Kang & Co. ដែលលោកនៅបន្តកាន់តំណែងរហូតមកដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។ ក្នុងឆ្នាំ២០១០ លោកបានបង្កើត និងកាន់តំណែងជានាយករបស់ក្រុមហ៊ុន BG Associates Ltd. ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលលោកនៅបន្តកាន់តំណែងតរហូតមកដល់កាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ។

លោកមិនមានកាន់តំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយផ្សេងពីក្រុមហ៊ុន PPSP ហើយលោកគឺជានាយក និងជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនរបស់ការិយាល័យ Billy Kang & Co. និង BG Associates Ltd.។

## លោក Tanate Piriyothinkul - អភិបាលមិនប្រតិបត្តិ

លោក Tanate Piriyothinkul ជនជាតិថៃ កើតនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៧៥ នៅប្រទេសថៃ គឺជាអភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុន។ លោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦។

លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រ (MSc) ដឹកជញ្ជូន សម្ភារៈ និងគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ ពីសាលាគ្រប់គ្រង Kellogg នៃសាកលវិទ្យាល័យ Northwestern ក្នុងឆ្នាំ២០០២. ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម. សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ. ពីសាលា Wharton នៃសាកលវិទ្យាល័យ Pennsylvania ក្នុងឆ្នាំ២០០៤ និងថ្នាក់អនុបណ្ឌិតគ្រប់គ្រងជាន់ខ្ពស់ពីវិទ្យាស្ថាន គ្រប់គ្រងពាណិជ្ជកម្ម Sasin នៃសាកលវិទ្យាល័យ Chulalongkorn ក្នុងឆ្នាំ២០០៧។

លោកគឺជាអ្នកដែលមានបទពិសោធន៍ មានជំនាញ និងប្រកបដោយវិជ្ជាជីវៈ លើសពី១៧ឆ្នាំ ទាំងក្នុងស្រុកនិងអន្តរជាតិ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់អន្តរជាតិ ការដឹកជញ្ជូន និងដឹកជញ្ជូនតាមនាវាជាមួយក្រុមហ៊ុន AP Moller Maersk Group. Damco។ លោកគឺជានាយកគ្រប់គ្រងរបស់ Damco ប្រទេសម៉ាឡេស៊ី។ បច្ចុប្បន្ននេះ លោកគឺជាដៃគូ និងជានាយកគ្រប់គ្រងនៅ JWD Group/JWD តំបន់អាស៊ី ដែលជាក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនលំដាប់កំពូលមួយនៅក្នុងតំបន់។ លោកទទួលបានចំណេះដឹង និងសមិទ្ធិផលជាច្រើននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងការដឹកជញ្ជូនតាមរយៈតួនាទីគ្រប់គ្រងជាច្រើនក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ ការអភិវឌ្ឍអាជីវកម្ម ឃ្លាំង និងការចែកចាយ ការគ្រប់គ្រងអតិថិជន ការដឹកជញ្ជូន និងសេវាដឹកជញ្ជូនទំនិញតាមផ្លូវគោកជាដើម។ លោកក៏មានសមត្ថភាព និងបទពិសោធន៍ទាំងក្នុងប្រទេស និងមុខងារក្នុងការគ្រប់គ្រងនៅក្នុងតំបន់ ជាមួយនឹងបទពិសោធន៍អន្តរជាតិនៅក្នុងប្រទេសនានាដូចជាថៃ ឥណ្ឌា អារ៉ាប់រួម ដាណឺម៉ាក វៀតណាម ម៉ាឡេស៊ី ជាដើម។

## ខ. ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក

ជាកម្មសិទ្ធិករ ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ ដូចមានក្នុងតារាងខាងក្រោម ៖

| ល.រ | ឈ្មោះរបស់អភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬ កម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | លោកជំទាវឧកញ៉ា លីម ឈីវហូរ | • ក្រុមហ៊ុន Attwood Import Export Co.. Ltd.<br>• ក្រុមហ៊ុន Attwood Investment Group Co.. Ltd.<br>• ក្រុមហ៊ុន LCH Investment Group Co.. Ltd.<br>• ក្រុមហ៊ុន LCH Sky Precious Metals Co.. Ltd.<br>• ក្រុមហ៊ុន សហ័ស ភីភីអេសអ៊ីហ្សិត<br>• ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត | • ភាគហ៊ុនិកមានសម្លេង បោះឆ្នោតភាគច្រើន និងជាអភិបាលមិនប្រតិបត្តិ<br>• ភាគហ៊ុនិកមានសម្លេងបោះឆ្នោតភាគច្រើន និងជាអភិបាលមិនប្រតិបត្តិ<br>• ភាគហ៊ុនិកមានសម្លេងបោះឆ្នោតភាគច្រើន និងជាអភិបាលមិនប្រតិបត្តិ<br>• ភាគហ៊ុនិកមានសម្លេងបោះឆ្នោតភាគច្រើន និងជាអភិបាលមិនប្រតិបត្តិ<br>• អភិបាលមិនប្រតិបត្តិ<br>• អភិបាលមិនប្រតិបត្តិ |
| ២ | លោក Hiroshi Uematsu | • ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត | • អភិបាល |
| ៣ | លោក តាន់ កាក់យុន | • ក្រុមហ៊ុន L CH Investment Group Co.. Ltd.<br>• ក្រុមហ៊ុន LCH Mobile Co.. Ltd.<br>• ក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត<br>• ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត | • អភិបាល<br>• អភិបាល<br>• អភិបាល<br>• អភិបាល |
| ៤ | លោកស្រី តាន់ ស៊ីយមួយ | • ក្រុមហ៊ុន L.C.H Development Co.. Ltd.<br>• ក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត<br>• ក្រុមហ៊ុន ខូលបេន ភីភីអេសអ៊ីហ្សេត<br>• ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត | • អភិបាល<br>• អភិបាល<br>• អភិបាល<br>• អភិបាល |
| ៥ | លោក Hiroshi Otsubo | • ក្រុមហ៊ុន Zephyr | • អភិបាល |
| ៦ | លោក Kenji Toyota | • ក្រុមហ៊ុន TSK Company<br>• ក្រុមហ៊ុន OHO Management Co.. Ltd.<br>• ក្រុមហ៊ុន Zephyr (Cambodia) Co.. Ltd. | • អភិបាល<br>• អភិបាល<br>• អភិបាល |
| ៧ | លោក Kang Wei Geih | • ការិយាល័យ Billy Kang & Co.<br>• ក្រុមហ៊ុន BG Associates Ltd. | • ម្ចាស់ភាគហ៊ុន<br>• ម្ចាស់ភាគហ៊ុន |
| ៨ | លោក Tanate Piriyothinkul | • JWD Group / JWD Asia | • អភិបាលប្រតិបត្តិ |
| ៩ | លោក ហែម សុវត្ថិ | គ្មាន | គ្មាន |

## គ. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដើម្បីដើរតួនាទីក្នុងនាមជំនួសភាគហ៊ុនិក ដើម្បីត្រួតពិនិត្យដំណើរការកិច្ចការអាជីវកម្មប្រចាំថ្ងៃ។ ក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវដោយផ្ទាល់ទៅម្ចាស់ភាគហ៊ុនិក និងរៀងរាល់ឆ្នាំ ក្រុមហ៊ុននឹងរៀបចំនូវកិច្ចប្រជុំទូទៅប្រចាំឆ្នាំ (AGM) ដែលអភិបាលទាំងអស់ ត្រូវផ្តល់របាយការណ៍ទៅឱ្យភាគហ៊ុនិកទៅលើលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន អ្វីជាផែនការ និងយុទ្ធសាស្ត្រថ្ងៃអនាគតរបស់ខ្លួន និងការដាក់ខ្លួនសម្រាប់ការបោះឆ្នោតជាក្រុមប្រឹក្សាភិបាលជាថ្មីម្តងទៀត។

គោលបំណងដ៏សំខាន់របស់ក្រុមប្រឹក្សាភិបាល គឺដើម្បីធានាឱ្យបាននូវភាពរុងរឿងរបស់ក្រុមហ៊ុនដោយការចូលរួមដោយផ្ទាល់ ក្នុងការដឹកនាំកិច្ចការរបស់ក្រុមហ៊ុន ដើម្បីបំពេញតម្រូវការផលប្រយោជន៍សមស្របទៅដល់ភាគហ៊ុនិក និងអ្នកពាក់ព័ន្ធផ្សេងទៀត។ លើសពីបញ្ហាអាជីវកម្ម និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលក៏ត្រូវចូលរួមដោះស្រាយជាមួយនឹងបញ្ហា និងការប្រកួតប្រជែងដែលទាក់ទងទៅនឹងអភិបាលកិច្ចសាជីវកម្ម ការទទួលខុសត្រូវក្នុងសកម្មភាពសង្គម និងក្រមសីលធម៌អាជីវកម្ម។

វាជាការសំខាន់ណាស់ដែលថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានប្រារព្ធឡើងជាទៀងទាត់ ដូច្នេះអភិបាល អាចបំពេញការទទួលខុសត្រូវរបស់ខ្លួនដើម្បីគ្រប់គ្រងរាល់ស្ថានភាពទូទៅ យុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រុមហ៊ុន និងត្រួតពិនិត្យការអនុវត្តរាល់ការផ្ទេរសិទ្ធិអំណាចរបស់អភិបាលនីមួយៗ ហើយដូច្នេះអភិបាលនីមួយៗ អាចរាយការណ៍តែទៅលើផ្នែកដែលពួកគាត់ទទួលខុសត្រូវតែប៉ុណ្ណោះ។

## ឃ. សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងឆ្នាំ២០១៦ ក្រុមប្រឹក្សាភិបាលបានដឹកនាំក្រុមហ៊ុនឆ្ពោះទៅមុខមួយជំហានទៀត។ កាលពី ថ្ងៃទី ៣០ ខែឧសភា កន្លងទៅនេះ ក្រុមហ៊ុនបានធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង និងក្លាយទៅជាក្រុមហ៊ុនចុះបញ្ជីទីបួន នៅទីផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនបោះផ្សាយចំនួន ១១.៥៧៥.០០០ ភាគហ៊ុនត្រូវបានបោះផ្សាយក្នុងតម្លៃ ២.៨៦០ រៀល (០.៧១៣ ដុល្លារ) ក្នុងមួយភាគហ៊ុន។ ប្រាក់ចំនួន ៣២.៨០១.៨៤៤ ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងត្រូវបានប្រើក្នុងទិសដៅបីគឺ ១.ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសថ្មីស្ថិតនៅក្រុងប៉ោយប៉ែត ដែលជាច្រកពាណិជ្ជកម្មជាប់ព្រំដែនថៃស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ២. ការទូទាត់សងប្រាក់កម្ចី ៣. លក្ខខណ្ឌតម្រូវលើការងារមូលធនរយៈពេលខ្លី។

ទោះបីជាប្រាក់ចំណូលសរុបពីការលក់ និងប្រាក់ចំណេញមានការធ្លាក់ចុះក៏ដោយ ដោយស្ថិតក្រោមការសម្រេចបានគោលដៅ និងគោលបំណងនៃគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនទទួលបានជោគជ័យក្នុងការកែលម្អតួលេខហិរញ្ញវត្ថុប្រកបដោយចីរភាព។ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួម ការធ្វើឲ្យប្រសើរឡើង នៅក្នុង ឆ្នាំ២០១៦ បើធៀបទៅនឹង ឆ្នាំ២០១៥ ត្រូវបានសង្ខេបដូចដែលបានបង្ហាញខាងក្រោមនេះ៖

| ពិពណ៌នា | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ | មានភាពប្រសើរឡើង |
|---|---|---|---|
| ប្រាក់ចំណូលពីសេវាកម្ម (ពាន់រៀល) | ៨.៥៤៩.៥២៦ | ៧.៧៦៤.១៧៤ | មាន |
| គម្លាតចំណេញដុល (%) | ៦៩.៥៧% | ៦២.៨៥% | មាន |
| អនុបាតចរន្ត | ៥.១០x | ២.៩៤x | មាន |
| អនុបាតចរន្តលឿន | ២.១១x | ១.២៥x | មាន |
| អនុបាតបំណុលធៀបនឹងមូលធន | ០.៥៥x | ០.៧៨x | មាន |

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ង. ការបណ្តុះបណ្តាលអភិបាល

នៅក្នុងឆ្នាំ២០១៦ ចំនួនអភិបាលដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមានដូចខាងក្រោម៖

| ល.រ | ឈ្មោះ | តំណែង | ប្រធានបទ | កាលបរិច្ឆេទ | អ្នករៀបចំ |
|---|---|---|---|---|---|
| ១ | លោកស្រី តាន់ សីយមួយ | អភិបាលមិនប្រតិបត្តិ | BDO ASEAN Cyber Security Exchange | ១៥ កញ្ញា ២០១៦ | ប៊ីឌីអូ (ខេមបូឌា) |
| ២ | លោក Eric Tan | អភិបាលមិនប្រតិបត្តិ | ប្រកាសអំពីការបង្ហាញព័ត៌មានក្រុមហ៊ុន | ១៧ តុលា ២០១៦ | គណៈកម្មការមូលបត្រកម្ពុជា |
| ៣ | លោក Hiroshi Uematsu | នាយកប្រតិបត្តិ | | | |
| ៤ | ក្រុមប្រឹក្សាភិបាល | | បទប្បញ្ញត្តិទាក់ទងទៅនឹងអភិបាលកិច្ចសាជីវកម្មនៅក្នុងទីផ្សារមូលបត្រ | ២៦ កក្កដា ២០១៦ | គណៈកម្មការមូលបត្រកម្ពុជា |

## ច. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

### ច.១. គណៈកម្មាធិការសវនកម្ម

*ច.១.១. សមាសភាព*

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោក KANG WEI GEIH | អភិបាលឯករាជ្យ | ប្រធាន |
| ២ | លោកស្រី តាន់ សីយមួយ | អភិបាលមិនប្រតិបត្តិ | សមាជិក |
| ៣ | លោក ហែម សុវត្ថិ | អភិបាលឯករាជ្យ | សមាជិក |

*ច.១.២. សកម្មភាពការងារ*

គោលបំណងចម្បង នៃគណៈកម្មាធិសវនកម្មគឺដើម្បីផ្តល់នូវការត្រួតពិនិត្យ នៃដំណើរការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ដំណើរការសវនកម្ម ប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។

គណៈកម្មាធិការសវនកម្ម អាចរំពឹងថានឹងពិនិត្យឡើងវិញនូវបញ្ហាគណនេយ្យនិងរបាយការណ៍សំខាន់ៗមួយចំនួន និង ការប្រកាសនូវជំនាញវិជ្ជាជីវៈនិងបទប្បញ្ញត្តិថ្មីៗ ដើម្បីយល់ពីផលប៉ះពាល់សក្តានុពលលើរបាយការណ៍ហិរញ្ញវត្ថុ។ ការយល់ដឹងពី របៀបនៃគណៈគ្រប់គ្រង បង្កើតព័ត៌មានហិរញ្ញវត្ថុបណ្តោះអាសន្នផ្ទៃក្នុង គឺជាការចាំបាច់ដើម្បីវាយតម្លៃថា តើរបាយការណ៍ពេញលេញនិងមានភាពត្រឹមត្រូវ។

គណៈកម្មាធិការសវនកម្ម ពិនិត្យឡើងវិញនូវលទ្ធផលនៃការធ្វើសវនកម្មជាមួយនឹងគណៈគ្រប់គ្រងនិងសវនករខាងក្រៅ រួមទាំងបញ្ហាចាំបាច់នានា ដែលតម្រូវឲ្យធ្វើទំនាក់ទំនង ទៅនឹងគណៈកម្មាធិការនៅក្រោមស្តង់ដារសវនកម្មដែលបានអនុម័តជាទូទៅ។

គណៈកម្មាធិការសវនកម្ម នឹងពិចារណាអំពីការគ្រប់គ្រងផ្ទៃក្នុង និងពិនិត្យឡើងវិញពីប្រសិទ្ធភាពរបស់ខ្លួន។ របាយការណ៍ស្តីពី និងការឆ្លើយតបរបស់គណៈគ្រប់គ្រងទៅកាន់ការសង្កេត និងការរកឃើញ សំខាន់មួយចំនួន គួរតែត្រូវបានទទួលយក និងពិនិត្យឡើងវិញដោយគណៈកម្មាធិការ។ ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ សន្តិសុខខាងបច្ចេកវិទ្យាព័ត៌មាន និងបញ្ហាប្រតិបត្តិការត្រូវស្ថិតក្រោមគណៈកម្មាធិការនេះ។

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ក្នុងឆ្នាំ២០១៦ គណកម្មាធិការសវនកម្ម ពុំមានសកម្មភាពការងារជាសំខាន់គួរអោយកត់សម្គាល់នោះទេ។

*ច.១.៣. បញ្ហាប្រឈម*

ក្នុងឆ្នាំ២០១៦ គណកម្មាធិការសវនកម្មពុំមានបញ្ហាជាសំខាន់ត្រូវប្រឈមមុខនោះទេ។

## ច.២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

*ច.២.១. សមាសភាព*

| ល.រ | ឈ្មោះ | តំណែង | |
|---|---|---|---|
| | | ក្នុងក្រុមហ៊ុន | ក្នុងគណៈកម្មាធិការ |
| ១ | លោក ហែម សុវត្ថិ | អភិបាលឯករាជ្យ | ប្រធាន |
| ២ | លោក HIROSHI UEMATSU | អភិបាលប្រតិបត្តិ | សមាជិក |
| ៣ | លោក តាន់ កាក់យុន | អភិបាលមិនប្រតិបត្តិ | សមាជិក |

*ច.២.២. សកម្មភាពការងារ*

គណៈកម្មាធិការហានិភ័យ ត្រូវបានបង្កើតឡើងដោយ និងក្នុងចំណោមក្រុមប្រឹក្សាភិបាលដើម្បីសម្របតាមឱ្យបានត្រឹមត្រូវជាមួយគណៈគ្រប់គ្រង ខណៈវាជាការចាប់ផ្តើមកម្មវិធីគ្រប់គ្រងហានិភ័យមួយ។ ការទទួលខុសត្រូវចម្បងនៃគណៈកម្មាធិការហានិភ័យ គឺដើម្បីត្រួតពិនិត្យនិងអនុម័តលើការអនុវត្តន៍ការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនធំទូលាយ ដើម្បីជួយដល់ក្រុមប្រឹក្សាភិបាលនៅក្នុង៖

- ការគ្រប់គ្រងមើលការខុសត្រូវ ថាក្រុមប្រតិបត្តិបានកំណត់និងបានវាយតម្លៃហានិភ័យទាំងអស់ដែលស្ថាប័ននេះប្រឈមមុខជាមួយ និងបានបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យដែលមានសមត្ថភាពក្នុងការដោះស្រាយហានិភ័យទាំងនោះ
- ការគ្រប់គ្រងមើលការខុសត្រូវ ក្នុងការភ្ជាប់ជាមួយគណៈកម្មាធិការកម្រិតក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាលទាំងមូល ប្រសិនបើអាចអនុវត្តបាន ហានិភ័យដូចជា យុទ្ធសាស្រ្ត ហិរញ្ញវត្ថុ ឥណទាន ទីផ្សារ សន្ទនិយភាព សន្តិសុខ ទ្រព្យសម្បត្តិ បច្ចេកវិទ្យាព័ត៌មាន ច្បាប់ បទប្បញ្ញត្តិ កេរ្តិ៍ឈ្មោះ និងហានិភ័យផ្សេងទៀត។
- ការគ្រប់គ្រងមើលការខុសត្រូវ ផ្នែកនៃការទទួលខុសត្រូវដែលពាក់ព័ន្ធនឹងហានិភ័យចំពោះគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ឲ្យបានច្បាស់ដូចដែលអាចធ្វើទៅបាន និងការអនុវត្តការវិភាគគម្លាត ដើម្បីកំណត់ថាការត្រួតពិនិត្យនៃហានិភ័យនានា មិនត្រូវបាន ខកខាន។
- នៅក្នុងការភ្ជាប់ជាមួយនឹងក្រុមប្រឹក្សាភិបាលទាំងមូល ការអនុម័តលើក្របខ័ណ្ឌនៃគ្រប់គ្រងហានិភ័យនៃសកម្មភាពជំនួញធំទូលាយ របស់ក្រុមហ៊ុន។

គណៈកម្មាធិការហានិភ័យ អាចមានសិទ្ធិអំណាចដើម្បីធ្វើការស៊ើបអង្កេតទៅលើ បញ្ហាណាមួយនៅក្នុងវិសាលភាពនៃការទទួលខុសត្រូវរបស់ខ្លួន និងទទួលការប្រឹក្សាយោបល់ និងជំនួយពីខាងក្រៅ ផ្នែកច្បាប់គណនេយ្យ ឬទីប្រឹក្សាផ្សេងទៀត ជាការចាំបាច់ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។

ក្នុងការអនុវត្តនូវភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន គណៈកម្មាធិការហានិភ័យ នឹងមានសិទ្ធិអំណាចផងដែរ ដើម្បីជួបជាមួយ និង ស្វែងរកព័ត៌មានណាមួយដែលវាតម្រូវឱ្យមានពីបុគ្គលិក មន្ត្រី អភិបាល ឬភាគីខាងក្រៅ។ លើសពីនេះទៅទៀត គណៈកម្មាធិការហានិភ័យ អាចធ្វើឱ្យប្រាកដ ដើម្បីជួបជាមួយគណៈកម្មាធិការក្រុមប្រឹក្សាភិបាលផ្សេងទៀត ដើម្បីចៀសវាងការត្រួតពិនិត្យលើគ្នា ព្រមទាំងគម្លាតដែលមានសក្តានុពលក្នុងការត្រួតពិនិត្យហានិភ័យនានារបស់ក្រុមហ៊ុន។

ក្នុងឆ្នាំ២០១៦ គណកម្មាធិការគ្រប់គ្រងហានិភ័យ ពុំមានសកម្មភាពការងារជាសំខាន់គួរអោយកត់សម្គាល់នោះទេ។

*ច.២.៣. បញ្ហាប្រឈម*

ក្នុងឆ្នាំ២០១៦ គណកម្មាធិការគ្រប់គ្រងហានិភ័យ ពុំមានបញ្ហាជាសំខាន់ត្រូវប្រឈមមុខនោះទេ។

## ៣.៤. បុគ្គលិកជាន់ខ្ពស់

*ក-សមាសភាពបុគ្គលិកជាន់ខ្ពស់*

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦នេះ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនយើង មានរៀបរាប់ដូចខាងក្រោមនេះ៖

| ល.រ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | លោក HIROSHI UEMATSU | នាយកប្រតិបត្តិ |
| ២ | លោក FONG NEE WAI | នាយកផ្នែកហិរញ្ញវត្ថុ |
| ៣ | លោក លាង តារា | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង |
| ៤ | លោក KENICHI YOSHIDA | ប្រធានវិស្វករ/ប្រធានផ្នែកវិស្វកម្ម |
| ៥ | លោកស្រី ZHAO MINQIAN | អ្នកគ្រប់គ្រងជាន់ខ្ពស់/ ប្រធានផ្នែកលក់ និងទីផ្សារ |
| ៦ | លោក ស៊ុន សាមឿន | អ្នកគ្រប់គ្រងជាន់ខ្ពស់/ ប្រធានផ្នែកធនធានមនុស្ស |
| ៧ | លោកស្រី ហ៊ុន ចាន់ប៉ី | អ្នកគ្រប់គ្រងជាន់ខ្ពស់/ ប្រធានផ្នែកគណនេយ្យនិង ហិរញ្ញវត្ថុ |
| ៨ | លោក SUSUMU NAGAOKA | អ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្នែកសេវាអតិថិជន |
| ៩ | បណ្ឌិត ARDISAK BOEPRASERT | ប្រធានផ្នែកទំនាក់ទំនងវិនិយោគិន/មន្ត្រីផ្នែកផ្តល់ព័ត៌មាន |

*ខ. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់*

ប្រវត្តិរូបរបស់លោក Hiroshi Uematsu អភិបាលប្រតិបត្តិរបស់យើង និងជា នាយកប្រតិបត្តិនៃក្រុមហ៊ុនរបស់យើង ត្រូវបានរាបរាប់នៅក្នុង ផ្នែក ៣.៣ នៃរបាយការណ៍នេះ។ ប្រវត្តិរូបរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្សេងៗទៀតរបស់យើង ត្រូវបានរាប់រាប់ដូចខាងក្រោម៖

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

### លោក Fong Nee Wai - នាយកផ្នែកហិរញ្ញវត្ថុ

លោក Fong Nee Wai ជនជាតិម៉ាឡេស៊ី កើតនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៦៧ នៅប្រទេសម៉ាឡេស៊ី គឺជានាយកផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើង តាំងពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។

លោកគឺជាសមាជិកនៃ Association of Chartered Certified Accountants និងជាសមាជិកពេញសិទ្ធិនៃ Malaysian Institute of Accountants (“MIA”)ដែលលោកមានតួនាទីជាគណនេយ្យករតាំងពីឆ្នាំ២០០១ និងជាសមាជិកនៃ Certified Financial Planner របស់ Financial Planning Association នៃប្រទេសម៉ាឡេស៊ី តាំងពីឆ្នាំ២០០៣ និងជាសមាជិកនៃ KICPAA តាំងពីឆ្នាំ២០០៥។ បច្ចុប្បន្ននេះ លោកកំពុងបន្តយកសញ្ញាបត្រ Professional Certified Public Accountants (“KICPAA”) ដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លោកមានបទពិសោធន៍ជាងម្ភៃប្រាំ (២៥) ឆ្នាំក្នុងវិស័យគណនេយ្យ និងហិរញ្ញវត្ថុ។ លោកបានចាប់ផ្តើមវិជ្ជាជីវៈរបស់លោកក្នុងតំណែងជា ជំនួយការអ្នកត្រួតពិនិត្យគណនេយ្យ ក្នុងក្រុមហ៊ុន Inview Corporation Sdn. Bhd. ក្នុងឆ្នាំ១៩៨៩ ហើយបន្តជាជំនួយការគណនេយ្យករ ក្នុងក្រុមហ៊ុន Antara Holiday Villas Sdn. Bhd. ក្នុងឆ្នាំ១៩៩១។ ក្រោយមក លោកបានបន្តធ្វើការជាមួយក្រុមហ៊ុន Colours & Frangrances Sdn. Bhd. ក្នុងឆ្នាំ១៩៩៥ ក្នុងតំណែងជា អ្នកគ្រប់គ្រងគណនេយ្យជាន់ខ្ពស់/គណនេយ្យករ។ លោកបានចូលកាន់តំណែងក្នុងក្រុមហ៊ុន ERMS Sdn. Bhd. ជាអ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល ក្នុងឆ្នាំ១៩៩៧។ លោកបានចូលទៅបម្រើការងារក្នុងក្រុមហ៊ុន Sunway City Bhd. ក្នុងឆ្នាំ១៩៩៩ ក្នុងនាមជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ទទួលបន្ទុកលើសណ្ឋាគារក្នុងប្រទេសម៉ាឡេស៊ី និងព្រះរាជាណាចក្រកម្ពុជា ហើយដែលក្រោយមកលោកត្រូវបានដំឡើងតំណែងជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុជាន់ខ្ពស់នៃក្រុមហ៊ុន Sunway City Bhd. ដែលជាក្រុមហ៊ុនបោះផ្សាយមូបត្រលក់ ជាសាធារណៈក្នុងវិស័យអចលនទ្រព្យនៅប្រទេសម៉ាឡេស៊ី។ បន្ទាប់មក លោកបានចូលកាន់តំណែងក្នុងក្រុមហ៊ុន Intercontinental Hotel Group ជាប្រធានផ្នែកសេវាជំនួយធុរកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៧។ ក្រោយពីនោះមកទៀត លោកបានចូលបម្រើក្នុងក្រុមហ៊ុន Attwood Investment Group Co.. Ltd. ជានាយកផ្នែកហិរញ្ញវត្ថុក្នុងឆ្នាំ២០០៩ មុនពេលលោកចូលកាន់តំណែងក្នុងក្រុមហ៊ុនយើងក្នុងឆ្នាំ២០១៣។

គិតមកថ្ងៃទី៣១ ខែធ្នូ ខែកញ្ញា ឆ្នាំ២០១៦ លោកគឺជាអ្នកចូលហ៊ុនក្នុងក្រុមហ៊ុន N.W. Fong & Associates នៅប្រទេសម៉ាឡេស៊ី។ លោកក៏មានកាន់តំណែងជានាយកប្រតិបត្តិក្នុងក្រុមហ៊ុន L C H Mobile Co.. Ltd.។ លោកមិនមានកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុនណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## លោក លាង តារា - ប្រធានការិយាល័យសវនកម្មផ្ទៃក្នុង

លោក លាង តារា សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៨៥ នៅប្រទេសកម្ពុជា គឺជាប្រធានការិយាល័យសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុនយើង។ លោកបានចូលកាន់តំណែងនៅក្រុមហ៊ុនរបស់យើងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៨ និងសញ្ញាបត្របរិញ្ញាបត្រភាសាអង់គ្លេសនៅសកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៩។ បច្ចុប្បន្ននេះ លោកកំពុងបន្តយកសញ្ញាបត្រ Professional Certified Public Accountants (“KICPAA”) ដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកមានបទពិសោធន៍ច្រើនជាងប្រាំមួយ(០៦)ឆ្នាំ ក្នុងវិស័យគណនេយ្យ និងហិរញ្ញវត្ថុ។ លោកចាប់ផ្តើមវិជ្ជាជីវៈរបស់លោកជាគណនេយ្យករនៅក្រុមហ៊ុន Anco Brother Co.. Ltd. ក្នុងឆ្នាំ២០០៨។ ក្រោយមក លោកបានចូលកាន់តំណែងសវនករជាន់ខ្ពស់សេវាធានារ៉ាប់រង នៅក្រុមហ៊ុន Ernst & Young (Cambodia) Ltd. ក្នុងឆ្នាំ២០០៩។ ក្រោយមកទៀត លោកបានចូលធ្វើជាអ្នកវិភាគអាជីវកម្មធនាគារពាណិជ្ជនៅធនាគារ CIMB Bank Plc. ក្នុងឆ្នាំ២០១៤ មុនពេលលោកចូលកាន់តំណែងក្នុងក្រុមហ៊ុនរបស់យើងក្នុងឆ្នាំ២០១៥។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកមិនមានកាន់តំណែងជាអភិបាល ឬកាន់កាប់ ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## លោក Yoshida Kenichi - ប្រធានវិស្វករ

លោក Yoshida Kenichi ជនជាតិជប៉ុន កើតនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៤៦ នៅប្រទេសជប៉ុន គឺជាប្រធានវិស្វកររបស់ក្រុមហ៊ុនយើង។ លោកបានកាន់តំណែងនេះ ចាប់តាំងពីពេលដែលលោកចាប់ផ្តើមការងារជាមួយក្រុមហ៊ុនយើងតាំងពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៣។

នាពេលបច្ចុប្បន្ន លោកមានតួនាទីមើលការខុសត្រូវលើការគ្រោង និងការចាត់ការទូទៅនៃហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងបរិស្ថាន និងសុវត្ថិភាពនៃអគារ និងបរិក្ខារក្នុង PPSEZ។ លោកបានទទួល សញ្ញាបត្របរិញ្ញាបត្រវិស្វកម្មស៊ីវិលពី Kumamoto University ប្រទេសជប៉ុន ក្នុងឆ្នាំ១៩៦៩។

លោកមានបទពិសោធន៍ជាងសែសិបប្រាំ(៤៥) ឆ្នាំក្នុងជំនាញវិស្វកម្ម។ លោកចាប់ផ្តើមវិជ្ជាជីវៈរបស់លោកជាវិស្វករការដ្ឋានឲ្យក្រុមហ៊ុន Fujita Corporation នៅប្រទេសជប៉ុន ក្នុងឆ្នាំ១៩៦៩ ដែលក្រោយមកលោកត្រូវបានដំឡើងតំណែងជាអ្នកគ្រប់គ្រងគម្រោងក្នុងឆ្នាំ១៩៨៨ និងក្រោយមកទៀតជាប្រធានវិស្វករក្នុងឆ្នាំ២០០០។ ក្នុងឆ្នាំ ២០០២ លោកបានចូលកាន់ការងារក្នុងក្រុមហ៊ុន Taisei Corporation ក្នុងនាមជាអ្នកគ្រប់គ្រងគម្រោងសម្រាប់ការងារសាងសង់ប្រព័ន្ធទឹកសំអុយ ក្នុងប្រទេសវៀតណាម។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ លោកបានធ្វើជាអ្នកគ្រប់គ្រងការដ្ឋាន (តាមគម្រោង) ឲ្យក្រុមហ៊ុនជាច្រើនលើការងារសាងសង់ស៊ីវិលខុសៗគ្នាក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាហ្រ្វិក។ក្រោយមកលោកបានចូលបម្រើការងារក្នុងក្រុមហ៊ុនKatahira&Engineers International Corporation ក្នុងតំណែងជាវិស្វករ (Resident Engineer) ក្នុងឆ្នាំ ២០០៦ ដែលលោកបានគ្រប់គ្រងគម្រោងស៊ីវិលជាច្រើន ក្នុងប្រទេសឥណ្ឌូនេស៊ី និងព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់មក លោកបានចូលធ្វើការនៅក្រុមហ៊ុន JEM Inc. ក្នុងឆ្នាំ២០១២ ជាវិស្វករ (Resident Engineer) មុនពេលចូលបម្រើការក្នុងក្រុមហ៊ុនរបស់យើងក្នុងឆ្នាំ២០១៣។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកមិនមានកាន់តំណែងជាអភិបាល ឬកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

PHONM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

### លោកស្រី Zhao Minqian - អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកលក់ និង ទីផ្សារ/សេវាអតិថិជន

លោកស្រី Zhao Minqian ជនជាតិចិន កើតនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៨៦ នៅសាធារណរដ្ឋប្រជាមានិតចិន (ប្រទេសចិន) គឺជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកលក់ និង ទីផ្សារ/សេវាអតិថិជនរបស់ក្រុមហ៊ុនយើងចាប់តាំងពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣។

មុខងារចម្បងរបស់លោកស្រីរួមមាន ការមើលការខុសត្រូវទូទៅលើទំនាក់ទំនងសាជីវកម្ម ដែលរួមមានទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម និងសកម្មភាពទីផ្សារ។ លោកស្រី បានទទួលសញ្ញាបត្របរិញ្ញាបត្រក្នុងជំនាញអក្សរសាស្រ្តភាសាជប៉ុនពី Xi'an International Studies University ប្រទេសចិនក្នុងឆ្នាំ២០០៨។

លោកស្រីមានបទពិសោធន៍ច្រើនជាងប្រាំមួយ(០៦) ឆ្នាំ ក្នុងវិស័យទីផ្សារ និងទំនាក់ទំនងសាធារណៈ។ លោកស្រីចាប់ផ្តើមវិជ្ជាជីវៈរបស់លោកស្រីជាបុគ្គលិកក្នុងក្រុមហ៊ុន Takeda Lace Co.. Ltd. នៅប្រទេសជប៉ុនក្នុងឆ្នាំ២០០៨។ ក្រោយមក លោកស្រីបានចូលបម្រើការងារក្នុងក្រុមហ៊ុន F.T. Apparel Co.. Ltd. នៅប្រទេសជប៉ុន ក្នុងឆ្នាំ២០១០ មានមុខងារជាអ្នកច្នៃម៉ូតហើយជាអ្នកគ្រប់គ្រងផ្នែកលក់ មុនពេលលោកស្រីចូលមកបម្រើការងារក្នុងក្រុមហ៊ុនយើងក្នុងឆ្នាំ២០១៣។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកស្រីមិនមានកាន់តំណែង ជាអភិបាល ឬកាន់កាប់ ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

### លោក ស៊ុន សាមឿន - អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកធនធានមនុស្ស

លោកស៊ុន សាមឿន សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៩ នៅប្រទេសកម្ពុជា គឺជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុនយើង តាំងពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៥។ លោកមានភារកិច្ចចម្បងលើរាល់បញ្ហាផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុនយើង។

លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកភាសាអង់គ្លេស (មានជំនាញបង្រៀនភាសាអង់គ្លេស ជាភាសាបរទេស និងទំនាក់ទំនងភាសាអង់គ្លេស) នៅសាកលវិទ្យាល័យន័រតុនព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០៥ និង សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំនៅ សកលវិទ្យាល័យ Concordia សហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៧។ លោកមានបទពិសោធន៍ច្រើនជាងដប់(១០) ឆ្នាំក្នុងវិស័យផ្សេងៗដែលពាក់ព័ន្ធនឹងធនធានមនុស្ស។ លោកចាប់ផ្តើមវិជ្ជាជីវៈ របស់លោកជាគ្រូបណ្តុះបណ្តាលភាសាអង់គ្លេស និងទំនាក់ទំនងអាជីវកម្មនៅសាកលវិទ្យាល័យន័រតុនក្នុងឆ្នាំ២០០៤ ហើយលាចេញពីតំណែងក្នុងឆ្នាំ២០០៦ ទៅបន្តការសិក្សារបស់លោកនៅសហរដ្ឋអាមេរិក។ ក្រោយពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លោកបានត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ ហើយចូលកាន់តំណែងជាអ្នកគ្រប់គ្រងវគ្គបណ្តុះបណ្តាលនៅសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ក្នុងឆ្នាំ២០០៨។ បន្ទាប់មកលោកបានចូលកាន់តំណែងក្នុងក្រុមហ៊ុន Nautisco Seafood Manufacturing Ltd. ជាអ្នកគ្រប់គ្រងធនធានមនុស្សក្នុងឆ្នាំ២០០៩។ ក្រោយមកទៀត លោកបានចូលធ្វើជាប្រធានផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុន First Cambodia Co.. Ltd. ក្នុងឆ្នាំ២០១២។ បន្តក្រោយមកទៀត លោកបានចូលកាន់តំណែងជាប្រធានផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុន DFI Lucky Private Limited ក្នុងឆ្នាំ២០១៣ មុនពេលលោកចូលកាន់តំណែងបច្ចុប្បន្នក្នុងក្រុមហ៊ុនរបស់យើងក្នុងឆ្នាំ២០១៥។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកមិនមានកាន់តំណែងជាអភិបាល ឬកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុនណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## លោកស្រី ហ៊ុន ចាន់ប៊ី - អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

លោកស្រី ហ៊ុន ចាន់ប៊ី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៨០ នៅប្រទេសកម្ពុជា គឺជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើងតាំងពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧។ លោកស្រីបានចូលបម្រើការក្នុងក្រុមហ៊ុនរបស់យើងក្នុងឆ្នាំ២០០៧ ជាគណនេយ្យករជាន់ខ្ពស់ និងមានតួនាទីរៀបចំ របាយការណ៍ហិរញ្ញវត្ថុ។ ក្រោយមក លោកស្រីត្រូវបានតម្លើងតំណែងជាអ្នកគ្រប់គ្រងគណនេយ្យរបស់ក្រុមហ៊ុនយើង ក្នុងឆ្នាំ២០១១ មុនពេលលោកស្រីត្រូវបានដំឡើងតំណែងមកតំណែងនាពេលបច្ចុប្បន្ននេះក្នុងឆ្នាំ២០១៣។

តួនាទីចម្បងរបស់លោកស្រីរួមមានរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងធ្វើការប្រកាសពន្ធរបស់ក្រុមហ៊ុនយើង។ លោកស្រីបានទទួលសញ្ញាបត្របរិញ្ញាបត្រពាណិជ្ជសាស្ត្រ ក្នុងជំនាញគណនេយ្យពីវិទ្យាស្ថានជាតិគ្រប់គ្រង ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០០ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ក្នុងជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសកលវិទ្យាល័យបៀលប្រាយព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០៨។ លោកស្រី មានបទពិសោធន៍ដប់បួន(១៤) ឆ្នាំក្នុងវិស័យ គណនេយ្យ និងហិរញ្ញវត្ថុ។ លោកស្រីចាប់ផ្តើមវិជ្ជាជីវៈរបស់លោកស្រីជាគណនេយ្យករ ឲ្យក្រុមហ៊ុន Media Services Limited ក្នុងឆ្នាំ២០០០ ហើយបន្ទាប់មក លោកស្រីបានចូលបម្រើការក្នុងសណ្ឋាគារ Casa ក្នុងតំណែងជាគណនេយ្យករ និងជំនួយការអ្នកគ្រប់គ្រង ហិរញ្ញវត្ថុក្នុងខែកញ្ញា ឆ្នាំ២០០១ មុនពេលលោកស្រីចូលបម្រើការក្នុងក្រុមហ៊ុន Attwood Import Export Co.. Ltd. ក្នុងតំណែងជាគណនេយ្យជាន់ខ្ពស់ និងរដ្ឋបាលក្នុងឆ្នាំ២០០៣។ ហើយក្រោយមក លោកស្រីបានចូលបម្រើការក្នុងក្រុមហ៊ុនយើងក្នុងឆ្នាំ ២០០៧។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកស្រីមិនមានកាន់តំណែងជាអភិបាល ឬកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

### លោក Nagaoka Susumu - អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកសេវាអតិថិជន - វិនិយោគិនជប៉ុន

លោក Nagaoka Susumu ជនជាតិជប៉ុន កើតនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៣ នៅប្រទេសជប៉ុនគឺជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្នែកសេវាអតិថិជន ចាប់តាំងពី១២ ខែវិច្ឆិកា ឆ្នាំ២០១៥។ បច្ចុប្បន្ន លោកជាអ្នកទទួលបន្ទុកក្នុងការលើកកម្ពស់ និងគ្រប់គ្រងស្តង់ដារខ្ពស់នៃការថែរក្សាអតិថិជន វិនិយោគិនជប៉ុនដែលមានក្នុងតំបន់។ លោកបានទទួលបរិញ្ញាបត្រផ្នែកសិល្បៈ ជំនាញមនុស្សសាស្ត្រ និងភាសាពីសាកលវិទ្យាល័យ Toyo Gakuen ប្រទេសជប៉ុន ក្នុងឆ្នាំ១៩៩៦។

លោកបានចាប់ផ្តើមអាជីពរបស់លោក ជាបុគ្គលិកផ្នែកលក់ក្រៅប្រទេស ក្នុងផ្នែកលក់ និងទីផ្សាររបស់ក្រុមហ៊ុន Orion Trading ប្រទេសជប៉ុនក្នុងឆ្នាំ១៩៩៦។ ក្នុងឆ្នាំ២០០៤ លោកបាន ចូលបម្រើការងារនៅ OCS ប្រទេសថៃ (ក្រុមហ៊ុនមេនៃក្រុមហ៊ុន ANA. All Nippon Airways) និងត្រូវបានចាត់តាំងឱ្យបម្រើការងារនៅ OCS ប្រទេសកម្ពុជា ក្នុងតួនាទីជាអ្នកតំណាងប្រទេសពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៤ មុនពេលដែលលោកបានចូលរួមជាមួយក្រុមហ៊ុនយើងនៅក្នុងឆ្នាំ២០១៥។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកមិនមានកាន់តំណែងជាអភិបាល ឬកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើន ក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

### បណ្ឌិត ARDISAK BOEPRASERT - ប្រធានផ្នែកទំនាក់ទំនងវិនិយោគិន/មន្ត្រីផ្នែកផ្តល់ព័ត៌មាន

បណ្ឌិត Ardisak Boeprasert ជនជាតិថៃ កើតនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៩ នៅសហរដ្ឋអាមេរិច គឺជាប្រធានផ្នែកទំនាក់ទំនងវិនិយោគិន/មន្ត្រីផ្នែកផ្តល់ព័ត៌មាន របស់ក្រុមហ៊ុនចាប់តាំងពីទី១ ខែកញ្ញា ឆ្នាំ២០១៦។

លោកទទួលខុសត្រូវក្នុងការទំនាក់ទំនងវិនិយោគិន និងបញ្ហាផ្នែកផ្តល់ព័ត៌មានរបស់ក្រុមហ៊ុន។ លោក បានទទួលបរិញ្ញាបត្រវិស្វកម្មផ្នែកគីមីពីសាកលវិទ្យាល័យ Chulalongkorn ប្រទេសថៃក្នុងឆ្នាំ២០០១។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យ Assumption ប្រទេសថៃក្នុងឆ្នាំ២០០៥ និងថ្នាក់បណ្ឌិតផ្នែកហិរញ្ញវត្ថុ (កម្មវិធីអន្តរជាតិ) ពីវិទ្យាស្ថានជាតិគ្រប់គ្រងការអភិវឌ្ឍន៍ ប្រទេសថៃក្នុងឆ្នាំ២០១២។

លោកមានបទពិសោធន៍លើសពី១០ (ដប់) ក្នុងជំនាញធ្វើផែនការ ការវាយតម្លៃការវិនិយោគ ការទំនាក់ទំនងវិនិយោគិន និងផ្នែកផ្តល់ព័ត៌មាន។ មុនពេលបម្រើការក្នុងក្រុមហ៊ុននេះ លោកបានបម្រើការក្នុងតំណែងជាអ្នកគ្រប់គ្រង នៅក្នុងក្រុមហ៊ុនចុះបញ្ជីនៅប្រទេសថៃអស់រយៈពេលជាច្រើនឆ្នាំ ក្នុងជំនាញទំនាក់ទំនងវិនិយោគគិន និងផ្នែកផ្តល់ព័ត៌មាន។ លោកក៏បានធ្វើការលើការវិភាគអាជីវកម្ម ការសិក្សាលទ្ធភាពផ្នែកហិរញ្ញវត្ថុ ការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងការគ្រប់គ្រងហិរញ្ញវត្ថុ ជាមួយក្រុមហ៊ុនចុះបញ្ជីធំៗនៅក្នុងប្រទេសថៃ ដូចជាផ្នែកឥន្ធនៈគីមី ទូរគមនាគមន៍ អាហារ និងភេសជ្ជៈផងដែរ។

គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ លោកមិនមានកាន់តំណែងជាអភិបាល ឬកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ក្នុងក្រុមហ៊ុនណាមួយក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## គ. លទ្ធផលការងាររបស់បុគ្គលិកជាន់ខ្ពស់

នៅក្នុងឆ្នាំ២០១៦ ប្រតិបត្តិការអាជីវកម្មរបស់យើងមានការធ្លាក់ចុះបើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥។ ខណៈពេលដែលប្រាក់ចំណូលពីការផ្តល់សេវា និងចំណូលពីការជួល គឺស្ថិតតាមផែនការណ៍ដែលបានគ្រោងទុក (កើនឡើង១០.១២% និង ១.៧៦% រៀងគ្នា)។ ក្រុមហ៊ុន មានភាពលំបាកពីការធ្លាក់ចុះនៃការលក់ដី ឬជួលអចិន្ត្រៃយ៍ដែលមានចំនួនត្រឹមតែ ២៦.២៦១.៨០៣ ពាន់រៀលប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ ដែលមានចំនួន ៥៥.២៤៥.៤៩៩ ពាន់រៀល។ នៅក្នុងឆ្នាំ២០១៦ នេះ យើងបានឈានដល់ការចុះកិច្ចព្រមព្រៀងដោយជោគជ័យទៅលើការទិញ/ជួល ជាមួយបណ្តាក្រុមហ៊ុនដូចខាងក្រោមនេះ៖

| ល.រ | ភាគីកិច្ចព្រមព្រៀង | វេបសាយ | ប្រទេស | វិស័យឧស្សាហកម្ម | ទំហំដី (ម៉ែត្រការេ) |
|---|---|---|---|---|---|
| ១ | Sankei Engineering | http://eng.sankei-engineering.com/ | ជប៉ុន | ផលិតគ្រឿងបង្គុំអគ្គិសនី | ៩.០០០ |
| ២ | China Animation Characters | http://www.animatechina.com/ | ចិន | ផលិតតុក្កតា | ៥.២៨៦ |
| ៣ | Midori Technopark | http://www.midori-anzen.co.jp/english/ | ជប៉ុន | ផលិតសម្ភារៈផ្នែកខាងក្នុងរថយន្ត | ១២.៦៦៩ |
| ៤ | Winsun Cambodia | http://taisun.trustpass.alibaba.com/ | តៃវ៉ាន់ | ផលិត ខោទឹកនោមសម្រាប់ទារក និង មនុស្សចាស់ សំឡីអនាម័យស្ត្រី និង កន្សែងសើម | ១៧.២៨៧ |
| ៥ | Shinohara | http://www.shinohara-web.co.jp/ | ជប៉ុន | ឧបករណ៍កែសម្ផស្ស | ១៣.៨៨៥ |
| ៦ | Avery Dennison | http://www.averydennison.com/ | អាមេរិច | ស្លាក និងការវេចខ្ចប់ | ៣.៥០០ |
| ៧ | Tanaka Foresight | http://www.tanaka-pd.co.jp/english/ | ជប៉ុន | ឧបករណ៍កែសម្ផស្ស | ១៣.៨៨៥ |
| ៨ | Kingtel (EMAXX) | http://www.kingtel.com.kh/ | ចិន | ឃ្លាំងសម្រាប់អ៊ិនធឺណែត | ១.៥០០ |
| ៩ | Herba Ingredients | http://www.herbaingredients.com/ | ហូឡង់ | លក់ដុំស្រូវអង្ករ គ្រាប់ធញ្ញជាតិ ម្សៅមី និង ស្ករ | ២០.៣៦៨ |
| ១០ | IKEE Paving Systems | http://www.ikee.jp/ | ជប៉ុន | សម្ភារៈសំណង់ | ៨.៣១០ |

ទោះបីជាប្រាក់ចំណូលសរុបពីការលក់ និងប្រាក់ចំណេញមានការធ្លាក់ចុះក៏ដោយ ដោយស្ថិតក្រោមការសម្រេចបានគោលដៅ និងគោលបំណងនៃគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនទទួលបានជោគជ័យក្នុងការកែលម្អតួលេខហិរញ្ញវត្ថុប្រកបដោយចីរភាព។ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួម ការធ្វើឲ្យប្រសើរឡើង នៅក្នុង ឆ្នាំ២០១៦ បើធៀបទៅនឹងឆ្នាំ២០១៥ ត្រូវបានសង្ខេបដូចដែលបានបង្ហាញខាងក្រោមនេះ៖

| ពិពណ៌នា | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ | មានភាពប្រសើរឡើង |
|---|---|---|---|
| ប្រាក់ចំណូលពីសេវាកម្ម (ពាន់រៀល) | ៨.៥៤៩.៥២៦ | ៧.៧៦៤.១៧៤ | មាន |
| គម្លាតចំណេញដុល (%) | ៦៩.៥៧% | ៦២.៨៥% | មាន |
| អនុបាតចរន្ត | ៥.១០x | ២.៩៤x | មាន |
| អនុបាតចរន្តលឿន | ២.១១x | ១.២៥x | មាន |
| អនុបាតបំណុលធៀបនឹងមូលធន | ០.៥៥x | ០.៧៨x | មាន |

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ឃ. ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់

### នៅក្នុងឆ្នាំ២០១៦ ចំនួនបុគ្គលិកជាន់ខ្ពស់ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលៈ

| ល.រ | ឈ្មោះ | តំណែង | ប្រធានបទ | ថ្ងៃបរិច្ឆេទ | អ្នករៀបចំ |
|---|---|---|---|---|---|
| ១ | លោក លាង តារា | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | ការវិភាគរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ | ១៥ កក្កដា ២០១៦ | ផ្សារមូលបត្រកម្ពុជា |
| | | | ការវិភាគជាមូលដ្ឋាន | ១២ សីហា ២០១៦ | ផ្សារមូលបត្រកម្ពុជា |
| ១ | អ្នកស្រី Michelle Zao | ប្រធានផ្នែកលក់ ទីផ្សារ និងសេវាអតិថិជន | សិល្បៈនៃការនិយាយជាសាធារណៈ | ១៣ សីហា ២០១៦ | ១៣ សីហា ២០១៦ |
| ៣ | លោក ស៊ុន សាមឿន | ប្រធានផ្នែកធនធានមនុស្ស | BDO ASEAN Cyber Security Exchange | ១៥ កញ្ញា២០១៦ | ប៊ីឌីអូ (ខេមបូឌា) លីមីតធីត |
| ៤ | លោក លាង តារា | ប្រធានផ្នែក សវនកម្មផ្ទៃក្នុង | | | |
| ៥ | អ្នកស្រី ហ៊ុន ចាន់ប៊ី | ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៦ | បណ្ឌិត Ardisak Boeprasert | ប្រធានផ្នែកទំនាក់ទំនងវិនិយោគិន និងបង្ហាញព័ត៌មាន | | | |
| ៧ | លោក Fong Nee Wai | នាយកផ្នែកហិរញ្ញវត្ថុ | | | |
| ៨ | លោក ស៊ុន សាមឿន | ប្រធានផ្នែកធនធានមនុស្ស | កម្មវិធីគ្រប់គ្រងជាន់ខ្ពស់ស្តីពីទំនាក់ទំនងវិជ្ជាជីវៈ និងការគ្រប់គ្រងធនធានមនុស្ស | ៣-១៤ តុលា ២០១៦ | Overseas Human Resources and Industry Development Association (HIDA). ប្រទេសជប៉ុន |
| ៩ | លោក ស៊ុន សាមឿន | ប្រធានផ្នែកធនធានមនុស្ស | ប្រកាសអំពីការបង្ហាញព័ត៌មានក្រុមហ៊ុន | ១៧ តុលា ២០១៦ | គណៈកម្មការមូលបត្រកម្ពុជា |
| ១០ | លោក លាង តារា | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | | | |
| ១១ | អ្នកស្រី ហ៊ុន ចាន់ប៊ី | ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ១២ | លោក Ardisak Boepraser | ផ្នែកទំនាក់ទំនង វិនិយោគិន និងបង្ហាញព័ត៌មាន | | | |
| ១៣ | អ្នកស្រី ហ៊ុន ចាន់ប៊ី | ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ | សិក្ខាសាលាស្តីពីការបង់ពន្ធ | ២៩ វិច្ឆិកា ២០១៦ | Transparency International Cambodia |
| ១៤ | លោក Ardisak Boepraser | ប្រធានផ្នែកទំនាក់ទំនងវិនិយោគិន និងបង្ហាញព័ត៌មាន | ការបណ្តុះបណ្តាលស្តីពីគាតព្វកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយក្នុងការរៀបចំបញ្ជិកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ | ១៥ធ្នូ២០១៦ | គណៈកម្មការមូលបត្រកម្ពុជា |
| ១៥ | អ្នកស្រី ហ៊ុន ចាន់ប៊ី | ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ | វឌ្ឍនភាពនៃការកំណែទម្រង់រដ្ឋបាល និងគោលនយោបាយស្តីពីពន្ធដារ | ១៦ ធ្នូ២០១៦ | អគ្គនាយកដ្ឋានពន្ធដារ |
| ១៦ | លោក ស៊ុន សាមឿន | ប្រធានផ្នែកធនធានមនុស្ស | គោលនយោបាយជាតិស្តីពី TVET ២០១៧-២០២៥ | ២០ ធ្នូ២០១៦ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

## ៣.៥. ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

សម្រាប់ឆ្នាំ២០១៦ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី មិនមានជាប់ពាក់ព័ន្ធក្នុងដំណើរការផ្លូវច្បាប់នោះទេ។

## ៣.៦. លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក. ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការដែលទទួលបាន

នៅក្នុងឆ្នាំ២០១៦ លាភការជាមធ្យម និងអត្ថប្រយោជន៍ ប្រមាណ ៤.១៦៩.៣១២.៨៧០រៀល ក្នុងម្នាក់។ លាភការឆ្នាំ២០១៦ និងអត្ថប្រយោជន៍ ដែលរួមបញ្ចូលទាំងប្រាក់បៀវត្សរ៍ ប្រាក់បំណាច់ ប្រាក់ដំឡើង ថ្លៃលាភការសរុប និងអត្ថប្រយោជន៍ ត្រូវបានបង់ទៅឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ សម្រាប់សេវារបស់ពួកគាត់ ផ្តល់ទៅឱ្យក្រុមហ៊ុនរបស់យើងតាមភារកិច្ចរបស់ពួកគាត់ សរុបទាំងអស់គឺ ២៣១.៦២៨.៤៩៣រៀល ។ ឈ្នួល ក៏ដូចជាប្រាក់បំណាច់ផ្សេងៗ (មិនរួមបញ្ចូលការទទួលបានអត្ថប្រយោជន៍ពីការចូលនិវត្តន៍) ត្រូវបានបង់ដូចខាងក្រោម៖

**អភិបាល**

| ល.រ | ឈ្មោះរបស់អភិបាល | តំណែង | ចំណាត់ថ្នាក់លាភការ |
|---|---|---|---|
| ១ | លោកជំទាវឧកញ៉ា លឹម ឈីវហូ | ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ | ក |
| ២ | លោក Hiroshi Uematsu | អភិបាលប្រតិបត្តិ | ខ |
| ៣ | លោក តាន់ កាក់យុន | អភិបាលមិនប្រតិបត្តិ | ឃ |
| ៤ | លោកស្រី តាន់ សឺយមួយ | អភិបាលមិនប្រតិបត្តិ | ឃ |
| ៥ | លោក Hiroshi Otsubo | អភិបាលមិនប្រតិបត្តិ | ឃ |
| ៦ | លោក Kenji Toyota | អភិបាលមិនប្រតិបត្តិ | ឃ |
| ៧ | លោក Kang Wei Geih | អភិបាលឯករាជ្យ | ឃ |
| ៨ | លោក Tanate Piriyothinkul | អភិបាលឯករាជ្យ | ឃ |
| ៩ | លោក ហែម សុវត្ថិ | អភិបាលមិនប្រតិបត្តិ | ឃ |

**បុគ្គលិកជាន់ខ្ពស់**

| ល.រ | ឈ្មោះរបស់បុគ្គលិកជាន់ខ្ពស់ | តំណែង | ចំណាត់ថ្នាក់លាភការ |
|---|---|---|---|
| ១ | លោក Fong Nee Wai | នាយកផ្នែកហិរញ្ញវត្ថុ | ខ |
| ២ | លោក លាង តារា | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | ឃ |
| ៣ | លោក Kenchi Yoshida | ប្រធានវិស្វករ/ប្រធានផ្នែកវិស្វកម្ម | គ |
| ៤ | លោកស្រី Zhao Minqian | អ្នកគ្រប់គ្រងជាន់ខ្ពស់/ប្រធានផ្នែកលក់និងទីផ្សារ និងសេវាអតិថិជន | គ |
| ៥ | លោក ស៊ុន សាមឿន | អ្នកគ្រប់គ្រងជាន់ខ្ពស់/ប្រធានផ្នែកធនធានមនុស្ស | ឃ |
| ៦ | លោកស្រី ហ៊ុន ចាន់ប៉ី | អ្នកគ្រប់គ្រងជាន់ខ្ពស់/ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ | ឃ |
| ៧ | លោក Susumu Nagaoka | អ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្នែកសេវាអតិថិជន | គ |
| ៨ | បណ្ឌិត Ardisak Boeprasert | ប្រធានផ្នែកទំនាក់ទំនងវិនិយោគិន/មន្ត្រីផ្នែកផ្តល់ព័ត៌មាន | ឃ |

សម្គាល់៖

ចំណាត់ថ្នាក់លាភការ ត្រូវបានបែងចែកដូចខាងក្រោមៈ

- ចំណាត់ថ្នាក់ "ក": ចំនួនលាភការចាប់ពី ៦០០.០០០.០០១ រៀលឡើងទៅនៅក្នុងឆ្នាំ២០១៦
- ចំណាត់ថ្នាក់ "ខ": ចំនួនលាភការចាប់ពី ៤០០.០០០.០០១ រៀល ទៅ ៦០០.០០០.០០រៀល នៅក្នុងឆ្នាំ ២០១៦
- ចំណាត់ថ្នាក់ "គ": ចំនួនលាភការចាប់ពី ២០០.០០០.០០១ រៀល ទៅ ៤០០.០០០.០០រៀល នៅក្នុងឆ្នាំ ២០១៦
- ចំណាត់ថ្នាក់ "ឃ": ចំនួនលាភការក្រោម ២០០.០០០.០០០ រៀលនៅក្នុងឆ្នាំ ២០១៦

### ខ. ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ

នៅក្នុងឆ្នាំ២០១៦ លាភការសរុប និងអត្ថប្រយោជន៍ត្រូវបានផ្តល់ជូន អភិបាលមិនប្រតិបត្តិ សម្រាប់ សេវារបស់ពួកគាត់ ដែលបានផ្តល់ឱ្យក្រុមហ៊ុនរបស់យើងតាមភារកិច្ច សរុបទាំងអស់ គឺ ១.៦០៣.៩៨៤.០០០ រៀល ។

### គ. ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់

នៅក្នុង ឆ្នាំ ២០១៦ លាភការសរុប និងអត្ថប្រយោជន៍ ត្រូវបានបង់ទៅឱ្យនាយក និងបុគ្គលិកជាន់ខ្ពស់ សម្រាប់សេវារបស់ពួកគាត់ ផ្តល់ទៅឱ្យក្រុមហ៊ុនរបស់យើងតាមភារកិច្ចរបស់ពួកគាត់ សរុបទាំងអស់គឺ ២.០៤១.៥៣៣.០០០ រៀល និង ២.១២៧.៧៧៩.៨៧០ រៀល។

### ឃ. ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់

យើងប្រមើលមើល លាភការសរុប និងអត្ថប្រយោជន៍ ត្រូវបានបង់ទៅឱ្យនាយក និងបុគ្គលិកជាន់ខ្ពស់ សម្រាប់សេវារបស់ពួកគាត់ ផ្តល់ទៅឱ្យក្រុមហ៊ុនរបស់យើងក្នុងត្រីមាសបន្ទាប់ នឹងមានចំនួនប្រមាណ ៤.៤០០.០០០.០០០ រៀល ។

### ង. ការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ របស់ក្រុមហ៊ុននៅក្នុងឆ្នាំសារពើពន្ធ ឬអនាគត

យើងប្រមើលមើលថា នឹងមិនមានការកើនឡើងក្នុងលាភការសរុប និងអត្ថប្រយោជន៍ត្រូវបានបង់ទៅឱ្យនាយក និង បុគ្គលិកជាន់ខ្ពស់ សម្រាប់សេវារបស់ពួកគាត់ ផ្តល់ទៅឱ្យក្រុមហ៊ុនរបស់យើងក្នុងឆ្នាំបន្ទាប់នោះទេ ។

## ៣.៧. ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក. គោលការណ៍នៃក្រមសីលធម៌

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មានបំណងឱ្យក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ("ក្រុមហ៊ុន") ក្លាយជាស្ថាប័នមួយ ដែលមានប្រសិទ្ធភាពក្នុងការធ្វើធុរកិច្ចរបស់ខ្លួន ដោយអនុលោមយ៉ាងពេញលេញទៅតាមគោលការណ៍អភិបាលកិច្ចល្អផ្នែកសាជីវកម្ម ក្នុងគោលបំណងបង្កើតអត្ថប្រយោជន៍ជាអតិបរមាសម្រាប់ភាគហ៊ុននិក តាមរយៈការគិតគូរទៅលើ អត្ថប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់ រួមជាមួយគោលការណ៍សីលធម៌ល្អ ដោយមានតម្លាភាព និងគណនីយភាពពេញលេញ។

ហេតុដូចនេះ ក្រុមហ៊ុនបានបង្កើតនូវគោលនយោបាយស្តីពី អភិបាលកិច្ចល្អផ្នែកសាជីវកម្មដូចខាងក្រោមសម្រាប់ប្រើប្រាស់ជាគោលការណ៍ប្រតិបត្តិ ដែលត្រូវអនុវត្តយ៉ាងតឹងរឹងដោយក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន។

PHNOM PENH SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

១. ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន មានកាតព្វកិច្ចប្តេជ្ញាចិត្តក្នុងការអនុម័ត និងអនុវត្ត “គោលការណ៍ជាមូលដ្ឋានទាំង៥ នៃអភិបាលកិច្ចល្អផ្នែកសាជីវកម្ម ដែលត្រូវបានកំណត់ដោយ “អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច” (OECD) ក្នុងការបំពេញការទទួលខុសត្រូវរបស់ពួកគេ៖

ក. សិទ្ធិរបស់ភាគីពាក់ព័ន្ធ

ខ. ការអនុវត្តដោយស្មើភាពគ្នាចំពោះភាគហ៊ុនិកទាំងអស់

គ. តួនាទីរបស់ភាគីពាក់ព័ន្ធ

ឃ. ការបង្ហាញព័ត៌មាន និងតម្លាភាព

ង. ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

២. ក្រុមប្រឹក្សាភិបាលក្រុមហ៊ុននឹងគ្រប់គ្រង និងមើលការខុសត្រូវក្រុមហ៊ុនក្នុងការធ្វើ ធុរកិច្ចរបស់ខ្លួនសម្រាប់ជាអត្ថប្រយោជន៍អតិបរមារបស់ភាគហ៊ុនិក (ពោលគឺភារកិច្ចកាន់ តំណែង ជាទីទំនុកចិត្ត) តាមរយៈការប្រកាន់ខ្ជាប់គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ ប្រតិបត្តិទាំងនេះ៖

ក. ការបំពេញភារកិច្ចដោយការយកចិត្តទុកដាក់ (ភារកិច្ចយកចិត្តទុកដាក់)

ខ. ការបំពេញភារកិច្ច ដោយភាពស្មោះត្រង់ និង សច្ចភាព (ភារកិច្ចស្មោះត្រង់)

គ. ការបំពេញភារកិច្ច ដោយអនុលោមតាមច្បាប់ជាធរមាន ព្រមទាំងដូចដែលមានចែងក្នុង កម្មវត្ថុអាជីវកម្ម និងលក្ខខន្តិកៈរបស់ក្រុមហ៊ុន និងសេចក្តីសម្រេចមហាសន្និបាតភាគហ៊ុនិកទាំងអស់ (ភារកិច្ចស្តាប់បង្គាប់)។

ឃ.ការបង្ហាញព័ត៌មានជូនទៅភាគហ៊ុនិកដោយត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងពោរពេញដោយ តម្លាភាព (ភារកិច្ចបង្ហាញព័ត៌មាន)។

៣. ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ប្តេជ្ញាចិត្តយ៉ាងមុតមាំប្រឹងប្រែងអនុវត្តឱ្យបានល្អបំផុតនូវ គោលការណ៍អភិបាលកិច្ចសាជីវកម្មដែលក្រុមហ៊ុនបានបង្កើតឡើង ព្រមទាំងគោលការណ៍ប្រតិបត្តិ ដែលពាក់ព័ន្ធនឹងគោលការណ៍និងក្រមសីលធម៌ល្អក្នុងការធ្វើធុរកិច្ច រួមជាមួយនឹងការប្រព្រឹត្តសីលធម៌ល្អរបស់ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ក្នុងការបំពេញភារកិច្ច និងការទទួលខុសត្រូវរបស់ពួកគេ។

៤. ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន នឹងប្តេជ្ញាចិត្តចំពោះគោលការណ៍សមធម៌ ដោយអនុវត្តស្មើគ្នាចំពោះក្រុមភាគហ៊ុនិក ដោយការយកចិត្តទុកដាក់ព្រមទាំងពិនិត្យមើលនូវការសម្រេចចិត្តរបស់ពួកគេទាំងអស់ រួមទាំងសកម្មភាពពាក់ព័ន្ធនានាដើម្បីចៀសវាងកុំឱ្យកើតមានវិវាទផលប្រយោជន៍ណាមួយ។

៥. ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន នឹងទទួលខុសត្រូវរៀងៗខ្លួន ដោយប្រុងប្រយ័ត្ន ដោយភាពស្មោះត្រង់ និងសច្ចភាព ព្រមទាំងអនុលោមដោយពេញលេញទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់និងបទប្បញ្ញត្តិដែលប្រកាសជាធរមាន និងបទប្បញ្ញត្តិរបស់ក្រុមហ៊ុនផងដែរ។

៦. ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ប្តេជ្ញាចិត្តក្នុងការបំពេញភារកិច្ច និងការទទួលខុសត្រូវរៀងៗខ្លួន ដោយលក្ខណៈស្មោះត្រង់ ស្មើភាព និងដោយការទទួលខុសត្រូវខ្ពស់។

៧. ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ទទួលស្គាល់ និងគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ភាគហ៊ុនិក ថាជាម្ចាស់ក្រុមហ៊ុនពិតប្រាកដ ព្រមទាំងដោយអនុវត្តដោយស្មើគ្នាចំពោះភាគហ៊ុនិក តាមរយៈការបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុដែលពាក់ព័ន្ធ ដោយត្រឹមត្រូវ ទាន់ពេលវេលា និងដោយជឿទុកចិត្តបាន។ ការធ្វើដូចនេះគឺដើម្បីឱ្យភាគហ៊ុនិក វិនិយោគិន ភាគីពាក់ព័ន្ធក្រុមហ៊ុនទាំងអស់ នឹងទទួលបានព័ត៌មាន និងការទំនាក់ទំនងគ្រប់គ្រាន់ ដោយមូលដ្ឋានស្មើភាពគ្នា។

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

៨. ក្រុមប្រឹក្សាភិបាល បានជ្រើសរើសយកការទំនាក់ទំនងតាមប្រភពផ្សេងៗ សម្រាប់ប្រើប្រាស់ដោយភាគហ៊ុនិក វិនិយោគិន និងអាជ្ញាធរប្រតិបត្តិផ្សេងៗ រួមជាមួយការធ្វើទំនាក់ទំនង ឬការបង្ហាញព័ត៌មានពាក់ព័ន្ធនានាដែលតម្រូវ ជូនទៅដល់ភាគីដែលចាប់អារម្មណ៍ និង ភាគីពាក់ព័ន្ធ។

៩. ក្រុមប្រឹក្សាភិបាល បានកំណត់ការអនុវត្តរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុន ដោយមានការអនុញ្ញាតពី អាជ្ញាធរពាក់ព័ន្ធដែលកំណត់យ៉ាងច្បាស់លាស់ ព្រមទាំងទំហំនៃការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង បុគ្គលិកជាន់ខ្ពស់។

១០. ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវចំពោះសកម្មភាពបង្កើតនូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងនីតិវិធីគ្រប់គ្រងហានិភ័យ ដែលសមរម្យ និងត្រឹមត្រូវ ជាមួយប្រព័ន្ធគណនី និងនីតិវិធីធ្វើរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រឹមត្រូវនិងអាចជឿទុកចិត្តបាន។

១១. ក្រុមប្រឹក្សាភិបាល បានកំណត់នូវគោលនយោបាយផ្សេងៗ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ/ការអនុវត្តដោយក្លែងបន្លំ ការមិនរំលោភបំពានកម្មសិទ្ធិបញ្ញា និងការគោរពច្បាប់និងសិទ្ធិមនុស្សនានា។

### ខ-ការអនុវត្តក្រមសីលធម៌

នៅក្នុងឆ្នាំ២០១៦ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនអនុវត្តទៅតាមក្រមសីលធម៌ដែលបានបញ្ជាក់ពីខាងដើម។

## ៣.៨. សិទ្ធិភាគីពាក់ព័ន្ធ

### ក-យន្តការការពារសិទ្ធិ

ក្រៅពីលើកឡើងពីខាងដើម នៅក្នុង គោលការណ៍នៃក្រមសីលធម៌ ក្រុមហ៊ុនទទួលស្គាល់ពីសារសំខាន់នៃសិទ្ធិរបស់ភាគីពាក់ព័ន្ធ និងធានាឱ្យមានការអនុវត្តដោយស្មើភាពគ្នា ចំពោះបណ្ដាភាគីពាក់ព័ន្ធទាំងអស់ ដោយមានសេចក្ដីលម្អិតដូចខាងក្រោម៖

#### ១. ភាគហ៊ុនិក

ក្រុមហ៊ុន ប្ដេជ្ញាចិត្តធ្វើជាអ្នកតំណាងដ៏ល្អរបស់ភាគហ៊ុនិក ក្នុងប្រតិបត្តិការធុរកិច្ចរបស់ខ្លួន ដើម្បីធ្វើឱ្យប្រាកដថា ភាគហ៊ុនិកមានការបំពេញចិត្តជាខ្លាំង ដោយគិតគូរអំពីការរីកចម្រើនរយៈពេលវែងរបស់ក្រុមហ៊ុនជាមួយនឹងផលតបស្នងល្អ និងមានស្ថេរភាព រួមទាំងការបង្ហាញព័ត៌មានប្រកបដោយតម្លាភាព និងអាចជឿទុកចិត្តបាន ជូនទៅភាគហ៊ុនិក។

#### ២. បុគ្គលិក

ក្រុមហ៊ុន ចាត់ទុកបុគ្គលិករបស់ខ្លួនទាំងអស់ ជាបុគ្គលសំខាន់ និងជាចំណែកក្នុងការជួយអភិវឌ្ឍធុរកិច្ចរបស់ក្រុមហ៊ុន ឆ្ពោះទៅកាន់អនាគត។ ហេតុនេះ ក្រុមហ៊ុនផ្ដោតលើការបន្តអភិវឌ្ឍគុណវុឌ្ឍិ ចំណេះដឹង សមត្ថភាព និងជំនាញរបស់បុគ្គលិក។ ក្រុមហ៊ុន បង្កើតនូវគោលនយោបាយលើការផ្ដល់ប្រាក់រង្វាន់ជូនដល់បុគ្គលិក ផ្អែកទៅលើលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន និងអត្រានៃការផ្ដល់ប្រាក់រង្វាន់ជាមធ្យមសម្រាប់បុគ្គលិក ដោយផ្អែកទៅលើកម្រិតប្រហាក់ប្រហែលនៃទីផ្សារ ដែលត្រូវពិនិត្យឡើងវិញជាប្រចាំឆ្នាំ រួមជាមួយលក្ខខណ្ឌនៃចំណេះដឹង និងសមត្ថភាពរបស់បុគ្គលិកម្នាក់ៗ។ ក្រុមហ៊ុន ថែមទាំងផ្ដល់នូវបរិយាកាសការងារ ដែលធានាដល់គុណភាពនៃការរស់នៅ និងសុវត្ថិភាពការងារ។ ក្រុមហ៊ុនចាត់ទុកបុគ្គលិកទាំងអស់ដោយស្មើភាព និង យុត្តិធម៌។ ក្នុងន័យនេះ ក្រុមហ៊ុនទទួលខុសត្រូវ ថែរក្សាជាប្រក្រតីនូវបរិយាកាសការងារ ដើម្បីធានាថាសុវត្ថិភាពនៃការរស់នៅ និងទ្រព្យសម្បត្តិរបស់បុគ្គលិកនីមួយៗ ហើយនិងគោរពតាមបទប្បញ្ញត្តិច្បាប់ការងារដោយតឹងរឹង។ ក្រុមហ៊ុន គោរពសិទ្ធិឯកជនរបស់បុគ្គលិក ដោយទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ ដូចជា ប្រាក់បៀវត្សរ៍ កំណត់ត្រាព្យាបាលជំងឺ ជីវប្រវត្តិគ្រួសារ នឹងមិនត្រូវបង្ហាញទៅភាគីទីបី ឬបុគ្គលមិនពាក់ព័ន្ធឡើយ លើកលែងតែ ព័ត៌មានដែលចាំបាច់តម្រូវឱ្យបង្ហាញទៅភាគីទីបីដែលពាក់ព័ន្ធស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់។

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

### ៣. អតិថិជន/ ដៃគូអាជីវកម្ម

ក្រុមហ៊ុន បន្តអភិវឌ្ឍភាពជាដៃគូធុរកិច្ច លើមូលដ្ឋានយុត្តិធម៌ និងដោយការគោរពគ្នាទៅវិញទៅមក។ ក្រុមហ៊ុនខិតខំប្រឹងប្រែងយកចិត្តទុកដាក់ទៅលើ អតិថិជន និងដៃគូធុរកិច្ចទាំងអស់ អនុលោមទៅតាម កិច្ចព្រមព្រៀងពាណិជ្ជកម្ម/កិច្ចព្រមព្រៀងភាពជាដៃគូ ហើយចៀសវាងភាពមិនស្មោះត្រង់ណាមួយ ដែលធ្វើឱ្យបាត់បង់កិត្តិយសដល់ក្រុមហ៊ុនខ្លួនឯង។

### ៤. សហគមន៍ និងសង្គម

ក្រុមហ៊ុន ជាស្ថាប័នមួយមានសញ្ជាតិខ្មែរ សូមសម្តែងការដឹងគុណចំពោះប្រទេសជាតិ ក្នុងនាមជាសមាជិកទទួលខុសត្រូវមួយនៃសង្គម និង ផ្តល់ការឧបត្ថម្ភ និងគាំទ្រដល់សង្គមចំពោះសកម្មភាពក្នុងសហគមន៍ ដែល ខ្លួនធ្វើប្រតិបត្តិការធុរកិច្ច។ ក្រុមហ៊ុន ពិតជាមានការព្រួយបារម្ភអំពីផលប៉ះពាល់បរិស្ថាន ដោយជួយលើកកម្ពស់ឱ្យមានការយល់ដឹងអំពីការទទួលខុសត្រូវរបស់ក្រុមហ៊ុន ចំពោះសហគមន៍ និងសង្គម ព្រមទាំងផ្តល់ការគាំទ្រដល់សកម្មភាពដែលមានប្រយោជន៍សម្រាប់សាធារណជន និងចៀសវាងពីការពាក់ព័ន្ធសកម្មភាពខុសច្បាប់ផ្សេងៗ។

## ខ-សកម្មភាពនៃការការពារសិទ្ធិ

ឆ្នាំ២០១៦ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនអនុវត្តដោយផ្អែកលើសិទ្ធិរបស់ភាគីពាក់ព័ន្ធ។

# ផ្នែកទី ៤: បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ និង ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន

## ១- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| ចាប់ពី ៣០ % ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១ | ៣២.៩១០.០០០ | ៥៦.០០% |
| | | នីតិបុគ្គល | - | - | - |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |

## ២- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| ចាប់ពី ០៥%ដល់តិចជាង ៣០ % | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | ២ | ១៦.៨២៤.២៥៩ | ២៩.០៧% |

# ផ្នែកទី ៥: ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ

## ៥.១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

ឈ្មោះមូលបត្រកម្មសិទ្ធិ: ភាគហ៊ុនធម្មតា
អក្សរកូដមូលបត្រកម្មសិទ្ធិ: KH1000050000
ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ: មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: ២.០០០ រៀល
ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: ២.៨៦០ រៀល
បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: ៥៧.៨៧៥.០០០ មូលបត្រ
មូលធនូបនីយកម្មទីផ្សារ: ១៦៥.៥២២.៥០០.០០០ រៀល
ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត: ផ្សារមូលបត្រកម្ពុជា (ផ.ម.ក)
កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ: ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦

## ៥.២. ថ្លៃ និងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធិ | | មករា ២០១៦ | កុម្ភៈ ២០១៦ | មីនា ២០១៦ | មេសា ២០១៦ | ឧសភា ២០១៦ | មិថុនា ២០១៦ | កក្កដា ២០១៦ | សីហា ២០១៦ | កញ្ញា ២០១៦ | តុលា ២០១៦ | វិច្ឆិកា ២០១៦ | ធ្នូ ២០១៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (គិតជារៀល) | អតិបរមា | គ្មាន | គ្មាន | គ្មាន | គ្មាន | ២.៨៩០ | ២.៨៩០ | ២.៧៨០ | ២.៨៦០ | ២.៧៤០ | ២.៧៣០ | ២.៧៥០ | ២.៩២០ |
| | មធ្យម | គ្មាន | គ្មាន | គ្មាន | គ្មាន | ២.៨៩០ | ២.៧៦២ | ២.៦៤៩ | ២.៦៦៩ | ២.៦៨៥ | ២.៦៩៤ | ២.៦៥៩ | ២.៧២០ |
| | អប្បបរមា | គ្មាន | គ្មាន | គ្មាន | គ្មាន | ២.៨៩០ | ២.៤៩០ | ២.៥៣០ | ២.៦៤០ | ២.៦៥០ | ២.៦០០ | ២.៦០០ | ២.៥៦០ |
| បរិមាណជួញដូរ (គិតជាចំនួនភាគហ៊ុន) | អតិបរមា | គ្មាន | គ្មាន | គ្មាន | គ្មាន | ២៤.០៧៨ | ៥៥.១០៧ | ១០.០០០ | ១៦២.៦៩០ | ១០.០០០ | ៨២.៨០០ | ១.០០០ | ២៥.២១០ |
| | មធ្យម | គ្មាន | គ្មាន | គ្មាន | គ្មាន | ១២.២៨៩ | ៧.៣៧២ | ៣.០២០ | ៨.៥២០ | ១.៥៨០ | ៨.០៩៧ | ១២០ | ២.៨៧៧ |
| | អប្បបរមា | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥០០ | ០ | ០ | ០ | ០ | ០ | ០ | ០ |

# ផ្នែកទី ៦៖ របាយការណ៍សវនកម្មរបស់ សវនកម្មផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៦

## ១. សេចក្តីផ្តើម

ក្រុមហ៊ុនរួម មានធនធានគ្រប់គ្រាន់នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងមួយ ដើម្បីជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការរក្សាបាននូវភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ("នាយកដ្ឋាន") ត្រូវរាយការណ៍ទៅគណៈកម្មាធិការសវនកម្ម ហើយត្រូវមានភាពឯករាជ្យនៃរាល់សកម្មភាពដែលបានធ្វើសវនកម្ម។

## ២. គោលដៅ និង វិសាលភាពសវនកម្ម

តួនាទីរបស់នាយកដ្ឋាននេះ គឺអនុវត្តការត្រួតពិនិត្យជាទៀងទាត់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដូច្នេះដើម្បីផ្តល់នូវភាពប្រាកដជាក់លាក់ថា ការបង្កើតប្រព័ន្ធត្រួតពិនិត្យ គោលនយោបាយ និងនីតិវិធី គឺមានប្រសិទ្ធភាព និងអនុលោមតាម។

វិសាលភាពនៃការអនុវត្តសវនកម្មផ្ទៃក្នុងលើព័ត៌មានហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ក្រុមហ៊ុនគឺៈ

- វាយតម្លៃលើភាពអាចជឿទុកចិត្តបាន សុចរិតភាព និងភាពសមនឹងពេលវេលានៃព័ត៌មានសំខាន់ៗ ផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រង និងប្រតិបត្តិការ និងភាពគ្រប់គ្រាន់នៃការត្រួតពិនិត្យផ្ទៃក្នុងប្រើសំរាប់ការបកស្រាយ និងការរាយការណ៍នៃព័ត៌មានទាំងនេះ។
- ធានាលើការអនុលោមទៅតាមគោលនយោបាយ នីតិវិធី បទដ្ឋាន ច្បាប់ និងបទប្បញ្ញត្តិ។
- វាយតម្លៃលើការចាត់វិធានការដើម្បីការពារទ្រព្យសម្បត្តិ រួមបញ្ចូលទាំងការធ្វើតេស្តនៃភាពកើតមាន និងកម្មសិទ្ធិ។
- វាយតម្លៃថាតើ ធនធានរបស់ក្រុមហ៊ុនកំពុងត្រូវបានគ្រប់គ្រងនៅក្នុងលក្ខណៈសន្សំសំចៃ និងប្រកបដោយប្រសិទ្ធិភាព។

## ៣. សង្ខេបនៃការអនុវត្តន៍ការងារសវនកម្ម

ផែនការនៃការងារសវនកម្មផ្ទៃក្នុង ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ដោយអនុលោមតាមកាលវិភាគដែលបានព្រមព្រៀងជាមួយគណៈកម្មាធិការសវនកម្ម។ របាយការណ៍វឌ្ឍនភាពសវនកម្មជាទៀងទាត់ ត្រូវបានដាក់ជូនទៅគណៈកម្មាធិការសវនកម្មក្នុងអំឡុងឆ្នាំ ២០១៦ មានដូចខាងក្រោមនេះ។

| ល.រ | ក្រុមហ៊ុន / នាយកដ្ឋាន | ចំនួននៃរបាយការណ៍ | ចំនួននៃបញ្ហារកឃើញ | ចំនួននៃបញ្ហាដែលបានកែតម្រូវ |
|---|---|---|---|---|
| ១ | ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី | | | |

| | | | | |
|---|---|---|---|---|
| | ក. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | ៣ | ២០ | ១៦ |
| | ខ. នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល | ២ | ៩ | ៧ |
| | គ. នាយកដ្ឋានប្រតិបត្តិការ និងគំពោង | ២ | ១២ | ៦ |
| ២ | ក្រុមហ៊ុនសហ័ស ភីភីអេសអ៊ីហ្សិត ខូអិលធីឌី | ២ | ១១ | ១០ |
| ៣ | ក្រុមហ៊ុនប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ខូអិលធីឌី | ១ | ៨ | ៦ |

ការងារសវនកម្មផ្ទៃក្នុង បានយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើហានិភ័យនៃយុទ្ធសាស្ត្រ និងប្រតិបត្តិការ។ លទ្ធផលនៃការធ្វើសវនកម្មត្រួតពិនិត្យទាំងនេះ អាចបង្ហាញពីភាពទន់ខ្សោយនៃប្រព័ន្ធត្រួតពិនិត្យ ដែលអាចប៉ះពាល់លើប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។

សរុបជារួមមក យើងមានទំនុកចិត្តថា អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ និងការវាយតម្លៃនៃការត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរចនាឡើង និងអនុវត្តយ៉ាងមានប្រសិទ្ធិភាព ក្នុងដែនធានាដូចខាងក្រោម៖

- អភិបាលកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ
- ប្រតិបត្តិការនៃការផ្តល់សេវា និងមុខងារនៃការគ្រប់គ្រង
- ការគ្រប់គ្រងមូលធន និងទ្រព្យ
- អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ និងការអនុលោមតាមបទប្បញ្ញត្តិ
- ការធ្វើផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងលើការអនុវត្ត និងការធ្វើរបាយការណ៍

**ប្រធានគណៈកម្មាធិការសវនកម្ម**

លោក Kang Wei Geih

ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៧

**ប្រធានសវនកម្មផ្ទៃក្នុង**

លោក លាង តារា

ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៧

# ផ្នែកទី ៧: របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

លេខបញ្ជីពាណិជ្ជកម្ម៖
INV - ១០៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
# ( ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា )

# របាយការណ៍ហិរញ្ញវត្ថុ និង
# របាយការណ៍របស់សវនករឯករាជ្យ
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

(របាយការណ៍ជាភាសាខ្មែរនេះត្រូវបានបកប្រែចេញពីរបាយការណ៍ភាសាអង់គ្លេស។
ប្រសិនបើការបកប្រែមានភាពខុសគ្នានឹងរបាយការណ៍ជាភាសាអង់គ្លេស សូមយករបាយការណ៍ជាភាសាអង់គ្លេសជាគោល។)

លេខបញ្ជីពាណិជ្ជកម្ម៖
INV - ១០៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមប្រឹក្សាភិបាល | លោកជំទាវ ឧកញ៉ា លីម ឈីវហូរ<br>(Lok Chumteav Oknha Lim Chhiv Ho)<br>លោក ហ៊ីរ៉ូហ្ស៊ី អ៊ូម៉ាស៊ឹក (Hiroshi Uematsu)<br>លោក តាន់ កាក់ ឃុន (Tan Kak Khun)<br>លោកស្រី តាន់ សឿនមួយ (Tan Soeun Muoy)<br>លោក ហ៊ីរ៉ូហ្ស៊ី អ៊ូតស៊ូប៊ូ (Hiroshi Otsubo)<br>លោក ខេនជី តូយូតា (Kenji Toyota)<br>លោក ហែម សុវត្ថិ (Hem Sovath)<br>លោក កាំង វេយកេយ (Kang Wei Geih)<br>លោក ថាណេត ភិរីយុទ្ធិនកុល (Tanate Piriyuthinkul) |
| ទីស្នាក់ការ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ<br>ផ្លូវជាតិលេខ៤<br>សង្កាត់កន្ទោក<br>ខណ្ឌពោធិ៍សែនជ័យ<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ធនាគារ | ធនាគារ កម្ពុជាសាធារណៈ<br>ធនាគារ អេ អិន ហ្សិត រ៉ូយ៉ាល់<br>ធនាគារ មេយប៊ែង កម្ពុជា<br>ធនាគារ ភ្នំពេញ ពាណិជ្ជ<br>ធនាគារ មេហ្គា ពាណិជ្ជ<br>ធនាគារ អេស៊ីលីដា<br>ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី<br>ធនាគារ កាណាឌីយ៉ា ក.អ |
| សវនករ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត |

លេខបញ្ជីពាណិជ្ជកម្មៈ
INV - ១០៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**មាតិកា** ទំព័រ


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៥ |
| សេចក្តីរាយការណ៍របស់សវនករឯករាជ្យ | ៦ - ១០ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១១ - ១៣ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗ | ១៤ |
| របាយការណ៍បម្រែបម្រួលមូលធន | ១៥ - ១៦ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៧ - ១៩ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ២០ - ៧១ |

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួនដោយមាន ភ្ជាប់ជាមួយនូវរបាយការណ៍ប្រចាំឆ្នាំ និង របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺរួមមានការសាងសង់ ការអភិវឌ្ឍន៍ និងដំណើរការ តំបន់សេដ្ឋកិច្ចពិសេសក្នុងរាជធានីភ្នំពេញ និងរួមមានសកម្មភាពពាណិជ្ជកម្មដទៃទៀត។ សកម្មភាពចម្បងរបស់ក្រុមហ៊ុនចំណុះគឺ បានកំណត់នៅក្នុងកំណត់សម្គាល់លេខ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។ នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងៗទាំងនេះទេ។

### លទ្ធផលនៃប្រតិបត្តិការ

| | សម្ព័ន្ធ<br>ដុល្លារអាមេរិក | ក្រុមហ៊ុន<br>ដុល្លារអាមេរិក |
|---|---|---|
| ប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំហិរញ្ញវត្ថុ | ១.៤៤៥.៦៧២ | ១.៥៤៥.៣៣១ |
| *(ពាន់រៀល)* | ៥.៨៣៦.១៧៨ | ៦.២៣៨.៥០១ |

### ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍លើការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធនក្នុងការិយបរិច្ឆេទនេះទេ។

### ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលបំណុលពិបាកទារ និងបំណុលជាប់សង្ស័យ និងការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យ ត្រូវបានធ្វើឡើងហើយក្រុមប្រឹក្សាភិបាលជឿជាក់ថាពុំមានឥណទាន និង បុរេប្រទានអាក្រក់ ហើយពុំមានភាពចាំបាច់ធ្វើសំវិធានធនចំពោះបំណុលដែលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

មកទល់នឹងការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនាំឲ្យឥណទានអាក្រក់ដែលបានជំរះចេញពីបញ្ជីនិង ធ្វើសំវិធានចំពោះបំណុលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុនឡើយ។

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍លទ្ធផល និង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្ដាទ្រព្យសកម្មចរន្តលើកលែងបំណុលចេញ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់សម្ព័ន្ធ និង ក្រុមហ៊ុន ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែងនៅលើទីផ្សារ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និងក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវឡើយ។

### វិធីសាស្ត្រក្នុងការវាយតម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និងរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់សម្ព័ន្ធ និងក្រុមហ៊ុនដែលកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុននោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធ និងក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលនឹង ធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការសងបំណុលរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ ។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅ ក្នុងរបាយការណ៍នេះ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និងក្រុមហ៊ុន ដែលបណ្តាលឲ្យតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនត្រឹមត្រូវនោះទេ។

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់សម្ព័ន្ធ និងក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយដែលមានលក្ខណៈជាសារវន្ត និង មិនប្រក្រតីនោះឡើយ។

ក្រុមប្រឹក្សាភិបាលក៏មានមតិយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះពុំមានកែតម្រូវរាល់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីមានឡើង ដែលអាចនាំឲ្យបះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធ និងក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

### មូលទុនភាគហ៊ុន

ផ្គួបផ្សំជាមួយនឹងការចុះបញ្ជី និងការដាក់តម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន នៅលើផ្សារមូលបត្រកម្ពុជានៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៦ ក្រុមហ៊ុនបានបោះផ្សាយភាគហ៊ុនធម្មតាថ្មីចំនួន ១១.៥៧៥.០០០ ភាគហ៊ុន ដែលមានតម្លៃ ០.៥០ ដុល្លារអាមេរិក ទៅអោយសាធារណៈជន ក្នុងតម្លៃបោះផ្សាយ ២.៨៦០ រៀល ក្នុងមួយភាគហ៊ុន។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុន ក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទហិរញ្ញវត្ថុទេ។

### ព្រឹត្តិការណ៍សំខាន់នៅក្នុងឆ្នាំហិរញ្ញវត្ថុ

ព្រឹត្តិការណ៍សំខាន់ដែលកើតមាននៅក្នុងឆ្នាំហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣១ នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ព្រឹត្តិការណ៍សំខាន់ៗក្រោយការិយបរិច្ឆេទ

ព្រឹត្តិការណ៍សំខាន់ៗដែលកើតមាននៅក្រោយការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣២ នៃរបាយការណ៍ហិរញ្ញវត្ថុ ។

### សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការចាប់តាំងពីថ្ងៃចេញរបាយការណ៍ចុងក្រោយរួមមានៈ

លោកជំទាវ ឧកញ៉ា លីម ឈីវហូរ (Lok Chumteav Oknha Lim Chhiv Ho)

លោក ហ៊ីរ៉ូហ្ស៊ី អ៊ូម៉ាស៊ឹក (Hiroshi Uematsu)

លោក តាន់ កាក់ ឃុន (Tan Kak Khun)

លោកស្រី តាន់ សឿនមួយ (Tan Soeun Muoy)

លោក ហ៊ីរ៉ូហ្ស៊ី អ៊ុតស៊ូប៊ូ (Hiroshi Otsubo)

លោក ខេនជី តូយូតា (Kenji Toyota)

លោក ហែម សុវត្ថិ (Hem Sovath)

លោក កាំង វេយកេយ (Kang Wei Geih)

លោក ថាណេត ភិរីយុទ្ធិនកុល (Tanate Piriyuthinkul) (តែងតាំងថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៦)

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)
### អត្ថប្រយោជន៍របស់អគ្គនាយក

នៅក្នុងអំឡុង និងចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ មិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណា ម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់សម្ព័ន្ធ និងក្រុមហ៊ុនដទៃទៀតនោះទេ។

ចាប់តាំងពីថ្ងៃចុងក្រោយការិយបរិច្ឆេទនៃឆ្នាំកន្លងទៅ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួលឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យា ដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធណាមួយ ជាមួយនឹង ក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែអត្ថប្រយោជន៍ដទៃទៀតដែលអាចកើតឡើងពីប្រតិបត្តិការទាំងនោះ ដូចដែលមានបង្ហាញនៅក្នុងកំណត់សំគាល់ទី២៧នៃរបាយការណ៍ហិរញ្ញវត្ថុ។

### របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈកិច្ចធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវដើម្បីចង្អុល បង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធ និងក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ដំណាច់ឆ្នាំនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

ខ) អនុលោមតាមគោលការណ៍ស្តង់ដារគណនេយ្យកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយ ពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាក ទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព ។

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែ ក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត និង

ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធិភាព លើរាល់សេចក្តីសម្រេចសំខាន់ៗ ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានបង្ហាញត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលអះអាងថា ពួកគាត់បានអនុវត្តតាមនូវរាល់ តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

លេខបញ្ជីពាណិជ្ជកម្ម៖
INV - ១០៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី ១១ ដល់ ៧១ ត្រូវបានរៀបចំ អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និង ភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និង ស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំនេះ ។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សារភិបាល

| | |
|---|---|
| លោកជំទាវ ឧកញ៉ា លីម ឈីវហួរ | លោក ហ៊ីរ៉ូហ្ស៊ី អ៊ុយម៉ាស៊ឹក (Hiroshi Uematsu) |
| ប្រធានក្រុមប្រឹក្សាភិបាល | អគ្គនាយក |

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៧

BDO

Tel: +855 23 218 128
Fax: +855 23 993 225
www.bdo.com.kh

Suite 28 Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia

## របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ INV - ១០៧៦KH/២០០៦)

## សេចក្តីរាយការណ៍លើរបាយការណ៍ហិរញ្ញវត្ថុ

### *មតិយោបល់*

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុន សំរាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុនេះ និង សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញនៅលើទំព័រទី១១ ដល់ ៧១ ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវទិដ្ឋភាពពិត និង ត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធនិង របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និង ស្ថានភាពលំហូរសាច់ប្រាក់របស់សម្ព័ន្ធ និងរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

### *មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់*

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដារនេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ *ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និង សមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

### *ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌*

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយគោរពទៅតាម ក្រមសីលធម៌របស់គណនេយ្យករជំនាញ ("IESBA Code") របស់ក្រុមប្រឹក្សាភិបាលស្តង់ដារក្រមសីលធម៌អន្តរជាតិសំរាប់គណនេយ្យករជំនាញ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌ដទៃទៀតទៅតាម ក្រមសីលធម៌របស់គណនេយ្យករជំនាញនេះផងដែរ។

### *បញ្ហាសវនកម្មសំខាន់ៗ*

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះ យោងតាមការវិនិច្ឆ័យដោយ វិជ្ជាជីវៈរបស់យើងខ្ញុំ។ បញ្ហាទាំងនេះ ត្រូវបានបង្ហាញនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុនទាំងមូល ហើយនៅក្នុងការបង្កើតមតិយោបល់របស់យើងខ្ញុំនាពេលបន្ទាប់ យើងខ្ញុំមិនផ្តល់នូវមតិយោបល់ដាច់ដោយឡែកចំពោះបញ្ហាទាំងនេះឡើយ។

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្មៈ INV - ១០៧៦KH/២០០៦) (ត)

*បញ្ហាសវនកម្មសំខាន់ៗ(ត)*

(ក) **លទ្ធិភាពក្នុងការទទួលបានមកវិញនូវគណនីពាណិជ្ជត្រូវទទួល**

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ គណនីពាណិជ្ជត្រូវទទួលដែលហួសរយៈពេលត្រូវសង ប៉ុន្តែមិនមានឱនភាព មានចំនួន ១.៦២៩.៤៦៧ ដុល្លារអាមេរិក។ មួយផ្នែកធំនៃគណនីពាណិជ្ជនេះ គឺជាជំពាក់ពីក្រុមហ៊ុនញាតិសម្ព័ន្ធ។ ពត៌មាន លម្អិតនៃគណនីពាណិជ្ជ និង ហានិភ័យឥណទាន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ២៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងកំណត់ការខាតបង់ពីឱនភាពនៃគណនីពាណិជ្ជត្រូវទទួល ដោយផ្អែកលើហេតុការណ៍ពិត ឬ កាលទេសៈ ឬលទ្ធភាពក្នុងការសងរបស់អតិថិជន ដែលបានដឹង។

ការកំណត់ថាតើទឹកប្រាក់ដែលត្រូវទទួលអាចស្រង់មកវិញ គឺទាក់ទងនឹងការវិនិច្ឆ័យយ៉ាងសំខាន់របស់គណៈគ្រប់គ្រង ដោយសារតែសារជាតិបំរែបំរួលពាក់ព័ន្ធនឹងការធ្វើវិនិច្ឆ័យនេះ មានទំនាក់ទំនងជាមួយនឹងហានិភ័យឥណទាននៃអតិថិជន ។

ដូច្នេះហើយ យើងខ្ញុំបានធ្វើការពិចារណាថាតើការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងមានភាពសមរម្យ យោងទៅតាមអាយុកាលនៃគណនីពាណិជ្ជត្រូវទទួល នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ។

យើងខ្ញុំក៏ពិចារណាផងដែរលើគោលការណ៍របស់គណៈគ្រប់គ្រង ក្នុងការធ្វើឱនភាពលើគណនីពាណិជ្ជត្រូវទទួលទៅតាមអាយុកាលរបស់វា ហើយថាតើគោលការណ៍ទាំងនេះត្រូវបានអនុវត្តជាប់លាប់ក្នុងរយៈពេលកន្លងទៅនេះឬទេ ។

*ការឆ្លើយតបសវនកម្ម*

យើងខ្ញុំបញ្ជាក់ថា គោលការណ៍របស់គណៈគ្រប់គ្រង ក្នុងការធ្វើឱនភាពលើគណនីពាណិជ្ជត្រូវទទួលទៅតាមអាយុកាលរបស់វា ត្រូវបានអនុវត្តជាប់លាប់នៅក្នុងការិយបរិច្ឆេទ ។ យើងខ្ញុំក៏បានអនុវត្តនូវនិតិវិធីសវនកម្មដូចខាងក្រោម៖

- វាយតម្លៃលើដំណើរការដែលកំពុងអនុវត្តន៍ក្នុងការវាយតម្លៃ និង គ្រប់គ្រងរបស់គណៈគ្រប់គ្រងលើភាពទទួលបានមកវិញនៃគណនីពាណិជ្ជត្រូវទទួល ។
- កំណត់ថាអាយុកាលនៃគណនីពាណិជ្ជ គឺបានបង្ហាញត្រឹមត្រូវ ។
- វាយតម្លៃភស្តុតាងរបស់គណៈគ្រប់គ្រង ដែលថាមិនមានឱនភាពបន្ថែមទៀត ផ្អែកលើការវិភាគលើលទ្ធភាពឥណទាន ប្រវត្តិនៃនិន្នាការទូទាត់សង និង ការរំពឹងទុកនៃការទូទាត់សងរបស់អតិថិជន ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ INV - ១០៧៦KH/២០០៦) (ត)

### ពត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មខាងលើ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានទំនួលខុសត្រូវលើពត៌មានផ្សេងៗ។ ពត៌មានផ្សេងៗរួមមានពត៌មានដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទេ ។

មតិយោបល់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនរួមបញ្ចូលពត៌មានផ្សេងៗ ហើយយើងខ្ញុំនឹងមិនផ្តល់នូវទម្រង់សន្និដ្ឋានជាបែបធានាណាមួយឡើយ ។

ទាក់ទងនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវពត៌មានផ្សេងៗ និងពិចារណាថាតើពត៌មានផ្សេងៗមានភាពមិនសមស្របជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ចំណេះដឹងរបស់យើងខ្ញុំទទួលបានពីសវនកម្ម ឬបើមិនដូច្នោះទេ លេចឡើងមានកំហុសឆ្គងជាសារវន្ត ។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើពត៌មានផ្សេងៗ យើងខ្ញុំតម្រូវឲ្យរាយការណ៍នូវហេតុការណ៍ទាំងនោះ។ យើងខ្ញុំពុំមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ ។

### *ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ*

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និង បង្ហាញនូវទិដ្ឋភាពពិតនិងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសត្រូវក្នុងការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ ដែលអគ្គនាយកកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីកំហុសឆ្គង ជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភ័ន្តច្រឡំ ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលជាអ្នកទទួលការខុសត្រូវក្នុងការវាយតម្លៃទៅលើលទ្ធភាពបន្តប្រតិបត្តិការរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការបង្ហាញប្រសិនជាមាននូវកត្តាដែលពាក់ព័ន្ធនឹងនិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែបអនិរន្តរភាព លុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយ ប៉ុន្តែត្រូវតែធ្វើដូច្នេះ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ INV - ១០៧៦KH/២០០៦) (ត)

*ការទទួលខុសត្រូវរបស់សវនករឯករាជ្យលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ*

គោលបំណងរបស់យើងខ្ញុំ គឺទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និង របស់ក្រុមហ៊ុន ពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍សវនកម្មដែលរួមមាន មតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនបានធានាថា ការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្តពេលដែលវាកើតមានឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានចាត់ទុកជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្គុំ អាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃសវនកម្មអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដោយវិជ្ជាជីវៈ និងរក្សានូវការសង្ស័យដោយវិជ្ជាជីវៈនៅក្នុងសវនកម្មទាំងមូល ។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃលើហានិភ័យកំហុសឆ្គងជាសារវន្តក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់សម្ព័ន្ធនិង របស់ក្រុមហ៊ុន ថាតើវាបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីជាមូលដ្ឋានដល់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនបានរកឃើញនូវកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងហានិភ័យដែលបណ្តាលមកពីការភ័ន្តច្រឡំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬក៏ការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលត្រឹមត្រូវទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបញ្ចេញមតិយោបល់ពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុននោះឡើយ ។
- វាយតម្លៃភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានអនុវត្ត និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន និងកំណត់បង្ហាញដែលពាក់ព័ន្ធដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល ។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ដែលគណៈគ្រប់គ្រងប្រើប្រាស់ និងផ្អែកលើភស្តុតាងដែលទទួលបានថាតើមានភាពមិនប្រាកដប្រជាកើតឡើងជាសារវន្តដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចប៉ះពាល់ដល់លទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាភាពមិនប្រកដប្រជាជាសារវន្តមួយកើតឡើង យើងខ្ញុំត្រូវបានតម្រូវឲ្យទាញការយកចិត្តទុកដាក់ក្នុងរបាយការណ៍សវនកម្ម ភ្ជាប់នឹងការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុន ឬក៏កែប្រែមតិយោបល់របស់យើងខ្ញុំ ប្រសិនបើការបង្ហាញទាំងនោះមិនត្រឹមត្រូវ ។ សេចក្តីសន្និដ្ឋានយើងខ្ញុំ គឺផ្អែកលើភស្តុតាងដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណា ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឲ្យសម្ព័ន្ធ ឬ ក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃដំណើរការអាជីវកម្ម។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ INV - ១០៧៦KH/២០០៦) (ត)

*ការទទួលខុសត្រូវរបស់សវនករឯករាជ្យលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)*

- វាយតម្លៃលើបទបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុន រួមទាំងកំណត់បង្ហាញ ថាតើសម្ព័ន្ធ និង ក្រុមហ៊ុន តំណាងប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងៗ ក្នុងលក្ខខណ្ឌមួយដែលបង្ហាញនូវទិដ្ឋភាពសមស្របមួយ។
- ទទួលបានភស្តុតាងសវនកម្មគ្រប់គ្រាន់ ពាក់ព័ន្ធនឹងពត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬសកម្មភាពអាជីវកម្មនៅក្នុងសម្ព័ន្ធ ដើម្បីផ្តល់មតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ។ យើងខ្ញុំទទួលខុសត្រូវលើទិសដៅការត្រួតពិនិត្យ និង ការប្រតិបត្តិនៃសវនកម្មរបស់សម្ព័ន្ធទាំងមូល។ យើងខ្ញុំទទួលខុសត្រូវទាំងស្រុងចំពោះការបញ្ចេញមតិរបស់យើងខ្ញុំ។

ក្នុងចំណោមចំណុចពាក់ព័ន្ធផ្សេងៗ យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលអំពីផែនការទំហំការងារ និង ពេលវេលានៃសវនកម្ម និង ចំណុចសំខាន់ៗដែលបានរកឃើញ រួមមានកង្វះខាតនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញនៅក្នុងអំឡុងសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំក៏បានផ្តល់ជូនដល់ក្រុមប្រឹក្សាភិបាលជាមួយនឹងរបាយការណ៍ ដែលយើងបានអនុវត្តតាមតម្រូវការនៃក្រមសីលធម៌ពាក់ព័ន្ធផ្សេងៗដែលទាក់ទិននឹងឯករាជ្យភាព និងធ្វើការទំនាក់ទំនងជាមួយអ្នកដែលពាក់ព័ន្ធ ហើយនិងចំណុចផ្សេងទៀតដែលអាចមានឥទ្ធិពលលើឯករាជ្យភាពយើងខ្ញុំ និង ការការពារដែលពាក់ព័ន្ធប្រសិនជាមាន ។

អំពីបញ្ហាដែលយើងខ្ញុំបានទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាល យើងខ្ញុំកំណត់ថាបញ្ហាទាំងនោះគឺមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ របស់សម្ព័ន្ធ និង របស់ក្រុមហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះ ហើយវាក៏ជាចំណុចសំខាន់ៗពីសវនកម្មផងដែរ ។ យើងខ្ញុំនឹងពណ៌នាពីចំណុចទាំងនោះនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លុះត្រាតែច្បាប់ ឬបញ្ញត្តិ រារាំងការបង្ហាញជាសាធារណៈអំពីចំណុចទាំងនេះ ឬក៏ក្នុងកាលៈទេសៈដ៏កំរ យើងខ្ញុំកំណត់ថាចំណុចនេះមិនគួរបង្ហាញនៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារតែផលវិបាកជាអវិជ្ជមានពីការបង្ហាញនោះ អាចនឹងប៉ះពាល់ដល់អត្ថប្រយោជន៍សាធារណៈ ។

លឹម សេងស៊ី
*Partner*

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧

លេខបញ្ជីពាណិជ្ជកម្ម៖
៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

| | កំណត់ | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | | | | | |
| **ទ្រព្យសកម្មរយៈពេល វែង** | | | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | ៧ | ១៤.៧៧៤.៧៨៧ | ៥៩.៦៤៥.៨១៥ | ១៤.១១០.១៥១ | ១៤.៦១១.៧៤៨ | ៥៨.៩៨៧.៦២៧ | ១៤.១០៥.៣០២ |
| ទ្រព្យសម្បត្តិវិនិយោគ | ៨ | ៣.៦៧២.៨៧៩ | ១៤.៨២៧.៤១៣ | ៣.៤០៧.៤៤២ | ៣.៦៧២.៨៧៩ | ១៤.៨២៧.៤១៣ | ៣.៤០៧.៤៤២ |
| ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៩ | - | - | - | ៥.០០៥.០០០ | ២០.២០៥.១៨៥ | ៥.០០៥.០០០ |
| ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | ១០ | ៨.៤៩១.៧៩២ | ៣៤.២៨១.៣៦៤ | ៨.១៦១.៥៦០ | ៨.៤៩១.៧៩២ | ៣៤.២៨១.៣៦៤ | ៨.១៦១.៥៦០ |
| | | ២៦.៩៣៩.៤៥៨ | ១០៨.៧៥៤.៥៩២ | ២៥.៦៧៩.១៥៣ | ៣១.៧៨១.៤១៩ | ១២៨.៣០១.៥៨៩ | ៣០.៦៧៩.៣០៤ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | | | |
| សន្និធិ | ១១ | ១៧.១៥៨.៨៩២ | ៦៩.២៧០.៤៤៧ | ១៣.១៣៧.០៥៣ | ៧.៦១២.៤៨២ | ៣០.៧៣១.៥៩០ | ៧.៧៥៨.៥៣៥ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ១២ | ៩.៦៤៧.៩០៣ | ៣៨.៩៤៨.៥៨៤ | ៨.៤៨៦.១០៥ | ១៤.៣៩៣.១៣១ | ៥៨.១០៥.០៧០ | ៩.០៩១.១៣២ |
| សាច់ប្រាក់ និង សាច់ប្រាក់នៅធនាគារ | ១៣ | ២.៤១១.៧៤៨ | ៩.៧៣៦.២២៧ | ១.១៦៥.៧០៤ | ២.៣៨៣.០១៦ | ៩.៦២០.២៣៦ | ១.១៤១.៥០៨ |
| | | ២៩.២១៨.៥៤៣ | ១១៧.៩៥៥.២៥៨ | ២២.៧៨៨.៨៦២ | ២៤.៣៨៨.៦២៩ | ៩៨.៤៥៦.៨៩៦ | ១៧.៩៩១.១៧៥ |
| **ទ្រព្យសកម្មសរុប** | | ៥៦.១៥៨.០០១ | ២២៦.៧០៩.៨៥០ | ៤៨.៤៦៨.០១៥ | ៥៦.១៧០.០៤៨ | ២២៦.៧៥៨.៤៨៥ | ៤៨.៦៧០.៤៧៩ |

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ(ត)

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

| | កំណត់ | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **មូលធនរបស់ភាគហ៊ុនិក** | | | | | | | |
| ដើមទុន | ១៤ | ២៨.៩៣៧.៥០០ | ១១៦.៨២០.៦៨៨ | ២៣.១៥០.០០០ | ២៨.៩៣៧.៥០០ | ១១៦.៨២០.៦៨៨ | ២៣.១៥០.០០០ |
| ភាគហ៊ុនបុព្វលាភ | ១៥ | ១.៧២៣.៥៤៣ | ៦.៩៥៧.៩៤៣ | - | ១.៧២៣.៥៤៣ | ៦.៩៥៧.៩៤៣ | - |
| ចំណេញរក្សាទុក | | ៥.៥៨១.១៨៣ | ២២.៥៣១.២៣៦ | ៤.១៣៥.៥១១ | ៥.៨៩០.៨៩៨ | ២៣.៧៨១.៥៥៥ | ៤.៣៤៥.៥៦៧ |
| **មូលធនរបស់ភាគហ៊ុនិកសរុប** | | ៣៦.២៤២.២២៦ | ១៤៦.៣០៩.៨៦៧ | ២៧.២៨៥.៥១១ | ៣៦.៥៥១.៩៤១ | ១៤៧.៥៦០.១៨៦ | ២៧.៤៩៥.៥៦៧ |
| **បំណុល** | | | | | | | |
| **បំណុលរយៈពេលវែង** | | | | | | | |
| កម្ចី | ១៧ | ៣.២៣១.២៤២ | ១៣.០៤៤.៥២៤ | ១.៩៣២.៨០២ | ៣.២៣១.២៤២ | ១៣.០៤៤.៥២៤ | ១.៩៣២.៨០២ |
| ចំណូលពន្យា | ១៨ | ១០.៩៦០.០០០ | ៤៤.២៤៥.៥២០ | ១១.៥០៨.០០០ | ១០.៩៦០.០០០ | ៤៤.២៤៥.៥២០ | ១១.៥០៨.០០០ |
| | | ១៤.១៩១.២៤២ | ៥៧.២៩០.០៤៤ | ១៣.៤៤០.៨០២ | ១៤.១៩១.២៤២ | ៥៧.២៩០.០៤៤ | ១៣.៤៤០.៨០២ |

លេខបញ្ជីពាណិជ្ជកម្ម៖
៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ(ត)

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

| | កំណត់ | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **មូលធនរបស់ភាគហ៊ុនិក និងបំណុល (ត)** | | | | | | | |
| **បំណុល (ត)** | | | | | | | |
| **បំណុលរយៈពេលខ្លី** | | | | | | | |
| កម្ចី | ១៧ | ៣.៧៩០.៨៨៣ | ១៥.៣០៣.៧៩៥ | ៥.០១៧.៨២៣ | ៣.៧៩០.៨៨៣ | ១៥.៣០៣.៧៩៥ | ៥.០១៧.៨២៣ |
| ចំណូលពន្យា | ១៨ | ៥៤៨.០០០ | ២.២១២.២៧៦ | ៥៤៨.០០០ | ៥៤៨.០០០ | ២.២១២.២៧៦ | ៥៤៨.០០០ |
| គណនីពាណិជ្ជ និងគណនីត្រូវបង់ផ្សេងៗ | ១៩ | ១.៣៨៥.៣៥៤ | ៥.៥៩២.៦៧៣ | ២.១៧២.៣១០ | ១.០៨៧.៩៨២ | ៤.៣៩២.១៨៤ | ២.១៦៨.២៨៧ |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | | ២៩៦ | ១.១៩៥ | ៣.៥៦៩ | - | - | - |
| | | ៥.៧២៤.៥៣៣ | ២៣.១០៩.៩៣៩ | ៧.៧៤១.៧០២ | ៥.៤២៦.៨៦៥ | ២១.៩០៨.២៥៥ | ៧.៧៣៤.១១០ |
| **បំណុលសរុប** | | ១៩.៩១៥.៧៧៥ | ៨០.៣៩៩.៩៨៣ | ២១.១៨២.៥០៤ | ១៩.៦១៨.១០៧ | ៧៩.១៩៨.២៩៩ | ២១.១៧៤.៩១២ |
| **មូលធនរបស់ភាគហ៊ុនិក និងបំណុលសរុប** | | ៥៦.១៥៨.០០១ | ២២៦.៧០៩.៨៥០ | ៤៨.៤៦៨.០១៥ | ៥៦.១៧០.០៤៨ | ២២៦.៧៥៨.៤៨៥ | ៤៨.៦៧០.៤៧៩ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

លេខបញ្ជីពាណិជ្ជកម្ម៖
INV - ១០៧៦KH/២០០៦

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំនេញ ឬខាត និង ចំណូលផ្សេងៗ

សំរាប់ដំណាច់ឆ្នាំថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| ចំណូល | ២០ | ៩.៤៦០.១០៧ | ៣៨.១៩០.៤៥២ | ១៦.៣៧៧.៨៧៥ | ៩.២០០.៧៤០ | ៣៧.១៤៣.៣៨៧ | ១៦.១៥២.៦៣៥ |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម | ២១ | (២.៨៧៨.៦១១) | (១១.៦២០.៩៥៣) | (៦.០៨៥.០៥២) | (២.៦៥៦.៤០១) | (១០.៧២៣.៨៩១) | (៥.៨៣១.៤៧៤) |
| ចំណេញដុល | | ៦.៥៨១.៤៩៦ | ២៦.៥៦៩.៤៩៩ | ១០.២៩២.៨២៣ | ៦.៥៤៤.៣៣៩ | ២៦.៤១៩.៤៩៦ | ១០.៣២១.១៦១ |
| ចំណូលផ្សេងៗ | ២២ | ២៤.៦៥២ | ៩៩.៥២០ | ៣០.១៦៣ | ២៤.៦៤៤ | ៩៩.៤៨៨ | ៣០.១៦៣ |
| ចំណាយរដ្ឋបាល | ២៣ | (៤.៥៧៧.៦៧៧) | (១៨.៤៨០.០៨២) | (៤.១៥៤.៩០៧) | (៤.៤៤៤.២៦១) | (១៧.៩៤១.៤៨២) | (៣.៩៨៦.៦៣១) |
| ចំណាយការប្រាក់ | ២៤ | (៦៩៩.៨៧៤) | (២.៨២៥.៣៩១) | (១.០៥៦.៧៣០) | (៦៩៩.៨៧៤) | (២.៨២៥.៣៩១) | (១.០៥៦.៧៣០) |
| ការបែងចែកចំណេញ/ខាតពីក្រុមហ៊ុនញាតិសម្ព័ន្ធ | | ៣៣០.២៣២ | ១.៣៣៣.១៤៧ | (១២.៧២៨) | ៣៣០.២៣២ | ១.៣៣៣.១៤៧ | (១២.៧២៨) |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ១.៦៥៨.៨២៩ | ៦.៦៩៦.៦៩៣ | ៥.០៩៨.៦២១ | ១.៧៥៥.០៨០ | ៧.០៨៥.២៥៨ | ៥.២៩៥.២៣៥ |
| ចំណាយពន្ធ | ២៥ | (២១៣.១៥៧) | (៨៦០.៥១៥) | (៩៧៨.២៥៨) | (២០៩.៧៤៩) | (៨៤៦.៧៥៧) | (៩៧១.៩២២) |
| ចំណេញប្រចាំឆ្នាំ | | ១.៤៤៥.៦៧២ | ៥.៨៣៦.១៧៨ | ៤.១២០.៣៦៣ | ១.៥៤៥.៣៣១ | ៦.២៣៨.៥០១ | ៤.៣២៣.៣១៣ |
| ចំណេញផ្សេងៗក្រោយបង់ពន្ធ | | - | - | - | - | - | - |
| សរុបលទ្ធផលចំណេញប្រចាំឆ្នាំ | | ១.៤៤៥.៦៧២ | ៥.៨៣៦.១៧៨ | ៤.១២០.៣៦៣ | ១.៥៤៥.៣៣១ | ៦.២៣៨.៥០១ | ៤.៣២៣.៣១៣ |
| ចំណេញក្នុងមួយភាគហ៊ុនសម្រាប់ផ្តល់ដល់ភាគហ៊ុននិកធម្មតា | ១៦ | | | | | | |
| ចំណេញក្នុងមួយភាគហ៊ុនគោល | | ០.០២៥ | ០.១០១ | ០.០៨៩ | | | |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | | ០.០២៥ | ០.១០១ | ០.០៨៩ | | | |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិញ្ញវត្ថុមួយនេះ។*

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
សំរាប់ដំណាច់ឆ្នាំថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | ភាគហ៊ុនបុព្វលាភ ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **សម្ព័ន្ធ** | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥** | | **១.០០០.០០០** | **-** | **២២.១៦៥.១៤៨** | **២៣.១៦៥.១៤៨** |
| ចំណេញសុទ្ធប្រចាំឆ្នាំ តំណាងដោយ លទ្ធផលចំណេញសរុប | | - | - | ៤.១២០.៣៦៣ | ៤.១២០.៣៦៣ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការបោះផ្សាយភាគហ៊ុនបន្ថែម (Bonus issue) | ១៤ | ២២.១៥០.០០០ | - | (២២.១៥០.០០០) | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥/ ថ្ងៃទី១ ខែមករា ឆ្នាំ២០១៦** | | **២៣.១៥០.០០០** | **-** | **៤.១៣៥.៥១១** | **២៧.២៨៥.៥១១** |
| ចំណេញសុទ្ធប្រចាំឆ្នាំ តំណាងដោយ លទ្ធផលចំណេញសរុប | | - | - | ១.៤៤៥.៦៧២ | ១.៤៤៥.៦៧២ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការបោះផ្សាយភាគហ៊ុន | ១៤ | ៥.៧៨៧.៥០០ | ១.៧២៣.៥៤៣ | - | ៧.៥១១.០៤៣ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | **២៨.៩៣៧.៥០០** | **១.៧២៣.៥៤៣** | **៥.៥៨១.១៨៣** | **៣៦.២៤២.២២៦** |
| *(គិតជាពាន់រៀល)* | | *១១៦.៨២០.៦៨៨* | *៦.៩៥៧.៨៤៣* | *២២.៥៣១.២៣៦* | *១៤៦.៣០៩.៨៦៧* |

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន

សំរាប់ដំណាច់ឆ្នាំថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភ ដុល្លារអាមេរិក | ចំណេញរក្សាទុក ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **ក្រុមហ៊ុន** | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥** | | **១.០០០.០០០** | **-** | **២២.១៧២.២៥៤** | **២៣.១៧២.២៥៤** |
| ចំណេញសុទ្ធប្រចាំឆ្នាំ តំណាងដោយ លទ្ធផលចំណេញសរុប | | - | - | ៤.៣២៣.៣១៣ | ៤.៣២៣.៣១៣ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការបោះផ្សាយភាគហ៊ុនបន្ថែម (Bonus issue) | ១៤ | ២២.១៥០.០០០ | - | (២២.១៥០.០០០) | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥/ ថ្ងៃទី១ ខែមករា ឆ្នាំ២០១៦** | | **២៣.១៥០.០០០** | **-** | **៤.៣៤៥.៥៦៧** | **២៧.៤៩៥.៥៦៧** |
| ចំណេញសុទ្ធប្រចាំឆ្នាំ តំណាងដោយ លទ្ធផលចំណេញសរុប | | - | - | ១.៥៤៥.៣៣១ | ១.៥៤៥.៣៣១ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការបោះផ្សាយភាគហ៊ុន | ១៤ | ៥.៧៨៧.៥០០ | ១.៧២៣.៥៤៣ | - | ៧.៥១១.០៤៣ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | **២៨.៩៣៧.៥០០** | **១.៧២៣.៥៤៣** | **៥.៨៩០.៨៩៨** | **៣៦.៥៥១.៩៤១** |
| *(គិតជាពាន់រៀល)* | | *១១៦.៨២០.៦៨៨* | *៦.៩៥៧.៩៤៣* | *២៣.៧៨១.៥៥៥* | *១៤៧.៥៦០.១៨៦* |

# ភ្នំពេញ សេអ៊ីហ្សិត ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | សម្ព័ន្ធ ២០១៦ | | សម្ព័ន្ធ ២០១៥ | ក្រុមហ៊ុន ២០១៦ | | ក្រុមហ៊ុន ២០១៥ |
|---|---|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | | | |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ១.៦៥៨.៨២៩ | ៦.៦៩៦.៦៩៣ | ៥.០៩៨.៦២១ | ១.៧៥៥.០៨០ | ៧.០៨៥.២៥៨ | ៥.២៩៥.២៣៥ |
| និយ័តកម្ម: | | | | | | | |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ បរិក្ខារ | ៧ | ១.០៣៣.០៣៨ | ៤.១៧០.៣៧៤ | ៩៨៥.៤៨៣ | ១.០៣០.២៤៥ | ៤.១៥៩.០៩៩ | ៩៨៣.៨៦៧ |
| រំលស់ទ្រព្យសម្បត្តិវិនិយោគ | ៨ | ២២៨.៣៨២ | ៩២១.៩៧៨ | ១៩៣.៤៤៥ | ២២៨.៣៨២ | ៩២១.៩៧៨ | ១៩៣.៤៤៥ |
| ចំណូលការប្រាក់ | | (៥.៣៧០) | (២១.៦៧៩) | (២.១២៩) | (៥.៣៧០) | (២១.៦៧៩) | (២.១២៩) |
| ចំណាយការប្រាក់ | ២៤ | ៦៩៩.៨៧៤ | ២.៨២៥.៣៩១ | ១.០៥៦.៧៣០ | ៦៩៩.៨៧៤ | ២.៨២៥.៣៩១ | ១.០៥៦.៧៣០ |
| (ចំណេញ)/ខាតបង់ទៅលើការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | | (៣៣០.២៣២) | (១.៣៣៣.១៤៧) | ១២.៧២៨ | (៣៣០.២៣២) | (១.៣៣៣.១៤៧) | ១២.៧២៨ |
| ចំណូលប្រតិបត្តិការ មុនបម្រែបម្រួល ដើមទុនបង្វិល | | ៣.២៨៤.៥២១ | ១៣.២៥៩.៦១០ | ៧.៣៤៤.៨៧៨ | ៣.៣៧៧.៩៧៩ | ១៣.៦៣៦.៩០០ | ៧.៥៣៩.៨៧៦ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | | | | | |
| សន្និធិ | | (៤.០២១.៨៣៩) | (១៦.២៣៦.១៦៤) | (២.១៨៨.៤៧១) | ១៤៦.០៥៣ | ៥៨៩.៦១៦ | ៣.១៩០.០៤៧ |
| គណនីពាណិជ្ជ និង គណនីត្រូវទទួលផ្សេងៗ | | (៨២៨.៣៨៥) | (៣.៣៤៤.១៩០) | ៣.៥១៧.៧៣៨ | (៦៥៣.០១១) | (២.៦៣៦.២០៤) | ៣.៥៣៦.៧២៧ |
| គណនីពាណិជ្ជ និង គណនីត្រូវបង់ផ្សេងៗ | | (៩៣២.១៧៤) | (៣.៧៦៣.១៨៥) | (៣៥៨.៣៤២) | (៩៣៧.៣៩៦) | (៣.៧៨៤.២៦៧) | (៣៥៩.៨៦៧) |

# ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់ (ត)

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់ | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ (ត)** | | | | | | | |
| សាច់ប្រាក់(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | | (២.៤៩៧.៨៧៧) | (១០.០៨៣.៩២៩) | ៨.៣១៥.៨០៣ | ១.៩៣៣.៦២៥ | ៧.៨០៦.០៤៥ | ១៣.៩០៦.៧៨៣ |
| ពន្ធបានបង់ | | (២១៦.៤៣០) | (៨៧៣.៧២៨) | (១.១៤២.៧១១) | (២០៩.៧៤៩) | (៨៤៦.៧៥៧) | (១.១៣៩.៧៥៤) |
| ការប្រាក់បានបង់ | | (៦៧០.៣០៣) | (២.៧០៦.០១៣) | (១.០៥៦.៧៣០) | (៦៧០.៣០៣) | (២.៧០៦.០១៣) | (១.០៥៦.៧៣០) |
| សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | | (៣.៣៨៤.៦១០) | (១៣.៦៦៣.៦៧០) | ៦.១១៦.៣៦២ | ១.០៥៣.៥៧៣ | ៤.២៥៣.២៧៥ | ១១.៧១០.២៩៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧ | (២.១៩១.៤៩៣) | (៨.៨៤៧.០៥៧) | (១.០១៩.៣១៤) | (២.០៣០.៥១០) | (៨.១៩៧.១៦៩) | (១.០១៤.៨៤៤) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | ៨ | - | - | (៨.៧៥១) | - | - | (៨.៧៥១) |
| ចំណូលពីការប្រាក់ | | ៥.៣៧០ | ២១.៦៧៩ | ២.១២៩ | ៥.៣៧០ | ២១.៦៧៩ | ២.១២៩ |
| ប្រាក់បង់សុទ្ធទៅភាគីពាក់ព័ន្ធ | | (៤៤១.០៨៣) | (១.៧៨០.៦៥២) | (៤៤៣.១០៥) | (៧២៩.២១០) | (២.៩៤៣.៨២១) | (៤៤២.៥២៤) |
| បុរេប្រទានសុទ្ធបានបង់ជូនក្រុមហ៊ុនញាតិសម្ព័ន្ធ | | (១៤.៦៨៣) | (៥៩.២៧៥) | (១៦.៤១៥) | (១៤.៦៨៣) | (៥៩.២៧៥) | (១៦.៤១៥) |
| បុរេប្រទានផ្តល់ជូនអគ្គនាយក | | (៣១០.០០០) | (១.២៥១.៤៧០) | - | (៣១០.០០០) | (១.២៥១.៤៧០) | - |
| បុរេប្រទានផ្តល់ជូនក្រុមហ៊ុនបុត្រសម្ព័ន្ធ | | - | - | - | (៤.៣១៥.៥៧៥) | (១៧.៤២១.៩៧៦) | (៦១៧.៣០៩) |
| ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | | - | - | - | - | - | (៥.០០០.០០០) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (២.៩៥១.៨៨៩) | (១១.៩១៦.៧៧៥) | (១.៤៨៥.៤៥៦) | (៧.៣៩៤.៦០៨) | (២៩.៨៥២.០៣២) | (៧.០៩៧.៧១៤) |

# ភ្នំពេញ អេសអ៊ីហ្សិត អ៊ីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់ (ត)
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|---|
| | | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | | | |
| ចំណូលពីការបោះផ្សាយលក់ភាគហ៊ុនធម្មតា | ១៤ | ៨.១២៥.៣០២ | ៣២.៨០១.៨៤៤ | - | ៨.១២៥.៣០២ | ៣២.៨០១.៨៤៤ | - |
| ចំណាយលើការបោះផ្សាយភាគហ៊ុន | | (៦១៤.២៥៩) | (២.៤៧៩.៧៦៤) | - | (៦១៤.២៥៩) | (២.៤៧៩.៧៦៤) | - |
| ការបង់ត្រលប់ប្រាក់កម្ចី | | (១.១៧៨.៥០០) | (៤.៧៥៧.៦០៥) | (៤.៤៥៧.៧៥៧) | (១.១៧៨.៥០០) | (៤.៧៥៧.៦០៥) | (៤.៤៥៧.៧៥៧) |
| ការដកប្រាក់កម្ចី | | ២.០៥០.០០០ | ៨.២៧៥.៨៥០ | - | ២.០៥០.០០០ | ៨.២៧៥.៨៥០ | - |
| លំហូរសាច់ប្រាក់ពី/(ប្រើក្នុង)សកម្មភាពហិរញ្ញប្បទាន | | ៨.៣៨២.៥៤៣ | ៣៣.៨៤០.៣២៥ | (៤.៤៥៧.៧៥៧) | ៨.៣៨២.៥៤៣ | ៣៣.៨៤០.៣២៥ | (៤.៤៥៧.៧៥៧) |
| **កំណើននៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ២.០៤៦.០៤៤ | ៨.២៥៩.៨៨០ | ១៧៣.១៤៩ | ២.០៤១.៥០៨ | ៨.២៤១.៥៦៨ | ១៥៤.៨២៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា** | | ៣៦៥.៧០៤ | ១.៤៧៦.៣៤៧ | ១៩២.៥៥៥ | ៣៤១.៥០៨ | ១.៣៧៨.៦៦៨ | ១៨៦.៦៨០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | ១៣ | ២.៤១១.៧៤៨ | ៩.៧៣៦.២២៧ | ៣៦៥.៧០៤ | ២.៣៨៣.០១៦ | ៩.៦២០.២៣៦ | ៣៤១.៥០៨ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

# ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦

### ១. ព័ត៌មានអំពីក្រុមហ៊ុន
ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតនៅព្រះរាជាណាចក្រកម្ពុជា។ ក្រោយមកទៀត នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៥ ក្រុមហ៊ុនបានប្តូរជាក្រុមហ៊ុន មហាជនទទួលខុសត្រូវមានកំរិត ។ ក្រុមហ៊ុនបានចុះបញ្ជីនៅទីផ្សារមូលបត្រកម្ពុជានាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។

ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ នៅតាមបណ្តោយផ្លូវជាតិលេខ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ រួមមានរបាយការណ៍ របស់ ក្រុមហ៊ុនមេ និង ក្រុមហ៊ុនចំណុះ និងភាគកម្មសិទ្ធិរបស់សម្ព័ន្ធ នៅក្នុងក្រុមហ៊ុនសម្ព័ន្ធញាតិ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជា រូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។ ការបង្ហាញបញ្ជាក់បន្ថែមទៀត ក៏ត្រូវបានរៀបចំជា រូបិយប័ណ្ណខ្មែរ ("រ") ដើម្បីបំពេញតំរូវការរបស់អាជ្ញាធរក្នុងប្រទេសកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តឲ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៧។

### ២. សកម្មភាពចម្បង
សកម្មភាពចំបងរបស់ក្រុមហ៊ុនគឺការសាងសង់ ការអភិវឌ្ឍន៍ និងដំនើរការតំបន់សេដ្ឋកិច្ចពិសេសក្នុងរាជធានីភ្នំពេញ និងរួមមានសកម្មភាពពាណិជ្ជកម្មដទៃទៀត ។ សកម្មភាពចំបងនៃក្រុមហ៊ុនចំណុះត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុនេះទេ ។

### ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ចេញផ្សាយដោយ ក្រុមប្រឹក្សាជាតិគណនេយ្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៤. គោលនយោបាយគណនេយ្យសំខាន់ៗ
#### ៤.១ មូលដ្ឋានគណនេយ្យ
របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ និងរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងតាមវិធីសាស្រ្តសន្មត់តម្លៃដើម លើកលែងតែអ្វីដែលបានបញ្ជាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាម ស.រ.ហ.អ.ក តម្រូវឲ្យក្រុមប្រឹក្សាភិបាលធ្វើការ ប៉ាន់ស្មាន និង សន្មត់ដែលអាចប៉ះពាល់ដល់ ទ្រព្យសកម្ម បំណុល ចំណូល និង ការចំណាយដែលបានរាយការណ៍ ព្រមទាំងការបង្ហាញទ្រព្យសកម្មជាយថាហេតុ និង បំណុលជាយថាហេតុ។ បន្ថែមលើនេះ ក្រុមប្រឹក្សាភិបាលតម្រូវឲ្យធ្វើការវិនិច្ឆ័យ ស្របពេលជាមួយនឹងការអនុវត្តន៍នូវគោលនយោបាយគណនេយ្យទាំងនេះ។ ការវិនិច្ឆ័យ ការប៉ាន់ស្មាន និង ការសន្មត់ទាំងនេះ ត្រូវបានធ្វើការបង្ហាញនៅក្នុងកំណត់សម្គាល់របស់របាយការណ៍ហិរញ្ញវត្ថុលេខ៦។ ទោះបីជាការប៉ាន់ស្មាន និង ការសន្មត់ខាងលើ ធ្វើឡើងដោយការយល់ដឹងរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែលទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនោះ ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១ មូលដ្ឋានគណនេយ្យ (ត)

ការប្តូររូបិយវត្ថុជាប្រាក់រៀលខ្មែរត្រូវបានបង្ហាញនៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និង កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុគិតត្រឹម និង កំឡុងដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការចេញដោយ ធនាគារជាតិនៃកម្ពុជា នាការិយបរិច្ឆេទចេញរបាយការណ៍ហិរញ្ញវត្ថុនេះ ដែល ១ ដុល្លារអាមេរិក = ៤.០៣៧ រៀល (២០១៥: ១ ដុល្លារអាមេរិក = ៤.០៥០ រៀល) ។ ការបកប្រែរូបិយប័ណ្ណនេះ មិនត្រូវបានយកមកបកស្រាយជាអំណះអំណាងថា ប្រាក់ដុល្លារអាមេរិកតំណាងឲ្យ ឬ ត្រូវបានប្តូរទៅជាប្រាក់រៀលខ្មែរតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងៗទៀតបានឡើយ។

### ៤.២ មូលដ្ឋាននៃការរួមបញ្ចូល

ការរួមបញ្ចូលនៃរបាយការណ៍ហិរញ្ញវត្ថុ គឺជាការបញ្ចូលគ្នានៃរបាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ការគ្រប់គ្រងត្រូវបានធ្វើឡើងនៅពេលដែលសម្ព័ន្ធត្រូវបានបង្ហាញ ឬមានសិទ្ធិក្នុងការប្រមូលមកវិញដោយមានការផ្លាស់ប្តូរពីការរួមចំណែកជាមួយនឹងវិនិយោគិន និងមានលទ្ធភាពក្នុងការជះឥទ្ធិពលទៅលើការប្រមូលមកវិញនូវអនុភាពមាននៅលើវិនិយោគិនទាំងនោះ ជាពិសេសការគ្រប់គ្រងរបស់សម្ព័ន្ធទៅលើវិនិយោគិននៅពេលដែលសម្ព័ន្ធមានៈ

(ក) អនុភាពទៅលើវិនិយោគិន
(ខ) កំលាំង ឬសិទ្ធិនៃការប្រមូលមកវិញដោយមាននូវការផ្លាស់ប្តូរពីការរួមចំណែកជាមួយនឹងវិនិយោគិន និង
(គ) លទ្ធភាពក្នុងការប្រើប្រាស់នូវ អនុភាពទៅលើវិនិយោគិន ក្នុងការជះឥទ្ធិពលទៅលើការទទួលបានមកវិញ។

ប្រសិនបើសម្ព័ន្ធមានភាពតិចជាងនៅក្នុងការបោះឆ្នោត ឬមានសិទ្ធិប្រហាក់ប្រហែលនៃវិនិយោគិន សម្ព័ន្ធនឹងពិចារណាទៅលើរាល់ភាពពិតជាក់ស្តែងទាំងអស់ និងស្ថានភាពនៅក្នុងការវាយតម្លៃថាតើពួកគេមានអនុភាពទៅលើវិនិយោគិនឬអត់ ដោយរួមមានដូចជាៈ

(ក) ការរៀបចំកិច្ចព្រមព្រៀង ជាមួយអ្នកកាន់កាប់នូវសិទ្ធិទទួលបានការបោះឆ្នោត នៃវិនិយោគិនផ្សេងទៀត
(ខ) ការកើតឡើងនូវសិទ្ធិពីការរៀបចំកិច្ចព្រមព្រៀង និង
(គ) សិទ្ធិក្នុងការបោះឆ្នោតនៃសម្ព័ន្ធ និងសក្តានុពលនៃសិទ្ធិក្នុងការបោះឆ្នោត

តុល្យភាពរវាងអន្តរសម្ព័ន្ធ ប្រតិបត្តិការ ចំណូល និងចំណាយទាំងអស់សុទ្ធតែត្រូវបានលុបបំបាត់នៅក្នុងការបញ្ចូលគ្នា។ ការកើតឡើងនូវភាពចំណេញដែលមិនបានទទួលស្គាល់ពីប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាត្តិ និងការរកស៊ីចូលហ៊ុនគ្នា ត្រូវបានលុបបំបាត់ពីការវិនិយោគទៅនឹងទំហំនៃការកាន់កាប់របស់សម្ព័ន្ធនៅក្នុងការវិនិយោគ។ ការខាតបង់ដែលមិនបានទទួលស្គាល់ត្រូវបានលុបបំបាត់ដូចគ្នាទៅនឹងការមិនបានទទួលស្គាល់នូវភាពចំណេញ ប៉ុន្តែអ្វីប្រាកដនោះ គឺគ្មានការខាតបង់នូវការថយចុះតម្លៃនៃទ្រព្យសម្បត្តិនោះទេ។

របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបានរៀបចំសម្រាប់របាយការណ៍ក្នុងរយៈពេលដូចគ្នាទៅនឹងក្រុមហ៊ុនដោយប្រើប្រាស់នូវគោលការណ៍គណនេយ្យសង្គតិភាព។ នៅពេលដែលមានភាពចំបាច់ គោលការណ៍គណនេយ្យរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានផ្លាស់ប្តូរដើម្បីធានាឲ្យបាននូវស្ថេរភាព ជាមួយនឹងគោលការណ៍ដែលត្រូវបានទទួលយកដោយអង្គភាពដទៃទៀតនៅក្នុងសម្ព័ន្ធ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.២ មូលដ្ឋាននៃការរួមបញ្ចូល (ត)

ហ៊ុនភាគតិច គឺតំណាងឲ្យនូវមូលធននៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនអាច បែងចែកបានដោយផ្ទាល់ ឬដោយប្រយោលទៅនឹងភាពជាម្ចាស់នៃក្រុមហ៊ុនមេ ហើយវាត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងរបាយការណ៍លទ្ធផលរួម និងរបាយការណ៍ចំណូលផ្សេងៗ ដែលមានរួមមានមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម ដែលដាក់ដោយឡែកពីមូលធនដែលត្រូវផ្តល់ទៅឲ្យម្ចាស់ក្រុមហ៊ុន។ ការចំណេញ ឬខាតនិងធាតុនីមួយៗនៃចំណូលទូទៅផ្សេងៗ គឺត្រូវផ្តល់ទៅឲ្យក្រុមហ៊ុនមេ និងហ៊ុនភាគតិច។ ចំណូលទូទៅផ្សេងៗសរុបត្រូវផ្តល់ទៅឲ្យហ៊ុនភាគតិចទោះបីជាលទ្ធផលនេះធ្វើឲ្យមានឱនភាពសមតុល្យនៅក្នុង ហ៊ុនភាគតិចក៏ដោយ។

សម្ព័ន្ធធ្វើការវាយតម្លៃឡើងវិញថាតើពួកគេគ្រប់គ្រងទៅលើវិនិយោគិន ប្រសិនបើការពិតនិងស្ថានភាពចង្អុលបង្ហាញថាវាមានការផ្លាស់ប្តូរពី១ ឬច្រើននៃធាតុសំខាន់ៗទាំងបីនៃការគ្រប់គ្រង។ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានដាក់បញ្ចូលគ្នាចាប់ពីថ្ងៃនៃការគ្រប់គ្រងត្រូវបានផ្ទេរទៅកាន់សម្ព័ន្ធរហូតដល់ថ្ងៃ ដែលការគ្រប់គ្រងត្រូវបានបញ្ឈប់មានប្រសិទ្ធិភាព។ ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដែលទិញ ឬជំរះក្នុងឆ្នាំត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍លទ្ធផល និងចំណូលទូទៅផ្សេងៗពីថ្ងៃដែលសម្ព័ន្ធមានការគ្រប់គ្រងរហូតដល់ថ្ងៃដែលសម្ព័ន្ធបញ្ឈប់នូវការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ការផ្លាស់ប្តូរភាពជាម្ចាស់ក្រុមហ៊ុនក្នុងក្រុមហ៊ុនចំណុះ ដែលមិនជាលទ្ធផលនៃការបាត់បង់នៃការគ្រប់គ្រងត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធន។ នៅក្នុងស្ថានភាពបែបនេះ តម្លៃយោងពិតនៃការគ្រប់គ្រង និងហ៊ុនភាគតិច ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរក្នុងការកាន់កាប់ភាគហ៊ុនរបស់ខ្លួនក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ រាល់ភាពខុសគ្នានៃចំនួនដែលបានធ្វើនិយ័តកម្មក្នុងហ៊ុនភាគតិច និងតម្លៃទីផ្សារសមស្របនៃការគិតពិចារណាលើការទូទាត់ ឬការទទួលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធននិងផ្តល់ទៅឲ្យម្ចាស់ក្រុមហ៊ុន។

ប្រសិនបើសម្ព័ន្ធបាត់បង់នូវការគ្រប់គ្រងនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ចំណូល ឬចំណាយដែលបានជំរះត្រូវបានគណនាដូចខាងក្រោម៖

(១) តម្លៃពិតសមស្របនៃការបូកបញ្ចូលគ្នានៃការពិចារណាដែលអាចទទួលបាន និងតម្លៃពិតសមស្របនៃការប្រាក់ដែលនៅសល់ និង

(២) តម្លៃយោងពិតគណនេយ្យនៃទ្រព្យសកម្ម (រួមបញ្ចូលទាំងកេរ្តិ៍ឈ្មោះ) និងទ្រព្យអកម្មនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ និងហ៊ុនភាគតិចផ្សេងទៀត។

ចំនួនដែលបានទទួលស្គាល់ពីឆ្នាំមុននៅក្នុងចំណូលទូទៅផ្សេងៗទាក់ទងនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកត់ត្រា (ឧទាហរណ៍៖ ការចាត់ថ្នាក់ឡើងវិញទៅជាចំណេញ ឬខាត ឬផ្ទេរដោយផ្ទាល់ទៅប្រាក់ចំណេញរក្សាទុក) នៅក្នុងលក្ខណៈដូចគ្នា ប្រសិនបើទ្រព្យសកម្ម ឬបំណុលត្រូវបានជំរះ។ នៅថ្ងៃដែលការគ្រប់គ្រងបានបាត់បង់តម្លៃទីផ្សាររបស់ការវិនិយោគរក្សាទុកនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវចាត់ទុកថាតម្លៃទីផ្សារ នៅពេលទទួលស្គាល់ជាលើកដំបូង សម្រាប់គណនីបន្តបន្ទាប់ដែលយោងទៅតាម ស.គ.អ.ក ៣៩ *ឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់ និងការវាស់វែង* ឬនៅពេលអនុវត្តន៍ តម្លៃនៅពេលទទួលស្គាល់ជាលើជាដំបូងនៃការវិនិយោគក្នុងសម្ព័ន្ធ ឬការរកស៊ីរួមគ្នា។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៣ ការរួមបញ្ចូលគ្នានៃអាជីវកម្ម

ការរួមបញ្ចូលគ្នានៃអាជីវកម្មត្រូវបានកត់ត្រាដោយផ្អែកលើវិធីសាស្ត្រទិញនៃគណនេយ្យ។

ការកំណត់នូវអត្តសញ្ញាណនៃទ្រព្យសកម្មដែលបានទិញ ទ្រព្យអកម្មជាយថាហេតុដែលបានសន្មត់នៅក្នុងការរួមបញ្ចូលគ្នានៃអាជីវកម្ម ត្រូវបានវាស់វែងនៅតម្លៃទីផ្សារសមស្របរបស់វានៅថ្ងៃទិញ លើកលែងតែ៖

(ក) ពន្ធពន្យាលើទ្រព្យសកម្ម ឬទ្រព្យអកម្ម និងទ្រព្យអកម្ម ឬទ្រព្យសកម្មដែលទាក់ទងនឹងការរៀបចំអត្ថប្រយោជន៍និយោជិក ដែលត្រូវបានទទួលស្គាល់ និងវាស់វែងរៀងគ្នាទៅតាម ស.គ.អ.ក ១២ *ពន្ធលើប្រាក់ចំណេញ* និង ស.គ.អ.ក ១៩ *អត្ថប្រយោជន៍និយោជិក*។

(ខ) ទ្រព្យអកម្ម ឬឧបករណ៍មូលធនដែលទាក់ទងទៅនឹងប្រតិបត្តិការនៃការទូទាត់ដែលផ្អែកលើមូលដ្ឋាននៃការទិញ ឬជំនួសដោយសម្ព័ន្ធនៃប្រតិបត្តិការនៃការទូទាត់ដែលផ្អែកលើមូលដ្ឋានរបស់អ្នកទិញ ដែលត្រូវបានវាស់វែងដែលអនុលោមតាម ស.រ.ហ.អ.ក ២ *ការទូទាត់ផ្អែកលើមូលដ្ឋាន* នៅថ្ងៃទិញ និង

(គ) ទ្រព្យសកម្ម (ឬក្រុមជំរះ) ដែលត្រូវបានចាត់ថ្នាក់ជាការកាន់កាប់សម្រាប់លក់ដោយអនុលោមតាម ស.រ.ហ.អ.ក ៥ *ការកាន់កាប់ទ្រព្យអកម្មសម្រាប់លក់ និងការបញ្ឈប់ប្រតិបត្តិការ* ត្រូវបានវាស់វែងដោយផ្អែកទៅតាមស្តង់ដារនោះ។

ចំណាយដែលពាក់ព័ន្ធនឹងការទិញត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងកំឡុងពេលដែលថ្លៃកើតឡើង និងសេវាត្រូវបានទទួល។

តម្លៃតបស្នងជាយថាហេតុត្រូវបង់មួយចំនួន ត្រូវបានទទួលស្គាល់នៅតម្លៃទីផ្សារសមស្របនៅថ្ងៃទិញ។ ការធ្វើនិយ័តកម្មកំឡុងពេលការវាស់វែងសម្រាប់តម្លៃតបស្នងជាយថាហេតុត្រូវបានកំណត់ដូចខាងក្រោម៖

(ក) ប្រសិនបើតម្លៃតបស្នងជាយថាហេតុត្រូវបានកត់ត្រាជាមូលធន វាមិនត្រូវបានវាស់វែងឡើងវិញ និងការទូទាត់ត្រូវបានកត់ត្រានៅក្នុងមូលធន។

(ខ) ការប្រែប្រួលជាបន្តបន្ទាប់លើតម្លៃតបស្នងជាយថាហេតុត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម និងទ្រព្យអកម្មដែលជាឧបករណ៍ហិរញ្ញវត្ថុនៅក្នុងដែនកំណត់នៃ ស.គ.អ.ក ៣៩ ដែលត្រូវបានទទួលស្គាល់ទាំងក្នុងចំណេញ ឬខាត ឬនៅក្នុងចំណូលទូទៅដទៃទៀតដោយអនុលោមទៅតាម ស.គ.អ.ក ៣៩។ ការប្រែប្រួលជាបន្តបន្ទាប់ដទៃទៀតត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

មូលធននៅក្នុងការរួមបញ្ចូលគ្នា នៃអាជីវកម្មដែលសម្រេចបានក្នុងដំណាក់កាល ដែលកាលពីមុនមានភាគហ៊ុនតម្រូវឲ្យវាស់វែងឡើងវិញទៅនឹងតម្លៃទីផ្សារសមស្របនៅថ្ងៃទិញ ហើយការប្រែប្រួលគឺត្រូវទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត។

សមាសភាពនៃហ៊ុនភាគតិចនៅក្នុងក្រុមហ៊ុនលក់ ដែលតំណាងឲ្យម្ចាស់កម្មសិទ្ធិ ហើយដែលផ្តល់សិទ្ធិឲ្យម្ចាស់ភាគហ៊ុនទទួលបាននូវចំណែកជាសមាមាត្រនៃទ្រព្យសកម្មពិតរបស់អង្គភាព នៅក្នុងព្រឹត្តិការណ៍ជំរះបញ្ជី ត្រូវបានវាស់វែងជាលើកដំបូងតាមតម្លៃទីផ្សារសមស្រប។ សមាសភាពផ្សេងទៀត នៃហ៊ុនភាគតិច គួរតែវាស់វែងតាមតម្លៃទីផ្សារសមស្របនៅថ្ងៃទិញ លើកលែងតែមានការទាមទារដោយ ស.រ.ហ.អ.កឲ្យប្រើប្រាស់មូលដ្ឋាននៃការវាស់វែងជាក់លាក់មួយ។ ជម្រើសមូលដ្ឋាននៃការវាស់វែង គឺធ្វើឡើងដោយមូលដ្ឋានការរួមបញ្ចូលគ្នា។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង តម្លៃយោងពិតគណនេយ្យហ៊ុនភាគតិច គឺជាចំនួនភាគហ៊ុននៅពេលទទួលស្គាល់លើកដំបូង បូកជាមួយផ្នែកទទួលបានពីបំរែបំរួលជាបន្តបន្ទាប់នៅក្នុងមូលធន។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៣ ការរួមបញ្ចូលគ្នានៃអាជីវកម្ម (ត)

តម្លៃលើសពីផលសរុបនៃតម្លៃទីផ្សារសមស្របរបស់តម្លៃតបស្នង ដែលបានបញ្ចូលទៅក្នុងការរួមបញ្ចូលនៃអាជីវកម្ម ទឹកប្រាក់នៃហ៊ុនភាគតិច (ប្រសិនបើមាន) និងតម្លៃទីផ្សារសមស្របនៃភាគហ៊ុនពីមុនរបស់សម្ព័ន្ធនៅក្នុងក្រុមហ៊ុនលក់ (ប្រសិនបើមាន) ទៅលើតម្លៃទីផ្សារពិត នៃទ្រព្យសកម្មដែលអាចទទួលស្គាល់បាន និងទ្រព្យអកម្មត្រូវបានកត់ត្រាជាកេរ្តិ៍ឈ្មោះជំនួញ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ក្នុងករណីដែល ចំនួនទឹកប្រាក់ពេលក្រោយលើសចំនួនពីមុន ចំនួនទឹកប្រាក់ដែលលើសនោះ ត្រូវបានទទួលស្គាល់ជាការចំណេញនៅក្នុងរបាយការណ៍ចំណេញ ឬ ខាតនៅថ្ងៃទិញនោះ។

### ៤.៤ ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រនិង បរិក្ខារទាំងអស់ត្រូវបានកត់ត្រាតាមតម្លៃដើមដោយដកចេញនូវការកាត់រំលស់ និងការខាតបង់លើការថយចុះតំលៃនៃទ្រព្យសម្បត្តិ។ តម្លៃដើមរាប់បញ្ចូលនូវការចំណាយទាំងអស់ដែលទាក់ទងផ្ទាល់ នឹងការទិញទ្រព្យសកម្មទាំងនោះ ។

ចំណាយបន្ទាប់ ត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃពិតគណនេយ្យ របស់ទ្រព្យសកម្មទាំងនោះ ឬទទួលស្គាល់ជាទ្រព្យសកម្មមួយផ្សេងទៀត នៅពេលដែលទ្រព្យសកម្មនេះ មានលទ្ធភាពផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច នៅពេលអនាគតដល់សម្ព័ន្ធ ហើយតម្លៃនោះអាចវាស់វែងបានត្រឹមត្រូវ។ រាល់ការចំណាយបន្ទាប់បន្សំ សម្រាប់ការផ្លាស់ប្តូរបំណែកនៃទ្រព្យសកម្ម ត្រូវទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។ តម្លៃសេវាកម្មប្រចាំថ្ងៃរបស់ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ ក៏ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលចំណាយនោះបានកើតឡើងផងដែរ។ ថ្លៃដើមក៏រួមបញ្ចូលទាំងការប៉ាន់ស្មានជាលើកដំបូងនៃការយក ឬដោះចេញនូវទ្រព្យសកម្ម និងដំឡើងវាឡើងវិញទៅតាមកន្លែងដែលវាតាំងនៅសម្រាប់សម្ព័ន្ធនៅពេលដែលទ្រព្យសកម្មនោះត្រូវបានទិញប្រសិនបើមាន។

ផ្នែកនីមួយៗនៃទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារដែលមានតម្លៃដើមជាសារវន្តធៀបនឹងតម្លៃសរុបនៃទ្រព្យទាំងនោះ និងមានអាយុកាលប្រើប្រាស់ផ្សេង ត្រូវបានរំលស់ដោយឡែក។ ក្រោយការទទួលស្គាល់ជាលើកដំបូង ទ្រព្យសកម្មត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និង ការខាតបង់លើការថយចុះតំលៃនៃទ្រព្យសម្បត្តិផ្សេងៗ។

រំលស់ទៅលើទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារត្រូវបានគណនា ដោយបែងចែកថ្លៃដើម នៃទ្រព្យទាំងនោះ ដកតម្លៃកាកសំណល់តាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មទាំងនោះ។ អាយុកាលនៃគោលការណ៍រំលស់ មានដូចខាងក្រោម៖

| | |
|---|---|
| អាគារ និង ហេដ្ឋារចនាសម្ព័ន្ធ | ២០ ឆ្នាំ |
| គ្រឿងយន្ត | ១០ ឆ្នាំ |
| យានយន្ត បរិក្ខារ និង កំព្យូទ័រ | ៣ - ៥ ឆ្នាំ |

ដីមានអាយុកាលអមតៈ ហើយមិនធ្វើការរំលស់ទេ។ ការសាងសង់ដែលកំពុងដំណើរការ បង្ហាញពីថ្លៃដើមផ្ទាល់នៃអាគារ និង ហេដ្ឋារចនាសម្ព័ន្ធ ហើយត្រូវបានកំណត់ជាថ្លៃដើម។ ការសាងសង់ដែលកំពុងដំណើរការ គឺមិនត្រូវបានធ្វើរំលស់ទេ រហូតដល់ទ្រព្យសកម្មនោះ អាចប្រើប្រាស់បាន។

នៅរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ តម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មទាំងអស់ ត្រូវបានប៉ាន់ស្មានអំពីការខាតបង់លើការថយចុះតំលៃនៃទ្រព្យសម្បត្តិនៅពេលដែលមានព្រឹត្តិការណ៍ ឬបំលាស់ប្តូរណាមួយកើតឡើង ដែលធ្វើឲ្យបាត់បង់តម្លៃពិតគណនេយ្យនៃទ្រព្យទាំងនោះ។ ការខាតបង់លើការថយចុះតំលៃនៃទ្រព្យសម្បត្តិនឹងត្រូវបានទទួលស្គាល់ នៅពេលតម្លៃពិតគណនេយ្យលើសពីតម្លៃដែលអាចប្រមូលបាន (យោងទៅកំណត់សម្គាល់លេខ ៤.៨ ស្តីពី ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៤ ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ (ត)

តម្លៃកាកសំណល់នៃទ្រព្យសកម្ម អាយុកាលប្រើប្រាស់ និង វិធីសាស្ត្ររំលស់ ត្រូវបានពិនិត្យឡើងវិញនៅរៀងរាល់ចុងការិយបរិច្ឆេទ ដើម្បីធានាថា ចំនួនវិធីសាស្ត្រ និងរយៈពេលរំលស់មិនប្រែប្រួល បើធៀបទៅនឹងការប៉ាន់ស្មានទុកមុន និងទម្រង់នៃការប្រើប្រាស់ដែលរំពឹងទុកនៃអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតរបស់ទ្រព្យសកម្មទាំងនោះ។ ប្រសិនបើការរំពឹងទុក ខុសពីការប៉ាន់ស្មានពីមុន ការប្រែប្រួលបែបនេះ ត្រូវបានចាត់ទុកជាការផ្លាស់ប្តូរ ក្នុងគណនេយ្យប៉ាន់ស្មាន។

តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ត្រូវបានឈប់ទទួលស្គាល់នៅពេលលក់ ឬ នៅពេលមិនមាន អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតបន្តទៀត។ ចំនួនខុសគ្នារវាងតម្លៃទទួលបានពីការលក់ ប្រសិនបើមាន និង តម្លៃពិតគណនេយ្យត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### ៤.៥ ទ្រព្យសម្បត្តិវិនិយោគ

ទ្រព្យសម្បត្តិវិនិយោគ គឺជាទ្រព្យសម្បត្តិដែលកាន់កាប់ដើម្បីទទួលបានជាប្រាក់ឈ្នួល ឬក៏ទុកបង្កើនមូលធន ឬទាំងពីរ និងមិនត្រូវបានប្រើប្រាស់ដោយសម្ព័ន្ធ។ ទ្រព្យសម្បត្តិវិនិយោគក៏រួមបញ្ចូលផងដែរនូវ ទ្រព្យដែលកំពុងត្រូវបានសាងសង់ ឬ អភិវឌ្ឍន៍សម្រាប់ប្រើប្រាស់ទៅថ្ងៃអនាគត។ ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានវាស់វែងនៅគ្រាដំបូងទៅតាមថ្លៃដើមរបស់វា បូករួមទាំងតម្លៃប្រតិបត្តិការ ដករំលស់បង្គរ និងការខាតបង់លើការថយចុះតំលៃនៃទ្រព្យសម្បត្តិ។

ថ្លៃដើមបន្ទាប់បន្សំ ត្រូវបានដាក់បញ្ចូលក្នុងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម ឬ ទទួលជាទ្រព្យសកម្មដាច់ដោយឡែកតាមភាពសមស្រប នៅពេលដែលថ្លៃដើមនោះកើតឡើង ហើយមានការរំពឹងថានឹងអាចផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់សម្ព័ន្ធ និងថ្លៃដើមនៃទ្រព្យវិនិយោគ អាចត្រូវបានវាស់វែងដោយជឿជាក់បាន។ តម្លៃពិតគណនេយ្យ របស់ផ្នែកណាមួយដែលត្រូវបានផ្លាស់ប្តូរត្រូវបានឈប់ទទួលស្គាល់។ ចំណាយប្រចាំថ្ងៃលើសេវាកម្មរបស់ទ្រព្យសម្បត្តិវិនិយោគត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលចំណាយនោះកើតឡើង។ ថ្លៃដើមក៏បូកបញ្ចូល ផងដែរនូវការប៉ាន់ស្មានដំបូងនូវតម្លៃនៃការរំលស់ ការដកចេញនៃទ្រព្យសកម្ម និងការស្តារឡើងវិញនៃតំបន់ដែលទ្រព្យសកម្មនោះតាំងនៅដែលសម្ព័ន្ធមានកាតព្វកិច្ច នៅពេលដែលទ្រព្យសម្បត្តិវិនិយោគត្រូវបានសាងសង់ ប្រសិនបើមាន។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានកត់ត្រាតាមថ្លៃដើមរបស់វា បូករួមទាំងតម្លៃប្រតិបត្តិការ ដករំលស់បង្គរ និងការខាតបង់លើការថយចុះតំលៃនៃទ្រព្យសម្បត្តិប្រសិនបើមាន។

រំលស់ត្រូវបានធ្វើការគណនាដើម្បីលុបចោលថ្លៃដើម ឬវាយតម្លៃលើទ្រព្យសម្បត្តិវិនិយោគ ជាតម្លៃកាកសំណល់តាមវិធីសាស្ត្ររំលស់ថេរ ទៅលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាន។ អាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានកំណត់ចន្លោះពី ២០ ទៅ ៥០ ឆ្នាំ។

នៅចុងការិយបរិច្ឆេទនីមួយៗ តម្លៃពិតគណនេយ្យនៃទ្រព្យសម្បត្តិវិនិយោគមួយ ត្រូវបានធ្វើការវាយតម្លៃ ដើម្បីស្វែងរកមើលពីឱនភាព ឬនៅពេលដែលមានព្រឹត្តិការណ៍ ឬមានការផ្លាស់ប្តូរកាលៈទេសៈណាមួយ ដែលអាចជាកត្តាសង្ស័យថា តម្លៃពិតគណនេយ្យរបស់វាអាចនឹងស្រង់មកវិញមិនបាន។ ការកាត់បន្ថយត្រូវបានធ្វើឡើងប្រសិនបើតម្លៃពិតគណនេយ្យរបស់វាលើសពីចំនួនដែលអាចស្រង់មកវិញ (យោងកំណត់សម្គាល់លេខ៤.៨ ស្តីពី ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)។

តម្លៃកាកសំណល់នៃទ្រព្យសកម្មរយៈពេលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ ត្រូវបានពិនិត្យឡើងវិញនៅរាល់ចុងការិយបរិច្ឆេទដើម្បីធានាថា ចំនួន វិធីសាស្ត្រ និងរយៈពេលរំលស់មិនប្រែប្រួល បើធៀបទៅនឹងការប៉ាន់ស្មានពីមុន និងទម្រង់នៃការប្រើប្រាស់ដែលរំពឹងទុកនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្មទាំងនោះ។ ប្រសិនបើការរំពឹងទុកខុសពីការប៉ាន់ស្មានពីមុន ការប្រែប្រួលបែបនេះត្រូវបានចាត់ទុកជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៥ ទ្រព្យសម្បត្តិវិនិយោគ(ត)

ទ្រព្យសម្បត្តិវិនិយោគនឹងត្រូវឈប់ទទួលស្គាល់ នៅពេលលក់ចេញ ឬ នៅពេលដែលទ្រព្យសម្បត្តិវិនិយោគត្រូវបានដកចេញ ទាំងស្រុងពីការប្រើប្រាស់ និងគ្មានផលប្រយោជន៍ខាងសេដ្ឋកិច្ចនាពេលអនាគត ត្រូវបានសង្ឃឹមទុកពីការលក់របស់ទ្រព្យនោះ។ ចំណេញ ឬខាតកើតឡើងពីការចូលនិវត្តន៍ ឬ លក់ចេញនៃទ្រព្យវិនិយោគ នឹងត្រូវកំណត់ថា ជាភាពខុសគ្នារវាង ទឹកប្រាក់លក់បានសុទ្ធ និងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនោះ នឹងត្រូវទទួលស្គាល់ជាចំណេញ ឬ ខាត ក្នុងការិយបរិច្ឆេទនៃការចូលនិវត្តន៍ ឬ ការលក់ចេញនោះ។

### ៤.៦ ការនិយោគ

#### (ក) ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គភាពដែលសម្ព័ន្ធ និងក្រុមហ៊ុនមានអំណាចក្នុងការគ្រប់គ្រង ឬមានសិទ្ធិក្នុងការទទួលបាននូវ ប្រាក់ចំណេញអថេរពីការចូលរួមជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ និងមានលទ្ធភាពក្នុងការជះឥទ្ធិពលទៅលើប្រាក់ចំណេញតាមរយៈសិទ្ធិអំណាចដែលមានទៅលើក្រុមហ៊ុន។

ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលលុបបំបាត់នៅលើរបាយការណ៍រួម ត្រូវបានធ្វើឡើងដាច់ដោយឡែកនៅក្នុងរបាយការណ៍របស់ក្រុមហ៊ុននៅថ្លៃដើម។ សិទ្ធិលក់ហ៊ុនរបស់ហ៊ុនភាគតិច ចំពោះការទិញក្រុមហ៊ុនបុត្រសម្ព័ន្ធ គួរចាត់ទុកជាផ្នែកមួយនៃថ្លៃដើមវិនិយោគដាច់ដោយឡែកនៅក្នុងការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ការផ្លាស់ប្តូរជាបន្តបន្ទាប់នូវតម្លៃទីផ្សារសមស្របនៃការកត់ត្រាលើហ៊ុនភាគតិច គួរតែទទួលស្គាល់នៅក្នុង របាយការណ៍ចំណេញ ឬខាត។ ការកត់ត្រាការវិនិយោគនៃថ្លៃដើមទាំងអស់គួរកត់ត្រាដោយអនុលោមទៅតាម ស.រ.ហ.អ.ក ៥ *ការកាន់កាប់ទ្រព្យអកម្មសម្រាប់លក់ និងប្រតិបត្តិការមិនបន្ត* នៅពេលពួកវាត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ (ឬរួមបញ្ចូលនៅក្នុងក្រុមទ្រព្យលក់ ដែលចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់) ដែលអនុលោមនៅក្នុង ស.រ.ហ.អ.ក ៥។

នៅពេលការគ្រប់គ្រងនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមានការបាត់បង់ជាលទ្ធផលពីប្រតិបត្តិការ ព្រឹត្តិការណ៍ឬស្ថានភាពដទៃផ្សេងទៀត សម្ព័ន្ធគួរដកចេញនូវទ្រព្យសកម្ម ទ្រព្យអកម្ម និងហ៊ុនភាគតិចទាំងអស់តាមតម្លៃយោងពិតគណនេយ្យរបស់ពួកវា និងធ្វើការទទួលស្គាល់ឡើងវិញតាមតម្លៃទីផ្សារសមស្របនូវតម្លៃតបស្នងដែលទទួលបាន។ ភាគហ៊ុននៅសល់ផ្សេងទៀតនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺត្រូវបានទទួលស្គាល់នូវតម្លៃពិតទីផ្សារនៅថ្ងៃដែលសិទ្ធិគ្រប់គ្រងត្រូវបាត់បង់។ លទ្ធផលខុសគ្នាត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

#### (ខ) ញាតិសម្ព័ន្ធ

ញាតិសម្ព័ន្ធ គឺជាអង្គភាពដែលស្ថិតនៅក្រោមឥទ្ធិពលសំខាន់របស់សម្ព័ន្ធ និងក្រុមហ៊ុន និងមិនមែនជាបុត្រសម្ព័ន្ធ ឬជាការវិនិយោគក្នុងការរកស៊ីចូលហ៊ុនគ្នា។ ឥទ្ធិពលសំខាន់គឺជាអំណាចក្នុងការចូលរួម ក្នុងការសំរេចគោលការណ៍ហិរញ្ញវត្ថុ និងគោលការណ៍ប្រតិបត្តិការរបស់អ្នកទទួលប្រាក់វិនិយោគ ប៉ុន្តែមិនមែនជាការគ្រប់គ្រង ឬការគ្រប់គ្រងជារួមលើគោលការណ៍ទាំងនោះទេ។

ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយប្រើវិធីមូលធនផ្ទាល់នៃគណនេយ្យ។ ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃដើម និងក្រោយមកត្រូវបានធ្វើនិយ័តកម្មដើម្បីកែបម្រែបម្រួលនៃចំណែករបស់ទ្រព្យ និងការវិនិយោគទ្រព្យសកម្មដុលនៃភាគហ៊ុនរបស់សម្ព័ន្ធដែលត្រូវទទួលបាន ក្រោយការទិញយកក្រុមហ៊ុន ញាតិសម្ព័ន្ធនោះ ។

# ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## ៤.៦ ការនិយោគ (ត)

### (ខ) ញាតិសម្ព័ន្ធ (ត)

ភាគហ៊ុននៃការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ គឺជាតម្លៃពិតគណនេយ្យនៃការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធតាមវិធីមូលធនផ្ទាល់ ជាមួយនឹងសិទ្ធិរយៈពេលវែង ដែលជាផ្នែកនៃការវិនិយោគក្នុង ក្រុមហ៊ុនញាតិសម្ព័ន្ធរបស់សម្ព័ន្ធ។ របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការិយបរិច្ឆេទ បានបូកបញ្ចូលទាំងរបាយការណ៍លទ្ធផលរបស់សម្ព័ន្ធ ពីការវិនិយោគនៅក្នុងញាតិសម្ព័ន្ធ ក្រោយពីមាននិយ័តកម្ម ដើម្បីដាក់បញ្ចូលគោលការណ៍គណនេយ្យរបស់ញាតិសម្ព័ន្ធ ជាមួយនឹងគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធ ចាប់ពីថ្ងៃដែលមានឥទ្ធិពលរហូតដល់ថ្ងៃដែលឥទ្ធិពលនោះបញ្ចប់។ ចំណែកដែលទទួលបានពីញាតិសម្ព័ន្ធ បានធ្វើឲ្យតម្លៃពិតនៃការវិនិយោគថយចុះ។ និយ័តកម្មទៅលើតម្លៃពិតរបស់ទ្រព្យសកម្ម អាចជាដើមហេតុនៃការផ្លាស់ប្តូរចំណែកហ៊ុនរបស់សម្ព័ន្ធ នៅក្នុងញាតិសម្ព័ន្ធដោយសារតែការផ្លាស់ប្តូរមូលធនផ្ទាល់របស់ញាតិសម្ព័ន្ធ ដែលពុំទាន់បានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលរបស់ញាតិសម្ព័ន្ធ។ មូលហេតុនៃការផ្លាស់ប្តូរទាំងនេះរួមបញ្ចូលទាំងការវាយតំលៃឡើងវិញនូវទ្រព្យសម្បត្តិ និងបរិក្ខារ និងដោយសារការខុសគ្នាពីការប្តូរអត្រាការប្រាក់បរទេស។ ចំណែកនៃការប្រែប្រួលទាំងអស់នេះចំពោះក្រុមហ៊ុន ត្រូវបានគិតបញ្ចូលដោយផ្ទាល់ទៅក្នុងមូលធនរបស់ក្រុមហ៊ុន។

ប្រាក់ចំណេញ និងខាតដែលមិនទាន់ទទួលស្គាល់ទៅលើប្រតិបត្តិការរវាងសម្ព័ន្ធ និងញាតិសម្ព័ន្ធ ត្រូវបានជំរះទៅតាមចំណែកហ៊ុនរបស់សម្ព័ន្ធនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធទៅតាមករណី ដែលគ្មានការថយចុះតំលៃទ្រព្យសម្បត្តិ។

នៅពេលដែលប្រាក់ ខាតរបស់សម្ព័ន្ធពីការវិនិយោគនៅក្នុងញាតិសម្ព័ន្ធស្មើ ឬលើសពីហ៊ុនរបស់ក្រុមហ៊ុននៅក្នុងញាតិសម្ព័ន្ធ តម្លៃពិតនៃហ៊ុននោះនឹងធ្លាក់នៅសូន្យ ហើយក្រុមហ៊ុនមិនទទួលស្គាល់ប្រាក់ខាតជាបន្តលុះត្រាតែមានកាតព្វកិច្ចតាមច្បាប់ ឬមានប្រយោជន៍ ឬមានការបង់ប្រាក់ជំនួស។

របាយការណ៍ហិរញ្ញវត្ថុថ្មីបំផុតរបស់ញាតិសម្ព័ន្ធដែលអាចរកបាន គឺត្រូវបានប្រើប្រាស់ដោយសម្ព័ន្ធ តាមវិធីសាស្ត្រមូលធន។ នៅចុងការិយបរិច្ឆេទនៃការរាយការណ៍របាយការណ៍ហិរញ្ញវត្ថុមិនដូចគ្នា លទ្ធផលគឺទទួលបានពីការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មចុងក្រោយបង្អស់ ដែលគំលាតនៅចុងការិយបរិច្ឆេទនីមួយៗមិនលើសពី៣ខែ។ និយ័តកម្ម គឺធ្វើឡើងលើពេលដែលមានផលប៉ះពាល់ពីប្រតិបត្តិការសំខាន់ៗ ឬព្រឹត្តិការណ៍ដែលកើតឡើងរវាងចន្លោះការិយបរិច្ឆេទមួយៗ។

នៅពេលសម្ព័ន្ធឈប់មានឥទ្ធិពលសំខាន់ៗទៅលើសម្ព័ន្ធញាត្តិ ប្រាក់ចំណេញផ្សេងទៀតដែលនៅសល់នៅក្នុងអតីតសម្ព័ន្ធញាត្តិនៅថ្ងៃដែលបាត់បង់ឥទ្ធិពលសំខាន់ៗនោះ ត្រូវបានវាស់វែងនៅតម្លៃទីផ្សារសមស្របនិងចំនួនទៅតាមតម្លៃយោងពិតគណនេយ្យដំបូងនៃទ្រព្យហិរញ្ញវត្ថុមួយ។ ចំនួនដែលខុសគ្នារវាងតម្លៃទីផ្សារសមស្របនៃប្រាក់ចំណេញដែលទទួលបាន បូករួមនឹងការបន្តការបោះបង់សិទ្ធិ និងតម្លៃយោងពិតគណនេយ្យនៃថ្ងៃវិនិយោគ នៅពេលដែលវិធីសាស្ត្រមូលធនឈប់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

នៅពេលដែលភាគរយកាន់កាប់នៃសម្ព័ន្ធនៅក្នុងសម្ព័ន្ធញាត្តិធ្លាក់ចុះ ប៉ុន្តែមិនមានការបាត់បង់នៅក្នុងឥទ្ធិពលសំខាន់ៗ ប្រាក់ចំណេញដែលនៅសល់ផ្សេងទៀតមិនត្រូវបានវាស់វែងឡើងវិញទេ។ ការចំណេញ ឬខាតផ្សេងៗដែលកើតពីការធ្លាក់ចុះនៃការកាន់កាប់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ការចំណេញ ឬខាតផ្សេងៗដែលទទួលស្គាល់ក្នុងប្រាក់ចំណេញទូទៅផ្សេងៗពីមុនៗមក ក៏ត្រូវបានធ្វើការចាត់ថ្នាក់ឡើងវិញដោយសមាមាត្រទៅរបាយការណ៍ចំណេញ ឬខាត ប្រសិនបើការកើនឡើង ឬថយចុះត្រូវតម្រូវឲ្យធ្វើការចាត់ថ្នាក់ឡើងវិញទៅក្នុងរបាយការណ៍ចំណេញ ឬខាតនៅលើការលក់នៃទ្រព្យ ឬទ្រព្យអកម្មដែលពាក់ព័ន្ធ។

នៅពេលដែលមានការលក់ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ភាពខុសគ្នារវាងទឹកប្រាក់ទទួលបាន ពីការលក់ និងតម្លៃពិតគណនេយ្យរបស់វា ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៧ សន្និធិ

សន្និធិភាគច្រើនជាដីតំកល់ទុកសំរាប់លក់ ដែលត្រូវបានបង្ហាញ តាមតម្លៃទាបជាង និងតម្លៃលក់ពិត។

ថ្លៃដើមត្រូវបានកំណត់ ដោយប្រើប្រាស់វិធីសាស្ត្រមូលដ្ឋានមធ្យម។ ថ្លៃដើមរួមមាន ថ្លៃដើមលើការទិញ ថ្លៃដើមនៃការបំលែង បូករួមថ្លៃដើមក្នុងការដឹកជញ្ជូនសន្និធិមកទីតាំង និងលក្ខខណ្ឌបច្ចុប្បន្ន។

តម្លៃលក់ពិត គឺជាតម្លៃលក់ប៉ាន់ស្មានក្នុងដំណើរការអាជីវកម្មធម្មតា ដកថ្លៃដើមប៉ាន់ស្មាននៃការសម្រេចឲ្យបានផលិតផល និងចំណាយប៉ាន់ស្មានចាំបាច់ក្នុងការលក់។

ដីតំកល់ទុកសំរាប់លក់គឺរួចរាល់សំរាប់ការលក់ភ្លាមៗក្នុងលក្ខខណ្ឌបច្ចុប្បន្ន ហើយនឹងអាចទទួលបានមកវិញតាមរយៈការលក់ ជាជាងការបន្តប្រើប្រាស់។

### ៤.៨ ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃពិតគណនេយ្យ នៃទ្រព្យសកម្ម លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុ (មិនរាប់បញ្ចូល ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ និងញាត្តិសម្ព័ន្ធ) និង សន្និធិត្រូវពិនិត្យឡើងវិញ នៅរៀងរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីកំណត់ថាតើមានសញ្ញានៃឱនភាពដែលអាចកើតឡើងឬទេ។ ប្រសិនបើមានតម្លៃដែលអាចស្តារបាននឹងត្រូវប៉ាន់ស្មាន ។

តម្លៃដែលអាចស្តារបាននៃទ្រព្យសកម្មនីមួយៗ ត្រូវបានប៉ាន់ស្មានដាច់ដោយឡែកពីគ្នា។ ករណីដែលតម្លៃដែលអាចស្តារបាននៃទ្រព្យសកម្មមួយ មិនអាចប៉ាន់ស្មានដោយឡែក ការប៉ាន់ស្មានលើឱនភាពនឹងធ្វើឡើងជាក្រុមបង្កើនសាច់ប្រាក់ ("CGU") ដែលទ្រព្យសកម្មនោះស្ថិតនៅក្នុង។

តម្លៃដែលអាចស្តារបាននៃទ្រព្យសកម្ម ឬ ក្រុមទ្រព្យសកម្ម គឺតម្លៃដែលខ្ពស់ជាងរវាងតម្លៃទីផ្សារ ដកចំណាយការលក់ និងតម្លៃនៅបន្តប្រើប្រាស់។

ក្នុងការកំណត់តម្លៃនៅបន្តប្រើប្រាស់ លំហូរសាច់ប្រាក់ចេញ និងចូលដែលបានមកពី ការប្រើប្រាស់បន្ត និងពីការលក់ចុងក្រោយដែលបានធ្វើអប្បហារនៅត្រឹមតម្លៃបច្ចុប្បន្ន ដោយប្រើអប្បហារអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការវិភាគទីផ្សារបច្ចុប្បន្ននៃតម្លៃប្រាក់គិតតាមពេលវេលា និង ហានិភ័យដែលពាក់ព័ន្ធជាក់លាក់នឹងទ្រព្យសកម្ម ដែលលំហូរប៉ាន់ស្មាននាពេលអនាគតមិនបានធ្វើអប្បហារ។ ការខាតបង់ពីឱនភាពគឺ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលនៅពេលដែល តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្ម មានតម្លៃខ្ពស់ជាងតម្លៃដែលអាចស្តារបាន។ ការខាតបង់ពីឱនភាពទាំងអស់របស់ក្រុមទ្រព្យសកម្ម ("CGU") ត្រូវបែងចែងតាមមូលដ្ឋានសមាមាត្រ តាមតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មនីមួយៗក្នុងក្រុម។

កំហាតបង់ឱនភាពត្រូវបានកត់ត្រាឡើងវិញ លុះត្រាណាមានបម្រែបម្រួលការប៉ាន់ស្មានដែលបានប្រើប្រាស់ដើម្បីកំណត់តម្លៃ ដែលអាចស្តារបានរបស់ទ្រព្យសកម្ម ចាប់តាំងពីកំហាតឱនភាពត្រូវបានទទួលស្គាល់ចុងក្រោយ។

ការខាតបង់ពីឱនភាពនៃទ្រព្យសកម្មផ្សេងៗ អាចត្រូវបានកត់ត្រឡប់មកវិញ តែក្នុងករណីដែលមានការផ្លាស់ប្តូរវិធីសាស្ត្រប៉ាន់ស្មាន ក្នុងការកំណត់តម្លៃដែលអាចស្តារបាននៃទ្រព្យសកម្ម នោះចាប់តាំងពីការខាតបង់ពីឱនភាពត្រូវបានទទួលស្គាល់ចុងក្រោយតែប៉ុណ្ណោះ និង តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម មិនលើសពីតម្លៃពិតគណនេយ្យដែលបានកំណត់ដករំលស់ ប្រសិនបើមិនមានការខាតបង់ពីឱនភាពត្រូវបានទទួលស្គាល់។ ការកត់ត្រឡប់មកវិញបែបនេះ ត្រូវកត់ត្រាជាចំណូលនៅក្នុងរបាយការណ៍ចំណេញ ឬខាតភ្លាមៗ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៩ ភតិសន្យាប្រតិបត្តិការ

ភតិសន្យាមួយអាចចាត់ទុកជាភតិសន្យាប្រតិបត្តិការ ប្រសិនបើមិនមានការផ្ទេរទាំងស្រុងនូវរាល់ហានិភ័យ និងផលប្រយោជន៍ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ។

ថ្លៃឈ្នួលកិច្ចសន្យាក្រោមភតិសន្យាប្រតិបត្តិការ ត្រូវទទួលស្គាល់ជាចំណាយតាមវិធីសាស្ត្រថេរ ក្នុងអំឡុងពេលនៃភតិសន្យានោះ។

### ៤.១០ ឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុ គឺជាកិច្ចសន្យាទាំងឡាយណាដែលបង្កើនទ្រព្យសកម្មហិរញ្ញវត្ថុនៃសហគ្រាសមួយ ហើយបង្កើតជាឧបករណ៍មូលធន ឬ បំណុលហិរញ្ញវត្ថុនៃសហគ្រាសដទៃទៀត ។

ទ្រព្យសកម្មហិរញ្ញវត្ថុរួមមាន សាច់ប្រាក់ ឧបករណ៍មូលធននៃសហគ្រាសដទៃទៀត សិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលបានសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀតពីសហគ្រាសដទៃមួយទៀត ឬ សិទ្ធិក្នុងការដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុ ក្រោមលក្ខខណ្ឌជាប្រយោជន៍ដល់សម្ព័ន្ធ។

បំណុលហិរញ្ញវត្ថុគឺជាបំណុលទាំងឡាយណាដែលមានកាតព្វកិច្ចកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀតទៅឲ្យសហគ្រាសមួយទៀត ឬ កាតព្វកិច្ចកិច្ចសន្យាក្នុងការដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុក្រោមលក្ខខណ្ឌមិនជាប្រយោជន៍ដល់សម្ព័ន្ធ ។

ឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលសម្ព័ន្ធបានក្លាយទៅជា ភាគីមួយដែលមានកាតព្វកិច្ចកិច្ចសន្យាផ្តល់ ឬ ទទួលឧបករណ៍ហិរញ្ញវត្ថុទាំងនោះ ។ ឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់តាមតម្លៃទីផ្សាររួមទាំងចំណាយប្រតិបត្តិការ ដែលទាក់ទងផ្ទាល់ទៅនឹងការទិញ ឬ បង្កើតឧបករណ៍ហិរញ្ញវត្ថុទាំងនោះ ក្នុងករណីឧបករណ៍ហិរញ្ញវត្ថុ មិនវាស់វែងតាមតម្លៃទីផ្សារជាចំណេញ ឬ ខាត ។

ដេរីវេទីវដែលអែបជាប់ត្រូវបានបែងចែកដោយឡែកពីកិច្ចសន្យាកម្មសិទ្ធិ និង ត្រូវបានទទួលស្គាល់ជាដេរីវេទីវ ប្រសិនបើលក្ខណៈសេដ្ឋកិច្ច និង ហានិភ័យនៃដេរីវេទីវនេះ មិនពាក់ព័ន្ធជិតស្និទ្ធទៅនឹងលក្ខណៈសេដ្ឋកិច្ច និង ហានិភ័យនៃកិច្ចសន្យាកម្មសិទ្ធិ ឧបករណ៍ដោយឡែកដែលមានលក្ខខណ្ឌដូចគ្នាទៅនឹងដេរីវេទីវ អាចចាត់ទុកជាដេរីវេទីវ ហើយដេរីវេទីវកូនកាត់នេះមិនត្រូវបានកត់ត្រាតាមតម្លៃទីផ្សារជាចំណេញ ឬខាតឡើយ ។

#### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានបែងចែកជាបួនថ្នាក់ បន្ទាប់ពីការទទួលស្គាល់ដំបូង សម្រាប់ការវាស់វែងបន្តបន្ទាប់ដូចខាងក្រោម៖

##### (១) ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃទីផ្សារជាចំណេញ ឬខាត

ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃទីផ្សារជាចំណេញ ឬខាតរួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុដែលទុកសម្រាប់ធ្វើពាណិជ្ជកម្ម (ឧទាហរណ៍៖ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលទិញសម្រាប់គោលបំណងលក់វិញក្នុងរយៈពេលខ្លី) ដេរីវេទីវ (ទាំងមិនពាក់ព័ន្ធ និងបានបង្កប់) និងទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ក្នុងការបែងចែកនេះអាស្រ័យលើការទទួលស្គាល់ដំបូង។

បន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានបែងចែកជាតម្លៃទីផ្សារក្នុងចំណេញ ឬខាត ត្រូវបានវាស់វែងតាមតម្លៃទីផ្សារ។ ចំណេញ ឬខាត ដែលបានមកពីការផ្លាស់ប្តូរតម្លៃទីផ្សារ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។ ចំណេញ ឬខាតសុទ្ធ លើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបែងចែកជាតម្លៃទីផ្សារតាមរយៈការចំណេញ ឬខាត មិនរាប់បញ្ចូលចំណេញ ឬខាតលើអត្រាប្តូរប្រាក់បរទេស ការប្រាក់ និងចំណូលភាគលាភទេ។ ចំណូលទាំងនេះ ត្រូវបានទទួលស្គាល់ ដាច់ពីគ្នានៅក្នុងរបាយការណ៍លទ្ធផលជាសមាសភាគនៃចំណូលផ្សេងៗ ឬកំហាតប្រតិបត្តិការផ្សេងៗ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១០ ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

**(១) ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃទីផ្សារជាចំណេញ ឬខាត (ត)**

ប៉ុន្តែដេរីវេទីវដែលទាក់ទង ហើយដាច់ខាតធ្វើការទូរទាត់ដោយបញ្ជូនឧបករណ៍មូលធនដែលមិនបានស្រង់ ដែលគ្មានតម្លៃនៅលើទីផ្សារសកម្ម ត្រូវបានទទួលស្គាល់ជាថ្លៃដើមទាំងអស់។

**(២) ការវិនិយោគ ដែលរក្សាទុកដល់កាលកំណត់**

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានបែងចែកជា ការវិនិយោគដែលរក្សាទុកដល់កាលកំណត់រួមមានទ្រព្យសកម្មហិរញ្ញវត្ថុមិនមែនដេរីវេទីវ ដែលការបង់ប្រាក់មានលក្ខណៈថេរ ឬអាចកំណត់បាន ដែលមិនបានកំណត់នៅក្នុងទីផ្សារសកម្ម។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានចាត់ថ្នាក់ជាការវិនិយោគដែលរក្សាទុកដល់កាលកំណត់ ត្រូវបានវាស់វែងតាមថ្លៃដើមដែលបាន រំលស់ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធភាព។ ចំណេញ ឬខាតលើ ទ្រព្យសកម្មហិរញ្ញវត្ថុចាត់ថ្នាក់ជាការវិនិយោគដែល រក្សាទុកដល់កាលកំណត់ ត្រូវបានទទួលស្គាល់ក្នុង របាយការណ៍លទ្ធផលនៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុនោះ ត្រូវបានឈប់ទទួលស្គាល់ ឬមានឱនភាព និងតាមរយៈវិធីសាស្ត្ររំលស់។

**(៣) កម្ចី និងប្រាក់ត្រូវទទួល**

ទ្រព្យសកម្មហិរញ្ញវត្ថុដែលចាត់ជាកម្ចី និងប្រាក់ត្រូវទទួលរួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុមិនមែនដេរីវេទីវ ដែលមានសំណងថេរ ឬអាចកំណត់បាន ហើយមិនត្រូវបានបោះផ្សាយនៅក្នុងទីផ្សារសកម្ម។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជា កម្ចី និងប្រាក់ត្រូវទទួល ត្រូវបានវាស់វែងតាមថ្លៃដើមដែលបានរំលស់ ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធិភាព។ ចំណេញ ឬខាតលើទ្រព្យសកម្មហិរញ្ញវត្ថុចាត់ថ្នាក់ជាកម្ចី និងប្រាក់ត្រូវទទួល ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលនៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុនោះ ត្រូវបានឈប់ទទួលស្គាល់ ឬមានឱនភាព និងតាមរយៈវិធីសាស្ត្ររំលស់។

**(៤) ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់**

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលចាត់ជាទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់រួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុមិនមែនដេរីវេទីវដែលចាត់ជាសម្រាប់លក់ ឬដែលមិនបែងចែកជាកម្ចី និងប្រាក់ត្រូវទទួល ការវិនិយោគដែលរក្សាទុកដល់កាលកំណត់ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃទីផ្សារក្នុងគ្រាចំណេញ ឬខាត។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ គឺត្រូវបានវាយតម្លៃជាតម្លៃទីផ្សារ។ ប្រាក់ចំណេញ ឬខាតដែលបានមកពីការផ្លាស់ប្តូរតម្លៃទីផ្សារ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលផ្សេងៗ លើកលែងតែឱនភាព និងចំណេញ ឬខាតអត្រាការប្រាក់បរទេស រហូតដល់ទ្រព្យសកម្មត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលចំណេញ ឬខាតបង្គរដែលដំបូងទទួលស្គាល់ជាចំណូលផ្សេងៗ ហើយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល។ ប៉ុន្តែអត្រាការប្រាក់ដែលទូទាត់ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធភាព ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល ដែលស្របពេលគ្នានេះ ភាគលាភលើឧបករណ៍មូលធនផ្ទាល់សម្រាប់លក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលសិទ្ធិក្នុងការទទួលការទូទាត់របស់សម្ព័ន្ធត្រូវបានបង្កើតឡើង។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១០ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(ក) ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យធនាគារ និងបញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគរយៈពេលខ្លីផ្សេងៗដែលអាចបំលែងជាសាច់ប្រាក់យ៉ាងងាយ ជាមួយនិងអាយុកាលកំណត់តិចជាង ឬស្មើនឹង៣ខែហើយប្រឈមនឹងហានិភ័យក្នុងការផ្លាស់ប្តូរតម្លៃតិច ហើយ ត្រូវបានប្រើប្រាស់ដោយសម្ព័ន្ធក្នុងការគ្រប់គ្រងចំណាយជាប់កិច្ចសន្យារយៈពេលខ្លី។ សម្រាប់គោលបំណង ក្នុងរបាយការណ៍លំហូរសាច់ប្រាក់សាច់ប្រាក់និងសាច់ប្រាក់សមមូលត្រូវបានបង្ហាញ ដោយចេញឥណទានវិបារូប និងប្រាក់បញ្ញើបានសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែល សិទ្ធិកិច្ចសន្យាក្នុងការទទួលនូវលំហូរសាច់ប្រាក់ពីទ្រព្យសកម្មនោះហួសសុពលភាព។ នៅពេលទ្រព្យសកម្មហរិញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់ទាំងស្រុង ចំនួនខុសគ្នារវាងតម្លៃពិតគណនេយ្យនិងតម្លៃដែលអាចទទួលបាន (បូករួមទាំង ទ្រព្យសកម្មទទួលបានថ្មី ដកបំណុលឧបមារប្រសិនបើមាន) ហើយចំណេញ ឬខាតបង្គរ (ប្រសិនបើមាន) ដែលត្រូវបានទទួលស្គាល់ផ្ទាល់នៅក្នុងចំណូលផ្សេងៗ គួរតែទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

ការទិញ ឬលក់ជាទៀងទាត់គឺការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុក្រោមកិច្ចសន្យា ដែលលក្ខខណ្ឌតម្រូវឲ្យមានការផ្ទេរទ្រព្យសកម្មក្នុងថេរវេលាកំណត់មួយដែលកំណត់ដោយច្បាប់ ឬលក្ខខណ្ឌទីផ្សារឧបករណ៍ហិរញ្ញវត្ថុ។

**(ខ) បំណុលហិរញ្ញវត្ថុ**

ឧបករណ៍ហិរញ្ញវត្ថុត្រូវបានចាត់ទុកជា បំណុល ឬមូលធន យោងទៅតាមលក្ខណៈនៃកិច្ចសន្យា។ បំណុលហិរញ្ញវត្ថុត្រូវបានបែងចែកតាមប្រភេទដូចខាងក្រោម បន្ទាប់ពីការទទួលស្គាល់ដំបូងក្នុងគោលបំណងកំណត់តម្លៃបន្ទាប់៖

**(១) បំណុលហិរញ្ញវត្ថុតាមតម្លៃទីផ្សារ ជាចំណេញ ឬខាត**

បំណុលហិរញ្ញវត្ថុតាមតម្លៃទីផ្សារ ជាចំណេញ ឬខាត រួមមានបំណុលហិរញ្ញវត្ថុទុកសម្រាប់ធ្វើពាណិជ្ជកម្ម ដេរីវេទីវ (ទាំងមិនពាក់ព័ន្ធ និងបានបង្កប់) និងបំណុលហិរញ្ញវត្ថុដែលចាត់តាំងចូលទៅក្នុងការចាត់ថ្នាក់នេះ ដោយផ្អែកទៅលើការទទួលស្គាល់ដំបូង។

បន្ទាប់ពីការទទួលស្គាល់ដំបូង បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមតម្លៃទីផ្សារ តាមរយៈការចំណេញ ឬខាតត្រូវបានវាស់វែងតាមតម្លៃទីផ្សារ។ ចំណេញ ឬខាតដែលកើតចេញពីការផ្លាស់ប្តូរតម្លៃទីផ្សារនៃបំណុលហិរញ្ញវត្ថុ ដែលបានបែងចែកចាត់ថ្នាក់តាមតម្លៃទីផ្សារជាចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។ ចំណេញ ឬខាតសុទ្ធលើបំណុលហិរញ្ញវត្ថុ ដែលបែងចែកជាតម្លៃទីផ្សារជាចំណេញ ឬខាត មិនរាប់បញ្ចូលចំណេញ ឬខាតលើអត្រាប្តូរប្រាក់បរទេស ការប្រាក់ និងចំណូលភាគលាភទេ។ ចំណូលទាំងនេះ ត្រូវបានទទួលស្គាល់ដាច់ពីគ្នានៅក្នុងរបាយការណ៍លទ្ធផលជាសមាសភាគនៃចំណូល ឬការខាតនៃប្រតិបត្តិការផ្សេងៗ។

**(២) បំណុលហិរញ្ញវត្ថុផ្សេងៗ**

បំណុលហិរញ្ញវត្ថុដែលចាត់ជាបំណុលហិរញ្ញវត្ថុផ្សេងៗ រួមមានបំណុលហិរញ្ញវត្ថុមិនមែនជាដេរីវេទីវ ដែលមិនមែនរក្សាទុកសម្រាប់ការជួញដូរ ឬចាត់ជាបំណុលហិរញ្ញវត្ថុតាមតម្លៃទីផ្សារជាចំណេញ ឬខាត កាលទទួលស្គាល់ដំបូង។

បន្ទាប់ពីការទទួលស្គាល់ដំបូង បំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានវាស់វែងតាមថ្លៃដើមដែលបានរំលស់ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធភាព។ ចំណេញ ឬ ខាតពីបំណុលហិរញ្ញវត្ថុផ្សេងៗត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល នៅពេលបំណុលហិរញ្ញវត្ថុនោះត្រូវបានឈប់ទទួលស្គាល់ និងដោយប្រើវិធីសាស្ត្ររំលស់។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១០ ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ខ) បំណុលហិរញ្ញវត្ថុ (ត)

បំណុលហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលបំណុលត្រូវបានសង។ ឧទាហរណ៍ៈ នៅពេលដែលកាតព្វកិច្ចដែលចែងក្នុងកិច្ចសន្យាត្រូវបានចប់ លុបចោល ឬ ផុតកំណត់។ ការដោះដូររវាងឥណទាយិក និងឥណទាយក នូវឧបករណ៍បំណុល ដែលមានលក្ខខណ្ឌផ្សេងគ្នាជាសារវន្ត ត្រូវចាត់ទុកជាសំណងនៃបំណុលហិរញ្ញវត្ថុដើម ហើយបំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់។ ដូចគ្នាផងដែរ ការផ្លាស់ប្តូរជាសារវន្តនូវ លក្ខខណ្ឌនៃបំណុលហិរញ្ញវត្ថុដើមចាត់ទុកជាសំណងនៃបំណុលហិរញ្ញវត្ថុដើម ហើយបំណុលហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់។

ភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃបំណុលហិរញ្ញវត្ថុដែលបានសង ឬផ្ទេរទៅភាគីផ្សេងមួយទៀត និងតម្លៃតបស្នងរួមទាំងទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ដែលបានផ្ទេរ ឬបំណុលដែលបានកំណត់ ត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល។

កិច្ចសន្យាធានាហិរញ្ញវត្ថុ គឺជាកិច្ចសន្យាដែលតម្រូវឲ្យអ្នកចេញកិច្ចសន្យាបង់សំណង ឲ្យទៅម្ចាស់កម្មសិទ្ធ វាល់ការខាតបង់ដែលកើតមានឡើងដោយសារឥណាយិកណាមួយ មិនអាចធ្វើការបង់ទៅតាមពេលកំណត់អនុលោមតាមលក្ខខណ្ឌ នៃឧបករណ៍បំណុលដើម ឬលក្ខខណ្ឌនៃបំណុលដែលបានកែប្រែ។

#### (គ) មូលធន

ឧបករណ៍មូលធន គឺជាកិច្ចសន្យាទាំងឡាយណា ដែលបង្ហាញឲ្យឃើញនូវ តម្លៃកាកសំណល់នៃទ្រព្យសកម្មក្រោយពីដកនូវាល់បំណុលរបស់ក្រុមហ៊ុន។ ភាគហ៊ុនធម្មតាត្រូវបានចាត់ជាឧបករណ៍មូលធន។

ភាគហ៊ុនធម្មតាត្រូវបានកត់ត្រាតាមតម្លៃចារឹក ហើយបុព្វលាភដែលទទួលបាន លើសពីតម្លៃចារឹក ប្រសិនបើមាន ត្រូវទទួលស្គាល់ជាបុព្វលាភភាគហ៊ុន។ ទាំងភាគហ៊ុនធម្មតា និងបុព្វលាភភាគហ៊ុន ត្រូវបានចាត់ចូលជាមូលធន។ ចំណាយនៃប្រតិបត្តិការត្រូវទទួលស្គាល់ជាតំហយពីមូលធន ដករាល់អត្ថប្រយោជន៍ដែលបានអំពីពន្ធលើប្រាក់ចំណូលដែលពាក់ព័ន្ធ។ មិនដូច្នោះទេ ត្រូវកត់ចូលក្នុងរបាយការណ៍លទ្ធផល។

ភាគលាភប្រកាសមុនដំណាច់ឆ្នាំទៅឲ្យភាគហ៊ុនិក ត្រូវបានទទួលស្គាល់ក្នុងមូលធនក្នុងការិយបរិច្ឆេទដែលបានប្រកាស។ ភាគលាភចុងក្រោយត្រូវបានទទួលស្គាល់ នៅពេលដែលមានការអនុម័តពីភាគហ៊ុនិក។

### ៤.១១ ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

សម្ព័ន្ធធ្វើការវាយតម្លៃថាតើ មានភស្តុតាងជាយថាវត្ថុដែលអាចធ្វើឲ្យមានឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅចុងការិយបរិច្ឆេទនីមួយៗ។

#### (ក) កម្ចី និងគណនីត្រូវទទួល

សម្ព័ន្ធពិចារណាទៅលើកត្តាទាំងឡាយ ដូចជាភវនីយភាពនៃភាពក្សៀយទុន ឧបសគ្គហិរញ្ញវត្ថុសំខាន់ៗនៃគណនីត្រូវទទួល រួមទាំងភាពគ្មានលទ្ធភាពសងបំណុល ឬក៏ការពន្យាពេលសងបំណុលរយៈពេលយូរ ដើម្បីកំណត់ថាតើកត្តាទាំងនោះជាភស្តុតាង ដែលបញ្ជាក់ថាមានឱនភាពលើកម្ចី និងគណនីត្រូវទទួលបានកើតឡើង។ ភស្តុតាងផ្សេងទៀត រួមមានអត្រាការប្រមូលកម្ចី និងគណនីត្រូវទទួលដែលមានពីមុន និងការពិនិត្យលើការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងជាតិដែលទាក់ទងដោយផ្ទាល់ទៅនឹងអត្រាគ្មានលទ្ធភាពសងបំណុលដែលមានពីមុន។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១១ ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

**(ក) កម្ចី និងគណនីត្រូវទទួល (ត)**

បើមានភស្តុតាងបែបនេះកើតឡើង តម្លៃនៃការខាតបង់ត្រូវបានគណនាដោយកំណត់តម្លៃ ខុសគ្នារវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាអនាគតដែលបានធ្វើអប្បហារ តាមអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការខាតបង់ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

តម្លៃយោងពិតគណនេយ្យនៃកម្ចី និងគណនីត្រូវទទួលត្រូវកាត់បន្ថយ ដោយគណនីកាត់កង។ នៅការិយបរិច្ឆេទបន្ទាប់ ប្រសិនបើតម្លៃខាតបង់ពីឱនភាពថយចុះ ហើយទាក់ទងទៅនឹង ព្រឹត្តិការណ៍ណាមួយដែលកើតឡើងក្រោយការខាតបង់ ត្រូវបានទទួលស្គាល់ការខាតបង់ ដែលបានទទួលស្គាល់ពីមុន ត្រូវបានកត់ត្រឡប់មកវិញត្រឹមពេលដែលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មមិនលើសពីតម្លៃដែលបានរំលស់នៅថ្ងៃ ដែលកត់ត្រឡប់មកវិញ ។ ចំនួនដែលបានកត់ត្រឡប់មកវិញត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។

### ៤.១២ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមាន ពន្ធលើប្រាក់ចំណេញជាប់ពន្ធទាំងអស់។ ចំណាយលើពន្ធនៅក្នុង របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗរួមមានពន្ធក្នុងគ្រា និង ពន្ធពន្យា។

**(ក) ពន្ធក្នុងគ្រា**

ចំណាយពន្ធក្នុងគ្រា ត្រូវបានកំណត់ដោយអនុលោមតាមច្បាប់ ស្តីពីសារពើពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមបញ្ចូលទាំង មូលដ្ឋានពន្ធយោងតាមប្រាក់ចំណេញជាប់ពន្ធ។

**(ខ) ពន្ធពន្យា**

ពន្ធពន្យា ត្រូវបានទទួលស្គាល់ទាំងស្រុង ដោយប្រើវិធានបំណុលលើភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងពីភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬ បំណុល នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និង មូលដ្ឋានពន្ធរបស់វា។

ពន្ធពន្យា ត្រូវទទួលស្គាល់សម្រាប់រាល់ភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ លើកលែងតែ ពន្ធពន្យាដែលកើតចេញពីការទទួលស្គាល់បឋមនូវទ្រព្យសកម្ម ឬបំណុលក្នុងប្រតិបត្តិការ ដែលមិនមែនជាការទិញបង្រួមអាជីវកម្ម ហើយនៅពេលដែលប្រតិបត្តិការនោះកើតឡើង មិនមានផលប៉ះពាល់ណាមួយកើតឡើងចំពោះប្រាក់ចំណេញ តាមវិធីសាស្ត្រគណនេយ្យ ឬប្រាក់ចំណេញតាមវិធីសាស្ត្រពន្ធដារឡើយ។

ពន្ធពន្យាជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែនូវពេលដែលមានប្រាក់ចំណេញជាប់ពន្ធ អាចកើតមានឡើងដើម្បីទូទាត់ជាមួយនឹងចំនួនខុសគ្នាបណ្តោះអាសន្ន។ តម្លៃពិតគណនេយ្យនៃពន្ធពន្យាជាទ្រព្យសកម្មត្រូវពិនិត្យឡើងវិញនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ។ តម្លៃពិតគណនេយ្យនៃពន្ធពន្យាជាទ្រព្យសកម្ម ត្រូវបានកាត់បន្ថយ នៅពេលដែលដឹងថា ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមិនមានគ្រប់គ្រាន់ ដើម្បីប្រើប្រាស់មួយផ្នែក ឬទាំងស្រុងនៃទ្រព្យសកម្មពន្ធពន្យា។ ការកាត់បន្ថយបែបនេះត្រូវបានកត់ត្រឡប់មកវិញនៅពេលដែល ប្រាក់ចំណេញជាប់ពន្ធអាចនឹងមានគ្រប់គ្រាន់។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១២ ពន្ធលើប្រាក់ចំណេញ (ត)

**(ខ) ពន្ធពន្យា (ត)**

ពន្ធពន្យាជាទ្រព្យសកម្ម និងបំណុល អាចកាត់កងគ្នាបាននៅពេលដែល មានសិទ្ធិស្របច្បាប់ដើម្បីធ្វើការទូទាត់ពន្ធក្នុងគ្រាត្រូវទទួលទៅនឹងពន្ធក្នុងគ្រាត្រូវសង ហើយនៅពេលដែលចំណូលពន្ធពន្យាទាក់ទងទៅនឹងអាជ្ញាធរពន្ធដារដូចគ្នាលើ៖

(១) គ្រឹះស្ថានជាប់ពន្ធដូចគ្នា ឬ

(២) គ្រឹះស្ថានជាប់ពន្ធផ្សេងគ្នា ដែលមានបំណងនឹងទូទាត់ពន្ធក្នុងគ្រាត្រូវបង់ និងត្រូវ ទទួលសរុប ឬទទួលស្គាល់ពន្ធត្រូវទទួល ហើយទូទាត់ពន្ធត្រូវបង់បន្តបន្ទាប់គ្នា នៅក្នុងការិយបរិច្ឆេទនីមួយៗនាពេលអនាគត ដែលពន្ធពន្យាត្រូវបង់ និងត្រូវទទួលរំពឹងថានឹងធ្វើការទូទាត់ ឬទទួលបានមកវិញ។

ពន្ធពន្យានឹងត្រូវទទួលស្គាល់ជាចំណូល ឬចំណាយ ហើយកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាតលើកលែងតែក្នុងករណីពន្ធនោះទទួលស្គាល់ដោយផ្ទាល់ជាចំណាយ ឬ ចំណូលនៅក្នុងមូលធននៅក្នុងការិយបរិច្ឆេទដូចគ្នា ឬខុសគ្នា ក្នុងស្ថានភាពបែបនេះ ពន្ធពន្យានឹងត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងដើមទុន។

ពន្ធពន្យាទ្រព្យសកម្ម និងបំណុលត្រូវបានគណនាតាមអត្រាពន្ធ ដែលរំពឹងទុកថានឹងប្រើប្រាស់នៅក្នុងគ្រា នៅពេលដែលទ្រព្យសកម្មត្រូវបានទទួលស្គាល់ និងបំណុលត្រូវបានសងផ្អែកទៅលើអត្រា និងបទប្បញ្ញត្តិពន្ធដែលបានចូលជាធរមាន នៅថ្ងៃចុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.១៣ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលមានកាតព្វកិច្ចបច្ចុប្បន្នតាមផ្លូវច្បាប់ ឬ ប្រយោលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយនៅពេលដែលទំនងថាមានលំហូរចេញនូវធនធានតំណាងឲ្យផលប្រយោជន៍សេដ្ឋកិច្ចដែលតម្រូវឲ្យ ធ្វើការទូទាត់នូវកាតព្វកិច្ចនោះ និងការប៉ាន់ស្មានគួរឲ្យជឿជាក់អាចធ្វើទៅលើចំនួនទឹកប្រាក់នៃកាតព្វកិច្ចទាំងនោះ។

នៅពេលដែល ផលប៉ះពាល់នៃតម្លៃប្រាក់គិតតាមពេលវេលាមានលក្ខណៈជាសារវន្ត ចំនួននៃសំវិធានធន ត្រូវធ្វើអប្បហារមកតម្លៃបច្ចុប្បន្នតាមអត្រាមុនគិតពន្ធ ដែលអត្រានេះឆ្លុះបញ្ចាំងពីការវាយតម្លៃតាមទីផ្សារបច្ចុប្បន្ននៃតម្លៃប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ ពាក់ព័ន្ធទៅនឹងបំណុលនោះ។

សំវិធានធនត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញ នៅរៀងរាល់ចុងការិយបរិច្ឆេទនៃតារាងតុល្យការ និងកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានបច្ចុប្បន្នដែលត្រឹមត្រូវបំផុត។ សំវិធានធននឹងត្រូវធ្វើការកត់ត្រលប់មកវិញ ប្រសិនបើគ្មានលំហូរចេញនៃធនធាន ដែលតំណាងឲ្យផលប្រយោជន៍សេដ្ឋកិច្ចតម្រូវឲ្យធ្វើការទូទាត់នូវកាតព្វកិច្ចទាំងនោះ។

សំវិធានធនមិនត្រូវបានកំណត់សម្គាល់សម្រាប់កំហាតប្រតិបត្តិការអនាគតទេ។ ប្រសិនបើសម្ព័ន្ធមានកិច្ចសន្យា ដែលស្មុគស្មាញ កាតព្វកិច្ចបច្ចុប្បន្នដែលនៅក្នុងកិច្ចសន្យានឹងត្រូវបានសម្គាល់ និងចាត់ទុកជាសំវិធានធន។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១៤ បំណុលយថាហេតុ

បំណុលយថាហេតុគឺជាកាតព្វកិច្ចដែលអាចកើតមានឡើងចេញពីព្រឹត្តិការណ៍អតីតកាល ហើយដែលអត្ថិភាពរបស់វា នឹងត្រូវបានបញ្ជាក់ដោយការកើតមានឡើង ឬការមិនកើតមានឡើង នៃព្រឹត្តិការណ៍អនាគតមិនច្បាស់លាស់មួយឬ ច្រើន ដែលមិនឋិតក្នុងការគ្រប់គ្រងដោយសម្ព័ន្ធ និង ក្រុមហ៊ុន ឬជាកាតព្វកិច្ចបច្ចុប្បន្នដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាលប៉ុន្តែមិនត្រូវបានទទួលស្គាល់ ដោយសារតែមិនប្រហែលមានការហូរចេញនូវធនធានត្រូវបានតំរូវឲ្យទូទាត់សងកាតព្វកិច្ចនោះ។ បំណុលយថាហេតុអាចកើតឡើងក្នុងករណីដ៏កម្រមួយ ពេលដែលមានបំណុលមួយ ដែលមិនអាចទទួលស្គាល់បាន ដោយសារតែវាមិនអាចវាស់វែងតាមស្ថានភាពពិតប្រាកដបាន។ សម្ព័ន្ធ និង ក្រុមហ៊ុន មិនបានទទួលស្គាល់បំណុលជាយថាហេតុទេ ប៉ុន្តែបានបង្ហាញពីភាពកើតឡើងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.១៥ ការទទួលស្គាល់ចំណូល

ចំណូល ត្រូវបានវាស់វែងតាមតម្លៃទីផ្សារនៃតម្លៃតបស្នងដែលបានទទួល ឬតម្លៃដែលនឹងត្រូវទទួល ដោយមិនគិតបញ្ចូលការបញ្ចុះតម្លៃ ឬការបញ្ជូនទំនិញត្រឡប់វិញទេ។

ចំណូលត្រូវបានទទួលស្គាល់តែនៅពេលដែលថា អត្ថប្រយោជន៍សេដ្ឋកិច្ចដែលទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលមកក្នុងសម្ព័ន្ធ ហើយចំណូល និងថ្លៃដើមដែលបានកើតឡើង ឬនឹងកើតឡើងទាក់ទងទៅនឹងប្រតិបត្តិការនោះ អាចត្រូវបានវាស់វែងគួរឲ្យទុកចិត្តបាន និងលក្ខខណ្ឌការទទួលស្គាល់ចំណូលជាក់លាក់សម្រាប់សកម្មភាពនីមួយៗរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

**(ក) ការលក់ដី**

ចំណូលពីការលក់ដីត្រូវទទួលស្គាល់ នៅពេលដែលហានិភ័យជាសារវន្ត និងភាពជាម្ចាស់កម្មសិទ្ធិលើដីបានផ្ទេរទៅឲ្យអ្នកទិញ ហើយចំនួនទឹកប្រាក់នៃចំណូលអាចត្រូវបានវាស់វែងគួរឲ្យទុកចិត្តបាន។

**(ខ) ការផ្តល់សេវាកម្ម**

ចំណូលដែលបានពីការបំពេញសេវាកម្ម ភាគច្រើនបានពីការធ្វើសំវិធានធនទៅលើ សេវាកម្មថែទាំ ការប្រើប្រាស់ទឹក ភ្លើង ការប្រើប្រាស់ខ្សែបញ្ជូនចរន្ត និងការផ្តល់សន្តិសុខ ដែលនឹងត្រូវបានទទួលស្គាល់ នៅពេលដែលការបំពេញសេវាកម្មត្រូវបានបញ្ចប់។

**(គ) ចំណូលភាគលាភ**

ចំណូលភាគលាភត្រូវបានទទួលស្គាល់ពេលដែលសិទ្ធិក្នុងការទទួលបានចំណូលត្រូវបានបង្កើតឡើង។

**(ឃ) ចំណូលការប្រាក់**

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់នៅពេលមានការកើតឡើង ដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធិផល។

**(ង) ចំណូលពីការជួល**

ចំណូលពីការជួល ត្រូវបានកត់ត្រាដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ដោយផ្អែកតាមលក្ខខណ្ឌនៃកិច្ចសន្យាជួល។ ថ្លៃដើមសរុបរបស់អត្ថប្រយោជន៍ ដែលផ្តល់ឲ្យអ្នកជួល ត្រូវបានទទួលស្គាល់ជាការកាត់កងជាមួយចំណូលពីការជួល ផ្អែកលើលក្ខខណ្ឌនៃការជួលតាមវិធីសាស្ត្ររំលស់ថេរ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១៦ អត្ថប្រយោជន៍និយោជិត

#### (ក) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

ប្រាក់ឈ្នួល ប្រាក់បៀវត្សន៍ វិភាគទានសន្តិសុខសង្គម ថ្ងៃសម្រាកប្រចាំឆ្នាំ ថ្ងៃសម្រាកឈឺទទួលកម្រៃ បុព្វលាភ និងអត្ថប្រយោជន៍មិនមែនជាសាច់ប្រាក់ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទពេលដែលនិយោជិតបានបង្ហាញសេវាកម្មទៅឲ្យសម្ព័ន្ធ។

អវត្តមានដែលទទួលសំណងបង្គររយៈពេលខ្លី ដូចជាថ្ងៃសម្រាកប្រចាំឆ្នាំទទួលកម្រៃ ត្រូវទទួលស្គាល់ជាចំណាយនៅពេលដែលនិយោជិត បង្ហាញនូវសេវាកម្មដែលបង្កើនសិទ្ធិក្នុងការទទួលបាននូវចំនួនថ្ងៃអវត្តមានទទួលកម្រៃនាពេលអនាគត ។ ចំនួនថ្ងៃអវត្តមានទទួលកម្រៃរយៈពេលខ្លីមិនបង្គរដូចជា ថ្ងៃសំរាកឈឺត្រូវទទួលស្គាល់នៅពេលដែលការអវត្តមាននោះកើតឡើង ហើយការឈប់សម្រាក់ទាំងនោះនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើសិទ្ធិឈប់សម្រាកទាំងនោះមិនបានប្រើប្រាស់នៅក្នុងឆ្នាំ និងមិនត្រូវបានទូទាត់ជាសាច់ប្រាក់សម្រាប់ការឈប់សម្រាកដែលមិនបានប្រើប្រាស់នៅពេលនិយោជិតចាកចេញពីសម្ព័ន្ធនោះទេ។

បុព្វលាភ ត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលមានកាតព្វកិច្ចផ្លូវច្បាប់ ឬជាកាតព្វកិច្ចប្រយោលដើម្បីធ្វើការទូទាត់ចំណាយបែបនេះ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយការប៉ាន់ស្មានគួរឲ្យជឿជាក់មួយត្រូវបានធ្វើឡើងលើចំនួននៃកាតព្វកិច្ចនោះ។

#### (ខ) អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិត ដោយសារការបញ្ឈប់ពីការងារមុនពេលថ្ងៃចូលនិវត្តន៍ ឬការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជន៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត។ អត្ថប្រយោជន៍ទាំងនោះ ត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលសម្ព័ន្ធមានគម្រោងបញ្ឈប់ការងារនិយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណា ដែលគម្រោងនេះត្រូវដកចេញ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្តដោយនិយោជិត អត្ថប្រយោជន៍នេះត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិត ដែលរំពឹងថានឹងទទួលនូវការស្នើសុំនេះ។

នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារហួសកាលកំណត់លើសពី ១២ ខែ បន្ទាប់ពីចុងការិយបរិច្ឆេទ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្ន ដោយផ្អែកលើទីផ្សារនៅចុងការិយបរិច្ឆេទនៃរបាយការណ៍។

### ៤.១៧ រូបិយប័ណ្ណបរទេស

#### (ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចំបង ដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ រូបិយប័ណ្ណជាតិរបស់ព្រះរាជាណាចក្រកម្ពុជាគឺ ប្រាក់រៀលខ្មែរ ("រៀល")។ យ៉ាងណាមិញ ដោយសារសម្ព័ន្ធធ្វើប្រតិបត្តិការអាជីវកម្ម និងរក្សានូវកំណត់ត្រាគណនេយ្យចំបងជាប្រាក់ដុល្លារអាមេរិក ("ដុល្លារអាមេរិក") ថ្នាក់ដឹកនាំក្រុមហ៊ុនកំណត់យកប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណបង្ហាញ ដោយសារវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់សម្ព័ន្ធ។

# ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## ៤.១៧ រូបិយប័ណ្ណបរទេស(ត)

### (ខ) សមតុល្យ និងការបកប្រែរូបិយប័ណ្ណបរទេស

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀត ក្រៅពីរូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន (ហៅកាត់ថា "រូបិយប័ណ្ណបរទេស") ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើប្រាស់អត្រាការប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាការប្រាក់នាថ្ងៃរបាយការណ៍ហិរញ្ញវត្ថុ លើកលែងតែត្រូវបានគាំទ្រដោយប្រើប្រាស់កិច្ចសន្យាអត្រាប្តូរប្រាក់បរទេសនាពេលអនាគត ក្នុងករណីបែបនេះ អត្រាដែលបានកំណត់នៅក្នុងកិច្ចសន្យានេះនឹងត្រូវបានប្រើប្រាស់។ អត្រាប្តូរប្រាក់ផ្សេងគ្នាដែលកើតឡើងពីការទូទាត់ និងការកែសម្រួលទ្រព្យសកម្ម និងបំណុលជាទឹកប្រាក់ ជារូបិយប័ណ្ណបរទេស ត្រូវកត់ត្រាក្នុងរបាយការណ៍លទ្ធផលនៅក្នុងការិយបរិច្ឆេទ ដែលកើតឡើង។ ទ្រព្យសកម្ម និងបំណុលមិនមែនជាទឹកប្រាក់ ដែលកត់ត្រាដំបូងជារូបិយប័ណ្ណបរទេស ហើយយោងជាតម្លៃដើមត្រូវបានប្រែសម្រួលដោយប្រើអត្រាដើមនៅថ្ងៃទិញ ហើយចំពោះទ្រព្យសកម្ម និងបំណុលមិនមែនជាសាច់ប្រាក់ដែលយោងជាតម្លៃទីផ្សារ ត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ ដែលកើតឡើងនៅពេលដែលតម្លៃនៃទ្រព្យសកម្ម និង បំណុលទាំងនោះត្រូវបានកំណត់ក្នុងគោលបំណងសម្រាប់បង្ហាញ។

## ៤.១៨ បន្ទុកលើប្រាក់កម្ចី

បន្ទុកប្រាក់កម្ចីដែលទាក់ទងផ្ទាល់នឹងការទិញ ឬសាងសង់ទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានធ្វើមូលធនកម្ម ជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្ម។ ការធ្វើមូលធនកម្មនេះ បន្តរហូតដល់សកម្មភាពចាំបាច់ផ្សេងៗដើម្បីសាងសង់ ឬរៀបចំទ្រព្យសកម្មត្រូវបានបញ្ចប់សព្វគ្រប់ សម្រាប់គោលបំណងប្រើប្រាស់ ឬលក់។ រាល់ការចំណាយបន្ទាប់នេះ ត្រូវបានគិតបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល។ ទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺជាទ្រព្យសកម្មមួយ ដែលត្រូវការរយៈពេលវែងមួយដើម្បីធ្វើឲ្យរួចរាល់ សម្រាប់គោលបំណងប្រើប្រាស់ ឬលក់។ មូលធនកម្មនៃបន្ទុកលើប្រាក់កម្ចីត្រូវបានពន្យានៅពេលដែលមានការផ្អាកការសាងសង់ទ្រព្យសកម្មនោះ។

តម្លៃនៃបន្ទុកលើប្រាក់កម្ចីដែលអាចធ្វើមូលធនកម្មបាន គឺជាបន្ទុកប្រាក់កម្ចីជាក់ស្តែងដែលបានកើតឡើង ទៅលើកម្ចីនៅក្នុងការិយបរិច្ឆេទ ដកចំណូលវិនិយោគដែលបានមកពីការវិនិយោគនៃកម្ចីបណ្តោះអាសន្ន។

បន្ទុកលើប្រាក់កម្ចីផ្សេងទៀត ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលនៅការិយបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។

## ៤.១៩ ការវាស់វែងនូវតម្លៃសមស្រប

តម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល លើកលែងប្រតិបត្តិការសម្រាប់ភតិសន្យា គឺត្រូវបានកំណត់ទៅតាមតម្លៃដែលអាចទទួលបានពីការលក់នូវទ្រព្យសកម្មមួយ ឬការបង់ដើម្បីផ្ទេរនូវបំណុលមួយទៅតាមលំដាប់លំដោយនៃប្រតិបត្តិការរវាងអ្នកចូលរួមក្នុងទីផ្សារនៅថ្ងៃដែលអាចវាស់វែងបាន។ ការវាស់វែងតម្លៃសមស្របសន្មត់ថាប្រតិបត្តិការពីការលក់នូវទ្រព្យសកម្មមួយ ឬការផ្ទេរនូវបំណុលទាំងនោះនៅក្នុងទីផ្សារដំបូង ឬមិននៅក្នុងទីផ្សារដំបូង នៅក្នុងទីផ្សារដែលមានគុណសម្បត្តិបំផុត។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១៩ ការវាស់វែងនូវតម្លៃសមស្រប (ត)

សម្ព័ន្ធធ្វើការវាស់វែងតម្លៃទីផ្សារសមស្របនៃទ្រព្យសកម្ម ឬបំណុលមួយដោយពិចារណាទៅលើលក្ខណៈសម្បត្តិនៃទ្រព្យសកម្ម ឬ បំណុល បើអ្នកចូលរួមក្នុងទីផ្សារពិចារណាទៅលើលក្ខណៈសម្បត្តិទាំងនេះនៅពេលកំណត់តម្លៃទ្រព្យសកម្ម ឬបំណុល។ សម្ព័ន្ធបានគិតពិចារណាទៅលើលក្ខណៈសម្បត្តិនៅពេលកំណត់តម្លៃសមស្របដូចខាងក្រោម៖

(ក) លក្ខខណ្ឌស្ថានភាព និងទីតាំងនៃទ្រព្យសកម្ម និង

(ខ) ការដាក់កម្រិតនៅលើការលក់ ឬប្រើប្រាស់ទ្រព្យសកម្មប្រសិនជាមាន។

ការវាស់វែងនូវតម្លៃសមស្របសម្រាប់ទ្រព្យសកម្មដែលមិនមែនជាហិរញ្ញវត្ថុ ត្រូវបានពិចារណាទៅលើបំណុលនៃអ្នកចូលរួមក្នុងទីផ្សារ ដើម្បីបង្កើតជាអត្ថប្រយោជន៍សេដ្ឋកិច្ចដោយប្រើប្រាស់នូវទ្រព្យសកម្មបានអស់ពីលទ្ធភាព ឬដោយលក់វាឲ្យអ្នកចូលរួមក្នុងទីផ្សារដទៃទៀតដោយប្រើប្រាស់នូវទ្រព្យសកម្មបានអស់ពីលទ្ធភាព។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឬឧបករណ៍មូលធនទ្រព្យម្ចាស់មួយ ត្រូវបានសន្មត់ដោយ៖

(ក) បំណុលមួយនៅសល់ និងអ្នកដែលចូលរួមក្នុងការផ្ទេរក្នុងទីផ្សារ ត្រូវបានទាមទារឲ្យបំពេញនូវកាតព្វកិច្ចរបស់ខ្លួន។ បំណុលមិនត្រូវបានដោះស្រាយដោយដៃគូ ឬបើមិនដូច្នេះ នឹងត្រូវបញ្ចប់នៅថ្ងៃវាស់វែង និង

(ខ) ឧបករណ៍មូលធនទ្រព្យម្ចាស់របស់អង្គភាពនៅសល់ និងអ្នកចូលរួមក្នុងការផ្ទេរក្នុងទីផ្សារ ត្រូវបានប្រើប្រាស់សិទ្ធិ និងទំនួលខុសត្រូវដែលពាក់ព័ន្ធជាមួយនឹងឧបករណ៍។ ឧបករណ៍ទាំងនោះមិនត្រូវបានលុបចោល ឬបើមិនដូច្នេះ នឹងត្រូវបញ្ចប់នៅថ្ងៃវាស់វែង។

## ៥. ការអនុវត្តនូវ ស្តង់ដាររបាយការណ៍ ទាក់ទងនឹង ហិរញ្ញវត្ថុ អន្តរជាតិនៃ កម្ពុជា ("ស.រ.ហ.អ.ក") ថ្មី

### ៥.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងឆ្នាំហិរញ្ញវត្ថុ

សម្ព័ន្ធ និង ក្រុមហ៊ុនបានអនុវត្តនូវគោលការណ៍គណនេយ្យ និង វិសោធនកម្ម ដូចខាងក្រោមក្នុងការិយបរិច្ឆេទនេះ ។

| | ថ្ងៃចូលជាធរមាន |
|---|---|
| ស.រ.ហ.អ.ក ១៤ *បទប្បញ្ញត្តិគណនីពន្យា* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ ស.រ.ហ.អ.ក ១២ និង *ស.គ.អ.ក ២៨ ស្ថាប័នវិនិយោគ៖ ការអនុវត្តនូវករណីលើកលែងនៃរបាយការណ៍ហិរញ្ញវត្ថុរួម* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១ *ចំណុចផ្តើមនៃការលាតត្រដាង* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.គ.អ.ក ១៦ និង ស.គ.អ.ក ៣៨ *ចំណាត់ថ្នាក់ នៃវិធីសាស្ត្រដែលអាចទទួលយកបាននៃការរំលស់ទ្រព្យសកម្មរូបី និង អរូបី* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១១ *គណនេយ្យសម្រាប់ការទិញនូវសិទ្ធនៅក្នុងប្រតិបត្តិការជារួម* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.គ.អ.ក ១៦ និង ស.គ.អ.ក ៤១ *វិស័យកសិកម្ម៖ រុក្ខជាតិយកផល* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.គ.អ.ក ២៧ *វិធីសាស្ត្រមូលធននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក *បរិវឌ្ឍកម្ម ខួប២០១២ ដល់ ២០១៤* | ១ មករា ២០១៦ |

ពុំមានផលប៉ះពាល់ជាសារវន្តចំពោះការអនុវត្តនូវគោលការណ៍គណនេយ្យ និង វិសោធនកម្មខាងលើនៅក្នុងការិយបរិច្ឆេទនេះទេ។

## ៥. ការអនុវត្តន៍ស្តង់ដាររបាយការណ៍ ទាក់ទងនឹង ហិរញ្ញវត្ថុ អន្តរជាតិនៃ កម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៥.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពីថ្ងៃទី១ខែ មករា ឆ្នាំ២០១៧

ខាងក្រោមនេះគឺជាស្តង់ដារ វិសោធនកម្ម និងការបកស្រាយ ដែលបានចេញផ្សាយរួច ប៉ុន្តែសម្ព័ន្ធ និង ក្រុមហ៊ុន ពុំទាន់បានអនុវត្ត៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.រ.ហ.អ.ក១២ *ការធ្វើអោយល្អប្រសើរប្រចាំឆ្នាំលើ ស.រ.ហ.អ.ក ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦* | ១ មករា ២០១៧ |
| វិសោធនកម្មលើ ស.គ.អ.ក ១២ *ការទទួលស្គាល់ពន្ធពន្យា នៃការខាតមិនបានទទួលស្គាល់* | ១ មករា ២០១៧ |
| វិសោធនកម្មលើ ស.គ.អ.ក ៧ *ការតាំងបង្ហាញ* | ១ មករា ២០១៧ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក១ *ការធ្វើអោយល្អប្រសើរប្រចាំឆ្នាំលើ ស.រ.ហ.អ.ក ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ២ *ការបែងចែក និង ការវាស់វែងតំលៃ នៃប្រតិបត្តិការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុន* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ (ចេញផ្សាយដោយ ក.ប.ស.គ.អ នៅខែកក្កដាឆ្នាំ២០១៤)* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* | ១ មករា ២០១៨ |
| ការបញ្ជាក់ពី ស.រ.ហ.អ.ក ១៥ | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការធ្វើអោយល្អប្រសើរប្រចាំឆ្នាំលើ ស.រ.ហ.អ.ក ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ៤០ *ការផ្ទេរទ្រព្យសម្បត្តិវិនិយោគ* | ១ មករា ២០១៨ |
| ការបកស្រាយ ២២ *ប្រតិបត្តិការរូបិយប័ណ្ណបរទេស និង បុរេប្រទាននៃតម្លៃតបស្នង* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ១៦ *ការជួល* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យ រវាង សហគ្រិន និងញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ពន្យា |

សម្ព័ន្ធ និង ក្រុមហ៊ុនកំពុងវិភាគលើផលប៉ះពាល់ពីការអនុវត្តស្តង់ដារគណនេយ្យ និង វិសោធនកម្មទាំងនេះ ដោយហេតុថាផលប៉ះពាល់ទាំងនេះអាចវាស់វែងបាន សម្រាប់តែការិយបរិច្ឆេទនាពេល អនាគតប៉ុណ្ណោះ។

## ៦. ការប៉ាន់ស្មាន និង ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

### ៦.១ ការផ្លាស់ប្តូរការប៉ាន់ស្មាន

ការប៉ាន់ស្មាន ត្រូវបានធ្វើការវាយតម្លៃជាបន្តបន្ទាប់ និងយោងតាមបទពិសោធ ព្រមទាំងកត្តា ផ្សេងៗទៀត រួមមានការរំពឹងទុកអំពីព្រឹត្តិការណ៍នាពេលអនាគត ដែលត្រូវបានគេជឿជាក់ថាមាន ភាពសមស្របក្នុងកាលៈទេសៈមួយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានការផ្លាស់ប្តូរជាសារវន្តនូវការប៉ាន់ស្មាននៅក្នុងកំឡុង និង ចុងការិយបរិច្ឆេទនោះទេ។

### ៦.២ ការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងក្នុងការអនុវត្តគោលការណ៍គណនេយ្យ

ខាងក្រោមនេះគឺជាការវិនិច្ឆ័យ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដើម្បីអនុវត្តនូវគោលការណ៍គណនេយ្យរបស់សម្ព័ន្ធ ដែលមានឥទ្ធិពលជាសារវន្តលើចំនួនដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

#### (ក) ការបែងចែកឡើងវិញរវាង ទ្រព្យសម្បត្តិវិនិយោគ និងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

សម្ព័ន្ធបានបង្កើតនូវលក្ខណៈវិនិច្ឆ័យមួយចំនួន ដោយយោងលើ ស.គ.អ.ក ៤០ ក្នុងការធ្វើវិនិច្ឆ័យថាតើទ្រព្យសម្បត្តិមួយមានលក្ខណៈគ្រប់គ្រាន់ជាទ្រព្យសម្បត្តិវិនិយោគ។ ទ្រព្យសម្បត្តិវិនិយោគ គឺជាទ្រព្យសម្បត្តិមួយដែលទុកដើម្បីទទួលបានចំណូលពីការជួល ឬសម្រាប់កំណើនមូលធនឬក៏ទាំងពីរ។

ទ្រព្យសម្បត្តិមួយចំនួន មានមួយផ្នែកទុកសម្រាប់ជួល ឬសម្រាប់កំណើនមូលធន ហើយមួយផ្នែកទៀតទុកសម្រាប់ ប្រើប្រាស់ក្នុងសកម្មភាពផលិតកម្ម ឬផ្គត់ផ្គង់ផលិតផល ឬសេវាកម្ម ឬសម្រាប់ប្រើប្រាស់ផ្នែករដ្ឋបាល។ ប្រសិនបើ ផ្នែកទាំងនេះ អាចលក់បានដាច់ពីគ្នា (ឬជួលដាច់ៗពីគ្នាជាភតិសន្យាហិរញ្ញវត្ថុ) នោះសម្ព័ន្ធនឹងកត់ត្រានូវផ្នែកនិមួយៗដាច់ៗពីគ្នា។

ប្រសិនបើផ្នែកនោះមិនអាចលក់ដាច់ពីគ្នាទេ នោះទ្រព្យសម្បត្តិមួយអាចចាត់ទុកជាទ្រព្យសម្បត្តិវិនិយោគបាន លុះត្រាតែផ្នែកតូចមួយរបស់ទ្រព្យនោះ ត្រូវបានទុកប្រើប្រាស់សម្រាប់សកម្មភាពផលិតកម្ម ឬផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ឬសម្រាប់សកម្មភាពរដ្ឋបាល។ ការវិនិច្ឆ័យ គឺធ្វើឡើងចំពោះទ្រព្យសម្បត្តិនីមួយៗ ដើម្បីកំណត់ថាតើសេវាកម្មចម្បង គឺសំខាន់ ដែលធ្វើអោយទ្រព្យសម្បត្តិមួយមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា ទ្រព្យសម្បត្តិវិនិយោគ។

#### (ខ) កិច្ចសន្យាភតិសន្យាប្រតិបត្តិការ - ក្រុមហ៊ុនជាអ្នកជួលអោយគេ

សម្ព័ន្ធបានធ្វើភតិសន្យាទ្រព្យសម្បត្តិពាណិជ្ជកម្ម ទៅលើផលប័ត្រទ្រព្យសម្បត្តិវិនិយោគរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនបានប្តេជ្ញារក្សានូវរាល់ហានិភ័យ និងអត្ថប្រយោជន៍ជាម្ចាស់កម្មសិទ្ធ ចំពោះទ្រព្យសម្បត្តិដែលស្ថិតក្រោមភតិសន្យាប្រតិបត្តិការ។

### ៦.៣ ប្រភពសំខាន់ៗនូវភាពមិនពិតប្រាកដនៃការប៉ាន់ស្មាន

ខាងក្រោមនេះ គឺជាការសន្និដ្ឋានសំខាន់ៗទាក់ទងទៅនឹងពេលអនាគត និងប្រភពសំខាន់ៗ ដទៃទៀតនៃភាពមិនពិតប្រាកដនៃការប៉ាន់ស្មានក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលមានហានិភ័យជាសារវន្ត ដែលបណ្តាលឲ្យមាននិយ័តកម្មជាសារវន្ត ទៅលើតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងការិយបរិច្ឆេទបន្ទាប់។

## ៦. ការប៉ាន់ស្មាន និង ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### ៦.៣ ប្រភពសំខាន់ៗនូវភាពមិនពិតប្រាកដនៃការប៉ាន់ស្មាន (ត)

#### (ក) ឱនភាពនៃទ្រព្យសកម្ម

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងការវិនិយោគទៅលើក្រុមហ៊ុនចំណុះ និងញាតិសម្ព័ន្ធ ត្រូវបានធ្វើការវាយតម្លៃលើការខាតបង់ពីឱនភាព នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរ ណាមួយដែលបង្ហាញថាតម្លៃពិតគណនេយ្យនៃទ្រព្យសម្បត្តិទាំងនោះនឹងមិនអាចទទួលបានមកវិញ។ ការវាយតំលៃនេះ ចាំបាច់ត្រូវការក្រុមប្រឹក្សាភិបាលធ្វើការប៉ាន់ស្មានទៅលើតម្លៃដែលអាចប្រមូលបាន។ តម្លៃខាតបង់ពីឱនភាពត្រូវបានទទួលស្គាល់ នៅពេលដែលតម្លៃតម្លៃពិតគណនេយ្យលើសពីតម្លៃដែលអាចប្រមូលបានមកវិញ ដែលស្មើនឹងតម្លៃដែលខ្ពស់ជាងរវាងតម្លៃទីផ្សាររបស់ទ្រព្យសកម្មដកតម្លៃលក់ និង តម្លៃនៅបន្តប្រើប្រាស់។ ក្រុមប្រឹក្សាភិបាលជឿជាក់ថា ការប៉ាន់ស្មាន ទៅលើតម្លៃដែលអាចប្រមូលបាន គឺសមហេតុផល។

#### (ខ) រំលស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទ្រព្យសម្បត្តិវិនិយោគ

ថ្លៃដើមនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទ្រព្យសម្បត្តិវិនិយោគត្រូវបានរំលស់ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ផ្អែកលើអាយុកាលប្រើប្រាស់របស់ទ្រព្យទាំងនោះ។ ថ្នាក់ដឹកនាំបានធ្វើការប៉ាន់ស្មាននូវអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មទាំងនេះ ដោយផ្អែកលើបទពិសោធន៍ ការប្រើប្រាស់រំពឹងទុក ការខូចខាត និងភាពហួសសម័យនៃបច្ចេកទេសដែលកើត ឡើងពីការផ្លាស់ប្តូរនៅក្នុងតម្រូវការទីផ្សារ ឬសេវាកម្មដែលផ្តល់ដោយទ្រព្យសកម្មទាំងនោះ។ ការផ្លាស់ប្តូរនូវកត្តាទាំងនេះអាចនឹងមានផលប៉ះពាល់ដល់អាយុកាលប្រើប្រាស់សេដ្ឋកិច្ច និង តម្លៃកាកសំណល់នៃទ្រព្យសកម្ម។ ដូច្នេះរំលស់នាពេលអនាគតអាចនឹងត្រូវបានកែប្រែ។

#### (គ) ការបន្ថយតម្លៃលើសន្និធិ

សម្ព័ន្ធវាយតម្លៃភាពសមស្របនៃកាត់បន្ថយតម្លៃនៃសន្និធិ ដោយផ្អែកទៅលើការវាយតម្លៃលើការប៉ាន់ស្មាននៃតម្លៃលក់សុទ្ធ សន្និធិត្រូវបានកាត់បន្ថយតម្លៃនៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរណាមួយដែលបង្ហាញថាតម្លៃពិតគណនេយ្យនឹងមិនអាចទទួលបានមកវិញ។ ថ្នាក់ដឹកនាំបានធ្វើវិភាគលើនិន្នាការ និងនិន្នាការសេដ្ឋកិច្ចនាពេលបច្ចុប្បន្នយ៉ាងច្បាស់លាស់ នៅពេលធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃការកាត់បន្ថយតម្លៃលើសន្និធិ។ នៅពេលដែលការរំពឹងទុកខុសពីតម្លៃប៉ាន់ស្មានដើមភាពខុសគ្នា នោះនឹងប៉ះពាល់ដល់តម្លៃ ពិតគណនេយ្យនៃសន្និធិនោះ។

#### (ឃ) ឱនភាពនៃគណនីត្រូវទទួល

សម្ព័ន្ធវាយតម្លៃភាពសមស្របនៃការធ្វើឱនភាពលើទឹកប្រាក់ត្រូវទទួល ដោយផ្អែកទៅលើការវិនិច្ឆ័យលើភាពដែលអាចស្រង់មកវិញបាន របស់ទឹកប្រាក់ដែលត្រូវទទួល។ ឱនភាពត្រូវបានធ្វើឡើង លើទឹកប្រាក់ត្រូវទទួល នៅពេលដែលការផ្លាស់ប្តូរបរិយាកាសណាមួយដែលអាចជាកត្តាជំរុញ ធ្វើឲ្យតម្លៃពិតគណនេយ្យអាចនឹងស្រង់មកវិញមិនបាន។ គណៈគ្រប់គ្រងបានធ្វើការវិភាគស៊ីជម្រៅ លើប្រវត្តិបំណុលពិបាកទារ ការផ្តោតអារម្មណ៍របស់អតិថិជន ភាពគួរ ឲ្យជឿជាក់របស់អតិថិជន និន្នាការសេដ្ឋកិច្ចបច្ចុប្បន្ន និងការផ្លាស់ប្តូរលក្ខខណ្ឌនៃការបង់ប្រាក់ នៅពេលដែល ធ្វើការវិនិច្ឆ័យមួយ ដើម្បីវាយតម្លៃភាពគ្រប់គ្រាន់នៃឱនភាពរបស់ទឹកប្រាក់ត្រូវទទួល។ នៅពេលដែលមាន ភាពខុសគ្នារវាងការរំពឹងទុក និងការប៉ាន់ស្មានដំបូង ភាពខុសគ្នានោះនឹងប៉ះពាល់ដល់តម្លៃពិតគណនេយ្យ នៃទឹកប្រាក់ត្រូវទទួល។

## ៦. ការប៉ាន់ស្មាន និង ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### ៦.៣ ប្រភពសំខាន់ៗនូវភាពមិនពិតប្រាកដនៃការប៉ាន់ស្មាន (ត)

#### (ង) តម្លៃទីផ្សាររបស់កម្ចី

តម្លៃទីផ្សាររបស់កម្ចី ត្រូវបានប៉ាន់ស្មានដោយកាត់បន្ថយលំហូរសាច់ប្រាក់ជាប់កិច្ចសន្យា នាពេលអនាគត ដោយផ្អែកលើអត្រាការប្រាក់ទីផ្សារបច្ចុប្បន្នដែលអាចរកបានសម្រាប់សម្ព័ន្ធ ចំពោះឧបករណ៍ហិរញ្ញវត្ថុស្រដៀងគ្នា ។ ការវិភាគលើផលប៉ះពាល់នៃហានិភ័យអត្រាការប្រាក់ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុលេខ ២៩ ។

#### (ច) ការចំណាយលើប្រាក់ពន្ធ

ការវិនិច្ឆ័យសំខាន់ៗ ត្រូវបានរួមបញ្ចូលក្នុងការកំណត់នូវសំវិធានធនរបស់សម្ព័ន្ធសម្រាប់ពន្ធលើប្រាក់ចំណេញ។ សម្ព័ន្ធនឹងទទួលស្គាល់បំណុលសម្រាប់រាល់ចំណាយលើពន្ធដែលរំពឹងទុក ផ្អែកទៅលើ ការប៉ាន់ស្មានតាមរយៈការបកស្រាយបទប្បញ្ញត្តិពន្ធផ្សេងៗដោយថ្នាក់ដឹកនាំ ថាតើពន្ធទាំងនោះត្រូវបង់ឬទេ។ នៅពេលដែលលទ្ធផលពន្ធខុសគ្នាពីការប៉ាន់ស្មានដែលត្រូវបានទទួលស្គាល់ពីមុន ភាពខុសគ្នាទាំងនោះនឹងមានផលប៉ះពាល់ដល់សំវិធានធនពន្ធក្នុងការិយបរិច្ឆេទ ដែលការកំណត់នោះត្រូវបានធ្វើឡើង។

## ៧. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| សម្ព័ន្ធ | ដី<br>ដុល្លារអាមេរិក | អគារ និង<br>ហេដ្ឋារចនាសម្ព័ន្ធ<br>ដុល្លារអាមេរិក | ម៉ាស៊ីន<br>ដុល្លារអាមេរិក | យានយន្ត<br>បរិក្ខារ និង កំព្យូទ័រ<br>ដុល្លារអាមេរិក | ការសាងសង់<br>កំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| ***ថ្លៃដើម*** | | | | | | |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **១ ខែមករា ឆ្នាំ២០១៥** | - | ១៦.២២៨.៧២០ | ១.៤៨៨.១១៥ | ២៦២.៣៦៧ | - | ១៧.៩៧៩.២០២ |
| ការទិញបន្ថែម | - | ៥១៨.៨២៤ | ៣៩.៩៦០ | ១១៦.៤៤៦ | ៣៤៤.០៨៤ | ១.០១៩.៣១៤ |
| ការជម្រះចេញពីបញ្ជី | - | - | - | (៤១.០៦៦) | - | (៤១.០៦៦) |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៥** | - | ១៦.៧៤៧.៥៤៤ | ១.៥២៨.០៧៥ | ៣៣៧.៧៤៧ | ៣៤៤.០៨៤ | ១៨.៩៥៧.៤៥០ |
| ការទិញបន្ថែម | - | ៣៦.២១៥ | ៣.២៣៧ | ៤០.៤២៨ | ២.១១១.២១៣ | ២.១៩១.៤៩៣ |
| ការចាត់ថ្នាក់ឡើងវិញ | ៣៦១.៧៦៥ | (៣៦១.៧៦៥) | - | - | - | - |
| ការបែកចែកឡើងវិញ | - | ១.៧២១.៤៥០ | - | - | (១.៧២១.៤៥០) | - |
| ការបែកចែកឡើងវិញទៅ ទ្រព្យសម្បត្តិវិនិយោគទុន (កំណត់សម្គាល់លេខ ៨) | - | (៧១០.៣៣៩) | - | - | - | (៧១០.៣៣៩) |
| ការជម្រះចេញពីបញ្ជី | - | - | - | (១៩.៦២៥) | - | (១៩.៦២៥) |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៦** | ៣៦១.៧៦៥ | ១៧.៤៣៣.១០៥ | ១.៥៣១.៣១២ | ៣៥៨.៥៥០ | ៧៣៣.៨៤៧ | ២០.៤១៨.៥៧៩ |
| *(គិតជាពាន់រៀល)* | *១.៤៦០.៤៤៥* | *៧០.៣៧៧.៤៤៥* | *៦.១៨១.៩០៧* | *១.៤៤៩.០៨១* | *២.៩៦២.៥៤០* | *៨២.៤៣១.៤១៨* |
| ***រំលស់បង្គរ*** | | | | | | |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **១ ខែមករា ឆ្នាំ២០១៥** | - | ៣.០៦៩.៣៨២ | ៦៦២.០១១ | ១៧១.៤៨៩ | - | ៣.៩០២.៨៨២ |
| រំលស់ក្នុងឆ្នាំ | - | ៧៩១.៩៣៩ | ១៥០.២០៦ | ៤៣.៣៣៨ | - | ៩៨៥.៤៨៣ |
| ការជម្រះចេញពីបញ្ជី | - | - | - | (៤១.០៦៦) | - | (៤១.០៦៦) |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៥** | - | ៣.៨៦១.៣២១ | ៨១២.២១៧ | ១៧៣.៧៦១ | - | ៤.៨៤៧.២៩៩ |
| រំលស់ក្នុងឆ្នាំ | - | ៨២៣.៣៦០ | ១៤៩.៨២៨ | ៥៩.៨៥០ | - | ១.០៣៣.០៣៨ |
| ការបែកចែកឡើងវិញទៅ ទ្រព្យសម្បត្តិវិនិយោគទុន (កំណត់សម្គាល់លេខ ៨) | - | (២១៦.៥២០) | - | - | - | (២១៦.៥២០) |
| ការជម្រះចេញពីបញ្ជី | - | - | - | (១៩.៦២៥) | - | (១៩.៦២៥) |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៦** | - | ៤.៤៦៨.១៦១ | ៩៦២.០៤៥ | ២១៣.៩៨៦ | - | ៥.៦៤៤.១៩២ |
| *(គិតជាពាន់រៀល)* | - | *១៨.០៣៧.៩៦៦* | *៣.៨៨៣.៧៧៦* | *៨៦៣.៨៦១* | - | *២២.៧៨៥.៦០៣* |

## ៧. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| សម្ព័ន្ធ | ដី<br>ដុល្លារអាមេរិក | អាគារ និង ហេដ្ឋារចនាសម្ព័ន្ធ<br>ដុល្លារអាមេរិក | ម៉ាស៊ីន<br>ដុល្លារអាមេរិក | យានយន្ត បរិក្ខារ និង កំព្យូទ័រ<br>ដុល្លារអាមេរិក | ការសាងសង់ កំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| ***តម្លៃពិតគណនេយ្យ*** | | | | | | |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៦** | **៣៦១.៧៦៥** | **១២.៩៦៤.៩៤៤** | **៥៦៩.២៦៧** | **១៤៤.៩៦៤** | **៧៣៣.៨៤៧** | **១៤.៧៧៤.៧៨៧** |
| *(គិតជាពាន់រៀល)* | *១.៤៦០.៤៤៥* | *៥២.៣៣៩.៤៧៩* | *២.២៩៨.១៣១* | *៥៨៥.២២០* | *២.៩៦២.៥៤០* | *៥៩.៦៤៥.៨១៥* |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៥** | **-** | **១២.៨៨៦.២២៣** | **៧១៥.៨៥៨** | **១៦៣.៩៨៦** | **៣៤៤.០៨៤** | **១៤.១១០.១៥១** |
| **ក្រុមហ៊ុន** | | | | | | |
| ***ថ្លៃដើម*** | | | | | | |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **១ ខែមករា ឆ្នាំ២០១៥** | - | ១៦.២២៨.៧២០ | ១.៤៨៨.១១៥ | ២៥៨.៩៥៧ | - | ១៧.៩៧៥.៧៩២ |
| ការទិញបន្ថែម | - | ៥១៨.៨២៤ | ៣៩.៩៦០ | ១១១.៩៧៦ | ៣៤៤.០៨៤ | ១.០១៤.៨៤៤ |
| ការជម្រះចេញពីបញ្ជី | - | - | - | (៤១.០៦៦) | - | (៤១.០៦៦) |
| **សមតុល្យនាថ្ងៃទី** | - | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៥** | | ១៦.៧៤៧.៥៤៤ | ១.៥២៨.០៧៥ | ៣២៩.៨៦៧ | ៣៤៤.០៨៤ | ១៨.៩៤៩.៥៧០ |
| ការទិញបន្ថែម | - | ១៧.១៣៥ | ៣.២៣៧ | ៣២.១៥៧ | ១.៩៧៧.៩៨១ | ២.០៣០.៥១០ |
| ការចាត់ថ្នាក់ឡើងវិញ | ៣៦១.៧៦៥ | (៣៦១.៧៦៥) | - | - | | - |
| ការបែកចែកឡើងវិញ | - | ១.៧២១.៤៥០ | - | - | (១.៧២១.៤៥០) | - |
| ការបែកចែកឡើងវិញទៅ ទ្រព្យសម្បត្តិវិនិយោគទុន (កំណត់សម្គាល់លេខ ៨) | - | (៧១០.៣៣៩) | - | - | - | (៧១០.៣៣៩) |
| ការជម្រះចេញពីបញ្ជី | - | - | - | (១៩.៦២៥) | - | (១៩.៦២៥) |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៦** | ៣៦១.៧៦៥ | ១៧.៤១៤.០២៥ | ១.៥៣១.៣១២ | ៣៤២.៣៩៩ | ៦០០.៦១៥ | ២០.២៥០.១១៦ |
| *(គិតជាពាន់រៀល)* | *១.៤៦០.៤៤៥* | *៧០.៣០០.៤១៩* | *៦.១៨១.៩០៧* | *១.៣៨២.២៦៥* | *២.៤២៤.៦៨៣* | *៨១.៧៤៩.៧១៩* |

## ៧. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | ដី<br>ដុល្លារអាមេរិក | អាគារ និង ហេដ្ឋារចនាសម្ព័ន្ធ<br>ដុល្លារអាមេរិក | ម៉ាស៊ីន<br>ដុល្លារអាមេរិក | យានយន្ត បរិក្ខារ និង កំព្យូទ័រ<br>ដុល្លារអាមេរិក | ការសាងសង់ កំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **ក្រុមហ៊ុន** | | | | | | |
| ***រំលស់បង្គរ*** | | | | | | |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **១ ខែមករា ឆ្នាំ២០១៥** | - | ៣.០៦៩.៣៨២ | ៦៦២.០១១ | ១៧០.០៧៤ | - | ៣.៩០១.៤៦៧ |
| រំលស់ក្នុងឆ្នាំ | - | ៧៩១.៩៣៩ | ១៥០.២០៦ | ៤១.៧២២ | - | ៩៨៣.៨៦៧ |
| ការជម្រះចេញពីបញ្ជី | - | - | - | (៤១.០៦៦) | - | (៤១.០៦៦) |
| **សមតុល្យនាថ្ងៃទី** | - | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៥** | | ៣.៨៦១.៣២១ | ៨១២.២១៧ | ១៧០.៧៣០ | - | ៤.៨៤៤.២៦៨ |
| រំលស់ក្នុងឆ្នាំ | - | ៨២៣.២៨០ | ១៤៩.៨២៨ | ៥៧.១៣៧ | - | ១.០៣០.២៤៥ |
| ការបែកចែកឡើងវិញទៅ | | | | | | |
| ទ្រព្យសម្បត្តិវិនិយោគទុន | | | | | | |
| (កំណត់សម្គាល់លេខ ៨) | - | (២១៦.៥២០) | - | - | - | (២១៦.៥២០) |
| ការជម្រះចេញពីបញ្ជី | - | - | - | (១៩.៦២៥) | - | (១៩.៦២៥) |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៦** | - | ៤.៤៦៨.០៨១ | ៩៦២.០៤៥ | ២០៨.២៤២ | - | ៥.៦៣៨.៣៦៨ |
| *(គិតជាពាន់រៀល)* | *-* | *១៨.០៣៧.៦៤៣* | *៣.៨៨៣.៧៧៦* | *៨៤០.៦៧៣* | *-* | *២២.៧៦២.០៩២* |
| ***តម្លៃពិតគណនេយ្យ*** | | | | | | |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៦** | **៣៦១.៧៦៥** | **១២.៩៤៥.៩៤៤** | **៥៦៩.២៦៧** | **១៣៤.១៥៧** | **៦០០.៦១៥** | **១៤.៦១១.៧៤៨** |
| *(គិតជាពាន់រៀល)* | *១.៤៦០.៤៤៥* | *៥២.២៦២.៧៧៦* | *២.២៩៨.១៣១* | *៥៤១.៥៩២* | *២.៤២៤.៦៨៣* | *៥៨.៩៨៧.៦២៧* |
| **សមតុល្យនាថ្ងៃទី** | | | | | | |
| **៣១ ខែធ្នូ ឆ្នាំ២០១៥** | - | ១២.៨៨៦.២២៣ | ៧១៥.៨៥៨ | ១៥៩.១៣៧ | ៣៤៤.០៨៤ | ១៤.១០៥.៣០២ |

## ៨ ទ្រព្យសម្បត្តិវិនិយោគ

| សម្ព័ន្ធ និង ក្រុមហ៊ុន | ដី<br>ដុល្លារអាមេរិក | អាគារ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| **ថ្លៃដើម** | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥** | - | ៤.០៧៨.៩០៧ | ៤.០៧៨.៩០៧ |
| ការទិញបន្ថែម | - | ៨.៧៥១ | ៨.៧៥១ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | - | ៤.០៨៧.៦៥៨ | ៤.០៨៧.៦៥៨ |
| ការបែងចែកឡើងវិញមកពីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (កំណត់សម្គាល់លេខ ៧) | - | ៧១០.៣៣៩ | ៧១០.៣៣៩ |
| ការចាត់ថ្នាក់ឡើងវិញ | ៤០០.៣៦៨ | (៤០០.៣៦៨) | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ៤០០.៣៦៨ | ៤.៣៩៧.៦២៩ | ៤.៧៩៧.៩៩៧ |
| ***រំលស់បង្គរ*** | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥** | - | ៤៨៦.៧៧១ | ៤៨៦.៧៧១ |
| រំលស់ក្នុងឆ្នាំ | - | ១៩៣.៤៤៥ | ១៩៣.៤៤៥ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | - | ៦៨០.២១៦ | ៦៨០.២១៦ |
| រំលស់ក្នុងឆ្នាំ | - | ២២៨.៣៨២ | ២២៨.៣៨២ |
| ការបែងចែកឡើងវិញមកពីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (កំណត់សម្គាល់លេខ ៧) | - | ២១៦.៥២០ | ២១៦.៥២០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | - | ១.១២៥.១១៨ | ១.១២៥.១១៨ |
| ***តម្លៃពិតគណនេយ្យ*** | | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | **៤០០.៣៦៨** | **៣.២៧២.៥១១** | **៣.៦៧២.៨៧៩** |
| *(គិតជាពាន់រៀល)* | *១.៦១៦.២៨៦* | *១៣.២១១.១២៧* | *១៤.៨២៧.៤១៣* |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | - | ៣.៤០៧.៤៤២ | ៣.៤០៧.៤៤២ |
| ***តម្លៃទីផ្សារសមស្រប*** | | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ៤.៧៨៩.០៦៥ | ៣.៤៦៨.២១៥ | ៨.២៥៧.២៨០ |
| *(គិតជាពាន់រៀល)* | *១៩.៣៣៣.៤៥៥* | *១៤.០០១.១៨៥* | *៣៣.៣៣៤.៦៤០* |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | - | ៤.៨៩០.៣៤៥ | ៤.៨៩០.៣៤៥ |

## ៨ ទ្រព្យសម្បត្តិវិនិយោគ (ត)

(ក) ទ្រព្យសម្បត្តិវិនិយោគ រួមមានទ្រព្យសម្បត្តិដែលជួលឲ្យភាគីទីបី ។ ពុំមានការជួលរំពឹងទុកមុន ត្រូវបានគិតបញ្ចូលទេ។

(ខ) តម្លៃទីផ្សារសមស្របនៃទ្រព្យសម្បត្តិវិនិយោគ ត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាលផ្អែកលើការវាយតម្លៃដែលទទួលបានមកពីអ្នកជំនាញវាយតម្លៃ ពីព័ត៌មានទីផ្សារដែលអាចទទួលបាន។

## ៩. ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

| | ក្រុមហ៊ុន | | |
|---|---|---|---|
| | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| តម្លៃទិញ | ៥.០០៥.០០០ | ២០.២០៥.១៨៥ | ៥.០០៥.០០០ |

ព័ត៌មានលម្អិតទាក់ទងនឹងក្រុមហ៊ុនញាតិសម្ព័ន្ធមានដូចខាងក្រោម៖

| ឈ្មោះក្រុមហ៊ុន | ប្រទេសដែលបានចុះបញ្ជីពាណិជ្ជកម្ម | ភាគហ៊ុនក្នុងមូលធន ២០១៦ % | ២០១៥ % | សកម្មភាពចម្បង |
|---|---|---|---|---|
| សហ័ស ភីភីអេសអ៊ីហ្សិត ខូ អិលធីឌី | កម្ពុជា | ១០០ | ១០០ | សេវាសន្តិសុខ |
| ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ខូ អិលធីឌី | កម្ពុជា | ១០០ | ១០០ | បង្កើត អភិវឌ្ឍ និងដំណើរការតំបន់សេដ្ឋកិច្ចពិសេស |

## ១០. ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

| | សម្ព័ន្ធ និងក្រុមហ៊ុន | | |
|---|---|---|---|
| | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| តម្លៃទិញ | ៦.៧៥០.០០០ | ២៧.២៤៩.៧៥០ | ៦.៧៥០.០០០ |
| ផលចំណេញពីញាតិសម្ព័ន្ធបន្ទាប់ពីការទិញ | ៣.១៤១.៧៩២ | ១២.៦៨៣.៤១៤ | ២.៨១១.៥៦០ |
| ដកៈ ការខាតបង់ឱនភាព | (១.៤០០.០០០) | (៥.៦៥១.៨០០) | (១.៤០០.០០០) |
| | ៨.៤៩១.៧៩២ | ៣៤.២៨១.៣៦៤ | ៨.១៦១.៥៦០ |

## ១០. ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (ត)

ព័ត៌មានលម្អិតទាក់ទងនឹងក្រុមហ៊ុនញាតិសម្ព័ន្ធមានដូចខាងក្រោម៖

| | | ភាគហ៊ុនក្នុងមូលធន | | |
|---|---|---|---|---|
| | ប្រទេសដែលបាន | ២០១៦ | ២០១៥ | |
| ឈ្មោះក្រុមហ៊ុន | ចុះបញ្ជីពាណិជ្ជកម្ម | % | % | សកម្មភាពចម្បង |
| ខូលប៊ីន អេនើជី (ខេមបូឌា) ភីភីអេសអ៊ីហ្សិត លីមីតធីត | កម្ពុជា | ៥១ | ៥១ | ផ្គត់ផ្គង់ថាមពលអគ្គិសនី |
| ផៃស្ទូត បុកសេង ភីភីអេសហ្សិត ខូអិលធីឌី * | កម្ពុជា | ៤០ | ៤០ | ផៃស្ទូត |

* មិនត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន ប៊ី ឌី អូ ឬសមាជិកក្រុមហ៊ុន ប៊ី ឌី អូ

(ក) ខូលប៊ីន អេនើជី (ខេមបូឌា) ភីភីអេសអ៊ីហ្សិត លីមីតធីត ហៅកាត់ថា ("CEZ") មានដំណាច់ឆ្នាំហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦។ ដោយសារការប្រើប្រាស់វិធីសាស្ត្រ មូលធនគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុរបស់ CEZ សំរាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៦ ត្រូវបានប្រើប្រាស់ ហើយនិយ័តកម្មពីប្រតិបត្តិការសំខាន់ត្រូវបានធ្វើដោយសមស្រប នៅចន្លោះពីថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ។

(ខ) ក្រុមហ៊ុនបានចុះកិច្ចសន្យាភាគហ៊ុនិកជាមួយ ខូលប៊ីន អេនើជី ហូលឌីង (ភីភីអេសអ៊ីហ្សិត) លីមីតធីត ហៅកាត់ថា ("CEHZ") ដែលជាម្ចាស់ភាគហ៊ុនរបស់ CEZ នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៨ ហៅកាត់ថា ("ថ្ងៃចុះកិច្ចសន្យា") ដើម្បីបញ្ជាក់ពីបញ្ហាវិនិយោគជាមួយ CEZ ។ ក្នុងថ្ងៃចុះកិច្ចសន្យា CEHZ បានផ្តល់កម្ចីភាទុនិកចំនួន ៨.៣៤ លានដុល្លារអាមេរិក សំរាប់ការបន្តគំរោងអភិវឌ្ឍន៍ និងសាងសង់របស់ CEZ។ ទឹកប្រាក់ចំនួន ២.៤លានដុល្លារអាមេរិក ពីកម្ចីភាទុនិក ត្រូវបានផ្ទេរទៅជាប្រាក់មូលធនរបស់ CEZ នៅថ្ងៃចុះកិច្ចសន្យានោះ ។ ស្របពេលនោះដែរ ក្រុមហ៊ុនបានបញ្ចូលមូលធនទៅក្នុង CEZ ចំនួន ២.៥៥លានដុល្លារអាមេរិក។ ជារួមមក ក្រុមហ៊ុនមានភាគហ៊ុនចំនួន ៥១% ហើយ CEHZ មានភាគហ៊ុនចំនួន ៤៩% នៅក្នុងCEZ។

បើតាមកិច្ចសន្យាភាហ៊ុនិក CEHZ មានសិទ្ធឯកតោ ក្នុងការបំលែងសមតុល្យដែលនៅសល់ពីកម្ចីភាទុនិកចំនួន ៥.៩៤ លានដុល្លារអាមេរិក ជាភាគហ៊ុនធម្មតាចំនួន ១.១៨៦.៧៧២ ដែលមានតម្លៃ ៥ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។ ចំនួនភាគហ៊ុនដែលនឹងត្រូវបំលែង ត្រូវបានផ្លាស់ប្តូរមកត្រឹម ១.១៨៧ ភាគហ៊ុនធម្មតា ដោយយោងទៅតាមការប្រែប្រួលនៃតំលៃសន្ទត់នៃភាគហ៊ុនធម្មតារបស់ CEZ ពី ៥ដុល្លារអាមេរិក ទៅជា៥.០០០ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩។ ដូច្នេះ CEHZ គួរតែមានភាគហ៊ុន ៧៧% និង ក្រុមហ៊ុនមាន ២៣% នៅក្នុង CEZ ក្រោយពី CEHZ បានបំលែងកម្ចី ទៅជាភាគហ៊ុនធម្មតា។

ក្រុមហ៊ុនបានយល់ព្រមដាក់ភាគហ៊ុនរបស់ខ្លួនទាំងអស់ក្នុង CEZ ដែលមានចំនួនប្រមាណ ២.៥៥លានដុល្លារអាមេរិក ជាមូលប័ត្រជាប់ធានា សំរាប់ CEHZ ក្នុងការពង្រីកកម្ចីភាទុនិករបស់ខ្លួននៅក្នុង CEZ ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាដែលបានតែងតាំងដោយ CEHZ មានសិទ្ធិទាំងស្រុង ចំពោះរឿងរ៉ាវទាំងឡាយដែលកើតឡើងក្នុង CEZ។ ជាលទ្ធផល ក្រុមប្រឹក្សាភិបាលរបស់ CEZ ត្រូវស្ថិតនៅក្រោមអ្នកតំណាងពី CEHZ ចំពោះរាល់ការសំរេចចិត្តផ្សេងៗ ហើយតាំងពីដើមមក ក្រុមហ៊ុនគ្មានសិទ្ធបោះឆ្នោតប្រឆាំង ចំពោះរាល់សេចក្តីសំរេចធ្វើឡើងដោយ CEHZ ទេ។ ដូច្នេះ ក្រុមហ៊ុនគ្មានសិទ្ធិគ្រប់គ្រងចំពោះការវិនិយោគទេ ទោះបីជាមានភាគហ៊ុន៥១%ក៏ដោយ យ៉ាងណាមិញ ក្រុមហ៊ុននៅតែមានឥទ្ធិពលសំខាន់ ដែលអាចចាត់ទុកបានថាភាគហ៊ុននៅ CEZ ជាញាតិសម្ព័ន្ធ។

## ១០. វិនិយោគទុនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (ត)

(គ) ព័ត៌មានហិរញ្ញវត្ថុដោយសង្ខេបរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធមានដូចខាងក្រោម៖

| | ២០១៦ | | ២០១៥ |
|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម និងបំណុល** | | | |
| ទ្រព្យសកម្មរយៈពេលវែង | ៤៨.៧០៣.៩៨៧ | ១៩៦.៦១៧.៩៥៦ | ៥០.២៩១.៦៨៦ |
| ទ្រព្យសកម្មរយៈពេលខ្លី | ២.៤៩១.៤១២ | ១០.០៥៧.៨៣០ | ២.០១៦.១៤៧ |
| បំណុលរយៈពេលវែង | (២៨.៧១៣.៧២៧) | (១១៥.៩១៧.៣១៦) | (៣១.៦៦០.៦៧១) |
| បំណុលរយៈពេលខ្លី | (៤.៣៤៥.៤៣៨) | (១៧.៥៤២.៥៣៣) | (៣.២៣៥.៨៣៨) |
| | ១៨.១៣៦.២៣៤ | ៧៣.២១៥.៩៧៧ | ១៧.៤១១.៣២៤ |
| **លទ្ធផល** | | | |
| ចំណូល | ១៣.១៣១.៣៦៦ | ៥៣.០១១.៣២៥ | ១១.៣៥៧.២២៦ |
| ចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ | ៦៧៩.៥០១ | ២.៧៤៣.១៤៦ | (១៧.៨៤០) |
| សរុបលទ្ធផលចំណេញ/(ខាត) | ៦៧៩.៥០១ | ២.៧៤៣.១៤៦ | (១៧.៨៤០) |
| លំហូរសាច់ប្រាក់(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | (១.១១០.៧៨៥) | (៤.៤៨៤.៦៨០) | ១.១៣៧.១៤៦ |
| លំហូរសាច់ប្រាក់បានពី/(ប្រើក្នុង)សកម្មភាពវិនិយោគ | ១.០៨៧.៧៧២ | ៤.៤០៥.៤៧៧ | (២៧៦.៩៦១) |
| លំហូរសាច់ប្រាក់ប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | - | - | (៨២២.១៧៥) |
| (តំហាយ)/កំណើននៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | (២៣.០១៣) | (៩៣.២០៣) | ៣៨.០១០ |

(ឃ) ខាងក្រោមជាការផ្ទៀងផ្ទាត់រវាងទ្រព្យសកម្មសុទ្ធរបស់ញាតិសម្ព័ន្ធ និង តម្លៃវិនិយោគពិតនៅក្នុងញាតិសម្ព័ន្ធ៖

| | សម្ព័ន្ធ និងក្រុមហ៊ុន | | ក្រុមហ៊ុន |
|---|---|---|---|
| | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| ទ្រព្យសកម្មសុទ្ធ/តំលៃពិតគណនេយ្យ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៨.៤៩១.៧៩២ | ៣៤.៣៩១.៧៥៨ | ៨.១៦១.៥៦០ |
| **លទ្ធផល** | | | |
| ចំណេញ/(ខាត) | ៣៣០.២៣២ | ១.៣៣៧.៤៤៧ | (១២.៧២៨) |
| លទ្ធផលផ្សេងៗទៀត | - | - | - |
| សរុបលទ្ធផលចំណេញ/(ខាត) | ៣៣០.២៣២ | ១.៣៣៧.៤៤៧ | (១២.៧២៨) |

## ១១. សន្និធិ

| | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| សមតុល្យដើមគ្រា | ១៣.១៣៧.០៥៣ | ៥៣.០៣៤.២៨៣ | ១០.៩៤៨.៥៨២ | ៧.៧៥៨.៥៣៥ | ៣១.៣២១.២០៦ | ១០.៩៤៨.៥៨២ |
| ទិញក្នុងឆ្នាំ | ២.២១៤.៦២៤ | ៨.៩៤០.៤៣៧ | ៥.២៧៧.០០០ | - | - | - |
| ការអភិវឌ្ឍដីក្នុងឆ្នាំ | ៣.៣២៨.៧៥១ | ១៣.៤៣៨.១៦៨ | ១.៦៧៨.៩៨២ | ១.៣៧៥.៤៨៣ | ៥.៥៥២.៨២៥ | ១.៥៧៧.៤៦៤ |
| លក់ក្នុងឆ្នាំ (កំណត់សម្គាល់លេខ ២១) | (១.៥២១.៥៣៦) | (៦.១៤២.៤៤១) | (៤.៧៦៧.៥១១) | (១.៥២១.៥៣៦) | (៦.១៤២.៤៤១) | (៤.៧៦៧.៥១១) |
| សមតុល្យចុងគ្រា | ១៧.១៥៨.៨៩២ | ៦៩.២៧០.៤៤៧ | ១៣.១៣៧.០៥៣ | ៧.៦១២.៤៨២ | ៣០.៧៣១.៥៩០ | ៧.៧៥៨.៥៣៥ |

ទំហំដីសរុបដែលអាចលក់បានមានដូចខាងក្រោមៈ

| | សម្ព័ន្ធ | | ក្រុមហ៊ុន | |
|---|---|---|---|---|
| | ២០១៦ | ២០១៥ | ២០១៦ | ២០១៥ |
| | ហិកតា | ហិកតា | ហិកតា | ហិកតា |
| សមតុល្យដើមគ្រា | ១៤០ | ១១៥ | ៨៧ | ១១៥ |
| ទិញ | ១៣ | ៥៣ | - | - |
| លក់ | (៧) | (២៨) | (៧) | (២៨) |
| សមតុល្យចុងគ្រា | ១៤៦ | ១៤០ | ៨០ | ៨៧ |

ទំហំដីដែលអាចលក់បានខាងលើចំនួន ៦៧ហិកតា (២០១៥៖ ៧២ហិកតា) ដែលមានតំលៃយោងពិតចំនួន ១.១៤៨.៥៥៦ ដុល្លារអាមេរិក (២០១៥៖ ១.២២៨.៥៩៧ ដុល្លារអាមេរិក) ត្រូវបានដាក់ជាទ្រព្យធានា នៅធនាគារកម្ពុជាសាធារណៈធនាគារភ្នំពេញពាណិជ្ជ ធនាគារស៊ីអាយអិមប៊ី និង ធនាគារពាណិជ្ជកម្មអន្តរជាតិមេហ្គា ដើម្បីទទួលបានប្រាក់កម្ចី (កំណត់សម្គាល់លេខ ១៧)។

## ១២. គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ

| | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| **គណនីពាណិជ្ជ** | | | | | | |
| ភាគីទីបី | ១២.៧៥៦ | ៥១.៤៩៦ | ១៦៣.៦៤៨ | - | - | ១៥១.៩៤៥ |
| ភាគីពាក់ព័ន្ធ | ១.៦៣៧.៧៥៧ | ៦.៦១១.៦២៥ | ១.៦៣៦.៦៥៣ | ១.៦២៣.០០០ | ៦.៥៥២.០៥១ | ១.៦២៣.០០០ |
| | ១.៦៥០.៥១៣ | ៦.៦៦៣.១២១ | ១.៨០០.៣០១ | ១.៦២៣.០០០ | ៦.៥៥២.០៥១ | ១.៧៧៤.៩៤៥ |
| **គណនីត្រូវទទួលផ្សេងៗ** | | | | | | |
| ញាតិសម្ព័ន្ធ | ២.៧៣៦.១៥៨ | ១១.០៤៥.៨៧០ | ២.៧៣៤.៤៣៩ | ២.៧៣៦.១៥៨ | ១១.០៤៥.៨៧០ | ២.៧៣៤.៤៣៩ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | ៤.៩៥៣.៥៥២ | ១៩.៩៩៧.៤៨៩ | ៦៣៧.៩៧៧ |
| ភាគីពាក់ព័ន្ធ | ១១៣.៩៥៨ | ៤៦០.០៤៨ | ៩២.២៦៤ | ១១៣.៩៥៨ | ៤៦០.០៤៨ | ៩២.២៦៤ |
| អភិបាល | ៣១០.០០០ | ១.២៥១.៤៧០ | - | ៣១០.០០០ | ១.២៥១.៤៧០ | |
| អាករលើធាតុចូល | ៤៩៣.៣២៤ | ១.៩៩១.៥៤៩ | ៤២៨.៦៤៧ | ៣១២.៥៩៣ | ១.២៦១.៩៣៨ | ៤២១.១៣៣ |
| ឥណទានពន្ធកាត់ទុក | ១.៥៣១.០៨៨ | ៦.១៨១.០០២ | ៧៧៨.២៤៤ | ១.៥៣១.០៨៨ | ៦.១៨១.០០២ | ៧៧៨.២៤៤ |
| គណនីត្រូវទទួលផ្សេងៗ | ១៣៣.៥៩៨ | ៥៣៩.៣៣៥ | ១១១.៤០៣ | ១៣៣.៥៩៨ | ៥៣៩.៣៣៥ | ១១១.៤០៣ |
| | ៥.៣១៨.១២៦ | ២១.៤៦៩.២៧៤ | ៤.១៤៤.៩៩៧ | ១០.០៩០.៩៤៧ | ៤០.៧៣៧.១៥២ | ៤.៧៧៥.៤៦០ |
| កម្ចីនិងទឹកប្រាក់ត្រូវទទួល | ៦.៩៦៨.៦៣៩ | ២៨.១៣២.៣៩៥ | ៥.៩៤៥.២៩៨ | ១១.៧១៣.៩៤៧ | ៤៧.២៨៩.២០៣ | ៦.៥៥០.៤០៥ |
| **បញ្ញើ និងចំណាយបង់មុន** | | | | | | |
| បញ្ញើ | ២.៤៥៩ | ៩.៩២៧ | ១.៩១០ | ២.៣៧៩ | ៩.៦០៥ | ១.៨៣០ |
| ចំណាយបង់មុន | ២.៦៧៦.៨០៥ | ១០.៨០៦.២៦២ | ២.៥៣៨.៨៩៧ | ២.៦៧៦.៨០៥ | ១០.៨០៦.២៦២ | ២.៥៣៨.៨៩៧ |
| | ២.៦៧៩.២៦៤ | ១០.៨១៦.១៨៩ | ២.៥៤០.៨០៧ | ២.៦៧៩.១៨៤ | ១០.៨១៥.៨៦៧ | ២.៥៤០.៧២៧ |
| | ៩.៦៤៧.៩០៣ | ៣៨.៩៤៨.៥៨៤ | ៨.៤៨៦.១០៥ | ១៤.៣៩៣.១៣១ | ៥៨.១០៥.០៧០ | ៩.០៩១.១៣២ |

(ក) គណនីពាណិជ្ជត្រូវទទួលគឺជាគណនីមិនមានការប្រាក់ ហើយរយៈកំណត់សងគឺ ១ ទៅ ៣ ខែ (២០១៥: ១ ទៅ ៣ ខែ) ដែលត្រូវបានទទួលស្គាល់តាមតម្លៃវិក័យប័ត្រដែលអាចបញ្ជាក់ពីតម្លៃទីផ្សារ នៅពេលដែលទទួលស្គាល់ដំបូង។

(ខ) គណនីត្រូវទទួលផ្សេងៗជំពាក់ដោយ ញាតិសម្ព័ន្ធ បុត្រសម្ព័ន្ធ ភាគីពាក់ព័ន្ធ និង អភិបាលគឺទាក់ទងនឹងបុរេប្រទាន និងចំណាយបង់មុន ដោយបង់ប្រាក់ជំនួស ដែលមិនមានការធានា និងការប្រាក់ទេ ព្រមទាំងត្រូវសងតាមតម្រូវការជាសាច់ប្រាក់ ឬសាច់ប្រាក់សមមូល។

(គ) ទឹកប្រាក់នៅក្នុងទឹកប្រាក់បង់ទុកជាមុន ចំនួន ២.២២២.៥៣៤ ដុល្លារអាមេរិក (២០១៥៖ ២.២២២.៥៣៤ ដុល្លារអាមេរិក) ត្រូវបានកើតឡើងទាក់ទងនឹងការទិញដី។

## ១២. គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ (ត)

(ឃ) ទឹកប្រាក់នៅក្នុងទឹកប្រាក់បង់ទុកជាមុន ចំនួន ៣០៥.០០០ ដុល្លារអាមេរិក (២០១៥៖ ៣០៥.០០០ ដុល្លារអាមេរិក) ត្រូវបានធ្វើឡើងនៅក្នុងការបង្កើតក្រុមហ៊ុន Savan - ជប៉ុន ជំញ ឌីវេឡុបម៉ែន ខូ អិលធីឌី (Savan - Japan Joint Development Co.. Ltd.) ។ ក្រុមហ៊ុនមានគំរោងនឹងកាន់កាប់ភាគហ៊ុនចំនួន ២០% នៅក្នុងក្រុមហ៊ុននេះ ។ ដំណើរការនៃការបង្កើត ក្រុមហ៊ុននេះនៅតែមិនទាន់បញ្ចប់នាថ្ងៃដំណាច់ឆ្នាំហិរញ្ញវត្ថុនេះ។

(ង) គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក ។

(ឆ) ការវិភាគអាយុកាលនៃគណនីពាណិជ្ជត្រូវទទួល របស់សម្ព័ន្ធ និងរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ២០១៦ | | ២០១៥ |
|---|---|---|---|
| **សម្ព័ន្ធ** | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** |
| មិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព | ២១.០៤៦ | ៨៤.៩៦៣ | ១៩.៨៣៤ |
| ហួសរយៈពេលត្រូវសង ប៉ុន្តែមិនមានឱនភាព | | | |
| ពី៣១ ដល់ ៦០ថ្ងៃ | ៣.៤១៨ | ១៣.៧៩៨ | ៥.៥២២ |
| ពី៦១ ដល់ ៩០ថ្ងៃ | ១.៩៧៥ | ៧.៩៧៣ | - |
| ពី៩១ ដល់ ១២០ថ្ងៃ | ១.៦២៤.០៧៤ | ៦.៥៥៦.៣៨៧ | ១.៧៧៤.៩៤៥ |
| លើសពី ១២០ថ្ងៃ | - | - | - |
| | ១.៦២៩.៤៦៧ | ៦.៥៧៨.១៥៨ | ១.៧៨០.៤៦៧ |
| ហួសរយៈពេលត្រូវសង និងមានឱនភាព | - | - | - |
| | ១.៦៥០.៥១៣ | ៦.៦៦៣.១២១ | ១.៨០០.៣០១ |
| **ក្រុមហ៊ុន** | | | |
| មិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព | - | - | - |
| ហួសរយៈពេលត្រូវសង ប៉ុន្តែមិនមានឱនភាព | | | |
| ពី៣១ ដល់ ៦០ថ្ងៃ | - | - | - |
| ពី៦១ ដល់ ៩០ថ្ងៃ | - | - | - |
| ពី៩១ ដល់ ១២០ថ្ងៃ | - | - | ១.៧៧៤.៩៤៥ |
| លើសពី ១២១ថ្ងៃ | ១.៦២៣.០០០ | ៦.៥៥២.០៥១ | - |
| | ១.៦២៣.០០០ | ៦.៥៥២.០៥១ | ១.៧៧៤.៩៤៥ |
| ហួសរយៈពេលត្រូវសង និងមានឱនភាព | - | - | - |
| | ១.៦២៣.០០០ | ៦.៥៥២.០៥១ | ១.៧៧៤.៩៤៥ |

## ១២. គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ (ត)

<u>ទឹកប្រាក់ត្រូវទទួលដែលមិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព</u>

គណនីពាណិជ្ជត្រូវទទួលដែលមិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព គឺកូនបំណុលដែលអាចជឿជាក់បាន ដែលមានប្រវត្តិបង់ប្រាក់ល្អជាមួយនឹងសម្ព័ន្ធ និងក្រុមហ៊ុន។ អតិថិជននេះបានរក្សានូវទំនាក់ទំនងល្អជាមួយនឹងសម្ព័ន្ធ និងក្រុមហ៊ុន ហើយនៅចុងការិយបរិច្ឆេទ ពុំមានកត្តាសង្ស័យណាមួយដែលថាកូនបំណុលទាំងនោះនឹងមិនបំពេញនូវកាតព្វកិច្ចសងប្រាក់របស់ខ្លួនទេ។ ពុំមានគណនីពាណិជ្ជត្រូវទទួលរបស់សម្ព័ន្ធ និងក្រុមហ៊ុនដែលមិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព ដែលត្រូវបានចរចារឡើងវិញទេនៅក្នុងការិយបរិច្ឆេទនេះទេ។

<u>ទឹកប្រាក់ត្រូវទទួលដែលហួសរយៈពេលត្រូវសង ប៉ុន្តែមិនមានឱនភាព</u>

ឈរលើហេតុផលមិនមានព្រឹត្តិការណ៍ខាតបង់ ដែលកើតឡើងចំពោះទឹកប្រាក់ត្រូវទទួលទាំងនេះ ដូចជាផលវិបាកផ្នែកហិរញ្ញវត្ថុជាសារវន្ត ពុំមានឱនភាពត្រូវបានធ្វើឡើងដែលទាក់ទិននឹងគណនីពាណិជ្ជ ត្រូវទទួលដែលហួសរយៈពេលត្រូវសង។ ជាក់ស្តែងទឹកប្រាក់ត្រូវទទួលទាំងនេះគឺពុំមានការធានាទេ។

## ១៣. សាច់ប្រាក់ និងសមតុល្យធនាគារ

| | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| សាច់ប្រាក់ក្នុងដៃ | ១.០៧៨ | ៤.៣៥២ | ១.០៥៦ | ៩៨១ | ៣.៩៦០ | ១.០១៨ |
| សាច់ប្រាក់នៅធនាគារ | ២.៤១០.៦៧០ | ៩.៧៣១.៨៧៥ | ១.១៦៤.៦៤៨ | ២.៣៨២.០៣៥ | ៩.៦១៦.២៧៦ | ១.១៤០.៤៩០ |
| | ២.៤១១.៧៤៨ | ៩.៧៣៦.២២៧ | ១.១៦៥.៧០៤ | ២.៣៨៣.០១៦ | ៩.៦២០.២៣៦ | ១.១៤១.៥០៨ |

(ក) សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និង សាច់ប្រាក់សមមូលមានជារួមនៅក្នុងសាច់ប្រាក់ក្នុងដៃ និងក្នុងធនាគារ។

| | សម្ព័ន្ធ | | | ក្រុមហ៊ុន | | |
|---|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | ២០១៦ | | ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| សាច់ប្រាក់ក្នុងដៃ | ១.០៧៨ | ៤.៣៥២ | ១.០៥៦ | ៩៨១ | ៣.៩៦០ | ១.០១៨ |
| សាច់ប្រាក់នៅធនាគារ | ២.៤១០.៦៧០ | ៩.៧៣១.៨៧៥ | ១.១៦៤.៦៤៨ | ២.៣៨២.០៣៥ | ៩.៦១៦.២៧៦ | ១.១៤០.៤៩០ |
| រូបារូប (រួមបញ្ចូលក្នុងកម្ចី) | - | - | (៨០០.០០០) | - | - | (៨០០.០០០) |
| | ២.៤១១.៧៤៨ | ៩.៧៣៦.២២៧ | ៣៦៥.៧០៤ | ២.៣៨៣.០១៦ | ៩.៦២០.២៣៦ | ៣៤១.៥០៨ |

(ខ) សាច់ប្រាក់ និងសមតុល្យធនាគារ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក។

## ១៤. ដើមទុន

| | សម្ព័ន្ធ និងក្រុមហ៊ុន | | | | |
|---|---|---|---|---|---|
| | ២០១៦ | | ២០១៥ | | |
| | ចំនួនភាគហ៊ុន នៃ០.៥០ដុល្លារ ក្នុងមួយភាគហ៊ុន | ដុល្លារអាមេរិក | ចំនួនភាគហ៊ុន នៃ១០០ដុល្លា ក្នុងមួយភាគហ៊ុន | ចំនួនភាគហ៊ុន នៃ០.៥០ដុល្លារ ក្នុងមួយភាគហ៊ុន | ដុល្លារអាមេរិក |
| ភាគហ៊ុនធម្មតា ដែលបានបោះផ្សាយៈ | | | | | |
| នៅថ្ងៃទី១ ខែមករា | ៤៦.៣០០.០០០ | ២៣.១៥០.០០០ | ១.០០០ | - | ១.០០០.០០០ |
| ការបែងចែក | - | - | (១.០០០) | ២.០០០.០០០ | - |
| | ៤៦.៣០០.០០០ | ២៣.១៥០.០០០ | - | ២.០០០.០០០ | ១.០០០.០០០ |
| ការបន្ថែមកំឡុងពេលកាលបរិច្ឆេទ | ១១.៥៧៥.០០០ | ៥.៧៨៧.៥០០ | - | ៤៤.៣០០.០០០ | ២២.១៥០.០០០ |
| | ៥៧.៨៧៥.០០០ | ២៨.៩៣៧.៥០០ | - | ៤៦.៣០០.០០០ | ២៣.១៥០.០០០ |
| បានបោះផ្សាយ និងបានបង់ៈ | | | | | |
| សមតុល្យនៅថ្ងៃទី១ ខែមករា | ៤៦.៣០០.០០០ | ២៣.១៥០.០០០ | ១.០០០ | - | ១.០០០.០០០ |
| ការបង្កើតបន្ថែមក្នុងគ្រា | - | - | (១.០០០) | ២.០០០.០០០ | - |
| | ៤៦.៣០០.០០០ | ២៣.១៥០.០០០ | - | ២.០០០.០០០ | ១.០០០.០០០ |
| ការបោះផ្សាយភាគហ៊ុនបន្ថែម (Bonus issue) | - | - | - | ៤៤.៣០០.០០០ | ២២.១៥០.០០០ |
| ការបោះផ្សាយថ្មី | ១១.៥៧៥.០០០ | ៥.៧៨៧.៥០០ | - | - | - |
| នៅថ្ងៃទី ៣១ ខែធ្នូ | ៥៧.៨៧៥.០០០ | ២៨.៩៣៧.៥០០ | - | ៤៦.៣០០.០០០ | ២៣.១៥០.០០០ |
| *(គិតជាពាន់រៀល)* | *-* | *១១៦.៨២០.៦៨៨* | *-* | *-* | *៩៤.៤៥២.០០០* |

នៅក្នុងឆ្នាំហិរញ្ញវត្ថុមុន ក្រុមហ៊ុនបានកែសម្រួលលក្ខន្តិកៈក្រុមហ៊ុន ដើម្បីបែងចែករាល់ភាគហ៊ុន ដែលមានតម្លៃ ១០០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុនទៅជា ២.០០០.០០០ ភាគហ៊ុន ដែលមានតម្លៃ ០.៥០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន និងបោះផ្សាយភាគហ៊ុនធម្មតាថ្មីចំនួន ៤៤.៣០០.០០០ ដែលមានតម្លៃ ០.៥០ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុនតាមរយៈការបោះផ្សាយបន្ថែម និងចែកចាយភាគហ៊ុនទាំងនោះ ដូចខាងក្រោមៈ

(ក) ភាគហ៊ុនធម្មតាចំនួន ៣២.៤១០.០០០ ដែលមានតម្លៃ០.៥០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន ទៅឲ្យលោកជំទាវ ឧកញ៉ា លីម ឈីវហូរ ។

(ខ) ភាគហ៊ុនធម្មតាចំនួន ១០.១៨៦.០០០ ដែលមានតម្លៃ០.៥០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ទៅឲ្យស៊ិបភី (ខេមបូឌា) ខូ អិលធីឌី ។

(គ) ភាគហ៊ុនធម្មតាចំនួន ១.៨៥២.០០០ ដែលមានតម្លៃ០.៥០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ទៅឲ្យលោកស្រី លឹម ស្រីពៅ។

(ឃ) ភាគហ៊ុនធម្មតាចំនួន ១.៨៥២.០០០ ដែលមានតម្លៃ០.៥០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ទៅឲ្យ លោកស្រី អាន មុយខន។

## ១៤. ដើមទុន (ត)

ផ្ទួបផ្សំជាមួយនឹងការចុះបញ្ជី និងការដាក់តម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន នៅលើផ្សារមូលបត្រកម្ពុជានៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៦ ក្រុមហ៊ុនបានបោះផ្សាយភាគហ៊ុនធម្មតាថ្មីចំនួន ១១.៥៧៥.០០០ ភាគហ៊ុន ដែលមានតម្លៃ ០.៥០ ដុល្លារអាមេរិក ទៅអោយសាធារណៈជន ក្នុងតម្លៃបោះផ្សាយ ២.៨៦០រៀលក្នុងមួយភាគហ៊ុន។ ចំណូលសុទ្ធសរុបបន្ទាប់ពីអប្បហារ បានពីការបោះផ្សាយមានចំនួន ៨.១២៥.៣០២ ដុល្លារអាមេរិក ហើយចំណាយលើការបោះផ្សាយមានចំនួន ៦១៤.២៥៩ ដុល្លារអាមេរិក ត្រូវបានកាត់កងជាមួយបុព្វលាភ ។

ជាលទ្ធផល ភាគហ៊ុនដែលបានបោះផ្សាយនិងបានបង់របស់ក្រុមហ៊ុននេះ បានកើនឡើងដល់ទៅ ២៨.៩៣៧.៥០០ ដុល្លារអាមេរិក។

ក្រៅអំពីការពិពណ៌នាខាងលើ ពុំមានការបោះផ្សាយ ការធ្វើមោឃភាព ការទិញ ឬ លក់វិញ និងការបង់ឡើងវិញនូវដើមទុនមូលបត្រក្នុងការិយបច្ឆេទនេះទេ ។

## ១៥. ភាគហ៊ុនបុព្វលាភ

ផ្ទួបផ្សំជាមួយនឹងការចុះបញ្ជី និងការដាក់តម្លៃ ភាគហ៊ុនរបស់ក្រុមហ៊ុន នៅលើផ្សារមូលបត្រកម្ពុជានៅថ្ងៃ ទី៣០ ខែឧសភា ឆ្នាំ២០១៦ ក្រុមហ៊ុនបានបោះផ្សាយភាគហ៊ុនធម្មតាថ្មីចំនួន ១១.៥៧៥.០០០ ភាគហ៊ុន ដែលមានតម្លៃ ០.៥០ ដុល្លារអាមេរិក ទៅអោយសាធារណៈជន ក្នុងតម្លៃបោះផ្សាយ ២.៨៦០រៀល ក្នុងមួយភាគហ៊ុន។

ភាគហ៊ុនបុព្វលាភ សំដៅលើចំនួនទឹកប្រាក់លើសពីតម្លៃចារឹក នៃភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនទទួលបានពីការបោះផ្សាយលក់ភាគហ៊ុន និង បន្ទាប់ពីកាត់កងនូវចំណាយប្រតិបត្តិការផ្សេងៗ ដែលកើតចេញផ្ទាល់ពីការរបោះផ្សាយភាគហ៊ុន។

## ១៦. ចំណេញក្នុងមួយភាគហ៊ុន

| | សម្ព័ន្ធ | | |
|---|---|---|---|
| | ៣១ ធ្នូ ២០១៦ | | ៣១ ធ្នូ ២០១៥ |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក |
| ចំណេញសម្រាប់ផ្តល់ដល់ភាគហ៊ុនិកធម្មតា | ១.៤៤៥.៦៧២ | ៥.៨៣៦.១៧៨ | ៤.១២០.៣៦៣ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់ គិតជាមធ្យម | ៥៧.៨៧៥.០០០ | ៥៧.៨៧៥.០០០ | ៤៦.៣០០.០០០ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០.០២៥ | ០.១០១ | ០.០៨៩ |
